សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការធ្វើចំណាកស្រុក

(ករណីសិក្សា ៖ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង)

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ថៃ សុម៉ារី**
**ឡា ស៊ីឡាយ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ពហុ**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ២

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេររបាយការណ៍ ២០១៨

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំ **ថៃ សុម៉ារី** និង **ឡា ស៊ីឡាយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ២ ក្រុម E៤DA១ ឆ្នាំសិក្សា ២០១៧-២០១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកដែលពាក់ព័ន្ធមួយចំនួនដូចមានរាយនាមខាងក្រោម ដែលបានជម្រុញឲ្យការធ្វើសារណាបញ្ចប់ការសិក្សា ដើម្បីបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

- លោកឪពុក **ថៃ សុវិជ្ជា** និងអ្នកម្ដាយ **សុត លីនី** ដែលបានផ្ដល់កំណើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សា ក៏ដូចជាផ្ដល់ដំបូន្មាន និងជម្រុញឲ្យកូនសិក្សារៀនសូត្ររហូតដល់សព្វថ្ងៃនេះ។ អាណាព្យាបាល **ថៃ សុភ័គ** ដែលខិតខំទំនុកបម្រុងសព្វបែបយ៉ាង ទាំងថវិកា សម្ភារៈ និងស្មារតីរហូតដល់កូនមានថ្ងៃនេះ។ កូនសូមអរគុណដល់លោកទាំងបីនាក់ ដែលបានណែនាំឲ្យកូនដើរលើមាគ៌ាត្រឹមត្រូវ តាមរយៈបញ្ជូនកូនឲ្យសិក្សារហូតដល់បញ្ចប់ថ្នាក់ឧត្ដមសិក្សា។

- លោកឪពុក **ហាក់ ឡា** និងអ្នកម្ដាយ **ចេង គឹមសៀង** ដែលអ្នកមានគុណទាំងទ្វេបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្ដី ប្រកបដោយក្ដីមេត្តា និងព្រហ្មវិហារធម៌។ លោកទាំងពីរ បានជួយជ្រោមជ្រែង និងគាំទ្រកម្លាំងកាយចិត្ត និងផ្ដល់ឱកាសឲ្យកូនបានបន្តការសិក្សារហូតមកដល់សព្វថ្ងៃ ជាពិសេសផ្គត់ផ្គង់ស្មារតី និងហិរញ្ញវត្ថុ។

- ឯកឧត្ដម **លុយ ចណ្ណា** សាកលវិទ្យាធិការ ឯកឧត្ដមសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនតាំងពីថ្នាក់មូលដ្ឋានរហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ តែងជួយណែនាំពេលមានកំហុសឆ្គង ឬបញ្ហានានា និងសម្រួលដល់ការសិក្សាប្រចាំថ្ងៃ ដូចជាការសិក្សាស្រាវជ្រាវឯកសារ និងកិច្ចការទំនាក់ទំនងផ្សេងៗ។

- លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** ដែលបានខិតខំបង្ហាត់បង្រៀនយើងខ្ញុំអស់ពេលវេលាទាំង ៤ ឆ្នាំនេះ និងចំណាយពេលវេលាជួយណែនាំសរសេររបាយការណ៍ស្រាវជ្រាវមួយនេះ។

- អ្នកគ្រូ សំណាង ផលដេត ដែលបានជួយក្នុងការសម្របសម្រួលក្នុងការស្នើសុំចុះស្រាវជ្រាវឯកសារប្រកបដោយភាពរលូន។

- លោកអ៊ុំមេឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង លឹម ផេង ដែលបានផ្ដល់ជាឯកសារសម្រាប់ការស្រាវជ្រាវយើងខ្ញុំ និងអនុញ្ញាត ក៏ដូចជាសម្រួលដល់ការចុះសម្ភាសន៍ប្រជាជន

នៅក្នុងភូមិទាំង ៩ នៃឃុំនេះ។

ជាចុងក្រោយ ខ្ញុំសូមប្រសិទ្ធពរជ័យ សេរីមង្គល មហាបវរ ជូនលោកអ្នកមានគុណទាំងទ្វេ ព្រមទាំងឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ ឈុន ពហុ បណ្ឌាសាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឲ្យជួបតែសេចក្តីសុខ មានសុខភាពបរិបូរណ៍ ទទួលជោគជ័យគ្រប់ភារកិច្ច កុំបីអាក់ខានឡើយ និងជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម យើងខ្ញុំសុំលំឱនកាយ អនុញ្ញាតគោរពជម្រាបសួរលោកគ្រូសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ និងមិត្តនិស្សិតជាទីគោរព និងស្រឡាញ់រាប់អាន។

កន្លងមក បើទោះបីជាសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងពិតមែន ប្រជាជនកម្ពុជានៅតែប្រឈមនឹងបញ្ហាជីវភាពជាពិសេសប្រជាជននៅជនបទ។ បញ្ហាចំណាកស្រុកទៅកាន់ទីក្រុងភ្នំពេញ និងក្រៅប្រទេស ជាបញ្ហាមួយដ៏ធំដែលកំពុងចោទឡើងនៅកម្ពុជា។ ពីមួយឆ្នាំទៅមួយឆ្នាំចលនាចំណាកស្រុករបស់ប្រជាជនខ្មែរកើនឡើងជាលំដាប់។ ម្យ៉ាងទៀតបញ្ហានេះ គឺជាកត្តាដ៏ធំមួយក្នុងការរាំងស្ទះការអភិវឌ្ឍន៍ និងរីកចម្រើនរបស់ប្រទេសកម្ពុជា ព្រមទាំងបង្កើតឲ្យមានបញ្ហាផ្សេងៗជាច្រើនដល់ជនចំណាកស្រុកផ្ទាល់ ក៏ដូចជាសង្គមជាតិ។

ដោយសម្លឹងឃើញពី បញ្ហា និងហេតុផលនៃការធ្វើចំណាកស្រុក ដែលប្រទេសកម្ពុជាយើងកំពុងជួបប្រទះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី "**ការធ្វើចំណាកស្រុក**" ដែលកើតឡើងនៅក្នុងភូមិទាំង ៩ របស់ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តស្វាយរៀង ដើម្បីមកធ្វើការសរសេរជាសារណាបញ្ចប់ការសិក្សា ក្នុងឆ្នាំសិក្សា ២០១៧~២០១៨ នេះ។ នៅក្នុងសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំនឹងបកស្រាយអំពីនិយមន័យនៃការធ្វើចំណាកស្រុក ទ្រឹស្តីទាំងឡាយពីការធ្វើចំណាកស្រុក គោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលចំពោះការធ្វើចំណាកស្រុក មូលហេតុ ផលប៉ះពាល់ និងដំណោះស្រាយទប់ស្កាត់ការធ្វើចំណាកស្រុក ដែលកើតមានឡើងក្នុងឃុំប្រាសាទ។

យើងខ្ញុំសង្ឃឹមថា កិច្ចការស្រាវជ្រាវមួយនេះនឹងក្លាយជាមិត្តដ៏ល្អរបស់និស្សិតជំនាន់ក្រោយដែលមានបំណងចង់ដឹង និងស្រាវជ្រាវពីការធ្វើចំណាកស្រុក តាមរយៈការផ្តល់នូវព័ត៌មានដ៏មានសារៈប្រយោជន៍ ដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅថែមទៀតពីការធ្វើចំណាកស្រុក ។

រាល់កិច្ចការទាំងឡាយ គឺមិនអាចជៀសផុតពីកំហុសឆ្គងបានឡើយ ដូច្នេះសូមលោកគ្រូសាស្ត្រាចារ្យ មេត្តាសណ្តោស ប្រោសប្រណី ខន្តីអធ្យាស្រ័យនូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនារបស់យើងខ្ញុំដោយក្តីអនុគ្រោះ។ យើងខ្ញុំនឹងរង់ចាំដោយក្តីសោមនស្សរីករាយនូវរាល់ការរិះគន់ទាំងឡាយ ដើម្បីស្ថាបនា និងកែលម្អប្រធានបទមួយនេះ ឲ្យមានអត្ថន័យកាន់តែល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**

បញ្ជីអក្សរកាត់ ............ viii
បញ្ជីតារាង ............ ix
បញ្ជីរូបភាព ............ x
បញ្ជីដ្យាក្រាម ............ xi
បញ្ជីឧបសម្ព័ន្ធ ............ xii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ............ ១
២. ចំណោទបញ្ហា ............ ២
៣. គោលបំណងនៃការស្រាវជ្រាវ ............ ៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៤
៦. សារៈសំខាន់នៃការស្រាវជ្រាវ ............ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៦

## ជំពូកទី ១
## ការសិក្សាអំពីទ្រឹស្តីនៃការធ្វើចំណាកស្រុក

១.១. និយមន័យ ............ ៧
១.២. សញ្ញាណសំខាន់ៗនៃការធ្វើចំណាកស្រុក ............ ៧
១.៣. ទ្រឹស្តីនៃការធ្វើចំណាកស្រុក ............ ៨
    ១.៣.១. ទ្រឹស្តីរបស់លោក Duncan ............ ៩
    ១.៣.២. ទ្រឹស្តីរបស់លោក Everett Lee ............ ១០
    ១.៣.៣. ទ្រឹស្តីសេដ្ឋកិច្ច Neoclassic ............ ១១
    ១.៣.៤. ទ្រឹស្តីសេដ្ឋកិច្ចថ្មី ............ ១១
    ១.៣.៥. គំរូ Harris-Todaro នៃការធ្វើចំណាកស្រុក ............ ១២
    ១.៣.៦. គំរូរបស់លោក Lewis នៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង ............ ១៦

១.៤. ទ្រឹស្តីគតិយុត្តិស្តីពីការធ្វើចំណាកស្រុក ............................................................................. ១៩
១.៥. គោលនយោបាយកាត់បន្ថយចំណាកស្រុក ..................................................................... ២១
១.៥.១. គោលនយោបាយរាជរដ្ឋាភិបាលកាត់បន្ថយចំណាកស្រុក ............................... ២១
១.៥.១.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ........................................................................................... ២១
១.៥.១.២. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ ........... ២៣
១.៥.១.៣. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ .. ២៤
១.៥.១.៤. គោលនយោបាយគណបក្សប្រជាធិបតេយ្យមូលដ្ឋាន ............................. ២៥
១.៥.១.៥. គោលនយោបាយបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) ......................... ២៨
១.៥.១.៦. គោលនយោបាយប្រជាជន ....................................................................... ២៨
១.៥.១.៧. គោលនយោបាយអភិវឌ្ឍន៍ជនបទ .......................................................... ២៩
១.៥.២. គោលនយោបាយផ្សេងៗទៀត ................................................................... ៣០
១.៥.២.១. ការឧបត្ថម្ភធនទៅដល់ជនបទ ................................................................. ៣០
១.៥.២.២. ការបង្កើត និងការលើកកម្ពស់ឲ្យមានតំបន់ទីក្រុងរណបឲ្យបានច្រើន ........ ៣១
១.៦. បញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ ............................................................. ៣១
១.៦.១. បញ្ហាប្រឈមក្នុងការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ............................................................................................................ ៣១
១.៦.២. បញ្ហាប្រឈមក្នុងការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ..... ៣២
១.៦.៣. បញ្ហាប្រឈមក្នុងការអភិវឌ្ឍមុខរបរ និងការងារ ............................................. ៣៣
១.៦.៤. បញ្ហាប្រឈមក្នុងការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ..................................................... ៣៣
១.៦.៥. បញ្ហាប្រឈមក្នុងការពង្រឹងអភិបាលកិច្ចល្អ .................................................... ៣៤
១.៦.៦. បញ្ហាប្រឈមផ្សេងៗទៀត ............................................................................ ៣៤
១.៧. ស្ថានភាពសេដ្ឋកិច្ច ការងារ និងការធ្វើចំណាកស្រុកនៅកម្ពុជា ..................................... ៣៦
១.៧.១. ស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជា ....................................................................... ៣៦
១.៧.២. ស្ថានភាពការងារនៅកម្ពុជា .......................................................................... ៣៨

១.៧.៣. ស្ថានភាពនៃការធ្វើចំណាកស្រុកនៅកម្ពុជា ..... ៤០
១.៨. បទពិសោធន៍បរទេសក្នុងការទប់ស្កាត់បញ្ហាចំណាកស្រុក ..... ៤២
១.៨.១. យុទ្ធសាស្ត្រដោះស្រាយបញ្ហាចំណាកស្រុករបស់រដ្ឋាភិបាលនៃប្រទេសចិន ..... ៤២
១.៨.២. វិធានការរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់បញ្ហាចំណាកស្រុកនៅអាហ្វ្រិក.... ៤៤
១.៨.២.១. កែលម្អវិស័យចិញ្ចឹមជីវិតនៅជនបទ ..... ៤៤
១.៨.២.២. ផ្តោតលើការបង្កើតហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន ..... ៤៤
១.៨.២.៣. ប្រព័ន្ធវិមជ្ឈការ ..... ៤៤
១.៨.២.៤. សេដ្ឋកិច្ចទីផ្សារ ..... ៤៥
១.៨.២.៥. ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ..... ៤៥
១.៨.២.៦. ជំរុញវិស័យមិនមែនកសិកម្មនៅតំបន់ជនបទ ..... ៤៥
១.៩. សន្និដ្ឋាន ..... ៤៦

## ជំពូកទី ២
## ស្ថានភាពទូទៅនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ

២.១. ស្ថានភាពទូទៅរបស់ឃុំប្រាសាទ ..... ៤៧
២.១.១. ប្រវត្តិនៃឃុំប្រាសាទ ..... ៤៧
២.១.២. ទីតាំងភូមិសាស្ត្រ ..... ៤៧
២.១.៣. ស្ថានភាពប្រជាជន ..... ៤៨
២.១.៤. សក្តានុពលរបស់ឃុំប្រាសាទ ..... ៤៨
២.១.៥. ការវិភាគស្ថានភាពបច្ចុប្បន្ន ..... ៤៨
២.១.៥.១. ផ្នែកសេដ្ឋកិច្ច ..... ៤៩
២.១.៥.២. ផ្នែកសង្គមកិច្ច ..... ៤៩
២.១.៥.៣. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន ..... ៥០
២.១.៥.៤. ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ ..... ៥០
២.១.៥.៥.ផ្នែកយេនឌ័រ ..... ៥០
២.២. ក្របខ័ណ្ឌវិនិយោគ និងគម្រោងវិនិយោគរបស់ឃុំប្រាសាទ ..... ៥១
២.២.១. ក្របខ័ណ្ឌវិនិយោគ ..... ៥១

២.២.២. គម្រោងវិនិយោគ ........................................................ ៥១
២.២.២.១.ថវិកាវិនិយោគតាមប្រភព ........................................................ ៥១
២.២.២.២. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ ........................................................ ៥២
២.២.២.៣. គម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ ........................................................ ៥៣
២.៣. រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ឃុំប្រាសាទ ........................................................ ៥៦
២.៤. ការគ្រប់គ្រងរដ្ឋបាលឃុំ ........................................................ ៥៩
២.៤.១. ក្រុមប្រឹក្សាឃុំប្រាសាទ ........................................................ ៥៩
២.៤.២. ការលើកកម្ពស់ប្រសិទ្ធិភាព ការគ្រប់គ្រងរដ្ឋបាលឃុំតាមរយៈការប្រជុំ ........................................................ ៥៩
២.៤.៣. ការងាររដ្ឋបាល ........................................................ ៥៩
២.៤.៤. ការផ្តល់សេវារដ្ឋបាល ........................................................ ៥៩
២.៥. ការប្រព្រឹត្តទៅនៃការធ្វើចំណាកស្រុកនៅឃុំប្រាសាទ ........................................................ ៦០
២.៥.១. ដំណើរការលើករណីសិក្សា ........................................................ ៦០
២.៥.១.១. លក្ខណៈរួមអំពីចំនួនប្រជាសាស្រ្ត ........................................................ ៦០
២.៥.១.២. ស្ថានភាពមុខរបរចម្បង ........................................................ ៦០
២.៥.១.៣. ការធ្វើចំណាកស្រុកស្វែងរកការងារធ្វើ ........................................................ ៦១
២.៥.២. ភាពជោគជ័យនៃការកាត់បន្ថយចំណាកស្រុក ........................................................ ៦៣
២.៥.២.១. វិស័យសេដ្ឋកិច្ច ........................................................ ៦៣
២.៥.២.២. វិស័យអប់រំ ........................................................ ៦៤
២.៥.២.៣. វិស័យសុខាភិបាល ........................................................ ៦៥
២.៥.២.៤. វិស័យគមនាគមន៍ ........................................................ ៦៦
២.៥.២.៥. វិស័យធារាសាស្រ្ត ........................................................ ៦៧
២.៥.២.៦. ការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនី ........................................................ ៦៧
២.៥.២.៧. ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........................................................ ៦៨
២.៥.៣. ការលំបាកក្នុងការកាត់បន្ថយចំណាកស្រុក ........................................................ ៦៩
២.៥.៣.១. បញ្ហានិកម្មភាព ........................................................ ៦៩
២.៥.៣.២ បញ្ហាបម្រែបម្រួលអាកាសធាតុ ........................................................ ៦៩

២.៥.៣.៣. បញ្ហាកង្វះថវិកាក្នុងការអភិវឌ្ឍភូមិ-ឃុំ ........ ៧០
២.៥.៣.៤. បញ្ហាកង្វះដីធ្វើស្រែចម្ការ ........ ៧១
២.៥.៤. ដំណោះស្រាយក្នុងការកាត់បន្ថយចំណាកស្រុក ........ ៧១
២.៥.៤.១. គោលនយោបាយអភិវឌ្ឍន៍ឃុំប្រសាទបន្តឆ្នាំ ២០១៧-២០២២ ........ ៧១
២.៥.៤.២. ការបណ្ដុះបណ្ដាលវិជ្ជាជីវៈជូនដល់ប្រជាពលរដ្ឋ ........ ៧២
២.៥.៤.៣. ការទាក់ទាញវិនិយោគិន ........ ៧២

## ជំពូកទី ៣

## ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅ ........ ៧៥
៣.១.១ អាយុ និងភេទរបស់ជនចំណាកស្រុក ........ ៧៥
៣.១.២ ស្ថានភាពគ្រួសាររបស់អ្នកចំណាកស្រុក ........ ៧៦
៣.១.៣ កម្រិតវប្បធម៌របស់អ្នកចំណាកស្រុក ........ ៧៦
៣.១.៤. ប្រភពព័ត៌មាននៃការធ្វើចំណាកស្រុក ........ ៧៧
៣.១.៥. រយៈពេលនៃការធ្វើចំណាកស្រុក ........ ៧៧
៣.១.៦. គោលដៅនៃការធ្វើចំណាកស្រុក ........ ៧៨
៣.២. ប្រភេទនៃការងារនៃអ្នកធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ ........ ៧៨
៣.៣. មូលហេតុនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ ........ ៧៩
៣.៣.១. ជីវភាពលំបាក ........ ៨០
៣.៣.២. កង្វះការងារ ........ ៨០
៣.៣.៣. កង្វះដីធ្លីធ្វើស្រែចម្ការ ........ ៨១
៣.៣.៤. សន្សំលុយ និងរកចំណូលបន្ថែម ........ ៨១
៣.៣.៥. មុខរបរមិនកាក់កប ........ ៨១
៣.៣.៦. ចង់មានសេរីភាព ........ ៨២
៣.៣.៧. ចង់ទទួលបានបទពិសោធន៍ការងារ ........ ៨២
៣.៣.៨. រៀនមិនចូល ........ ៨២
៣.៣.៩. បញ្ហាផ្សេងៗទៀត ........ ៨២

៣.៤. ផលប៉ះពាល់នៃការធ្វើចំណាកស្រុកនៅក្នុងឃុំប្រាសាទ ........ ៨២
៣.៤.១. ផលវិជ្ជមាន ........ ៨២
៣.៤.១.១. ស្ថានភាពជីវភាពប្រជាជន ........ ៨៣
៣.៤.១.២. ចំណេះដឹង និងបទពិសោធន៍ ........ ៨៤
៣.៤.២. ផលអវិជ្ជមាន ........ ៨៤
៣.៤.២.១. នឹកផ្ទះ និងគ្រួសារ ........ ៨៥
៣.៤.២.២. ការងារមានភាពពិបាក ........ ៨៥
៣.៤.២.៣. បញ្ហាសុវត្ថិភាព ........ ៨៥
៣.៤.២.៤. ស្ថានភាពនៃការរស់នៅ ........ ៨៦
៣.៤.២.៥. បញ្ហាម្ហូបអាហារ ........ ៨៧
៣.៤.២.៦. បញ្ហាតម្លៃទឹក ភ្លើង និងផ្ទះជួល ........ ៨៧
៣.៤.២.៧. ចៅហ្វាយស្តីបន្ទោស ........ ៨៧
៣.៤.២.៨. បញ្ហាសុខភាព ........ ៨៧
៣.៤.២.៩. បញ្ហានៃការបើកប្រាក់ខែ ........ ៨៧
៣.៤.២.១០. មិនមានបញ្ហាពិបាក ........ ៨៨
៣.៤.២.១១. បញ្ហាផ្សេងៗទៀត ........ ៨៨
៣.៥. ទស្សនៈនៃជនចំណាកស្រុកនៅក្នុងឃុំប្រាសាទ ........ ៨៨
៣.៥.១. មូលហេតុដែលបន្តការធ្វើចំណាកស្រុក ........ ៨៩
៣.៥.២. មូលហេតុដែលបញ្ឈប់ការធ្វើចំណាកស្រុក ........ ៨៩
៣.៦. ដំណោះស្រាយចំពោះបញ្ហាចំណាកស្រុកក្នុងឃុំប្រសាទ ........ ៩០
៣.៦.១ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ ........ ៩១
៣.៦.២. បង្កើតការងារចម្រុះ ........ ៩១
៣.៦.៣. ប្រាក់ខែសមរម្យ ........ ៩២
៣.៦.៤ ទីផ្សារតម្លៃផលិតផលកសិកម្មខ្ពស់ ........ ៩៣
៣.៦.៥. បណ្តុះបណ្តាលកសិកម្ម ........ ៩៣
៣.៦.៦. តម្លៃទំនិញ និងសេវាកម្មទាប ........ ៩៤

៣.៦.៧. សុវត្ថិភាពសន្តិសុខសង្គម ........................................................................ ៩៥

**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

១.សេចក្ដីសន្និដ្ឋាន ........................................................................ ៩៧
២.អនុសាសន៍ ........................................................................ ៩៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank |
| CLTS | Community Led Total Sanitation |
| DBST | Double Bituminous Surface Treatment |
| GNI | Gross National Income |
| ILO | International Labour Organization |
| ODOV | Organization to Develop Our Villages |
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ |
| ប.ស.ស | បេឡាជាតិរបបសន្តិសុខសង្គម |

# បញ្ជីតារាង

តារាងទី ៣.១. ប្រភពព័ត៌មាននៃការធ្វើចំណាកស្រុកគិតជាភាគរយ ....................................... ៧៧
តារាងទី ៣.២ គោលដៅនៃអ្នកធ្វើចំណាកស្រុកគិតជាភាគរយ ................................................ ៧៨
តារាងទី ៣.៣ ប្រភេទការងារនៃអ្នកធ្វើចំណាកស្រុកក្នុងឃុំប្រាសាទគិតជាភាគរយ ................. ៧៨
តារាងទី ៣.៤ មូលហេតុនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទគិតជាភាគរយ ......................... ៧៩
តារាងទី ៣.៥ ផលអវិជ្ជមាននៃការធ្វើចំណាកស្រុកគិតជាភាគរយ ............................................ ៨៤
តារាងទី ៣.៦ មូលហេតុនៃការបន្ត ឬបញ្ឈប់ការធ្វើចំណាកស្រុកគិតជាភាគរយ ....................... ៨៨
តារាងទី ៣.៧ ដំណោះស្រាយបញ្ហាចំណាកស្រុកក្នុងឃុំប្រាសាទ ............................................ ៩០

# បញ្ជីរូបភាព

រូបភាពទី ១.១ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........................................................................................៦
រូបភាពទី ១.២ ម៉ូដែលនៃវិស័យទ្វេភាគរបស់ Lewis នៃការអភិវឌ្ឍ...........................................១៧
រូបភាពទី ២.១ រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ឃុំប្រាសាទ .................................................... ៥៦

# បញ្ជីដ្យាក្រាម

ដ្យាក្រាមទី១.១ Full Employment and Harris Todaro Equilibrium ........................................ ១៤
ដ្យាក្រាមទី ១.២ Transfer of Labour to the Capitalist Sector ................................................ ១៨
ដ្យាក្រាមទី ២.១ ចំនួនអ្នកធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេសចាប់តាំងពីឆ្នាំ ២០១៣ ដល់ ឆ្នាំ ២០១៦ ........................................................................................................ ៦១
ដ្យាក្រាមទី ២.២ ភាគរយអ្នកធ្វើចំណាកស្រុកក្នុងប្រទេស (អាយុ ១៨ ឆ្នាំឡើង) ........................ ៦២
ដ្យាក្រាមទី ២.៣ ភាគរយអ្នកធ្វើចំណាកស្រុកក្រៅប្រទេស (អាយុ ១៨ ឆ្នាំឡើង) ...................... ៦២
ដ្យាក្រាមទី ២.៤ ចំនួនមនុស្សធ្វើចំណាកស្រុកនៅក្នុងប្រទេស និងក្រៅប្រទេស...................... ៦៣
ដ្យាក្រាមទី ៣.១ ការបែងចែកក្រុមអាយុ និងភេទរបស់ជនចំណាកស្រុកគិតជាភាគរយ...........៧៥
ដ្យាក្រាមទី ៣.២ ការបង្ហាញអំពីកម្រិតអប់រំរបស់អ្នកចំណាកស្រុកតាមភេទគិតជាភាគរយ ......៧៦
ដ្យាក្រាមទី ៣.៣. ភាគរយនៃរយៈពេលធ្វើចំណាកស្រុក ......................................................៧៧
ដ្យាក្រាមទី ៣.៤ ជីវភាពប្រជាជនមុនធ្វើចំណាកស្រុក.......................................................... ៨៣
ដ្យាក្រាមទី ៣.៥ ជីវភាពប្រជាជនក្រោយពេលធ្វើចំណាកស្រុក............................................. ៨៣

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ : កម្រងសំណួរ

ឧបសម្ព័ន្ធទី ២ : ស្រង់ទិន្នន័យដែលបានមកពីការសម្ភាសន៍ដែលត្រូវបានប្រើប្រាស់ក្នុងជំពូកទី ៣

ឧបសម្ព័ន្ធទី ៣ : តារាង Frequency និងតារាង Crosstabs បង្ហាញអំពីភាពជាប់ទាក់ទងនៃកម្រិតចំណេះដឹង ភេទ និងអាយុនៃអ្នកធ្វើចំណាកស្រុក

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

មនុស្សភាគច្រើនតែងគិតថា ការធ្វើចំណាកស្រុកជាបាតុភូតថ្មីៗ។ ប៉ុន្តែការពិត ការធ្វើចំណាកស្រុក បានកើតឡើងអស់ជាច្រើនសតវត្សរ៍មកហើយ។ មនុស្សតែងតែផ្លាស់ទីលំនៅជាក្រុម ឬជាបុគ្គល ដើម្បីស្វែងរកសេរីភាពពីសង្គ្រាម និងជម្លោះ ព្រមទាំងដើម្បីគេចចេញពីភាពអត់ឃ្លាន និងភាពក្រីក្រ ដើម្បីស្វែងរកឱកាសសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការងារថ្មី។ លើសពីនេះ មនុស្សចាកចោលស្រុកក៏ដើម្បីគេចចេញពីការមិនអត់ឱនចំពោះសាសនា ឬការបង្ក្រាបនយោបាយផ្សេងៗ[1]។

ខណៈពេលដែលប្រទេសកម្ពុជានៅតែជាប្រទេស ដែលមានប្រជាជនរស់នៅតាមទីជនបទភាគច្រើន ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ការហូរចូលនៃជនចំណាកស្រុកទៅកាន់រាជធានីភ្នំពេញ ក៏ដូចជាទៅកាន់ប្រទេសផ្សេងៗទៀត មានការកើនឡើងជាលំដាប់។ បច្ចុប្បន្ននេះ ការរីកលូតលាស់នៃឧស្សាហកម្មកាត់ដេរ ក៏ដូចជាវិស័យសំណង់ គឺជាកត្តាដ៏សំខាន់ ដែលទាក់ទាញប្រជាជននៅតាមទីជនបទមកកាន់ទីក្រុងភ្នំពេញ ដើម្បីមកធ្វើជាកម្មកររោងចក្រ និងកម្មករសំណង់។ រីឯវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជាក៏បាននឹងកំពុងរីកចម្រើន ដោយមនុស្សមកពីគ្រប់ទិសទីទូទាំងពិភពលោក ចូលមកទស្សនាប្រាសាទដែលមានវប្បធម៌ដ៏មហាស្ចារ្យ និងតំបន់ទេសចរណ៍ធម្មជាតិផ្សេងៗនៅកម្ពុជា[2]។

នេះបណ្តាលឲ្យមនុស្សនាំគ្នាចាកចោលស្រុកមកស្វែងរកការងារ ដែលមានដូចជាអ្នកបម្រើតាមភោជនីយដ្ឋាន អ្នកបោសសម្អាតតាមផ្ទះសំណាក់ ឬសណ្ឋាគារ អ្នករត់ម៉ូតូឌុប និងរ៉ឺម៉កកង់បីជាដើម។ ចំណែកឯ ការធ្វើចំណាកស្រុកទៅកាន់ប្រទេសដទៃទៀត ជាពិសេសប្រទេសជិតខាងដូចជា ថៃ ម៉ាឡេស៊ី ចិន ជប៉ុន កូរ៉េខាងត្បូង -ល- គឺធ្វើឡើងក្នុងគោលបំណង និងសេចក្តីរំពឹងទុកថានឹងទទួលបានប្រាក់ចំណូលខ្ពស់។ ការងារដែលពួកគាត់ធ្វើនៅទីនោះច្រើនតែជាការងារដែលទាក់ទងនឹងវិស័យកសិកម្ម រួមមានរោងចក្រផលិតជី ប្រមូលផលដំណាំ ព្រមទាំងធ្វើការនៅលើទូកនេសាទជាដើម។

ការធ្វើចំណាកស្រុកទូទាំងប្រទេសកម្ពុជា ជាបញ្ហាចោទមួយនៅក្នុងប្រទេសកម្ពុជា ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ។ ចលនាចំណាកស្រុករបស់ប្រជាជនក្រីក្រ និងឥតការងារធ្វើ មាន

[1] ដកស្រង់ចេញពីគេហទំព័រ http://www.striking-women.org/module/migration/history-migration

[2] ដកសង់ប្រភព http://cambodia.unfpa.org/en/publications/migration-cambodia

កើនឡើងជារៀយៗ ដោយគ្មានភាពថមថយទាល់តែសោះ។ អាកាសធាតុក្តៅហួតហែង កង្វះប្រព័ន្ធធារាសាស្ត្រ កង្វះបច្ចេកទេសក្នុងការធ្វើកសិកម្ម កង្វះខាតដីធ្លីធ្វើស្រែចម្ការ កង្វះខាតការងារ និងការជំពាក់បំណុល ជាកត្តាជុំរុញឲ្យប្រជាកសិករនៅតាមជនបទ សម្រេចចិត្តចាកចោលស្រុកកំណើតរបស់ខ្លួន ដើម្បីសេដ្ឋកិច្ចគ្រួសារ។ បើទោះបីជា ការធ្វើចំណាកស្រុកជួយឲ្យប្រជាជនមួយចំនួនមានជីវភាពប្រសើរឡើង ប៉ុន្តែប្រជាជនមួយចំនួនធំនៅតែមានជីវភាពដដែល ហើយមួយចំនួនទៀតថែមទាំងមានជីវភាពលំបាកជាងមុនទៅទៀត ដោយសារពួកគាត់បានចាញ់បោកជនខិលខូចអស់ប្រាក់កាសពីខ្លួន។ បញ្ហាផ្សេងៗទៀត ដែលពួកគាត់ជួបប្រទះមានដូចជា ការវាយធ្វើបាបពីសំណាក់ម្ចាស់ផ្ទះ ឬទូកនេសាទដែលពួកគាត់ធ្វើការឲ្យ ការឃ្លាតឆ្ងាយពីគ្រួសារជាទីស្រឡាញ់ និងមិនបានមើលថែគ្រួសាររបស់ខ្លួន ព្រមទាំងកង្វះខាតចំណេះដឹង ដែលនាំឲ្យពួកគាត់ទទួលបានតែការងារតូចទាប ប្រើប្រាស់កម្លាំងពលកម្មច្រើន ហើយទទួលបានប្រាក់កំរៃតិចតួចប៉ុណ្ណោះ។ ក៏ដូចជាខេត្តនានានៅក្នុងប្រទេសកម្ពុជាដែរ ខេត្តព្រៃវែងកំពុងតែជួបប្រទះនឹងបញ្ហាចំណាកស្រុកនេះ។ ជាក់ស្តែង ក្នុងឃុំប្រាសាទ ខេត្តព្រៃវែង ប្រជាជនចំណាកស្រុកមានប្រមាណ ២០៦០ នាក់ ស្មើនឹង ៦,៣៩ ភាគរយនៃប្រជាជនសរុប។

បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជា បាននឹងកំពុងអនុវត្តន៍យុទ្ធសាស្ត្រចតុកោណនីតិកាលទី៣ ដោយព្យាយាមទាក់ទាញវិនិយោគិនក្នុង និងក្រៅប្រទេស ដើម្បីបង្កើនការងារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ ដើម្បីជួយឲ្យតំបន់ជនបទនានារីកចម្រើនដូចជានៅទីក្រុងដែរ។ ដូចគ្នានេះដែរ ក្រុមប្រឹក្សារដ្ឋបាលឃុំប្រាសាទបានដាក់ចេញនូវគម្រោងអភិវឌ្ឍន៍ផ្លូវផ្សេងៗ និងបណ្តុះបណ្តាលយុវជន និងយុវនារីឲ្យមានចំណេះដឹង ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងលើកកម្ពស់ជីវភាពប្រជាជននៅក្នុងឃុំ កាត់បន្ថយការធ្វើចំណាកស្រុក[3]។

## ២. ចំណោទបញ្ហា

ការធ្វើចំណាកស្រុកគឺជា បញ្ហាមួយដែលបានចោទឡើងយ៉ាងខ្លាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ហេតុដូច្នេះហើយបានជាមានការលើកឡើងនូវសំនួរមួយចំនួនដែលទាក់ទងនឹងបញ្ហាចំណាកស្រុកនេះ។តើកត្តាអ្វីខ្លះដែលធ្វើអោយប្រជាពលរដ្ឋរស់នៅតំបន់ជនបទ ធ្វើការចំណាកស្រុកមកកាន់ទីក្រុង ឬទៅធ្វើការនៅក្រៅប្រទេស? តើការធ្វើចំណាកស្រុកបានជះឥទ្ធិពលវិជ្ជមាន ឬ

[3] សង្ខេបចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិទ្ធ និងចន សុផាន់ណាក់ ចំណងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ១-២

អវិជ្ជមាន ដល់ខ្លួនឯងផ្ទាល់ និងសង្គមជាតិទាំងមូល? ហេតុអ្វី? តើដំណោះស្រាយយ៉ាងដូចម្ដេច ឬវិធានការណ៍បែបណាដែលមានប្រសិទ្ធិភាពចំពោះការដោះស្រាយបញ្ហាចំណាកស្រុកនេះ? ចម្ងល់ដែលបានលើកឡើងអំពីបញ្ហាចំណាកស្រុកខាងលើនេះ នឹងត្រូវបានយកមកសិក្សា និងពន្យល់បកស្រាយ នៅក្នុងកិច្ចការងារស្រាវជ្រាវដោយយើងខ្ញុំទាំងពីរនាក់ ក្រោមប្រធានបទ " **ការធ្វើចំណាកស្រុក** " ។ ខ្លឹមសារ និងអត្ថន័យដែលបង្ហាញអំពីអត្ថបទនេះមានដូចតទៅ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះគឺ ដើម្បីស្វែងរកឬសគល់អំពីមូលហេតុរបស់អ្នកធ្វើចំណាកស្រុក។ ដោយហេតុឃើញថា ការធ្វើចំណាកស្រុកនៅក្នុងឃុំប្រាសាទមានការកើនឡើងគួរឲ្យគត់សម្គាល់ ទើបពួកយើងចង់ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលធ្វើការចំណាកស្រុកទាំងនោះ។ លើសពីនេះទៅទៀត ពួកយើកមានបំណងរកឲ្យឃើញថា តើអ្វីជាកត្តាជម្រុញខ្លាំងបំផុត ដែលធ្វើឲ្យពួកគាត់សម្រេចចិត្តចាកស្រុកបែបនេះ។ មួយវិញទៀត ពួកយើងខ្ញុំទាំងពីរនាក់មានបំណងចង់ដឹងអំពី ផលបះពាល់ដែលរងឥទ្ធិពលដោយការធ្វើចំណាកស្រុកនេះ។ គោលដៅមួយទៀតរបស់យើងខ្ញុំគឺ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក ដោយស្វែងរកឲ្យឃើញនូវដំណោះស្រាយ ដែលមានប្រសិទ្ធិភាព ដោយផ្អែកលើទ្រឹស្តី បទពិសោធន៍របស់បរទេស និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលទាំងថ្នាក់ជាតិ និងក្រោមជាតិ ក្នុងការដោះស្រាយបញ្ហានេះ។

បន្ថែមពីការរៀបរាប់ខាងលើ យើងនឹងធ្វើសេចក្តីសន្និដ្ឋាន អំពីលទ្ធផលដែលបានរកឃើញ រួមទាំងធ្វើការវិភាគលើសមិទ្ធិផល បញ្ហាប្រឈម និងដំណោះស្រាយ។ បន្ទាប់មកទៀត យើងនឹងពាំនាំយកការស្នើសុំរបស់ប្រជាពលរដ្ឋ ដែលធ្វើចំណាកស្រុកនៅក្នុងឃុំប្រសាទ មកបកស្រាយ និងពន្យល់ដើម្បីជាការផ្ញើសារជូនដល់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីងាយស្រួលចាត់វិធានការណ៍ ក្នុងការអភិវឌ្ឍផងដែរ។ ជាកិច្ចចុងក្រោយ យើងនឹងធ្វើការផ្តល់អនុសាសន៍ និងយោបល់បន្ថែម ចំពោះបញ្ហាចំណាកស្រុកនេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវពីបញ្ហាចំណាកស្រុកនេះ ធ្វើឡើងនៅក្នុងភូមិចំនួន ៩ ក្នុងឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយផ្តោតលើការស្វែងរកមូលហេតុ និងផលប៉ះពាល់ ជាពិសេសរកឲ្យឃើញនូវដំណោះស្រាយ ចំពោះបញ្ហាចំណាកស្រុកក្នុងឃុំប្រាសាទនេះ។ ការចុះកម្មសិក្សា ប្រព្រឹត្តទៅចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ដែលការសិក្សា

ស្រាវជ្រាវនេះធ្វើឡើងសម្រាប់តែរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា។ ដោយសារតែ បញ្ហាការធ្វើចំណាកស្រុកទូទាំងប្រទេសកម្ពុជាមានលក្ខណៈធំធេងពេក ទើបយើងខ្ញុំសម្រេចចិត្តលើកឡើងតែពីករណីសិក្សាតូចមួយស្ដីពី **ការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង** ដោយសិក្សាស្វែងរកនូវឫសគល់ ដែលនាំឲ្យប្រជាជនក្នុងឃុំនេះចាកចោលស្រុក ផលវិជ្ជមាន និងផលអវិជ្ជមាននៃការធ្វើចំណាកស្រុកនេះ ព្រមទាំងវិធីសាស្ត្រផ្សេងៗ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋក្នុងឃុំនេះ ដោយផ្អែកលើទ្រឹស្ដីអ្នកប្រាជ្ញនានា បទពិសោធន៍បរទេស និងយុទ្ធសាស្ត្ររាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រផ្សេងៗរបស់អាជ្ញាធរភូមិ-ឃុំ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ ត្រូវបានធ្វើឡើងទៅតាមបែបបរិមាណផង និងបែបគុណភាពផង។

### ក. វិធីសាស្ត្រប្រមូលទិន្នន័យ

តាមរយៈការចុះស្រាវជ្រាវកន្លងមកនេះ យើងបានប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីជាជំនួយដល់ការស្រង់យកពត៌មានដែលទាក់ទងនឹងប្រធានបទខាងលើ។ ការសិក្សាស្រាវជ្រាវពីការធ្វើចំណាកស្រុកនៅក្នុងឃុំប្រសាទ ខេត្តព្រៃវែងនេះគឺ ធ្វើឡើងដោយផ្អែកលើឯកសារមួយចំនួនដែលមានតម្កល់នៅក្នុងឃុំ ហើយពាក់ព័ន្ធនឹងការសរសេររបាយការណ៍កម្មសិក្សាខាងលើនេះ។ ប្រភពទិន្នន័យដែលប្រមូលបានមកពីការស្រាវជ្រាវ យើងបានបែងចែកជាពីរប្រភេទគឺៈ

❖ **ទិន្នន័យចម្បង**

- ជាប្រភេទទិន្នន័យដែលបានចុះទៅយកដោយផ្ទាល់នៅក្នុងឃុំប្រសាទ ខេត្តព្រៃវែង
- ទិន្នន័យប្រភេទនេះ បានមកពីការសំភាសន៍ជាមួយប្រជាពលរដ្ឋ នៅក្នុងឃុំប្រសាទ ដែលបានធ្វើការចំណាកស្រុកដោយផ្ទាល់
- លើសពីនេះទៅទៀត ពួកយើងក៏បានសួរនាំ លោកអ៊ុំមេឃុំ មេភូមិ និងចាស់ព្រឹទ្ធាចារ្យនៅក្នុងឃុំ ដែលអាចផ្ដល់ទិន្នន័យ និងព័ត៌មាន ដែលពាក់ព័ន្ធនឹងប្រធានបទខាងលើ។

❖ **ទិន្នន័យបន្ទាប់បន្សំ**

ជាប្រភេទទិន្នន័យដែលប្រមូលយកមកតាមរយៈសម្រង់ឯកសារមួយចំនួនដូចខាងក្រោមៈ

- ឯកសារដែលលោកអ៊ុំមេឃុំប្រគល់ឲ្យ ដែលមានភាពជាប់ទាក់ទងនឹងប្រធានបទ

- ឯកសារដែលបានមកពីបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនិតីសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារដែលបានមកពី Internet ជាពិសេសពីគេហទំព័ររបស់ក្រសួងនានា។

### ខ. វិធីសាស្ត្រវិភាគទិន្នន័យ

ក្នុងកិច្ចការងារស្រាវជ្រាវលើប្រធានបទខាងលើនេះ ការស្រង់យកទិន្នន័យធ្វើឡើងតាមរបៀបបរិមាណផង និងរបៀបគុណភាពផង។ ចំពោះទិន្នន័យដែលទទួលបាន គឺត្រូវបានត្រួតពិនិត្យ កែសម្រួល និងរៀបចំតាមប្រភេទផ្សេងៗគ្នា។ បន្ទាប់ពីការចាត់ចែងដាក់ទិន្នន័យតាមប្រភេទរួចស្រេចហើយ ពួកយើងបានដាក់បញ្ចូលទិន្នន័យទាំងនោះទៅក្នុងកម្មវិធី SPSS (Statistical Package for Social Science) ដែលបង្ហាញអំពី Frequency, Table, Descriptive... ។ ក្រៅពីនេះ យើងបានប្រើប្រាស់កម្មវិធី Microsoft Excel និង Microsoft Word ដើម្បីសម្រួលដល់ការសរសេររបាយការណ៍នេះផងដែរ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ការធ្វើចំណាកស្រុក ដែលក្រុមយើងខ្ញុំបានចុះកម្មសិក្សាស្រាវជ្រាវពីមូលហេតុ ផលប៉ះពាល់ ក៏ដូចជាដំណោះស្រាយនៃបញ្ហានេះ នៅក្នុងភូមិទាំង ៩ ក្នុងឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង យើងខ្ញុំជឿជាក់ថា ស្នាដៃស្រាវជ្រាវមួយនេះពិតជាមានសារៈសំខាន់ណាស់ និងបានផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

- ស្នាដៃនេះ នឹងជួយឲ្យអ្នកអានយល់ច្បាស់ពី មូលហេតុដែលនាំឲ្យមានចំណាកស្រុក ផលប៉ះពាល់ពីបញ្ហានេះ ព្រមទាំងដំណោះស្រាយ ដែលមាននៅក្នុងឃុំប្រាសាទ។
- កិច្ចការស្រាវជ្រាវមួយនេះ ដែលជាស្នាដៃរបស់យើងខ្ញុំ អាចជួយទៅដល់អ្នកសិក្សាស្រាវជ្រាវ ប្អូនៗនិស្សិតជំនាន់ក្រោយ ដែលមានគោលបំណងសិក្សាបន្ថែម ទៅលើបញ្ហាចំណាកស្រុក។
- ការងារនេះ ជួយឲ្យយើងខ្ញុំពង្រីកចំណេះដឹង និងសិក្សាបន្ថែមពីនិតិវិធីនៃការស្រាវជ្រាវ និងអាចក្លាយជាទុនបម្រុង ឬស្ពានចម្លងទៅកាន់កិច្ចការស្រាវជ្រាវដទៃទៀតនាថ្ងៃអនាគត។
- ផ្តល់ជូនជាអនុសាសន៍ ក៏ដូចជាដំណោះស្រាយ ដើម្បីជួយទៅដល់ការអភិវឌ្ឍទាំងមូលនៃឃុំប្រាសាទ និងអាចកាត់បន្ថយ ឬឈានទៅដល់ការបញ្ឈប់ការធ្វើចំណាកស្រុកចេញពីភូមិ-ឃុំ។

- យើងខ្ញុំអាចនឹងចែករំលែកចំណេះដឹងផ្ទាល់ខ្លួនមួយចំនួន ដែលបានសិក្សារៀនសូត្រកន្លងមកអស់រយៈពេល ៤ ឆ្នាំ លើជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ដើម្បីជួយដល់ប្រទេសជាតិឲ្យមានការរីកចម្រើន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ




**រូបភាពទី ១.១ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

# ជំពូកទី ១

# ការសិក្សាអំពីទ្រឹស្តីនៃការធ្វើចំណាកស្រុក

# ជំពូកទី ១

# ការសិក្សាអំពីទ្រឹស្តីនៃការធ្វើចំណាកស្រុក

## ១.១. និយមន័យ

ការធ្វើចំណាកស្រុក ត្រូវបានកំណត់ថា ជាដំណើរផ្លាស់ប្តូរកន្លែងរស់នៅរបស់មនុស្សម្នាក់ ឬមនុស្សមួយក្រុមពីភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត ដោយឆ្លងកាត់ព្រំដែនរដ្ឋបាល ឬនយោបាយ ក្នុងគោលបំណងតាំងទីលំនៅជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន នៅកន្លែងមួយក្រៅពីកន្លែងដើមកំណើតរបស់ពួកគេ[4]។

## ១.២. សញ្ញាណសំខាន់ៗនៃការធ្វើចំណាកស្រុក

❖ ប្រភេទនៃការធ្វើចំណាកស្រុក

ការធ្វើចំណាកស្រុក ចែកចេញជាច្រើនប្រភេទ និងប្រព្រឹត្តឡើងក្រោមរូបភាពជាច្រើនទម្រង់។ ការធ្វើចំណាកស្រុកប្រព្រឹត្តទៅឡើង អាស្រ័យលើកត្តាមួយចំនួនដូចជា លំហូរនៃជនចំណាកស្រុក ចំនួនមនុស្សដែលពាក់ព័ន្ធ ហេតុផលរបស់ពួកគេ ពេលវេលាដែលពួកគេចំណាយក្នុងការធ្វើចំណាកស្រុក និងធម្មជាតិនៃការធ្វើចំណាកស្រុក។ ប្រភេទចម្បងៗនៃការធ្វើចំណាកស្រុកមានដូចជា៖

- **ការធ្វើចំណាកស្រុកផ្ទៃក្នុង** គឺជាការផ្លាស់ប្តូរទីកន្លែងរស់នៅ នៅក្នុងទីក្រុង ខេត្ត ប្រទេស ឬទ្វីបតែមួយ។
- **ការធ្វើចំណាកស្រុកខាងក្រៅ** គឺជាការផ្លាស់ប្តូរទីកន្លែងរស់នៅទៅកាន់ទីក្រុង ខេត្ត ប្រទេស ឬទ្វីបឯទៀត។
- **ការផ្លាស់ប្តូរប្រជាជន** គឺជាពេលដែលរដ្ឋាភិបាលរុញច្រាន ឬបង្ខំឱ្យក្រុមមនុស្សមួយក្រុមធំចេញពីប្រទេស ឬតំបន់មួយ។ ជាទូទៅ វាមានភាពទាក់ទងនឹងបញ្ហាជនជាតិ (ពូជអម្បូរ) ឬសាសនា។ ការធ្វើចំណាកស្រុកបែបនេះ ត្រូវបានគេស្គាល់ផងដែរថាជា ការធ្វើចំណាកស្រុកដោយបង្ខំ ឬការធ្វើចំណាកស្រុកដោយអចេតនា។

[4] ដកស្រង់ចេញពីឯកសារស្រាវជ្រាវរបស់ Ranyta Yusran ក្រោមប្រធានបទ Violence, Exploitation, and Abuse and Discrimination in Migration Affecting Women and Children in ASEAN: A Baseline Study នៃសាកលវិទ្យាល័យឥណ្ឌូនេស៊ី សាខាដេប៉ុក (University of Indonesia-Depok Campus) នៃប្រទេសឥណ្ឌូនេស៊ី ដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស ឆ្នាំ ២០១១ ទំព័រទី ៣៨៩

- **ការធ្វើចំណាកស្រុកបែបបង្ខំ** គឺជាចាកចេញពីប្រទេស ឬតំបន់ ដោយសារតែស្ថានភាពមិនអំណោយផល ដោយសារកត្តានយោបាយ សាសនា និងសង្គម។ វាត្រូវបានគេហៅផងដែរថាជា ចំណាត់ការនៃការធ្វើចំណាកស្រុក ឬការធ្វើចំណាកស្រុកដែលស្នាក់ស្នើរ។
- **ការធ្វើចំណាកស្រុកបែបជំហាន** គឺជាការផ្លាស់ប្តូរកន្លែងរស់នៅបែបជំហានៗ ពីទិសដៅជិតទៅទិសដៅកាន់តែឆ្ងាយ (ឧទាហរណ៍: ពីទីក្រុងមួយទៅខេត្តមួយ ទៅរាជធានីមួយ រួចទៅប្រទេសដទៃ។)
- **ការធ្វើចំណាកស្រុកជាលក្ខណៈបន្ត** គឺជាការធ្វើចំណាកស្រុកលក្ខណៈគ្រួសារ ឬក្រុមមនុស្សដែលជាជាតិសាសន៍ដូចគ្នា ដោយបុគ្គលណាម្នាក់នាំសមាជិកគ្រួសារដទៃទៀតចាកចេញពីស្រុកបន្ទាប់ពីខ្លួនចាកចេញពីស្រុកបានមួយរយៈ។ (ឧទាហរណ៍: ជនជាតិចិន)
- **ការធ្វើចំណាកស្រុកជនបទ-ទីក្រុង** គឺជាចលនាផ្លាស់ប្តូរទីលំនៅពីទីជនបទនានាទៅកាន់ទីក្រុង ដែលជាទូទៅ ដើម្បីស្វែងរកឱកាសការងារ ឬឱកាសផ្សេងៗ ដើម្បីរកលុយ។ (ឧទាហរណ៍: ប្រជាជនខ្មែរនាំគ្នាចាកចេញពីស្រុកស្រែចម្ការ ឬខេត្តផ្សេងៗ មកកាន់ទីក្រុងភ្នំពេញ។)
- **ការធ្វើចំណាកស្រុកតាមរដូវ** គឺជាការផ្លាស់ប្តូរកន្លែងរស់នៅដោយសារអាកាសធាតុ ឬមូលហេតុនៃការដាំដុះ។ មនុស្សរស់នៅក្នុងសម័យបុរាណ បានផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ក្នុងគោលបំណងដាំដុះ និងប្រមូលផលដំណាំ។ នាពេលបច្ចុប្បន្ននេះ មនុស្សផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀតដោយសារអាកាសធាតុ។ អ្នកចូលនិវត្តន៍ខ្លះផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀតដោយសារបញ្ហាអាកាសធាតុ ដែលប៉ះពាល់ដល់ការដាំដុះរបស់ពួកគេ។
- **ការធ្វើចំណាកស្រុកដោយត្រឡប់មកវិញ** គឺជាការវិលត្រឡប់មកប្រទេស ឬកន្លែងដើមកំណើតវិញ បន្ទាប់ពីការធ្វើចំណាកស្រុក ជាពិសេសនៅពេលដែលពួកគេចូលនិវត្តន៍ ពួកគេនឹងវិលត្រឡប់មករកគ្រួសារ និងមិត្តភក្តិរបស់ពួកគេវិញ[5]។

## ១.៣. ទ្រឹស្តីនៃការធ្វើចំណាកស្រុក

ចំពោះការពន្យល់បកស្រាយអំពីបញ្ហាដែលទាក់ទងនឹងការធ្វើចំណាកស្រុក មានទ្រឹស្តីជាច្រើនដែលពាក់ព័ន្ធ។ នៅក្នុងការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ បានលើកឡើងនូវទ្រឹស្តីមួយចំនួនដែលនិយមប្រើ និងមានប្រសិទ្ធិភាពដើម្បីដោះស្រាយបញ្ហាចំណាកស្រុកនេះ។ ទ្រឹស្តីដែលលើក

[5] ប្រភព https://www.ultimatevisa.com/types-of-migration/

យកមកបកស្រាយដំបូង គឺទ្រឹស្តីរបស់លោក Duncan ដែលនិយាយអំពីមូលហេតុដែលមានឥទ្ធិពលចំពោះការធ្វើចំណាកស្រុក។ ចំណែកឯទ្រឹស្តីទីពីរ គឺទ្រឹស្តីរបស់លោក Everett Lee ដែលបង្ហាញអំពីការសម្រេចចិត្តធ្វើចំណាកស្រុក និងកត្តាដែលធ្វើឲ្យមានចំណាកស្រុក។ ទ្រឹស្តីទីបីដែលពាក់ព័ន្ធនឹងបញ្ហានៃការធ្វើចំណាកស្រុកនោះ គឺទ្រឹស្តីសេដ្ឋកិច្ច Neoclassic។ ទ្រឹស្តីទីបួន គឺទ្រឹស្តីសេដ្ឋកិច្ចថ្មី ហើយទ្រឹស្តីនេះមានការបកស្រាយផ្ទុយពីទ្រឹស្តីសេដ្ឋកិច្ច Neoclassic។ គំរូចុងក្រោយដែលយើងខ្ញុំលើកយកមកបកស្រាយនោះ គឺគំរូ Harris-Todaro នៃការធ្វើចំណាកស្រុក និងគំរូ Lewis។ ទ្រឹស្តីទាំងអស់ដែលរៀបរាប់ខាងលើ យើងខ្ញុំទាំងពីរនាក់នឹងបង្ហាញជូនដូចខាងក្រោម។

**១.៣.១. ទ្រឹស្តីរបស់លោក Duncan**

យោងតាមលោក Duncan បានលើកឡើងថា ផលប៉ះពាល់ដែលបានកើតឡើងដោយការផ្លាស់ប្តូរនៃកត្តារចនាសម្ព័ន្ធនៃប្រទេស គឺជាផលប៉ះពាល់ដែលបណ្តាលមកពីការធ្វើចំណាកស្រុក។ លោកបាននិយាយថា ការធ្វើចំណាកស្រុកបណ្តាលមកពីកត្តាធំៗចំនួន៤ គឺះ

❖ **កត្តាសេដ្ឋកិច្ច និងបច្ចេកទេស**

ផលិតកម្មទាំងអស់ ត្រូវបានបង្កើតឡើងដោយការផ្លាស់ប្តូរនូវបច្ចេកទេស របៀបវិធីសាស្ត្រ និង ស្ថានភាពថ្លៃដែលជាហេតុធ្វើឲ្យប្រាក់ឈ្នួលមានការផ្លាស់ប្តូរ។

❖ **កត្តាសង្គម**

ការអភិវឌ្ឍសង្គម បានបង្កើតឲ្យមាននូវរចនាសម្ព័ន្ធស្ថាបត្យកម្ម តំបន់ដីធ្លី ការដឹកជញ្ជូន ប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ។ ការរៀបចំ និងការបែងចែករវាងរដ្ឋបាលសាធារណៈ និងតម្រូវការថែរក្សាគ្រួសារ។

❖ **កត្តាខ្លួនឯង**

បុគ្គលដែលមានតម្រូវការខ្ពស់ និងគំនិតច្នៃប្រឌិត ចង់ដឹង ចង់ស្គាល់នូវអ្វីថ្មីៗ ហើយនឹងដោយសារតែការគំរាមកំហែង និងការចង់មានសេរីភាពផងនោះ ក៏សម្រេចចិត្តធ្វើការចំណាកស្រុក។

❖ **កត្តាធម្មជាតិ**

ការរស់នៅក្នុងបរិយាកាស និងបរិស្ថានដែលមានជំងឺផ្សេងៗកើតឡើងជាញឹកញាប់ ដូចជាជំងឺគ្រុនឈាម គ្រុនចាញ់ កាមរោគ ផ្តាសាយបក្សី -ល-។ ការកើតមានឡើងនូវទឹកជំនន់ ភាពរាំងស្ងួត គ្រោះធម្មជាតិផ្សេងៗ និងការប្រែប្រួលអាកាសធាតុ ដែលជាហេតុធ្វើឲ្យពួកគាត់ពិបាកក្នុងការរស់នៅ។

### ១.៣.២. ទ្រឹស្តីរបស់លោក Everett Lee

លោក Everett Lee បាននិយាយថា ការសម្រេចចិត្តធ្វើចំណាកស្រុក និងដំណើរការនៃការធ្វើចំណាកស្រុកកើតឡើងដោយសារកត្តាបួនប្រភេទដូចខាងក្រោម៖

❖ **កត្តាតំបន់ដើម (Place of Origin Factors)**

យោងតាមលោក Lee កន្លែងនីមួយៗមានកត្តាវិជ្ជមាន និងអវិជ្ជមាន។ ខណៈពេលដែលកត្តាវិជ្ជមាន គឺជាកាលៈទេសៈដែលផ្តល់ភាពងាយស្រួលដល់មនុស្សដែលរស់នៅទីនោះ ហើយអាចទាក់ទាញមនុស្សពីតំបន់ដទៃទៀតផងដែរ ចំណែកឯកត្តាអវិជ្ជមានមានទំនោររុញច្រានពួកគេ។ មានកត្តាជាច្រើនដែលជម្រុញឱ្យមនុស្សចាកចេញពីកន្លែងដើមកំណើតរបស់ខ្លួន ហើយឆ្ពោះទៅកាន់តំបន់ខាងក្រៅដែលហៅថា កត្តាជំរុញ (Push Factors)។

❖ **កត្តាតំបន់ទិសដៅ (Place of Destination Factors)**

មានកត្តាជាច្រើនដែលអូសទាញឱ្យមនុស្សចាកចេញពីកន្លែងដើមកំណើតរបស់ខ្លួន ហើយឆ្ពោះទៅកាន់តំបន់ខាងក្រៅដែលហៅថា កត្តាអូសទាញ (Pull Factors)។

❖ **ឧបសគ្គអន្តរាគមន៍(Intervening Obstacles)**

ឧបសគ្គអន្តរាគមន៍ដូចជា ចម្ងាយ និងការដឹកជញ្ជូនដែលបង្កើនឲ្យមានការជ្រើសរើសដល់អ្នកចំណាកស្រុកនៃតំបន់គោលដៅ។ ឧបសគ្គទាំងអស់នេះត្រូវបានគេបន្ថយចុះនៅសម័យទំនើបជាមួយនឹងបច្ចេកវិទ្យាទំនើប។ លោក Lee សំដៅទៅលើការចំណាយនៃការផ្លាស់ប្តូរ និងកត្តាផ្ទាល់ខ្លួន គឺជាឧបសគ្គអន្តរាគមន៍។

❖ **កត្តាផ្ទាល់ខ្លួន(Personal Factors)**

ក្រៅពីកត្តាដែលទាក់ទងនឹងទីកន្លែងដើម និងទិសដៅ និងឧបសគ្គអន្តរាគមន៍មានកត្តាផ្ទាល់ខ្លួនជាច្រើនដែលជំរុញការធ្វើចំណាកស្រុកនៅក្នុងតំបន់ណាមួយ។ ដំណើរការនៃការធ្វើចំណាកស្រុកគឺអាស្រ័យទៅលើកត្តាផ្ទាល់ខ្លួនដូចជា ការយល់ដឹង បញ្ញា ការទំនាក់ទំនង និងបរិយាកាសវប្បធម៌របស់បុគ្គលម្នាក់ៗ។ កត្តាផ្ទាល់ខ្លួន គឺអាស្រ័យទៅតាមទីកន្លែងនៃទិសដៅ។ នៅក្នុងន័យនេះវាគឺជាការយល់ឃើញរបស់បុគ្គលម្នាក់ៗ ចំពោះកម្លាំងអូសទាញ និងការរុញច្រានដែលមានឥទ្ធិពលលើការធ្វើចំណាកស្រុក ។

លើសពីនេះ លោក Lee បានធ្វើសេចក្តីសន្និដ្ឋានថា កត្តាជំរុញ-អូសទាញ (Pull-Push Factors) គឺមានឥទ្ធិពលខ្លាំងខ្លាណាស់ចំពោះការធ្វើចំណាកស្រុក។ ជាទូទៅលោក Lee សង្កេត

ឃើញថា កត្តាអូសទាញបានធ្វើឲ្យមានការចំណាកស្រុកពីទីជនបទមកកាន់ទីប្រជុំជនខ្លាំងជាងកត្តាជំរុញ[6]។

**១.៣.៣. ទ្រឹស្តីសេដ្ឋកិច្ច Neoclassic**

ទីកន្លែងដែលមានកង្វះកម្លាំងពលកម្ម ហើយមានតម្រូវការកម្លាំងពលកម្មខ្ពស់ នោះនឹងផ្តល់ប្រាក់ខែ ឬ ប្រាក់ឈ្នួលខ្ពស់ ដែលអាចទាញយកការចំណាកស្រុក ពីតំបន់ដែលមានកម្លាំងពលកម្មលើស[7]។

ទ្រឹស្តីនេះ គឺជាក្របខ័ណ្ឌទ្រឹស្តីដំបូង ដែលបានបង្កើតឡើង ដើម្បីពន្យល់អំពីបញ្ហាការធ្វើចំណាកស្រុក។ ទ្រឹស្តីនេះយល់ឃើញថា ការធ្វើចំណាកស្រុកកើតឡើងដោយសារតែភាពខុសគ្នារវាងទីតាំងភូមិសាស្ត្រ រវាងការផ្គត់ផ្គង់កម្លាំងពលកម្ម និងតម្រូវការការងារ។ ភាពខុសគ្នាទាំងនេះអាចកើតមានឡើងទាំងនៅក្នុងកម្រិតអន្តរជាតិ និងនៅក្នុងកម្រិតជាតិ។ បើយោងតាមទ្រឹស្តីនេះ ការធ្វើចំណាកស្រុកដែលមានលក្ខណៈអន្តរជាតិ គឺបណ្តាលមកពីភាពខុសគ្នារវាងកម្រិតប្រាក់ឈ្នួលរវាងប្រទេស និងទីផ្សារការងារ។

ប្រសិនបើភាពខុសគ្នានៃប្រាក់ឈ្នួលនេះត្រូវបានលុបចោល នោះបញ្ហាការធ្វើចំណាកស្រុកដើម្បីការងារនឹងអាចបញ្ឈប់បាន។ ម្យ៉ាងវិញទៀត ទីផ្សារការងារ គឺជាយន្តការសំខាន់ដែលជះឥទ្ធិពលដល់ការធ្វើចំណាកស្រុកអន្តរជាតិ។ ដូច្នេះ រដ្ឋាភិបាលអាចដោះស្រាយបញ្ហាការធ្វើចំណាកស្រុកតាមរយៈគោលនយោបាយទីផ្សារការងារ[8]។

**១.៣.៤. ទ្រឹស្តីសេដ្ឋកិច្ចថ្មី**

ទ្រឹស្តីសេដ្ឋកិច្ចថ្មីនៃការធ្វើចំណាក គឺមានចំណុចខុសគ្នាបើប្រៀបធៀបទៅនឹងទ្រឹស្តីសេដ្ឋកិច្ច Neoclassic ដែលបានលើកឡើងខាងលើ។ យោងទៅតាមទ្រឹស្តីនេះ ការសម្រេចចិត្តធ្វើការចំណាកស្រុក គឺការសម្រេចចិត្តដោយខ្លួនឯង ហើយវាគឺជាលទ្ធផលនៃការសម្រេចចិត្តសមូហភាព ដើម្បីបង្កើនប្រាក់ចំណូល ឱកាសការងារ និងកាត់បន្ថយហានិភ័យ។

ប្រទេសកំពុងអភិវឌ្ឍន៍ អាចកាត់បន្ថយហានិភ័យរបស់ខ្លួនតាមរយៈប្រព័ន្ធសុខុមាលភាព និងប្រព័ន្ធធានារ៉ាប់រង។ ដូច្នេះ ឧទាហរណ៍ថា ប្រសិនបើកសិករធ្វើការដាំដំណាំមួយបរាជ័យ មានទីផ្សារធានារ៉ាប់រងដំណាំ។ លើសពីនេះ មានលទ្ធភាពទទួលបានទីផ្សារអនាគត ដើម្បីទទួលបាន

[6] ដកស្រង់ចេញពី http://www.sociologydiscussion.com/demography/migration-demography/top-3-theories-of-migration/3148

[7] ប្រភព http://family.jrank.org/pages/1170/Migration-Theories-Migration.html

[8] ប្រភព https://www.futurelearn.com/courses/migration-theories/0/steps/35078

ការធានានូវតម្លៃសម្រាប់ការលក់ផលិតផលកសិកម្មផងដែរ។ ប្រសិនបើនរណាម្នាក់ជួបគ្រោះថ្នាក់ រងរបួស ឬបាត់បង់ការងារ ប៉ុន្តែពួកគេអាចទទួលបានអត្ថប្រយោជន៍ពីភាពអត់ការងារធ្វើរបស់ពួកគេ។ ប្រសិនបើនរណាម្នាក់ព្យាយាមកែលម្អអាជីវកម្មរបស់ខ្លួន នោះមានស្ថាប័នឥណទាន និងទីផ្សារមូលធនដែលផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបបំផុត។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ហានិភ័យទាំងអស់នេះ គឺជាបញ្ហាប្រឈមដែលកើតឡើងនៅក្នុងគ្រួសារ។ ដូចនេះ ការធ្វើចំណាកស្រុក គឺជាយុទ្ធសាស្ត្រមួយដើម្បីកាត់បន្ថយហានិភ័យនៅក្នុងគ្រួសាររបស់ពួកគេ។ ការធ្វើចំណាកស្រុកអន្តរជាតិអាចធ្លាក់ចុះនៅពេលដែលមានការបង្កើនការងារ និងការផលិតក្នុងស្រុក។ ដូច្នេះ បញ្ហាការធ្វើចំណាកស្រុកអាចធ្លាក់ចុះ ទោះបីជាភាពខុសគ្នានៃប្រាក់ឈ្នួលពុំទាន់រលាយបាត់ក៏ដោយ។

រដ្ឋាភិបាលមានឥទ្ធិពលដល់ការចាត់វិធានការ ដោះស្រាយបញ្ហាធ្វើចំណាកស្រុកមិនត្រឹមតែតាមរយៈគោលនយោបាយទីផ្សារការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចដោះស្រាយតាមរយៈគោលនយោបាយនានានៅលើទីផ្សារផ្សេងទៀតដែលបានកំណត់ខាងលើ (ប្រព័ន្ធសុខុមាលភាព ប្រព័ន្ធធានារ៉ាប់រង ឥណទាន -ល-)[9]។

### ១.៣.៥. គំរូ Harris-Todaro នៃការធ្វើចំណាកស្រុក

លោកសាស្ត្រាចារ្យ Harris និង Todaro បានលើកឡើងនៅក្នុងអត្ថបទមួយដែលស្តីពី "ការធ្វើចំណាកស្រុក ភាពគ្មានការងារធ្វើ និងការអភិវឌ្ឍន៍"។ នៅឆ្នាំ ១៩៧០ លោកបានបង្ហាញគំរូមួយដែលស្តីពីការធ្វើចំណាកស្រុកនៅតាមទីជនបទ នៅបណ្តាប្រទេសកំពុងការអភិវឌ្ឍ។

ការលើកឡើងចម្បងនៅក្នុងគំរូ Harris-Todaro គឺថាការធ្វើចំណាកស្រុកនៅក្នុងបណ្តាប្រទេសដែលស្ថិតនៅក្រោមការអភិវឌ្ឍ គឺដោយសារភាពខុសគ្នានៃប្រាក់ឈ្នួលរវាងទីជនបទ និងទីប្រជុំជន ដែលគេរំពឹងទុកជាមធ្យមជាជាងប្រាក់ខែជាក់ស្តែង។ បើយោងតាមគំរូ Harris-Todaro ការធ្វើចំណាកស្រុកត្រូវបានគេមើលឃើញថា ជាគម្លាតប្រាក់ឈ្នួល ឬ ប្រាក់ចំណូលរវាងវិស័យនៅតាមទីក្រុង និងជនបទ។ ប៉ុន្តែអ្នកធ្វើចំណាកមកកាន់ទីប្រជុំជនទាំងអស់ មិនមែនសុទ្ធតែអាចទទួលបាននូវប្រាក់ឈ្នួលខ្ពស់នៅក្នុងវិស័យនៅទីក្រុងនោះទេ។ ជនចំណាកស្រុកមួយចំនួនមិន

[9] ដកស្រង់ពីគេហទំព័រ https://www.futurelearn.com/courses/migration-theories/0/steps/35078

បានស្វែងរកការងារធ្វើទេ ហើយខ្លះទៀតទទួលបានការងារក្រៅផ្លូវការដែលមានប្រាក់ខែតិចជាងនៅក្នុងវិស័យជនបទ។ ដូច្នេះ ពួកគេបានក្លាយជាជនគ្មានការងារធ្វើនៅតាមទីប្រជុំជន[10]។

❖ **ការបកស្រាយទ្រឹស្តី Harris-Torado ដោយប្រើក្រាប**

យន្តការពីលើម៉ូដែលនេះ អាចត្រូវបានគេបញ្ជាក់បន្ថែមតាមរយៈដ្យាក្រាម។ ដ្យាក្រាមទី៤ បង្ហាញពីអនិកម្មភាពពេញលេញ និងលំនឹង Harris Torado ដែលត្រូវបានបង្កើតឡើងដោយ Corden និង Findlay នៅក្នុងឆ្នាំ១៩៧៥ នៅត្រង់ចំនុច " Urban Unemployment, Intersectoral Captain Mobility and Development" ក្នុងសៀវភៅ Economic មួយដែលជាស្នាដៃពួកលោក។

$O_A$ ជាចំនុចចាប់ផ្តើមសម្រាប់បៀវត្សក្នុងវិស័យកសិកម្ម $W_A$ ។ សមមូលគ្នាដែរ $O_M$ ជាចំនុចចាប់ផ្តើមសម្រាប់កម្លាំងពលកម្មដែលត្រូវបានគេប្រើប្រាស់ក្នុងវិស័យកម្មមន្តសាល និងអ័ក្សឈរនៅខាងស្តាំដែរវាស់ពីប្រាក់បៀវត្សក្នុងវិស័យកម្មន្តសាល ($W_M$)។ ខ្សែកោង MN តំណាងឲ្យ MPL ក្នុងវិស័យកម្មន្តសាល ចំនែកឯខ្សែកោង AA តាងឲ្យចំនុចសមមូលគ្នានៅក្នុងផលិតកម្មនៃវិស័យកសិកម្ម។ ខ្សែកោងទាំងពីប្រសប់គ្នាត្រង់ចំនុច Z (លំនឹងនៃអនិកម្មភាពពេញ)។ និយោជិកទាំងអស់ទទួលបាននូវប្រាក់បៀវត្សដូចគ្នាដែលតាងដោយ ($W_z$)។ អង្កត់ [$O_AL_Z$] តាងការងារក្នុងវិស័យកសិកម្មផ្ទុយទៅវិញអង្កត់ [$O_ML_Z$] តំណាងឲ្យកម្លាំងពលកម្មដែលត្រូវបានគេជួលក្នុងវិស័យឧស្សាហ៍កម្ម។ ចូរចងចាំថាប្រាកឈ្នួលនៅក្នុងវិស័យឧស្សាហ៍កម្មគឺត្រូវបានគេកំណត់នៅត្រង់ ($W_M$)។ គំនិតក្នុងខ្សែកោង Harris Torado ត្រូវបានគេលើកឡើងដើម្បីស្វែងរកចំណុចលំនឹង។ ទាញចេញពីលក្ខខណ្ឌនឹងសមីការ (៥)

$$W_AL_U = W_M L_M$$

- $W_A$ = Agricultural wage
- $L_U$ = Total amount of labor in the urban area, $L_U = L_M+L_{UN}$
- $W_M$ = Minimum wage
- $L_M$ = Total amount of labor in manufacturing sectors
- $L_{UN}$ = Total amount of the unemployed

[10] ដកស្រង់ចេញពីគេហទំព័រ http://www.sociologydiscussion.com/demography/migration-demography/top-3-models-of-migration/3160

ដ្យាក្រាមទី១.១ Full Employment and Harris Todaro Equilibriam




អត្រាប្រាក់បៀវត្ស ទាំងក្នុងពីរវិស័យត្រូវបានគេសន្មតថាស្មើទៅនឹង MPL នៅក្នុងវិស័យនោះ។ ជាមួយនឹងលក្ខខណ្ឌខាងលើ យើងទាញបានខ្សែកោងអ៊ីពែប៉ូលឬខ្សែកោង (qq) របស់ Harris Torado អាចត្រូវបានគេគូសជាមួយភាពយឺតស្មើ១ ហើយវាផ្តល់ឲ្យនូវពីរចំណុច H និង R ដែលបង្កើតឲ្យមានចំណុចលំនឹង។ អត្រាប្រាក់បៀវត្សក្នុងវិស័យកសិកម្ម គឺទាបជាងលំនឹងអនិកម្មភាពពេញលេញដូច្នេះ $W_A<W_F$។ អង្កត់ $[O_ML_M]$ និង $[O_AL_A]$ តំណាងឲ្យពលកម្មដែលត្រូវបានគេជួលរៀងគ្នាក្នុងវិស័យឧស្សាហកម្ម និងកសិកម្ម។ ដូច្នេះអង្កត់ $[L_AL_M]$ គឺជាពលកម្មដែលមិនត្រូវបានគេជួល។

មានគោលនយោបាយមួយចំនួនដែលបានស្នើឡើងដោយ Harris Torado ដើម្បីកាត់បន្ថយនិកម្មភាពនៅទីក្រុង ហើយដែលក្នុងនោះឧបត្ថម្ភធនទៅលើប្រាក់បៀវត្សត្រូវបានគេចាត់ទុកថាមានឥទ្ធិពលប្រសើរបំផុត។

ជារឿយៗគេសង្កេតឃើញថា ជនធ្វើចំណាកស្រុកដែលមកពីតំបន់ជនបទដូចគ្នាតែងតែមកស្នាក់នៅក្នុងតំបន់ទីក្រុងដូចគ្នាឬនៅក្នុងតំបន់ទីប្រជុំជនដែលនៅក្បែរខាងគ្នា ឬអាចថាជួយចែករំលែកគ្នានៅផ្ទះ (ជួល) ជាមួយគ្នា។ នៅក្នុងម៉ូដែលដែលបានបង្កើតឡើងដោយ William Carrington Enrica Detragiache និង Tara Vishwanath បានបង្ហាញថា អ្នកធ្វើចំណាកស្រុកពីមុ

នៗបានបង្កើតឲ្យមាននូវផលប៉ះពាល់ខាងក្រៅជាវិជ្ជាមាន (Positive Externality) សម្រាប់ជនធ្វើចំណាកស្រុកដែលមានសក្តានុពល (Potential Migrants) ក្រោយៗដែលចាកចេញពីស្រុករបស់ពួកគេតាមរយៈការរួមចំណែកបន្ទាបថ្លៃចាយវាយរស់នៅក្នុងទីក្រុង ឬទីប្រជុំជនដោយជួយឲ្យមាននូវទីស្នាក់អាស្រ័យ និងជួយកាត់បន្ថយនូវការងារ ឬប្រាប់ពីដំណឹងទាក់ទងនឹងការងារដែលពួកគាត់អាចធ្វើបាន។ ដូច្នេះ ការស្វែងរកការងារធ្វើ ការសម្រេចចិត្តជ្រើសយកការធ្វើចំណាកស្រុក និងឥរិយាបទនៃការរង់ចាំមើលនូវឱកាសការងារ អាចជាកត្តាដែលរួមចំណែកក្នុងការធ្វើឲ្យមាននូវស្ថានភាពលំនឹងនៅក្នុងម៉ូដែលចំណាកស្រុក។

សរុបមកជារួម ម៉ូដែល Harris Torado នៃចំណាកស្រុកមានលក្ខណៈជាមូលដ្ឋានបួនដូចខាងក្រោម÷

- ការធ្វើចំណាកស្រុក គឺត្រូវបានជំរុញជាបឋមដោយការគិតពិចារណាបែបសេដ្ឋកិច្ច ដោយឈរលើគោលការណ៍សនិទានីយ៍ (Rational) ដែលមានទំនាក់ទំនងទៅនឹងអត្ថប្រយោជន៍ និងចំណាយ ហើយភាគច្រើនគេគិតក្នុងន័យផ្នែកហិរញ្ញវត្ថុ ហើយក៏មានជាផ្នែកផ្លូវចិត្តផងដែរ។
- ការសម្រេចធ្វើចំណាកស្រុក គឺអាស្រ័យទៅនឹងភាពលំអៀងនៃប្រាក់ចំណូលរំពឹងទុក រវាងជនបទ និងទីក្រុង ជាជាងប្រាក់ចំណូលជាក់ស្តែង ដែលចំណូលរំពឹងទុកត្រូវវាស់ស្ទង់ដោយទំនាក់ទំនងរវាងអថេរពីរ គឺភាពលំអៀងនៃប្រាក់ចំណូលជាក់ស្តែងនៅជនបទ និងទីក្រុង រួមជាមួយនឹងប្រូបាបនៃការរកបានការងារធ្វើ ដោយជោគជ័យនៅទីក្រុង។
- ប្រូបាបនៃការទទួលបានការងារធ្វើនៅទីក្រុង មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងអត្រានៃការងារនៅក្រុង។ ហើយផ្ទុយមកវិញ វាមានទំនាក់ទំនងច្រាស់គ្នាទៅនឹងអត្រានិកម្មភាពនៅទីក្រុង។
- ស្ថានភាពដែលអត្រានៃការធ្វើចំណាកស្រុក មានភាពលើស ឬធំធេងជាងអត្រានៃកំណើនការងារធ្វើ គឺមិនត្រឹមតែអាចទៅរួចនោះទេ ហើយថែមទាំងជាអ្វីដែលគេហៅថា "សនិទានីយ" ឬ "Rational" នៃការសម្រេចចិត្ត ដែលបណ្តាលមកពីភាពខុសខ្លាំងរវាងប្រាក់ឈ្នួលដែលរំពឹងទុកនៅតាមទីជនបទ និងទីក្រុង។ អត្រានិកម្មភាពខ្ពស់នៅទីក្រុង គឺមិនអាចនឹងជៀសផុតនោះទេ ដែលវាជាលទ្ធផលនៃវិសមភាពដ៏ធ្ងន់ធ្ងរនៃឱកាសសេដ្ឋកិច្ចរវាងតំបន់

នៅជនបទ និងទីក្រុង ជារឿយៗ គេប្រទះឃើញកើតមានឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច[11]។

## ១.៣.៦. គំរូរបស់លោក Lewis នៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង

ម៉ូដែល Dual Sector ឬអាចហៅបានម្យ៉ាងទៀតថា ម៉ូដែល Lewis គឺជាម៉ូដែលនៅក្នុងសេដ្ឋកិច្ចអភិវឌ្ឍដំបូងឡើយ វាគ្រាន់តែជាអត្ថបទវិភាគធម្មតាទេ ប៉ុន្តែដោយសារការរួមចំណែកយ៉ាងមានសក្តានុពលរបស់វា នៅក្នុងមូលដ្ឋានគ្រឹះនៃជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ វាក៏ត្រូវបានគេចាត់ទុកថាជាម៉ូដែលន៍ ដែលធ្វើការពន្យល់បកស្រាយលើកំណើនសេដ្ឋកិច្ចតាមរយៈការផ្លាស់ប្តូររវាងពីរវិស័យ ដូចជាវិស័យកសិកម្មបែបប្រពៃណី និងវិស័យឧស្សាហកម្មទំនើប។

Lewis បានពន្យល់ទៅលើម៉ូដែលរបស់លោក ដោយលើកយកវិស័យសំខាន់ចំនួនពីរ ដែលមានដូចជា វិស័យកសិកម្ម និងវិស័យឧស្សាហកម្មទំនើប។ Lewis យល់ថា ដោយសារតែកម្រិតផលិតភាពរបស់ពលករក្នុងវិស័យកសិកម្មនូវទាបខ្លាំងនៅឡើយ វាអាចសបញ្ជាក់ឲ្យយើងឃើញថាកម្លាំងពលកម្មក្នុងវិស័យកសិកម្មពុំមានឥទ្ធិពលខ្លាំង ឬបន្តិចណាសោះទៅលើ Output សរុបរបស់ជាតិ បើទោះបីជាមានលំហូរយ៉ាងធំធេងនៃកម្លាំងពលកម្ម ពីវិស័យកសិកម្មទៅកាន់វិស័យឧស្សាហកម្ម ដែលមានរំលើសពលកម្មយ៉ាងលើសលប់ក៏ដោយ។ Lewis បានបង្ហាញទៀតផងដែរថា ការកើនឡើងនៃអត្រាសន្សំ និងវិនិយោគ ធ្វើឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ច។ កំណើននៃការសន្សំកើនឡើង គឺដោយសារពលករអាចរកប្រាក់ចំណូលបានច្រើនជាងមុន។ Lewis យល់ថា មានតែការធ្វើបែបនេះទេ ទើបធ្វើឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូលបាន។

ដូចនេះ គេអាចនិយាយបានថា ការធ្វើចំណាកស្រុកពីជនបទមកទីក្រុង គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងម៉ូដែលវិស័យទ្វេភាគនេះ ដោយសារថា មានការផ្ទេរកម្លាំងពលកម្មពីកន្លែងដែលមានភាពរំលើសមកកាន់កន្លែងដែលកំពុងត្រូវការកម្លាំងពលកម្មខ្លាំង។ លំហូរនៃពលកម្មនេះ នឹងត្រូវបង្ហាញនៅក្នុងរូបភាពដូចខាងក្រោម៖

[11] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ២៦-២៨

**រូបភាពទី ១.២ ម៉ូដែលនៃវិស័យទ្វេភាគរបស់ Lewis នៃការអភិវឌ្ឍ[12]**




- **ការបកស្រាយគំរូរបស់លោក Lewis នៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុងតាមក្រាប**

នៅក្នុងអត្ថបទរបស់សាស្ត្រាចារ្យ W. Arthur Lewis ដែលមានចំណងជើងថា "ការផ្គត់ផ្គង់ពលកម្មគ្មានកំណត់" (Unlimited Supplies of Labour) បានពន្យល់ពីដំណើរការនៃការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុង នៅក្នុងសេដ្ឋកិច្ចដែលមានការអភិវឌ្ឍ។ សេដ្ឋកិច្ចមិនទាន់អភិវឌ្ឍ គឺជាសេដ្ឋកិច្ចដែលមានវិស័យពីរគឺ សេដ្ឋកិច្ចទំនើប (សេដ្ឋកិច្ចឧស្សាហកម្ម) និងសេដ្ឋកិច្ចប្រពៃណី (សេដ្ឋកិច្ចកសិកម្ម)។

ក្នុងចំនោមទាំងពីរនេះ សេដ្ឋកិច្ចទំនើប គឺជាវិស័យដែលលេចធ្លោបំផុត។ នៅក្នុងសេដ្ឋកិច្ចទំនើបនេះ អ្នកមូលធននិយម (ម្ចាស់ផលិតកម្ម) គឺជាអ្នកយកដើមទុន (កត្តាផលិតកម្ម) ដែលអាចផលិតឡើងវិញបានមកប្រើប្រាស់ ពីព្រោះវាផ្តល់ឲ្យពួកគេនូវប្រាក់ឈ្នួលសម្រាប់ជួលពលកម្ម និងប្រាក់ចំណេញ។ ពោលគឺ ពួកគេជួលកម្លាំងពលកម្មផលិតផលិតផល ហើយលក់ចេញនូវផលិតផលទាំងនោះ ដើម្បីទទួលបានប្រាក់ចំណេញ។ ប៉ុន្តែនៅក្នុងវិស័យកសិកម្មជនបទ គ្មាន

[12] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ១៧-១៨

នរណាចេះប្រើប្រាស់ ឬថ្ងៃដើមទុនទាំងនោះឲ្យផលិតបានឡើងវិញ ដើម្បីប្រើប្រាស់នោះទេ។ ជាលទ្ធផល កម្លាំងពលកម្មមាននៅសល់សម្បូរបែប ហើយនិកម្មភាពក្លែងក្លាយបានលេចឡើង។ ផលិតភាពទាបនៃកម្លាំងពលកម្មក្នុងវិស័យកសិកម្ម អាចជាសូន្យ ឬក៏អវិជ្ជមាន។

ដើម្បីដោះស្រាយបញ្ហានៃនិកម្មភាពក្លែងក្លាយនេះ លោកសាស្ត្រាចារ្យ Lewis ចង់ឲ្យវិស័យមូលធននិយម (ឧស្សាហកម្ម) ពង្រីកឧស្សាហកម្មរបស់ខ្លួន ដោយការផ្ទេរពលកម្មពីវិស័យកសិកម្មជនបទឲ្យទៅជាវិស័យមូលធននិយម។ គាត់សន្មត់ថា ការផ្គត់ផ្គង់កម្លាំងពលកម្ម មានភាពយឺត (elastic) ល្អបំផុត នៅពេលដែលប្រាក់ឈ្នួលសមល្មម។

**ដ្យាក្រាមទី ១.២ Transfer of Labour to the Capitalist Sector**




នៅក្នុងដ្យាក្រាម ចំនួននៃកម្លាំងពលកម្មត្រូវបានបង្ហាញនៅលើអក្សអាប់ស៊ីស (X) និងអក្សអរដោនេ (Y) តំណាងឲ្យប្រាក់ឈ្នួល និងផលិតផលអប្បបរមា។ OA គឺជាអត្រាប្រាក់ឈ្នួលរបស់វិស័យកសិកម្ម ហើយ OW ជាប្រាក់ឈ្នួលរបស់វិស័យឧស្សាហកម្ម។ $WW_1$ បង្ហាញពីការផ្គត់ផ្គង់ពលកម្ម ដែលមានភាពយឺត (elastic) ល្អបំផុតនៅអត្រាប្រាក់ឈ្នួល OW។ $N_1D_1$ គឺជាខ្សែកោងផលិតភាពអប្បបរមានៃការងារ ដែលបង្ហាញពីតម្រូវការកម្លាំងពលកម្ម។ ដោយសារតែវិស័យឧស្សាហកម្មបង្កើនប្រាក់ចំណេញ អត្រាប្រាក់ឈ្នួលនៅតែមានកម្រិតស្មើនឹងផលិតភាពអប្បបរមានៃការងារ។ នៅត្រង់ប្រាក់ឈ្នួលបច្ចុប្បន្ន OW ភាពមានការងារធ្វើតាងដោយ OL ហើយផលិតផលសរុបនៃវិស័យឧស្សាហកម្មតាងដោយ $N_1PLO$ ដែល ប្រាក់ឈ្នួលស្មើនឹង OWPL ហើយប្រាក់ចំណេញរបស់ម្ចាស់មូលធនស្មើនឹង $WPN_1$។ ហើយ $WPN_1$ នេះនឹងត្រូវបានគេយក

ទៅវិនិយោគជាថ្មីម្តងទៀត ដើម្បីបង្កើតមូលធនថ្មី។ គន្លឹះនៃដំណើរការនេះ គឺការប្រើប្រាស់មូលធនលើស (Capitalist Surplus)។

ការវិនិយោគឡើងវិញនៃប្រាក់ចំណេញ និងការពង្រីកវិស័យមូលធននិយមក៏ជួយបង្កើតការងារបន្ថែមផងដែរ។ ចំនួនដើមទុនថេរ (Fixed Capital) កើនឡើង ដោយសារការវិនិយោគបន្ថែម ហើយផលិតភាពអប្បបរមានៃការងារក៏កើនឡើងទៅដល់ $N_2D_2$ បណ្តាលឲ្យកើតមានមូលធនលើស (Capital Surplus)។ ភាពមានការងារធ្វើក៏កើនឡើងរៀងគ្នាកាន់តែច្រើនដល់កម្រិត $WP_1N_2$ និង $OL_1$។ លើសពីនេះទៀត ការវិនិយោគឡើងវិញបង្កើនផលិតភាពនៃការងាររហូតដល់ $N_3D_3$ ហើយកម្រិតនៃភាពមានការងារធ្វើដល់ $OL_2$។ ដំណើរការនេះនឹងបន្តរហូតទាល់តែកម្លាំងពលកម្មជនបទលើសលប់ទាំងអស់ ត្រូវបានស្រូបយកទៅក្នុងវិស័យឧស្សាហកម្ម។ បន្ទាប់មកទៀត ប្រសិនបើពលកម្មបន្ថែម ត្រូវបានដកហូតពីវិស័យកសិកម្មចិញ្ចឹមជីវិតទៅកាន់វិស័យឧស្សាហកម្ម វានឹងធ្វើឲ្យមានការខាតបង់ក្នុងការផលិតស្បៀងអាហារនៅក្នុងវិស័យជនបទ ដោយសារតែសមាមាត្រនៃកម្មករ កម្មការិនីទៅនឹងដីកសិកម្មថយចុះ។ នេះមានន័យថា ផលិតភាពអប្បបរមានៃការងារដែលនៅសេសសល់ មិនស្មើសូន្យទៀតនោះទេ។ ដូច្នេះ ខ្សែកោងនៃកម្លាំងពលកម្ម $WW_1$ នឹងធ្លាក់ចុះពីឆ្វេងទៅស្តាំដូចខ្សែកោងផ្គត់ផ្គង់ធម្មតា ហើយប្រាក់ឈ្នួល និងភាពមានការងារធ្វើនឹងបន្តកើនឡើងស្របជាមួយនឹងកំណើនប្រជាជន និងកំលាំងពលកម្មក្នុងរយៈពេលវែង[13]។

## ១.៤. ទ្រឹស្តីគតិយុត្តិស្តីពីការធ្វើចំណាកស្រុក

- ប្រកាសលេខ ២៥២ កំណត់ពីការទទួលខុសត្រូវរបស់ទីភ្នាក់ងារជ្រើសរើសឯកជនចំពោះពលករទេសន្តរប្រវេសន៍ក្នុងប្រទេសទិសដៅ មានការទាមទារក្នុងការធ្វើកិច្ចការបន្ថែមទៀត ដើម្បីធានាឲ្យមានការការពារពលករទេសន្តរប្រវេសន៍ ពេលកំពុងធ្វើការនៅបរទេស។
- អនុក្រឹត្យលេខ ១៩០ ប្រកាស ០៤៦ ជាមួយនឹងឯកសារណែនាំតម្រង់ទិសស្តង់ដារថ្នាក់ជាតិ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអាចធានាថា ពលករទេសន្តរប្រវេសន៍នីមួយៗ បានដឹងពីសិទ្ធិនៅកន្លែងការងារ និងការអនុវត្តនៅកន្លែងការងារ វប្បធម៌ និងប្រពៃណីនៅប្រទេសទិសដៅ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការយល់ដឹងពីសុខភាព និងវិធីក្នុងការទទួលបានសិទ្ធិរបស់ខ្លួន ទាំងនៅក្នុងប្រទេស និងនៅបរទេស។ ប្រកាសនេះធានា

[13] ប្រភព http://www.sociologydiscussion.com/demography/migration-demography/top-3-models-of-migration/3160

ថា អ្នកបណ្តុះបណ្តាលរបស់ទីភ្នាក់ងារជ្រើសរើស ត្រូវតែទទួលបានការបណ្តុះបណ្តាល ហើយពលករទេសន្តរប្រវេសន៍ត្រូវទទួលបានវិញ្ញាបនប័ត្រណែនាំតម្រង់ទិស មុនពេលចេញដំណើរ ដែលជាភស្តុតាងថា បានឆ្លងកាត់ការតម្រង់ទិស និងជាលក្ខខណ្ឌសម្រាប់ការធ្វើទេសន្តរប្រវេសន៍។

- អនុក្រឹត្យលេខ ២០៥ ស្តីពីការផ្តល់លិខិតឆ្លងដែនសញ្ជាតិខ្មែរធម្មតាដល់ពលរដ្ឋខ្មែរ និងសិស្សនិស្សិត បានចែងថា លិខិតឆ្លងដែនសម្រាប់ពលករទេសន្តរប្រវេសន៍ ត្រូវបានបង់ដោយរដ្ឋាភិបាល ហើយពលករទេសន្តរប្រវេសន៍ ត្រូវបង់ត្រឹមតែ ៤ ដុល្លារតែប៉ុណ្ណោះ សម្រាប់រូបថតក្នុងលិខិតឆ្លងដែន។
- ប្រកាសអន្តរក្រសួងលេខ ២៥៧៤ ស្តីពីទម្រង់ និងនីតិវិធីក្នុងការចេញលិខិតឆ្លងដែនធម្មតាសម្រាប់ពលករខ្មែរ ដើម្បីទៅធ្វើការនៅបរទេសដោយស្របច្បាប់ ចែងថាពលករទេសន្តរប្រវេសន៍នឹងទទួលបានលិខិតឆ្លងដែនរបស់ខ្លួន នៅនាយកដ្ឋានលិខិតឆ្លងដែនរបស់ក្រសួងមហាផ្ទៃ ក្នុងទីក្រុងភ្នំពេញ និងការិយាល័យលិខិតឆ្លងដែនតាមខេត្តរបស់ក្រសួងមហាផ្ទៃ។ នៅត្រឹមឆ្នាំ ២០១៤ មានការិយាល័យលិខិតឆ្លងដែនថ្នាក់ខេត្តមួយនៅខេត្តបាត់ដំបង។
- ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ និងក្រមព្រហ្មទណ្ឌ បានរួមបញ្ចូលនូវបទប្បញ្ញត្តិ ដែលគ្រប់សកម្មភាពជួញដូរ ការជ្រើសរើសដែលមានការកេងប្រវ័ញ្ច ការឃុំខ្លួនខុសច្បាប់ និងការបោកប្រាស់ និងការបោកបញ្ឆោត (ពាក់ព័ន្ធនឹងអត្តសញ្ញាណក្លែងក្លាយ) ដោយជនល្មើស ឬជនល្មើសដែលមានចេតនា ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ឬលើជើងហោះហើរ ឬនាវា ដែលមានទង់ជាតិកម្ពុជាក្នុងទឹកដីណាមួយ ដែលមានជនល្មើស ឬជនរងគ្រោះជាជនជាតិកម្ពុជា។
- ក្រមរដ្ឋប្បវេណី និងក្រឹត្យច្បាប់លេខ ៣៨ របស់ប្រទេសកម្ពុជាដែលគ្រប់គ្រងលើកិច្ចសន្យា និងការទទួលខុសត្រូវផ្សេងទៀត បានរួមបញ្ចូលនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការរំលោភកិច្ចសន្យា ការអះអាងមិនត្រឹមត្រូវ អសុពលភាពនៃកិច្ចសន្យា និងការទទួលខុសត្រូវជាទណ្ឌកម្ម (រួមមានទាំងការធ្វេសប្រហែស)។ លិខិតុបករណ៍ច្បាប់ទាំងនេះ អាចត្រូវបានប្រើជាសេចក្តីយោងនៅពេលដែលពលករមួយរូបត្រូវបានកេងប្រវ័ញ្ច ឬបោកប្រាស់នៅក្នុងស្ថានភាព ជាការអនុវត្តកិច្ចសន្យា ប៉ុន្តែមិនមានភស្តុតាង ឬមូលដ្ឋានគ្រប់គ្រាន់ក្នុងការបន្តបណ្តឹងព្រហ្មទណ្ឌ។ យ៉ាងណាមិញមកទល់ពេលបច្ចុប្បន្ននេះ លិខិតុបករណ៍ទាំងនេះ

មិនត្រូវបានយោង ឬប្រើប្រាស់ក្នុងការជួយដល់បណ្តឹងរដ្ឋប្បវេណីនោះទេ ហើយមានបណ្តឹងព្រហ្មទណ្ឌតិចតួចពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ ត្រូវបានប្តឹងបន្ត ដែលក្នុងនោះមានមួយចំនួនតូចប៉ុណ្ណោះ ត្រូវបានប្តឹងបន្តដោយជោគជ័យ។ ច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជាអនុវត្តន៍ចំពោះតែការងារ ដែលបំពេញក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ហើយមិនអនុវត្តន៍លើការងារ ដែលបានបំពេញនៅបរទេសឡើយ[14]។

## ១.៥. គោលនយោបាយកាត់បន្ថយចំណាកស្រុក

បច្ចុប្បន្ន មានពលរដ្ឋកម្ពុជាច្រើនម៉ឺននាក់ ធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ហើយចលនាចំណាកស្រុកពីជនបទមកទីក្រុងក៏កើនឡើងច្រើនដែរ។ ប្រសិនបើមានចលនាចំណាកស្រុកច្រើនពេក បង្កើតឲ្យមានវិបត្តិកម្លាំងពលកម្មដែលមិនអាចបំពេញតម្រូវការក្នុងស្រុកបាន។ ដូចនេះហើយ បញ្ហាចំណាកស្រុកមកកាន់ទីក្រុងភ្នំពេញ ឬខេត្តផ្សេងៗ ព្រមទាំងទៅក្រៅប្រទេសនេះ បានផ្តល់ផលប៉ះពាល់អវិជ្ជមានយ៉ាងច្រើនមកលើប្រទេសយើង។ អាស្រ័យដូចនេះហើយទើបរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ បានព្យាយាមបង្កើតនូវគោលនយោបាយ និងវិធានការផ្សេងៗ ដើម្បីទប់ស្កាត់ និងកាត់បន្ថយការធ្វើចំណាកស្រុកមិនឲ្យមានច្រើនខ្លាំងពេក។ យុទ្ធសាស្ត្រនៃគោលនយោបាយទាំងនោះគឺ រៀបចំបំពេញនូវតម្រូវការចំណុចខ្វះខាតនានា ដែលពាក់ព័ន្ធនឹងតម្រូវការការងារ និងការបង្កើនឱកាសការងារសមរម្យ ដើម្បីជាមូលដ្ឋានក្នុងការអនុវត្ត និងសម្រេចឲ្យបាននូវគោលដៅ និងសកម្មភាពបង្កើនឱកាសការងារសមរម្យតាមវិស័យ និងទីតាំងភូមិសាស្ត្រ។ លើសពីនេះ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការផ្តល់ព័ត៌មានទីផ្សារជាអាទិ៍។

### ១.៥.១. គោលនយោបាយរាជរដ្ឋាភិបាលកាត់បន្ថយចំណាកស្រុក

#### ១.៥.១.១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

ដើម្បីសម្រេចបាននូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមធម៌ ទាំងបរិមាណ និងគុណភាព ដែលឆ្លើយតបបានតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងសំដៅឈានទៅរកដំណោះស្រាយកាត់បន្ថយការធ្វើចំណាកស្រុក យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជ

[14] ប្រភពពី សៀវភៅ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាខែ ធ្នូ ឆ្នាំ ២០១៤ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ១៥-១៩

រដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់នូវយុទ្ធសាស្ត្រអាទិភាពចំនួន ៣ ធំៗ ។

**ក. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ**

យុទ្ធសាស្ត្រទី ១ គឺការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីធានាសិទ្ធសេរីភាព និងលក្ខខណ្ឌការងារ គោរពទៅតាមបទដ្ឋាន និងស្តង់ដាអន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែចង់ឃើញកម្មករនិយោជិត និងប្រជាពលរដ្ឋកម្ពុជាទទួលបានផលប្រយោជន៍សេដ្ឋកិច្ច ដែលកើតចេញពីការវិនិយោគប៉ុណ្ណោះទេ ថែមទាំងមានមហិច្ឆតាឲ្យកម្មករនិយោជិតខ្មែរទទួលការគោរពសិទ្ធិពីម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានផងដែរ។ គោលនយោបាយនេះ ផ្តោតសំខាន់ទៅលើការលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង និងពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការជំរុញអនុម័តច្បាប់ស្តីពីសហជីព ដោះស្រាយវិវាទការងារ និងបង្កើតតុលាការការងារ។ ការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារក៏មានសារៈសំខាន់ណាស់ដែរនៅក្នុងគោលនយោបាយនេះ ដោយហេតុថាបុគ្គលិកទាំងអស់នឹងមិនចាំបាច់ភ័យខ្លាច ឬព្រួយបារម្ភ ហើយប្រកបការងារដោយមានទំនុកចិត្តលើសហគ្រាស ឬក្រុមហ៊ុន។

**ខ. ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

យុទ្ធសាស្ត្រទី ២ គឺការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ក្នុងរយៈពេលចុងក្រោយនេះ រាជរដ្ឋាភិបាលបានធ្វើអាទិភាពកម្មវិស័យអប់រំមួយជំហានទៀត ដោយបានកំណត់ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីជំរុញការបណ្តុះបណ្តាល និងវិក្រិតការជំនាញ និងវិជ្ជាជីវៈ ព្រមទាំងការហ្វឹកហាត់កូនជាង ដោយផ្តល់ការលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជន សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារ និងបង្កើនចំណូលជូនពលករ និងនិយោជក។ យុទ្ធសាស្ត្រនេះ បានផ្តោតការយកចិត្តទុកដាក់លើ ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការងារ ដោះស្រាយ និងកាត់បន្ថយភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងបង្កើនចំណូលរបស់ប្រជាជន ដែលគោលដៅទាំងនេះអាចឈានទៅដល់ការកាត់បន្ថយចំណាកស្រុកផងដែរ។

**គ. ការអភិវឌ្ឍមុខរបរ និងការងារ**

យុទ្ធសាស្ត្រទី ៣ គឺការអភិវឌ្ឍមុខរបរ និងការងារ។ ការអភិវឌ្ឍមុខរបរ និងការងារសមរម្យដែលស្របតាមបទដ្ឋានស្តង់ដាអន្តរជាតិ ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំង

តាមរយៈការខិតខំទាក់ទាញវិនិយោគពីវិស័យឯកជនក្នុងស្រុក និងក្រៅស្រុក ដែលជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងកាត់បន្ថយពលករចាកចេញពីស្រុក។ យុទ្ធសាស្ត្រនេះ មានគោលដៅពង្រីកការផ្តល់សេវាការងារ និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានទីផ្សារ ជាពិសេសការផ្តល់ព័ត៌មានពីប្រាក់ឈ្នួល[15]។

### ១.៥.១.២. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥

គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ កំណត់ចេញនូវសសរស្តម្ភចំនួនបី ដែលផ្តោតទៅលើការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ ការជំរុញការអភិវឌ្ឍជំនាញ និងធនធានមនុស្ស និងការពង្រឹងអភិបាលកិច្ចទីផ្សារការងារ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងថា គោលនយោបាយជាតិស្តីពីមុខរបរ និងការងារលើកដំបូងរបស់ប្រទេសកម្ពុជានេះ នឹងជួយកាត់បន្ថយចំណាកស្រុកពីជនបទមកទីប្រជុំជន តាមរយៈការជួយបង្កើតជំនាញបច្ចេកទេសដល់អ្នកនៅតាមជនបទ[16]។

**ក. ការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់**

ការបង្កើនឱកាសការងារថ្មីដែលសមរម្យ និងមានផលិតភាពការងារខ្ពស់ និងការធ្វើឲ្យបរិយាកាសនៃការអភិវឌ្ឍសេដ្ឋកិច្ចមានលក្ខណៈអំណោយផល ដល់ការបង្កើតឱកាសការងារបន្ថែម គឺជាគោលនយោបាយដ៏សំខាន់មួយក្នុងការកាត់បន្ថយចំណាកស្រុក។ រាជរដ្ឋាភិបាលបានធ្វើការសិក្សាឲ្យច្បាស់អំពីគោលនយោបាយអភិវឌ្ឍន៍សហគ្រាស តាមវិស័យ និងនៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច ដោយពិចារណាពីទិដ្ឋភាពនៃភាពមានការងារធ្វើសមរម្យ ដើម្បីធានាថា គោលនយោបាយទាំងនោះលើកស្ទួយដល់ការបង្កើនការងារសមរម្យ និងដែលមានផលិតភាពការងារខ្ពស់។ គោលដៅនៃគោលនយោបាយទាំងនោះមានដូចជា លើកស្ទួយការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់នៅក្នុងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ ដែលគោលនយោបាយទាំងអស់នេះមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបី។ វិធានការក្នុងការបង្កើនឱកាសការងារសមរម្យនេះ គឺដាក់ចេញនូវគោលដៅ អំពីចំនួនឱកាសការងារដែលត្រូវបង្កើត កសាងសមត្ថភាព និងជំនាញបច្ចេកទេស

[15] ដកស្រង់ចេញពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ៥៩-៨៣

[16] ប្រភព https://www.rfa.org/khmer/news/social-economy/The-Benefits-of-National-Employment-Policy-10262015045427.html

ជំរុញការវិនិយោគក្នុងស្រុក និងវិនិយោគទុនផ្ទាល់ពីបរទេស ផ្សព្វផ្សាយច្បាប់ស្ដីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនដល់កម្មករ នយោជិត និងនយោជកជាដើម។

**ខ. ការលើកកម្ពស់ការអភិវឌ្ឍជំនាញ និងធនធានមនុស្ស**

កង្វះខាតជំនាញ គឺជាកត្តារាំងមួយដ៏ចម្បងដល់ការអភិវឌ្ឍខ្សែផលិតកម្មថ្មី ឬបង្កើនផលិតកម្ម។ ការកសាងសមត្ថភាព ជំនាញជូនពលរដ្ឋវ័យក្មេង និងកម្មករដែលកំពុងធ្វើការងារ ហើយមានផលិតភាពទាប និងទទួលបានចំណូលតិច ឲ្យប្រែក្លាយជាអាចផលិតបានផលិតភាពខ្ពស់ និងទទួលបានចំណូលសមរម្យ និងប្រសើរឡើង អាចកាត់បន្ថយ ឬបញ្ឈប់គំនិតដែលចង់ធ្វើចំណាកស្រុករបស់ពួកគេ ជាពិសេសចំពោះអ្នកដែលចង់ធ្វើចំណាកស្រុកទៅក្រៅប្រទេស។ ការបណ្តុះបណ្តាលជំនាញទន់ ក៏ដូចជាពង្រឹង និងពង្រីកការអភិវឌ្ឍមុខជំនាញនេះទៅដល់សិក្ខាកាម សិស្ស និស្សិត និងកម្មករនយោជិតជំរុញឲ្យពួកគេងាយរកការងារធ្វើបាននៅក្នុងស្រុក ព្រមទាំងទទួលបានប្រាក់ចំណូលសមរម្យថែមទៀតផង។ ក្រៅពីនេះ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវធ្វើឡើងឲ្យសមស្របទៅតាមតម្រូវការទីផ្សារការងារ។

**គ. ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ**

ដើម្បីទប់ស្កាត់ការចាកចេញពីស្រុករបស់ប្រជាពលរដ្ឋទៅកាន់ទីកន្លែងផ្សេងៗ ការពង្រឹងមូលដ្ឋានទិន្នន័យ ប្រព័ន្ធព័ត៌មានទីផ្សារការងារ និងសេវាកម្មការងារ ដើរតួយ៉ាងសំខាន់ក្នុងដំណើរការនេះ ដោយប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានពីការងារគ្រប់ប្រភេទ និងមានជម្រើស និងពិចារណាថានឹងជ្រើសរើសការងារមួយណា ដែលខ្លួនពេញចិត្ត ដោយមិនបាច់ភ័យខ្លាចថាពុំមានការងារធ្វើនោះឡើយ។ បន្ថែមពីលើនេះទៀត ការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងការពារកម្មការនយោជិត នឹងធ្វើឲ្យគុណភាពជីវិតរបស់ពួកគេមានភាពប្រសើរឡើង ពោលគឺធ្វើឲ្យបរិយាកាសការងារល្អ ក៏អាចនឹងធ្វើឲ្យប្រជាពលរដ្ឋពិចារណាធ្វើការងារក្នុងស្រុកជាជាងទៅក្រៅស្រុក។ ដូចគ្នានេះដែរ ការធ្វើសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ និងពង្រឹងយន្តការកំណត់ប្រាក់ឈ្នួល បានលើកកម្ពស់សហជីព និងកាត់បន្ថយវិវាទការងារ ដែលនេះជាអ្វីដែលពលរដ្ឋចំណាកស្រុកភាគច្រើនចង់បាន[17]។

### ១.៥.១.៣. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥

នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានដាក់ចេញ និងជំរុញអនុវត្ត

[17] ដកស្រង់ពី សៀវភៅ គោលនយោបាយជាតិស្ដីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ៦-១៥)

វិធានការគោលនយោបាយសំខាន់ៗដូចជា ការជំរុញការទាក់ទាញវិនិយោគ តាមរយៈការសម្រួលដល់បរិយាកាសវិនិយោគ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម ដែលតំបន់ទាំងនេះភាគច្រើនស្ថិតនៅតាមទីជនបទ ឬខេត្តនានា ហើយដើម្បីសម្រួលដល់ដំណើរការនៃតំបន់នេះ ហេដ្ឋារចនាសម្ព័ន្ធដូចជា អគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ផ្លូវថ្នល់ ប្រព័ន្ធបញ្ចេញកាកសំណល់ និងទឹកសម្អុយ ព្រមទាំងសេវាសង្គម សុខាភិបាល និងអប់រំ ត្រូវបានអភិវឌ្ឍន៍។ ម្យ៉ាងទៀត ការពង្រីក និងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម បានជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ដោយរាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនទាំងឡាយណា ដែលបោះទីតាំងក្នុងតំបន់ក្បែរនឹងវត្ថុធាតុដើម (តំបន់ជនបទ ស្រុកស្រែចម្ការ) ជំរុញបច្ចេកទេសកែច្នៃកសិផលសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយផ្អែកលើខ្សែចង្វាក់តម្លៃច្បាស់លាស់។ មួយវិញទៀត ការរៀបចំទីផ្សារពលកម្ម និងទំនាក់ទំនងវិជ្ជាជីវៈ ការបណ្តុះបណ្តាលជំនាញធនធានមនុស្ស ការជំរុញវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ការកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មដូចជា ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវអាកាស និងកំពង់ផែ ក៏ជាគោលនយោបាយ និងផែនការសំខាន់សម្រាប់អភិវឌ្ឍន៍កម្ពុជា ជាពិសេសនៅតំបន់ជនបទ និងកាត់បន្ថយចំណាកស្រុក[18]។

### ១.៥.១.៤. គោលនយោបាយគណបក្សប្រជាធិបតេយ្យមូលដ្ឋាន

គោលនយោបាយអភិវឌ្ឍន៍មូលដ្ឋាន ភូមិ ឃុំ របស់គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គ.ប.ម) ក៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយចំណាកស្រុកផងដែរ។ គោលនយោបាយនេះ មានវិធានការដូចខាងក្រោម៖

**ក. មេឃុំមេភូមិល្អ**

- អ្នកភូមិយើងឈប់បែកបាក់គ្នាដោយសារតែរឿងនយោបាយ
- អ្នកភូមិយើងចេះសហការគ្នាអភិវឌ្ឍភូមិឃុំ
- អ្នកភូមិយើងទទួលបានសេវារដ្ឋបាលសាធារណៈល្អ
- អ្នកភូមិយើងជ្រើសរើសមេភូមិដោយផ្ទាល់តាមរយៈការបោះឆ្នោត
- អ្នកភូមិយើងមានផ្លូវល្អប្រើប្រាស់
- អ្នកភូមិយើងទទួលបានការសម្របសម្រួលដោះស្រាយទំនាស់ប្រកបដោយយុត្តិធម៌។

[18] ដកស្រង់ពី សៀវភៅ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ បោះពុម្ពផ្សាយដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ២២-៣៤

**ខ. គ្រូពេទ្យល្អ គ្រូបង្រៀនល្អ គ្រូកសិកម្មល្អគ្រប់គ្រាន់**

- អ្នកភូមិយើងទទួលបានសេវាសុខភាពល្អ
- កូនចៅអ្នកភូមិយើងចាប់ពីអាយុបីឆ្នាំឡើងទៅទទួលបានសេវាអប់រំល្អ
- កសិករយើងទទួលបានទឹក ទុន ទីផ្សារ និងបច្ចេកទេសកសិកម្មល្អ។

**គ. នគរបាលល្អ**

- អ្នកភូមិយើងទទួលបានសន្តិសុខ និងសុវត្ថិភាព
- ភូមិឃុំគ្មានគ្រឿងញៀន
- ភូមិឃុំគ្មានបងតូចបងធំ និងក្មេងទំនើង។

គោលនយោបាយអភិវឌ្ឍន៍ ភូមិ ឃុំ មានចំណុចសំខាន់ៗចំនួន១៦៖

១). ផ្តល់សេវារដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព ទទួលខុសត្រូវខ្ពស់ និងយុត្តិធម៌ដោយមិនមានការរើសអើង និងមិនប្រកាន់និន្នាការនយោបាយឡើយ។ យើងនឹងបង្កើតឱកាសនិងបរិយាកាសល្អដល់ប្រជាពលរដ្ឋគ្រប់រូបទាំងបុរស និងស្ត្រីឲ្យចូលរួមក្នុងកិច្ចការនយោបាយដឹកនាំឃុំ/សង្កាត់ដោយសេរី និងគ្មានការភ័យខ្លាច។ ក្នុងនោះដែរយើងនឹងសម្របសម្រួលឲ្យប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសមនុស្សល្អៗ ឲ្យធ្វើជាមេភូមិ របស់ខ្លួន។

២). ផ្តល់ឱកាសឲ្យកសិករគ្រប់រូបទទួលបានទុន ទឹក ទីផ្សារ បច្ចេកទេស និងមានដីសម្រាប់ប្រកបមុខរបរកសិកម្មបានប្រាក់ចំណូលខ្ពស់។ ក្រុមប្រឹក្សាឃុំ គ.ប.ម នឹងគាំទ្រឲ្យមានអង្គការសហគមន៍មូលដ្ឋាន និងគ្រូកសិកម្មល្អៗ មកធ្វើការបម្រើកសិករគ្រប់ៗគ្នា។ ក្រុមប្រឹក្សាឃុំនឹងស្វែងរកការសហការគាំទ្របន្ថែម ដល់សហគមន៍កសិករពីស្ថាប័ន និងក្រុមហ៊ុនពាក់ព័ន្ធ ដើម្បីឲ្យសហគមន៍កសិករទទួលបានទុន និងពង្រីកឱកាសទីផ្សារ។ សហគមន៍កសិករនឹងជួយធ្វើយ៉ាងណាឱ្យកសិករទទួលបានតម្លៃកសិផលរបស់ខ្លួនសមរម្យ។ យើងក៏រៀបចំឲ្យមានកសិដ្ឋានគំរូនៅគ្រប់ភូមិ ដើម្បីផ្តល់ឱកាសឲ្យកសិករបានរៀនសូត្រពីគ្នាទៅវិញទៅមក តាមរយៈទស្សនកិច្ចសិក្សាក្នុងនិងក្រៅឃុំ។

៣). ធ្វើការពង្រឹងពង្រីកហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ជាពិសេសធានាយ៉ាងណាឲ្យមានផ្លូវថ្នល់ ស្ពាន និង ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម ដែលមានគុណភាពល្អ។ យើងនឹងបង្កើតឲ្យមានសហគមន៍គាំទ្រ និងឃ្លាំមើលការអភិវឌ្ឍផ្លូវថ្នល់ ស្ពាន និងធារាសាស្ត្រនៅតាមមូលដ្ឋាន។

៤). ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវាព្យាបាលសុខភាព និងពិគ្រោះយោបល់គ្រប់គ្រាន់ពីមណ្ឌលសុខភាពនៅតាមឃុំ/សង្កាត់ ប្រកបដោយគុណភាព និងការទទួលខុសត្រូវខ្ពស់។ យើង

នឹងរៀបចំឲ្យមានការចូលរួមចំណែករបស់សមាគមន៍ប្រជាពលរដ្ឋក្នុងការទ្រទ្រង់ និងឃ្លាំមើលមណ្ឌលសុខភាពឃុំដើម្បីធ្វើយ៉ាងណាឲ្យមណ្ឌលសុខភាព មានសម្ភារៈបរិក្ខារល្អគ្រប់គ្រាន់ថ្នាំព្យាបាលល្អនិងគ្រូពេទ្យល្អ ធ្វើការបម្រើប្រជាពលរដ្ឋដោយស្មើភាពគ្នា និងគោរពតាមស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈគ្រូពេទ្យ។

៥). ធានាឲ្យបានប្រាកដថាកូនចៅរបស់ប្រជាពលរដ្ឋគ្រប់រូបបានទទួលការអប់រំល្អ ដោយស្មើភាពយ៉ាងតិចបំផុតបានរៀនចប់ថ្នាក់ទី០៩ ដោយមានចំណេះដឹងមូលដ្ឋានគ្រឹះគ្រប់គ្រាន់សម្រាប់អនាគតល្អប្រសើរ។ យើងនឹងរៀបចំឲ្យមានសហគមន៍ប្រជាពលរដ្ឋ ជំរុញការអប់រំឲ្យមានគុណភាព ដើម្បីធ្វើយ៉ាងណាឱ្យសាលារៀនមានគ្រូបង្រៀនល្អ កម្មវិធីសិក្សាល្អ និងបរិស្ថានសិក្សាល្អ។

៦). គាំទ្រដល់យុវជន និងយុវនារីដែលមិនមានលទ្ធភាពបន្តការសិក្សាដល់ថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យឲ្យទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទុនសម្រាប់បង្កើតមុខរបរដោយខ្លួនឯង។ យើងនឹងជ្រើសរើសមន្ត្រីជំនាញយ៉ាងតិច០១រូប ក្នុង០១ឃុំ ឲ្យជួយតម្រង់ទិស និងគាំទ្រដល់យុវជនដើម្បីទទួលបានការងារល្អ។

៧). បង្កើតឱកាសងាយស្រួលដល់សិប្បករសេវាករ និងពាណិជ្ជករក្នុងការអភិវឌ្ឍមុខរបរ និងបង្កើតការងារនៅតាមមូលដ្ឋាន **និងកាត់បន្ថយចំណាកស្រុក** ដូចជាជួយសម្រួលការចុះបញ្ជីការផ្សេងៗមិនយកលុយក្រៅប្រព័ន្ធ លើកលែងពន្ធដល់អ្នកចាប់ផ្តើមអាជីវកម្មដំបូង សម្របសម្រួលក្នុងការទទួលបានទុនកម្ចី និងជួយពង្រីកទីផ្សារ។

៨). រៀបចំឲ្យមានបណ្តាញការងារដែលមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ដើម្បីធានាឱ្យមានសន្តិសុខ និងសុវត្ថិភាពរស់នៅតាមឃុំ/សង្កាត់ ជាពិសេសធានាឲ្យនគរបាលមូលដ្ឋានមានសមត្ថភាពធនធាន និងឆន្ទៈធ្វើការបម្រើប្រជាពលរដ្ឋ។

៩). រៀបចំឱ្យមានបណ្តាញការងារដែលមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីចូលរួមក្នុងការអប់រំពលរដ្ឋ លុបបំបាត់ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន។

១០). រៀបចំឲ្យមានសហគមន៍ជួយគ្នាទៅវិញទៅមកនៅតាមមូលដ្ឋាន ជាពិសេសជួយគាំពារដល់ចាស់ជរាជនក្រីក្រគ្មានទីពឹងកុមារកំព្រា និងជនពិការ។

១១). គ្រប់គ្រងជនអន្តោប្រវេសន៍រស់នៅតាមមូលដ្ឋាន ឲ្យបានល្អតាមរយៈការពង្រឹងការសហការគ្នាឲ្យបានល្អ រវាងអាជ្ញាធរ និងប្រជាពលរដ្ឋនៅតាមភូមិឃុំ។ អាជ្ញាធរមូលដ្ឋានដែលដឹកនាំដោយ គ.ប.ម នឹងរៀបចំធ្វើស្ថិតិជនអន្តោប្រវេសន៍ឲ្យបានទៀងទាត់ និងឆ្លើយតបទាន់ពេលវេលាក្នុងករណីអន្តោប្រវេសន៍ខុសច្បាប់កើតឡើង។

១២). រៀបចំឱ្យមានតំបន់ទេសចរណ៍ធម្មជាតិ កសិកម្ម និងវប្បធម៌ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងការងារតាមមូលដ្ឋាន។

១៣). សហការជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដើម្បីស្តារឡើងវិញនូវធនធានធម្មជាតិជាពិសេសព្រៃឈើ និងធនធានជលផលតាមរយៈការដាំដើមឈើឡើងវិញ ការថែរក្សាព្រៃឈើសហគមន៍ស្តារស្រះសហគមន៍បឹង ប្រឡាយស្ទឹងអូរ និងព្រែកដែលមានតាមមូលដ្ឋាន។ យើងនឹងរៀបចំឱ្យមានកន្លែងអភិរក្សសត្វត្រីនៅតាមសហគមន៍មូលដ្ឋាន។ យើងនឹងធានាមិនឲ្យមានផលប៉ះពាល់អវិជ្ជមាន ដល់ប្រជាពលរដ្ឋពីគម្រោងអភិវឌ្ឍន៍ផ្សេងៗ។

១៤). រៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលស្ត្រីដើម្បីបង្កើនសមត្ថភាពយល់ដឹង និងការចូលរួមក្នុងកិច្ចការសេដ្ឋកិច្ចសង្គម និងនយោបាយ។

១៥). លើកកម្ពស់តួនាទីវត្តអារាមក្នុងការងារសង្គមកិច្ច និងបរិស្ថាន ដូចជាការជួយកុមារកំព្រាចាស់ជរា អប់រំអំពីបរិស្ថាន សីលធម៌ និងជំរុញការដាំដើមឈើឡើងវិញ។

១៦). រៀបចំឲ្យមានគណៈកម្មាធិការឃ្លាំមើលការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយសមាជិកគណៈកម្មាធិការនេះជាតំណាងប្រជាពលរដ្ឋដែលត្រូវបានបោះឆ្នោតជ្រើសរើសមកពីគ្រប់ភូមិ ដោយមិនប្រកាន់និន្នាការនយោបាយ[19]។

### ១.៥.១.៥. គោលនយោបាយបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs)

តំបន់សេដ្ឋកិច្ចពិសេស ជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយសារតែវានាំមកនូវ ហេដ្ឋារចនាសម្ព័ន្ធ ការងារ ជំនាញ បង្កើនផលិតភាព និងសំខាន់ជាងនេះទៅទៀត គឺកាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទ។ គោលនយោបាយរបស់រដ្ឋាភិបាល គឺចង់បង្កើតទីតាំងមូលដ្ឋានផលិតកម្មក្នុងតំបន់ផ្សេងៗ ជាជាងក្នុងទីក្រុងភ្នំពេញ ក្នុងគោលបំណង កសាងទំនាក់ទំនងសេដ្ឋកិច្ចរវាងតំបន់ទីប្រជុំជន និងជនបទ។ ដោយសារតែប្រទេសកម្ពុជាមិនទាន់ក្លាយជាសង្គមនគរូបនីយកម្មទាំងស្រុងនៅឡើយ តំបន់សេដ្ឋកិច្ចពិសេសនឹងបង្កើតការងារយ៉ាងច្រើនលើសលប់ដល់កម្លាំងពលកម្មក្នុងប្រទេស ដែលភាគច្រើនមកពីតាមខេត្ត និងជាពិសេសសម្រាប់ស្ត្រី។ បន្ថែមលើនេះទៀត ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស អាចជួយកាត់បន្ថយគម្លាតរវាងប្រាក់ចំណូលនៅជនបទ និងទីក្រុងបាន។

### ១.៥.១.៦. គោលនយោបាយជាតិប្រជាជន

គោលនយោបាយនេះ មានលក្ខណៈគ្របដណ្តប់ទូលំទូលាយ គ្រប់ជ្រុងជ្រោយ

[19] ប្រភព វិទ្យុបារាំងអន្តរជាតិ គេហទំព័រ https://www.rfa.org/khmer/policy-of-gdp-04212017223842.html

ដែលពាក់ព័ន្ធនឹងសកម្មភាពនានានៅក្នុងវិស័យជាច្រើនដូចជា សុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច យេនឌ័រ បម្លាស់ទីលំនៅ និងផ្នែកផ្សេងៗទៀត។ រាជរដ្ឋាភិបាលបាននឹងកំពុងបន្តពង្រឹងសមត្ថភាពធនធានមនុស្សសំដៅលើការអភិវឌ្ឍគ្រប់កម្រិត ដែលក្នុងនោះការកាត់បន្ថយផលប៉ះពាល់ជាងវិជ្ជមាននៃការផ្លាស់ប្តូរទីលំនៅរវាងជនបទ និងទីក្រុងក៏មានចែងក្នុងគោលនយោបាយនេះផងដែរ។ វិធានការចំពោះបញ្ហានេះរួមមាន៖

- ការវិភាគអំពីបម្លាស់ប្តូរទីលំនៅរវាងទីក្រុង និងជនបទ និងធ្វើឲ្យប្រសើរឡើងនូវការរកទិន្នន័យស្តីពីបម្លាស់ប្តូរទីលំនៅក្នុងស្រុក រួមមានទំហំ និងសមាសភាពនៃជនផ្លាស់ប្តូរទីលំនៅ។
- ផ្តល់នូវឱកាសផ្សេងៗដូចជា សេវាសង្គម ហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារ និងឱកាសការងារក្នុងតំបន់ជនបទ។
- បង្កើតតំបន់ជាយក្រុង ទីប្រជុំជន និងផ្សារ ដើម្បីបង្វែចេញនូវជនដែលមានបំណងផ្លាស់ប្តូរទីលំនៅទៅកាន់ទីក្រុងឲ្យនៅទីជនបទដដែល។
- គាំទ្រការបង្កើតការផ្សារភ្ជាប់សេដ្ឋកិច្ច និងស្ថាប័នរវាងទីក្រុង និងជនបទ។
- អនុវត្តគម្រោងសម្រាប់ការធ្វើបម្លាស់ទីលំនៅរបស់កសិករដែលគ្មានដីធ្លី ជនក្រីក្រនៅជនបទ ពីតំបន់ដីកសិកម្មដែលមានដង់ស៊ីតេខ្ពស់ ទៅតំបន់ដីដែលមិនទាន់ធ្វើកសិកម្ម ហើយផ្តល់ឲ្យពួកគាត់នូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដូចជា ផ្លូវ សាលារៀន សេវាកម្ម សុខាភិបាល -ល-[20]។

### ១.៥.១.៧. គោលនយោបាយអភិវឌ្ឍន៍ជនបទ

នៅក្នុងគោលដៅអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលសំដៅលើការធ្វើឲ្យប្រសើរឡើងនៃជីវភាពរបស់ប្រជាជននៅតាមជនបទ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវផលិតភាពក្នុងប្រព័ន្ធផលិតកម្មបែបគ្រួសារ និងកសិករតូចតាច។ ដើម្បីឈានទៅដល់គោលដៅមួយនេះ រាជរដ្ឋាភិបាលគួរធ្វើឲ្យមានភាពប្រសើរឡើងនៃការគ្រប់គ្រងដីធ្លី យន្តការទីផ្សារ តម្លាភាពនៃផ្នែកថ្លៃ និងការធានានូវការផ្គត់ផ្គង់ Inputs សម្រាប់ផលិតផលកសិកម្មឲ្យស្ថិតក្នុងតម្លៃសមរម្យ។ មួយវិញទៀត ឱកាសផ្នែកសេដ្ឋកិច្ច គួរតែត្រូវបានបង្កើតឡើងនៅក្នុងសេដ្ឋកិច្ចជនបទ ក្នុងគោលដៅធ្វើយ៉ាងណាឲ្យចំណូលក្រៅពីវិស័យកសិកម្មមានភាពប្រសើរឡើង និងស្រូបយកនូវកម្លាំងពលកម្មបន្ថែមទៀត

[20] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ៨៦-៨៧

ឲ្យចូលទៅក្នុងទីផ្សារការងារ។ ចំពោះការបណ្តុះបណ្តាលផ្នែកជំនាញកសិកម្ម និងក្រៅពីនេះ ព្រមទាំងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព គួរតែត្រូវបានលើកទឹកចិត្ត។

តាមរយៈបទពិសោធន៍កន្លងមក គេឃើញមានការធ្វើអន្តរាគមន៍ទាំងក្នុងវិស័យកសិកម្ម និងក្រៅកសិកម្ម។ ការធ្វើអន្តរាគមន៍លើវិស័យកសិកម្ម ស្ថិតក្រោមរូបភាពដូចជា ការជំរុញឲ្យមានការបង្កើតទីផ្សារកសិផលសរីរាង្គ និងផលិតផលបែបបុរាណ ព្រមទាំងការធ្វើឲ្យប្រសើរឡើងនៃផលិតភាពកសិករតាមរយៈការផ្ទេរបច្ចេកវិទ្យា។ ឯវិស័យក្រៅកសិកម្មវិញមានដូចជា ការលើកកម្ពស់វិស័យទេសចរណ៍នៅជនបទ ការលើកកម្ពស់ និងអភិវឌ្ឍន៍មុខជំនាញខ្នាតតូច និងមធ្យម និងគម្រោងការងារសាធារណៈសម្រាប់រដូវប្រាំង។

ក្រៅពីនេះ ការអភិវឌ្ឍលើផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា សុខាភិបាល អប់រំ កសិកម្ម ការផ្គត់ផ្គង់ទឹក និងអនាម័យ -ល- មានសារៈសំខាន់បំផុត ក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ។ ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការលើការផ្តល់សេវាកម្មសាធារណៈ ការផ្តល់ឥណទានដល់គ្រួសារ និងអាជីវកម្មខ្នាតតូច គឺជាអ្វីដែលរាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងសម្រេចឲ្យបាន ដើម្បីកាត់បន្ថយភាពក្រីក្រ និងការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ[21]។

### ១.៥.២. គោលនយោបាយផ្សេងៗទៀត

#### ១.៥.២.១. ការឧបត្ថម្ភធននៅដល់ជនបទ

នៅក្នុងទ្រឹស្តី Harris និង Todaro ការឧបត្ថម្ភធនដល់វិស័យជនបទ អាចជួយកាត់បន្ថយនិកម្មភាពនៅទីក្រុង និងជនបទ។ បើគោលដៅរបស់រដ្ឋាភិបាល ចង់បើកយុទ្ធនាការកាត់បន្ថយអត្រានិកម្មភាពនៅទីជនបទ និងទីក្រុង ការធ្វើឧបត្ថម្ភធនដល់វិស័យកម្មន្តសាល និងការដាក់កំហិតលើការធ្វើចំណាកស្រុក។ ប៉ុន្តែ គោលនយោបាយនេះពុំសូវត្រូវបានគេនិយមយកមកប្រើក្នុងស្ថានភាពជាក់ស្តែងទេ ព្រោះវាប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់មនុស្សក្នុងការដើរហើរ ហើយម្យ៉ាងទៀត គេមិនប្រាកដថា ការបែងចែកកម្លាំងពលកម្មរវាងទីក្រុង និងជនបទមានប្រសិទ្ធភាពទេ។ ដូច្នេះ ដើម្បីជៀសវាងការដាក់កំហិតលើការធ្វើចំណាកស្រុក ការធ្វើឧបត្ថម្ភធនដល់ជនបទ ជាជម្រើសដ៏ល្អបំផុត។ ការធ្វើឧបត្ថម្ភធនលើវិស័យកម្មន្តសាល អាចធ្វើឲ្យមានកំណើនឡើងនៃការងារនៅក្នុងទីក្រុង ដែលអាចកាត់បន្ថយអត្រានិកម្មភាពនៅក្នុងទីក្រុងបាន ស្របពេលដែលនិកម្មភាពនៅទីជនបទមានការកើនឡើង។ ផ្ទុយមកវិញ ប្រសិនបើវិស័យកសិកម្ម ត្រូវបានទទួល

[21] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុជាន់ណាក់ ចំណាងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ៨២-៨៤

ឧបត្ថម្ភធនពីរាជរដ្ឋាភិបាល នោះការងារនៅជនបទនឹងមានកំណើនឡើង។ ដូច្នេះ យុទ្ធសាស្ត្រដ៏ល្អបំផុត គឺការធ្វើឧបត្ថម្ភធនទៅលើវិស័យទាំងពីរ។

### ១.៥.២.២. ការបង្កើត និងការលើកកម្ពស់ឲ្យមានតំបន់ទីក្រុងរណបឲ្យបានច្រើន

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ការធ្វើចំណាកស្រុកកើតមានយ៉ាងលើសលប់ដោយមូលហេតុថា មានភាពលំអៀងខ្លាំងនៃទីប្រជុំជន (Urban Bias)។ ការលើកស្ទួយឲ្យមានតំបន់ទីក្រុងរណប (Secondary Cities) ជាការលើកកម្ពស់ដល់ការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យផ្សេងៗជាច្រើនទៀតនៅជនបទ ក៏ដូចជាកាត់បន្ថយនូវសម្ពាធនៃកំណើនទីក្រុងធំៗ (Main City)។ ការធ្វើឲ្យតំបន់ជនបទស្ថិតនៅជិតទីក្រុងរណប ជាការបើកផ្លូវឲ្យមានភាពងាយស្រួលដល់ការស្តុកទុកនូវផលិតផលកសិកម្ម តាមរយៈការកាត់បន្ថយចម្ងាយ និងរយៈពេលដឹកជញ្ជូនទៅផ្សារ ព្រមទាំងកាត់បន្ថយនូវការខាតបង់បន្ទាប់ពីធ្វើការប្រមូលផលរួច។ លើសពីនេះ តាមរយៈទិដ្ឋភាពនៃនគររូបនីយកម្ម ទីក្រុងរណបមានសក្តានុពលបំផុត ក្នុងការដើរតួនាទីជាផ្សារចម្លង ព្រមទាំងជួយបង្កើតការងារផងដែរ[22]។

## ១.៦. បញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ

ទោះបីជាមានការខិតខំប្រឹងប្រែងពីថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទពាក់ព័ន្ធដែលបានខិតខំជំនះគ្រប់ឧបសគ្គ ដើម្បីសម្រេចបាននូវសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏ក្រសួងនៅតែជួបបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ និងចាត់វិធានការដូចតទៅ៖

### ១.៦.១. បញ្ហាប្រឈមក្នុងការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

ជាក់ស្តែង នៅក្នុងវិស័យការងារ បញ្ហាប្រឈមចម្បងៗ ដែលក្រសួងបានជួបប្រទះមានដូចជា៖

- គុណភាព វិធីសាស្ត្រ និងប្រសិទ្ធភាពនៃការចុះធ្វើអធិការកិច្ចការងារ និងដោះស្រាយវិវាទការងារ នៅមានកម្រិតនៅឡើយ។
- សមត្ថភាពរបស់មន្ត្រីអធិការកិច្ចការងារ មន្ត្រីដោះស្រាយវិវាទការងារ និងមន្ត្រីអធិការកិច្ចពេទ្យការងារ នៅមានកម្រិតនៅឡើយ។

[22] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណាងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ៣៣-៣៥

- មិនទាន់មានជាលក្ខណៈប្រព័ន្ធក្នុងការគ្រប់គ្រងទិន្នន័យស្ថិតិរោងចក្រ សហគ្រាស គ្រឹះស្ថាន សហជីព កម្មករនិយោជិត និងរបាយការណ៍គ្រោះថ្នាក់ការងារ។
- កង្វះខាតយន្តការទប់ស្កាត់បញ្ហាកូដកម្ម បាតុកម្ម និងដោះស្រាយវិវាទការងារ ឲ្យកាន់តែប្រសើរឡើង ក្នុងគោលបំណងធានាសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មការនិយោជិត និងនិយោជក។
- កង្វះខាតបទប្បញ្ញត្តិមួយចំនួនសម្រាប់គ្រប់គ្រងផ្នែកនីមួយៗនៃវិស័យការងារ ដូចជាច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីការបង្កើតតុលាការការងារ និងគោលការណ៍ស្តីពីការពង្រឹង និងលើកកម្ពស់ប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារជាដើម។
- បរិយាកាស និងបរិស្ថាននៅកន្លែងធ្វើការ និងជិតកន្លែងធ្វើការនៅមិនទាន់បានរៀបចំឲ្យបានល្អប្រសើរនៅឡើយ ដែលអាចបង្កគ្រោះថ្នាក់ការងារ ការចុះខ្សោយនៃសុខភាព និងការដួលសន្លប់របស់កម្មករនយោជិត។

### ១.៦.២. បញ្ហាប្រឈមក្នុងការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

នៅក្នុងការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាអាណត្តិកន្លងមកក្រសួងបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- កង្វះខាតការយល់ដឹងពីតម្លៃនៃការអប់រំបច្ចេកទេស និងវិជ្ជាជិវៈ និងនិន្នាការជំរុញលើកទឹកចិត្តឲ្យកូនចៅទៅសិក្សា។
- កម្មវិធី និងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារ។
- កង្វះខាតអន្តេវាសិកដ្ឋាន សម្រាប់សិក្ខាកាម សិស្ស-និស្សិត ដែលមកចូលរៀនក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- ជំនាញមួយចំនួនដែលទីផ្សារមានតម្រូវការ ប៉ុន្តែគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពុំទាន់មានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីធ្វើការបណ្តុះបណ្តាលកម្លាំងពលកម្មសម្រាប់ផ្គត់ផ្គង់ទីផ្សារការងារ។
- ការបញ្ជ្រាបកម្មវិធីសហគ្រិនភាព និងជំនាញទន់ទៅក្នុងកម្មវិធីសិក្សា ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមានកម្រិត។

- កង្វះខាតព័ត៌មានទីផ្សារការងារ ស្តីពីប្រភេទជំនាញ កម្រិត សមត្ថភាព និងបរិមាណនៃតម្រូវការ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលឲ្យឆ្លើយតបតាមតម្រូវការទីផ្សារការងារ។
- កង្វះខាតធនធានថវិការ សម្ភារៈ និងព័ត៌មានសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យមាននិរន្តរភាព។

### ១.៦.៣. បញ្ហាប្រឈមក្នុងការអភិវឌ្ឍមុខរបរ និងការងារ

នៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយមុខរបរ និងការងារនាពេលកន្លងមក ក្រសួងបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនរួមមាន៖

- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធក្នុងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារឲ្យបានដល់ទីជនបទ និងគ្រប់តំបន់។
- កង្វះខាតកិច្ចសហការជិតស្និទ្ធពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្នុងដំណើរការប្រមូល និងចុះឈ្មោះអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន។
- កង្វះខាតធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីប្រមូលចងក្រង និងវិភាគព័ត៌មានទីផ្សារការងារ និងផ្តល់នូវការរំពឹងទុក និងព្យាករណ៍នាពេលអនាគត។
- កង្វះខាតបទប្បញ្ញត្តិគ្រប់គ្រងក្រុមហ៊ុន ឬវិស័យឯកជន ដែលផ្តល់សេវាការងារឲ្យពលករធ្វើការក្នុងស្រុក។

### ១.៦.៤. បញ្ហាប្រឈមក្នុងការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ចំណែកឯក្នុងវិស័យសន្តិសុខសង្គមវិញ សម្រាប់ជនទាំងឡាយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្រសួងបានជួបបញ្ហាប្រឈមដូចជា៖

- កង្វះខាតការយល់ដឹងច្បាស់លាស់ពីសំណាក់និយោជកស្តីពីច្បាប់ នីតិវិធី និងបែបបទនៃការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ។
- ការផ្តល់របាយការណ៍ហានិភ័យការងារមិនទាន់ច្បាស់លាស់ និងយឺតយ៉ាវ ដែលនាំឲ្យមានការលំបាកក្នុងការអង្កេតរកមូលហេតុគ្រោះថ្នាក់ការងារ និងនាំឲ្យការផ្តល់តាវកាលិកជូនជនរងគ្រោះមានការយឺតយ៉ាវ។
- កង្វះខាតការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា (Information Technology) ក្នុងការគ្រប់គ្រងការអនុវត្តកម្មវិធីសន្តិសុខសង្គមរបស់ក្រសួង។

### ១.៦.៥. បញ្ហាប្រឈមក្នុងការពង្រឹងអភិបាលកិច្ចល្អ

កន្លងមក ការពង្រឹងអភិបាលកិច្ចល្អលើការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ភាពជាដៃគូ ប្រសិទ្ធភាព និងគណនេយ្យភាព ជាពិសេសការបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈ បាន ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដែលជាឧបសគ្គក្នុងការអនុវត្តគោលនយោបាយរបស់ក្រសួង មានដូចជា៖

- តម្រូវការចំណាយរបស់ក្រសួងធំជាងលទ្ធភាពធនធានថវិកាដែលមាន រួមជាមួយនឹង នីតិវិធីទូទាត់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវការពេលវេលាមួយជាក់លាក់។
- ធនធានមនុស្ស សម្ភារៈ ថវិកា ទាក់ទងនឹងនីតិវិធីហិរញ្ញវត្ថុនៅមានកម្រិត មិនទាន់ឆ្លើយ តបទៅនឹងសំណូមពរការងាររបស់ក្រសួង។
- កង្វះខាតយន្តការប្រមូលព័ត៌មានពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀង រវាងអង្គភាពក្រោមឱវាទ និងដៃគូអភិវឌ្ឍន៍។
- ការផ្តល់របាយការណ៍ពីអង្គភាពថ្នាក់ក្រោមជាតិ មកនាយកដ្ឋានផែនការ ស្ថិតិ និងនីតិ កម្ម មានភាពយឺតយ៉ាវ និងគ្មានស្តង់ដារួម។
- កង្វះខាតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិក្នុងការ ទទួលបានការគាំទ្រ និងផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស[23]។

### ១.៦.៦. បញ្ហាប្រឈមផ្សេងៗទៀត

ការប្រមូលផ្តុំដីធ្លី និងប្រជាជនដែលគ្មានដី ស្ថិតនៅក្នុងនិន្នាការមួយ ដែលកំពុងមានការ កើនឡើង ដោយបង្កើតជាផលប៉ះពាល់អវិជ្ជមានមកលើ សមធម៌ និងប្រសិទ្ធភាពនៃការប្រើប្រាស់ ដីធ្លី។ ជាមួយគ្នានេះ ផ្ទៃដីដ៏ធំនៃតំបន់ដីសម្បទានសេដ្ឋកិច្ច ពុំទាន់ត្រូវបានប្រើប្រាស់ឲ្យមានប្រសិទ្ធ ភាពទៅតាមគោលដៅ ដោយតម្រូវឲ្យមានវិធានការដ៏តឹងរឹងរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយ បញ្ហាទាំងនេះ។ ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីខុសច្បាប់ ការទាមទារយកដោយខុសច្បាប់ នូវដីរដ្ឋ និងតំបន់ការពារធ្វើជាកម្មសិទ្ធិឯកជន និងការកាប់ឈើខុសច្បាប់នៅតែបន្តកើតមាននៅ ឡើយ។

ទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ក៏វិស័យថាមពលនៅតែជួបប្រទះនឹងបញ្ហា ប្រឈមចម្បងៗជាច្រើន ដូចជាការធានាឲ្យមានប្រសិទ្ធិភាព និងចីរភាពនៅក្នុងផលិតកម្ម ការផ្គត់

[23] ដកស្រង់ចេញពី សៀវភៅ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ៥២-៥៩

ផ្គង់ថាមពល និងការថែទាំយ៉ាងត្រឹមត្រូវនូវហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីនៅទូទាំងប្រទេស និងការបញ្ចុះថ្លៃដើមខ្ពស់ បើប្រៀបធៀបនឹងប្រទេសជិតខាង ដែលជាឧបសគ្គមួយដ៏ធំក្នុងការពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ក៏ដូចជាការទាក់ទាញវិនិយោគ និងការធ្វើឲ្យប្រសើរឡើងនូវការរស់នៅរបស់ប្រជាជន។ លទ្ធភាពមានអគ្គិសនីសម្រាប់ប្រើប្រាស់នៅតំបន់ជនបទមានមិនទាន់គ្រប់គ្រាន់ ដែលជាហេតុឲ្យរាំងស្ទះដល់ការវិនិយោគរបស់រោងចក្រ និងសហគ្រាស។

ប្រព័ន្ធធារាសាស្ត្រ មិនទាន់ត្រូវបានអភិវឌ្ឍន៍ឲ្យបានពេញលេញ និងប្រើប្រាស់ឲ្យអស់សក្តានុពលនៅឡើយ ដោយតម្រូវឲ្យមានការគ្រប់គ្រង និងការវិនិយោគដែលមានប្រសិទ្ធភាពជាងមុន។

នៅមានបញ្ហាប្រឈមជាច្រើនទៀតដូចជា ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការប្រព័ន្ធអប់រំឲ្យស្របនឹងច្បាប់អង្គការ និងកម្មវិធីថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ។ សាលារៀនមានមិនទាន់គ្រប់កម្រិតថ្នាក់ កង្វះគ្រូ និងផ្ទះស្នាក់នៅសម្រាប់គ្រូបង្រៀននៅតំបន់ជនបទដាច់ស្រយាល ជាពិសេសគ្រូបង្រៀនកម្រិតឧត្តមសិក្សា។ លើសពីនេះ សមត្ថភាព ចំណេះដឹងរបស់អ្នកចូលរួមស្តីពីបញ្ហាប្រជាជន នៅមានកម្រិត ភាពខ្វះខាតទិន្នន័យថ្មីៗសម្រាប់ធ្វើបច្ចុប្បន្នភាពសូចនាករប្រជាជន និងឯកសារយោងទាក់ទងនឹងប្រជាជន ការវិភាគស៊ីជម្រៅនូវបញ្ហានានាដែលទាក់ទងនឹងប្រជាជន ដែលចាំបាច់សម្រាប់ការស្វែងយល់ពីឫសគល់នៃបញ្ហា និងដំណោះស្រាយ[24]។

អ្នកជំនាញសង្គមសេដ្ឋកិច្ចបានអត្ថាធិប្បាយថា **ដើម្បីទប់ស្កាត់ឬកាត់បន្ថយការធ្វើចំណាកស្រុក** រដ្ឋាភិបាលត្រូវតែមានគោលនយោបាយធ្វើយ៉ាងណាជំរុញអោយក្រុមហ៊ុនសហគ្រាសធុនតូចឬធុនមធ្យម ទៅបោះទីតាំងនៅតាមតំបន់ជនបទអោយបានច្រើន និងរុញច្រានឲ្យធនធានមនុស្សល្អវិលត្រឡប់ទៅតំបន់ជនបទវិញ។ ប៉ុន្តែ ដើម្បីធ្វើអោយសម្រេចគោលបំណងនេះ រដ្ឋាភិបាលត្រូវអនុវត្តន៍គោលនយោបាយមួយចំនួនក្នុងនោះមានដូចជា ការសាងសង់ផ្លូវថ្នល់ ការសាងសង់បណ្តាញអគ្គិសនី ការកសាងបណ្តាញប្រព័ន្ធទឹកស្អាត និងការតភ្ជាប់បណ្តាញប្រព័ន្ធអ៊ីនធឺណិតឲ្យកាន់តែប្រសើរ។ ម្យ៉ាងទៀត រដ្ឋាភិបាលត្រូវតែមានកញ្ចប់លើកទឹកចិត្តពិសេស សម្រាប់ក្រុមហ៊ុនណាដែលសុខចិត្តបោះទុនវិនិយោគនៅតំបន់ជនបទ។ កញ្ចប់ពិសេសនោះ អាចជាការលើកលែងពន្ធរយៈពេល ៥ ឬ១០ឆ្នាំ ជាដើម។ ចំពោះធនធានមនុស្ស រដ្ឋាភិបាលគួររិះរកវិធានការណា

[24] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ៨៩

ដែលលើកទឹកចិត្ត ឬចងជាកិច្ចសន្យាដើម្បីឲ្យនិស្សិតរៀនចប់អាចទៅចូលរួមចំណែកអភិវឌ្ឍស្រុកកំណើតពួកគេ។ ជនបទមិនអាចរីកចម្រើនបានឡើយ ប្រសិនបើគ្មានធនធានមនុស្សល្អៗ។ នៅពេលណាក្រុមហ៊ុនមានវត្តមានកាន់តែច្រើននៅជនបទ បូកផ្សំនឹងមានវត្តមានធនធានមនុស្សល្អ ពេលនោះសកម្មភាពសេដ្ឋកិច្ចនៅជនបទនឹងរស់រវើក។ ជាលទ្ធផលចុងក្រោយ ចលនាចំណាកស្រុកនឹងកាត់បន្ថយដោយខ្លួនឯង ដូចសុភាសិតខ្មែរបាននិយាយថា *ជួញជិតប្រសើរជាងជួញឆ្ងាយ*[25]។

## ១.៧. ស្ថានភាពសេដ្ឋកិច្ច ការងារ និងការធ្វើចំណាកស្រុកនៅកម្ពុជា

### ១.៧.១. ស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជា

សេដ្ឋកិច្ចកម្ពុជា បាននឹងកំពុងតែរីកចម្រើនឡើងបែបលក្ខណៈវិជ្ជមានពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសចាប់តាំងពីរាជរដ្ឋាភិបាលបានបង្កើតយុទ្ធសាស្ត្រចតុកោណឡើង និងដាក់ឲ្យអនុវត្តន៍ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ប្រទេសប្រកបដោយចីរភាព និងទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់។ យោងទៅតាមទិន្នន័យធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សន្ទុះនៃការរីកលូតលាស់នៃផលិតផលសរុបក្នុងស្រុករបស់ប្រទេសយើងជាមធ្យមមាន ៧ ភាគរយ ចាប់តាំងពីឆ្នាំ ២០១៥ រហូតមកដល់ពេលបច្ចុប្បន្ន[26]។

ក្នុងឆ្នាំ ២០១៧ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជាមាន ២២,២៥ ពាន់លានដុល្លា ដែលក្នុងនោះ ផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់មាន ១ ៣៩០ ដុល្លាសហរដ្ឋអាមេរិក។ សំខាន់ជាងនេះទៅទៀត ប្រទេសកម្ពុជាបានទទួលឋានៈ ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ ដោយប្រាក់ចំណូលជាតិសរុប (GNI) របស់មនុស្សម្នាក់ៗ មានចំនួន ១ ០៧០ ដុល្លា។ កំណើនសេដ្ឋកិច្ច បានកើនឡើងដល់ ៦,៨ ភាគរយ នៅក្នុងឆ្នាំ ២០១៧[27]។

ភាពក្រីក្រនៅតែបន្តធ្លាក់ចុះនៅក្នុងប្រទេសកម្ពុជា ថ្វីបើយឺតជាងកាលពីមុនក៏ដោយ។ ក្នុងឆ្នាំ ២០១៤ អត្រានៃភាពក្រីក្រមានប្រមាណ ១៣,៥ ភាគរយ បើធៀបនឹង ៤៧,៨ ភាគរយ ក្នុងឆ្នាំ ២០០៧។ រីឯបញ្ហាសុខភាព និងការអប់រំ នៅតែជាបញ្ហាប្រឈមសំខាន់ៗក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ការចុះឈ្មោះកុមារចូលរៀននៅកម្រិតបឋមសិក្សា បានកើនឡើងពី ៨២ ភាគរយ ក្នុងឆ្នាំ ១៩៩៧ ដល់ ៩៧ ភាគរយ នៅឆ្នាំ ២០១៦។ ប៉ុន្តែក្នុងឆ្នាំ ២០១៥ អត្រាសិស្សមធ្យមសិក្សាបឋមភូមិមាន ៤៨ ភាគរយ ទាបជាងមធ្យមភាគសម្រាប់បណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិត

[25] ប្រភព https://thmeythmey.com/?page=detail&id=51308

[26] ប្រភព https://www.adb.org/countries/cambodia/economy#tabs-0-0

[27] ប្រភព https://knoema.com/atlas/Cambodia/GDP-per-capita

ទាប។ គិតត្រឹមឆ្នាំ ២០១៥ ៧០ ភាគរយ នៃប្រជាជនកម្ពុជា (១២,៣ លាននាក់) មិនមានលទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាតទេ ហើយ ៥៨ ភាគរយ (៩,៣ លាននាក់) មិនមានលទ្ធភាពទទួលបានអនាម័យល្អនៅឡើយ[28]។

វិស័យកសិកម្មបានរួមចំណែក ២៩ ភាគរយនៃសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ២០១៥។ ចំណែកឯវិស័យឧស្សាហកម្មវិញ ក្នុងឆ្នាំ ២០១៥ ឧស្សាហកម្មចម្បងមាន ២៦,១៨ ភាគរយនៃសេដ្ឋកិច្ចសរុប។ ចំពោះវិស័យសេវាកម្មវិញ វាបានឈានដល់ ៣៩,៥៣ ភាគរយនៃសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៥។ រីឯវិស័យពាណិជ្ជកម្មរបស់កម្ពុជាក៏មានការរីកចម្រើនផងដែរ។ គិតត្រឹមថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ តម្លៃនាំចេញមានប្រហែល ៥,៣៥ ពាន់លានដុល្លារ ដែលត្រូវបានគេមើលឃើញថាកើនឡើងជាង ២០,៥ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៤ ខណៈពេលដែលតម្លៃនាំចូលគឺ ៦,៧០ ពាន់លានដុល្លា។ បណ្តាប្រទេសគោលដៅសំខាន់ៗនៃការនាំចេញរួមមាន សហរដ្ឋអាមេរិក ហុងកុង ចិន សហភាពអឺរ៉ុប កាណាដា និងវៀតណាម។ បណ្តាប្រទេសនាំចូលសំខាន់ៗ គឺ ហុងកុង ចិន តៃវ៉ាន់ ថៃ និងវៀតណាម។ ផលិតផលនាំចេញចម្បងគឺ សំលៀកបំពាក់ដែលមានចំនួនច្រើនជាង ៨០ ភាគរយ នៃការនាំចេញសរុប។ ផលិតផលនាំចូលដ៏សំខាន់គឺ វាយនភណ្ឌ ផលិតផលប្រេង និងយានយន្ត[29]។

បើគិតមកត្រឹមត្រីមាសទី៣ ឆ្នាំ២០១៧ វិស័យកសិកម្មមានការរីកចម្រើនយ៉ាងគួរឲ្យកត់សម្គាល់ ដោយសារតែកំណើននៃការវិនិយោគរបស់ឯកជនលើវិស័យកសិកម្ម និងការបន្ថែមទុនវិនិយោគលើផ្នែកកសិ-ឧស្សាហកម្ម។ ក្នុងរយៈពេលនេះ បរិមាណផលស្រូវសម្រេចបានមាន ១,៥ លានតោន ដែលស្មើនឹងកំណើន ៨៣,២% និងបរិមាណនាំចេញអង្ករមានប្រមាណ ៣៨៥ ពាន់តោន ឬមានកំណើន ៩%។ ទន្ទឹមនឹងនេះ បរិមាណផលិត និងនាំចេញកៅស៊ូក្រែប មានចំនួន ១២៥ ពាន់តោន និង ១១០ ពាន់តោន ដោយបានកើន ៥៥,៥% និង ២៥,៦% រៀងគ្នា ដោយសារភាពប្រសើរឡើងនៃថ្លៃជ័រកៅស៊ូបង្កក។ រីឯបរិមាណផលិតផលជលផលមានចំនួន ៥២៧ ពាន់តោន ដែលបានកើនឡើង ៥%[30]។

ឧស្សាហកម្មចម្បងនៃវិស័យនេះ គឺឧស្សាហកម្មកាត់ដេរ។ ការនាំចេញសម្លៀកបំពាក់កើនឡើងដល់ ៨,៥ ភាគរយ (គិតជាតម្លៃ) នៅឆ្នាំ ២០១៦ ។ ការកើនឡើងនៃតម្លៃពលកម្ម ដែល

[28] ប្រភព http://www.worldbank.org/en/country/cambodia/overview

[29] ប្រភព http://www.cambodiainvestment.gov.kh/country-overview/economic-situation.html

[30] ប្រភព ព្រឹត្តបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី៣ បោះពុម្ពផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០១៧ ទំព័រទី ៣

បណ្ដាលមកពីការកើនឡើងតម្លៃនៃការរស់នៅប្រចាំថ្ងៃ ការឡើងតម្លៃទៅលើប្រាក់ដុល្លាអាមេរិក និងការប្រកួតប្រជែងពីប្រទេសដែលមានប្រាក់ឈ្នួលទាបក្នុងតំបន់ផ្សេងទៀត ជាពិសេសប្រទេសមីយ៉ាន់ម៉ាបន្តដាក់សម្ពាធលើតម្លៃនៃផលិតផលកាត់ដេរដែលកម្ពុជានាំចេញ។ លើសពីនេះ ការកើនឡើងលំនៅដ្ឋាន និងពាណិជ្ជកម្មសំណង់ ពោលគឺវិស័យសំណង់រីកដុះដាលនៅគ្រប់ទីកន្លែង។

ក្រឡេកមកមើលវិស័យទេសចរណ៍ឯនេះវិញ ចំនួនភ្ញៀវទេសចរណ៍បានកើនឡើង ៥ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ[31]។ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៧ កម្ពុជាទទួលបានអ្នកដំណើរប្រមាណជាង ១,២៥ លាននាក់ ដោយមានអត្រាកំណើន ៨,៩% ធៀបនឹងឆ្នាំមុន ដោយសារការបង្កើនចំនួនជើងហោះហើរត្រង់ ការបន្តផ្សព្វផ្សាយពីតំបន់ទេសចរណ៍សក្ដានុពល និងការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្ត ដូចជាការបង្កើនរយៈពេលស្នាក់នៅសម្រាប់ភ្ញៀវទេសចរមកពីជប៉ុន ចិន និងកូរ៉េ។

មកទល់ត្រីមាសទី៣ ឆ្នាំ២០១៧ ការនាំចេញសរុបរបស់កម្ពុជាមានទំហំ ១២ ៦៧៤ ប៊ីលានរៀល ឬមានអត្រាកំណើន ៥,១% ធៀបនឹងឆ្នាំមុន ដោយសារកំណើនទាបលើការនាំចេញផលិតផលកាត់ដេរ និងស្បែកជើង ដែលមានត្រឹមតែ ៣,៨% ប៉ុណ្ណោះ។ ជាការកត់សម្គាល់ ឆ្នាំ២០១៧នេះ គឺជាឆ្នាំអំណោយផលល្អដល់ផលិតកម្មកសិកម្ម និងការនាំចេញ។ តួយ៉ាង ការនាំចេញផលិតផលអង្ករ កៅស៊ូ ស្ករស ផលិតផលជលផល និងផលិតផលកសិកម្មផ្សេងៗទៀត មានកំណើនខ្ពស់ប្រមាណ ៦៨,៩% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៧ ធៀបនឹងឆ្នាំមុន។ ចំណែកការនាំចូលវិញ កម្ពុជានាំចចូលមុខទំនិញគ្រប់មុខ ដែលមានទំហំ ១៤ ៦៤០ ប៊ីលានរៀល ឬមានកំណើន ១៦,៩%[32]។

### ១.៧.២. ស្ថានភាពការងារនៅកម្ពុជា

ការបង្កើតការងារ និងការជួលបុគ្គលិកឲ្យធ្វើការ គឺជាមាគ៌ាមូលដ្ឋានមួយ ដែលឈានទៅដល់ការកាត់បន្ថយភាពក្រីក្រ។ យោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ (ILO) គោលនយោបាយមួយ ដែលមានប្រសិទ្ធិភាពបំផុតសម្រាប់ករកាត់បន្ថយភាពក្រីក្រនោះ គឺការផ្ដល់នូវការងារដែលសមរម្យ (Decent Work) ដែលអាចនាំទៅរកការអភិវឌ្ឍប្រកបដោយចីរភាព

[31] ប្រភព http://documents.worldbank.org/curated/en/780641494510994888/pdf/114938-PUBLIC-may-16-8pm-Cambodia-Economic-report-v2-s.pdf

[32] ប្រភព ព្រឹត្តបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី៣ បោះពុម្ពផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៧ ទំព័រទី ៣-៥

សមធម៌ និងសម្រាប់ទាំងអស់គ្នា។ ពាក្យថា **ការងារសមរម្យ** សំដៅលើ **ប្រភេទការងារ ដែលអាចធ្វើបានទាំងបុរស និងស្ត្រី ក្រោមលក្ខខណ្ឌនៃសេរីភាព សមធម៌ សុវត្ថិភាព និងភាពថ្លៃថ្នូរ**។ ដើម្បីសម្រេចគោលដៅនេះ គេត្រូវធានាឲ្យមាននូវការលើកស្ទួយកំណើនសេដ្ឋកិច្ច ការវិនិយោគ និងសហគ្រិនភាព ក្នុងការបង្កើតការងារ ដែលមានគុណភាពសម្រាប់ប្រជាពលរដ្ឋ។

ឆ្លងកាត់រយៈកាលជាងពីរទសវត្សរ៍ យើងដឹងហើយថា ប្រទេសកម្ពុជាទទួលបានបទពិសោធន៍នៃកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ ជាពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប៉ុន្តែ កំណើនសេដ្ឋកិច្ចមួយអន្លើ ធ្វើឲ្យគម្លាតកាន់តែខ្លាំងរវាងតំបន់ទីក្រុង និងតំបន់ជនបទ។ ក្នុងន័យនេះ គេចង់សំដៅថា អ្នកក្រមានលទ្ធភាពតិចតួចបំផុត ក្នុងការទទួលបាននូចសេវាសង្គម និងការរួចផុតពីអន្ទាក់នៃភាពក្រីក្រ (Poverty Trap) ដែលនេះជាស្ថានភាព ឬលក្ខខណ្ឌផ្ទុយស្រឡះពីអ្នកមាន ឬអ្នកមានទ្រព្យមធ្យម និងបង្គួរ។ ការស្ទុះឡើងនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជាកន្លងមកត្រូវបានគេទទួលស្គាល់ថា ពុំបាននាំមកនូវកំណើននៃការងារធ្វើ ដែលមានភាពសមមូលនោះឡើយ[33]។

អត្រានិកម្មភាពនៅកម្ពុជាបានកើនឡើងពី ០,២ ភាគរយនៅឆ្នាំ ២០១៦ ដល់ ០,៣ ភាគរយក្នុងឆ្នាំ ២០១៧ ។ អត្រានិកម្មភាពនៅកម្ពុជាជាមធ្យមមាន ០,៩៩ ភាគរយពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៧ ដែលអត្រានេះឈានដល់កម្រិតខ្ពស់បំផុតស្មើនឹង ២.៥ ភាគរយនៅឆ្នាំ ២០០០ និងទាបបំផុត ០,១ ភាគរយក្នុងឆ្នាំ ២០១៥[34]។

ទោះបីជា ប្រទេសកម្ពុជា ជាប្រទេសដែលមានអត្រានិកម្មភាពទាបក៏ដោយ ប៉ុន្តែយោងទៅតាម របាយការណ៍ការងារថ្មីមួយរបស់អង្គការពលកម្មអន្តរជាតិ (ILO) បានឱ្យដឹងថា អ្នកវិភាគព្រមានថាអត្រាទាបមិនប្រាប់រឿងទាំងស្រុងទេ។ បច្ចុប្បន្នប្រទេសកម្ពុជាកំពុងតែព្យាយាមបង្កើតទីផ្សារការងារ ប៉ុន្តែការងារទាំងនោះច្រើនជាការងារ ដែលផ្តល់ឲ្យនូវប្រាក់ចំណូលទាប និងមិនសូវមានសុវត្ថិភាព។ មនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជា កំពុងធ្វើការងារពីរ ឬបីម៉ោងក្នុងមួយសប្តាហ៍ ដូចជាការលក់ឥវ៉ាន់នៅតាមផ្លូវ ប៉ុន្តែស្របពេលនោះដែរ ពួកគេកំពុងស្វែងរកការងារមួយផ្សេងទៀត ដើម្បីរកប្រាក់ចំណូលបន្ថែមលើប្រភពចំណូលរបស់ពួកគេ។ ដូច្នេះ ក្នុងន័យនេះ ពួកគេមានការងារធ្វើផង និងគ្មានការងារធ្វើផង ក្នុងពេលតែមួយ។

[33] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណាងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ១០-១៣

[34] ប្រភព https://tradingeconomics.com/cambodia/unemployment-rate

បច្ចុប្បន្ន ៥១ ភាគរយនៃការងារនៅក្នុងប្រទេសកម្ពុជា គឺជាការងារដែលងាយរងគ្រោះ ដែលភាគរយនេះខ្ពស់ជាងមធ្យមភាគរបស់អាស៊ីអាគ្នេយ៍ ដែលមានត្រឹម ៤៦ ភាគរយប៉ុណ្ណោះ។ ប្រជាជនដែលធ្វើការងារងាយរងគ្រោះទាំងនោះមិនមានប្រាក់ខែទេ ពីព្រោះពួកគេធ្វើការជាកសិករ ឬធ្វើការឲ្យគ្រួសាររបស់ពួកគេ។ មនុស្សទាំងអស់នេះ ត្រូវបានសេដ្ឋវិទូនាពេលបច្ចុប្បន្ន ហៅថា "មនុស្សមិនមានការងារធ្វើ" (Underemployed)។ ប្រជាជនកម្ពុជាមួយភាគធំ នៅតែបន្តពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្ម ដែលជាផលលំបាកដោយសារតែបញ្ហាអាកាសធាតុ។ រីឯវិស័យផលិតកម្មកម្មន្តសាល នៅតែមានភាពតូចចង្អៀតនៅឡើយ។ មនុស្សជាច្រើននៅកម្ពុជា មានការងារច្រើនជាងមួយ ដោយសារតែប្រាក់ឈ្នួលនៅទាបពេក។ ចំណែកឯ ការងាររោងចក្រកាត់ដេរ មិនមែនជាការងារដ៏ល្អឥតខ្ចោះទេ ប៉ុន្តែវាក៏នៅតែជាការងារដោយមានការងារធ្វើប្រសើរជាងអត់ការងារធ្វើ[35]។ យោងទៅតាមអង្គការពលកម្មអន្តរជាតិ មូលហេតុដែលនាំឲ្យកម្ពុជាមានអត្រានិកម្មភាពទាប គឺដោយសារតែមនុស្សភាគច្រើនទទួលបានការងារ ដែលមិនត្រឹមត្រូវតាមច្បាប់។ ប្រាក់ឈ្នួល ដែលទទួលបានពីការងារនេះច្រើនតែជាទាប មិនបានចុះបញ្ជី និងមិនត្រឹមត្រូវទៅតាមច្បាប់ការងារបានកំណត់។ ឧទាហរណ៍សាមញ្ញ គឺការងារកសិកម្ម ការងារគ្រួសារ សហគ្រាសខ្នាតតូច និងសិប្បកម្មខ្នាតតូច[36]។

### ១.៧.៣. ស្ថានភាពនៃការធ្វើចំណាកស្រុកនៅកម្ពុជា

ដោយហេតុថា ប្រាក់ចំណូលដែលរកបាន ពុំទាន់គ្រប់គ្រាន់ក្នុងការបំពេញសេចក្តីត្រូវការរបស់ខ្លួន ឬពុំមានការងារធ្វើពេញលេញនៅជនបទ ទើបមនុស្សជាច្រើននៅតាមជនបទ ត្រូវបានជំរុញ ឲ្យធ្វើចំណាកស្រុកមករស់នៅ និងរកការងារធ្វើនៅទីក្រុង ក៏ដូចជាទៅក្រៅប្រទេស ដោយក្តីរំពឹងថា ពួកគាត់នឹងអាចរកបានប្រាក់ច្រើនជាងនៅទីជនបទ ចាកផុតពីភាពក្រីក្រ និងមានជីវភាពប្រសើរឡើង។ អ្នកខ្លះចាកចេញពីស្រុកតែម្នាក់ឯង បន្សល់ទុកនូវសមាជិកគ្រួសារដទៃទៀតនៅឯស្រុកឲ្យ រង់ចាំ និងទទួលប្រាក់បញ្ញើពីខ្លួន។ ខ្លះទៀតសម្រេចចិត្ត ធ្វើចំណាកស្រុកទាំងគ្រួសារតែម្តង។ ទាំងនេះសបញ្ជាក់ឲ្យឃើញថា កំណើនសេដ្ឋកិច្ច ដែលមានកន្លងមក និងតាមរយៈការធ្វើវិនិយោគបន្ត ពុំទាន់បានចូលរួមក្នុងការបង្កើតការងារសមស្រប ដែលអាចស្រូបយកកម្លាំងពលកម្មនៅក្នុងទីផ្សារនៅឡើយទេ។ នេះបើតាមការឲ្យនិយមន័យនៃពាក្យថា ការងារសមរម្យរបស់ ILO

[35] ប្រភព https://www.phnompenhpost.com/national/cambodias-low-rate-unemployment-doesnt-tell-whole-story-report-finds

[36] ដកស្រង់ចេញពី http://pepyempoweringyouth.org/unemployment-in-cambodia/

ដែលបានបង្ហាញខាងលើ[37]។

ដោយសារប្រជាជនកម្ពុជាវ័យក្មេងដ៏ច្រើន បានឈានជើងចូលក្នុងទីផ្សារការងារ ជាមួយនឹងឱកាសការងារនៅមានកម្រិត ហើយប្រាក់ឈ្នួល ដែលកាន់តែមានភាពទាក់ទាញនៅប្រទេសទទួលប្រជាជនកម្ពុជាកាន់តែច្រើនឡើងៗកំពុងធ្វើការពិចារណាក្នុងការចាកចេញពីប្រទេស ដើម្បីស្វែងរកការងារធ្វើ។ តាមការប៉ាន់ប្រមាណមួយដែលលើកឡើងថាប្រជាជនកម្ពុជាវ័យក្មេងចំនួន ៣០០ ០០០នាក់ ឈានជើងចូលក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ ហើយប្រជាជនកម្ពុជាដែលមានអាយុក្រោម ២៩ឆ្នាំ មានចំនួន៦០,១ភាគរយ រដ្ឋាភិបាលជួបប្រទះការប្រឈមក្នុងការផ្តល់ជំនាញដល់ប្រជាជនទាំងនេះ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារក្នុងការផ្តល់សេវាផ្គូរផ្គងការងារ និងក្នុងការសម្របសម្រួលនូវការចល័តរបស់ពួកគេនៅពេលដែលចាំបាច់។

កត្តាគន្លឹះមួយដែលជម្រុញក្នុងការជ្រើសរើសធ្វើចំណាកស្រុក គឺភាពខុសគ្នារវាងប្រាក់ឈ្នួលក្នុងប្រទេសកម្ពុជានិងប្រទេសគោលដៅ។ នៅឆ្នាំ ២០១២ ក្នុងចំណោមប្រជាជនដែលមានការងារធ្វើសរុបនៅក្នុងប្រទេសកម្ពុជាមានប្រជាជនចំនួន ៦០,២ ភាគរយ បានធ្វើការក្នុងវិស័យមិនរៀបរយ ពុំមានស្តង់ដាត្រឹមត្រូវនោះទេ (និយោជិកខ្លះទទួលបានប្រាក់ឈ្នួលតាមមូលដ្ឋាន អត្រាប្រចាំម៉ោង ឬថ្ងៃ អ្នកខ្លះទៀតតាមមូលដ្ឋានផលការងារជាក់ស្តែង ហើយការបើកប្រាក់ឈ្នួលអាចជាប្រាក់សុទ្ធ ឬជាសម្ភារៈប្រដាប់ប្រដារផ្សេងៗ) ហើយក៏មិនមានប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ដោយច្បាប់នៅឡើយទេ លើកលែងតែចំពោះកម្មករនិយោជិតក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើងតែប៉ុណ្ណោះ[38]។

ម្យ៉ាងទៀត បច្ចុប្បន្ន ប្រជាជនភាគច្រើនតែងមានបំណងចង់ធ្វើចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសប្រទេសជិតខាង។ ការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែនពីប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងកើនឡើង ខណៈពេលដែលកម្មករកសិកម្មរបស់ប្រទេសជាច្រើនកំពុងប្រឈមនឹងបំណុល កង្វះខាតជំនាញ និងបញ្ហាសេដ្ឋកិច្ច ដែលបណ្តាលមកពីលក្ខខណ្ឌអាកាសធាតុមិនល្អ។ អ្នករស់នៅជនបទភាគច្រើន ប្រកបរបរកសិកម្ម ហើយនៅក្នុងចំណោមនោះ ៧៥ ភាគរយ បានជំពាក់បំណុលគេ ដោយសារតែលក្ខខណ្ឌអាកាសធាតុមិនល្អដូចជា គ្រោះរាំងស្ងួត ឬទឹកជំនន់ ដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។ ប៉ុន្តែ កង្វះខាតការងារមិនមែនជាអ្វី

[37] ដកស្រង់ចេញពី សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណាងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១ ទំព័រទី ១៣

[38] ប្រភពពី សៀវភៅ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាខែ ធ្នូ ឆ្នាំ ២០១៤ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ២-៣

ដែលធ្វើឱ្យមនុស្សធ្វើចំណាកស្រុកនោះទេ ពោលគឺទីផ្សារការងារកម្ពុជា កំពុងជួបប្រទះនូវកង្វះបុគ្គលិកដែលមានសក្តានុពល ដោយអ្នកស្វែងរកការងារគ្មានការងារធ្វើ រីឯនិយោជករើសបុគ្គលិកពុំបាន។ ក្នុងចំណោម ១២៩ អាជីវកម្ម ជិត ៨០ ភាគរយ ប្រឈមនឹងកង្វះខាតកម្លាំងពលកម្ម ដែលមានជំនាញខ្ពស់ និងមានជំនាញទាប។ និយោជកភាគច្រើនស្វែងរកជួលមនុស្ស ដែលចេះអក្សរភាសាខ្មែរ និងអង់គ្លេស ហើយមានលិខិតបញ្ជាក់ថាពួកគេមានជំនាញទាក់ទងនឹងវិស័យរបស់ពួកគេ។ ផ្ទុយទៅវិញ អ្នកចំណាកស្រុកដែលមានសក្តានុពលភាគច្រើនមិនបានបញ្ចប់ការសិក្សា សូម្បីតែត្រឹមកម្រិតបឋមសិក្សា[39]។

ទោះបីជាកត្តាជំរុញភាគច្រើន គឺបណ្តាលមកពីកត្តាសេដ្ឋកិច្ច ការសិក្សាបានរកឃើញថាភាពលំបាកខាងហិរញ្ញវត្ថុរបស់មនុស្សម្នាក់ៗអាចមានទម្រង់ផ្សេងៗគ្នា ហើយកត្តាមិនមែនសេដ្ឋកិច្ច (ដូចជាការមានបណ្តាញគ្រួសារនៅក្រៅប្រទេស) ក៏អាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់ប្រជាជនក្នុងការធ្វើចំណាកស្រុកផងដែរ[40]។

## ១.៨. បទពិសោធន៍បរទេសក្នុងការទប់ស្កាត់បញ្ហាចំណាកស្រុក

បញ្ហាចំណាកស្រុកកើតឡើងស្ទើរគ្រប់ប្រទេសទាំងអស់នៅលើសកលលោក ហើយប្រទេសនីមួយៗ មានវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហានេះផ្សេងៗគ្នា។ ពួកខ្ញុំនឹងលើកយកវិធីសាស្ត្រដោះស្រាយមួយចំនួនរបស់បរទេសមកបកស្រាយ ដែលអាចជាជំនួយក្នុងការដោះស្រាយបញ្ហាចំណាកស្រុកនៅក្នុងប្រទេសកម្ពុជាបាន។

### ១.៨.១. យុទ្ធសាស្ត្រដោះស្រាយបញ្ហាចំណាកស្រុករបស់រដ្ឋាភិបាលនៃប្រទេសចិន

រដ្ឋាភិបាលចិនបានប្រកាសគោលនយោបាយមួយ ក្នុងគោលបំណងលើកទឹកចិត្តអ្នកចំណាកស្រុកពីតំបន់ជនបទទៅកាន់ទីក្រុងនានា ឱ្យត្រឡប់ទៅស្រុកកំណើតវិញហើយចាប់ផ្តើមអាជីវកម្ម។ គោលបំណងរបស់គោលនយោបាយនេះ គឺលើកទឹកចិត្តដល់ជនចំណាកដែលមានមូលធន ជំនាញ និងបទពិសោធន៍ ឲ្យត្រលប់ទៅធ្វើអាជីវកម្ម ឬ សហគ្រិនភាពនៅតាមទីជនបទវិញ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ និងកាត់បន្ថយបញ្ហាចំណាកស្រុក។ ដើម្បីពង្រីកសហគ្រិនភាពជនបទតាមរយៈការបញ្ជូនជនចំណាកស្រុកត្រឡប់មកវិញ រដ្ឋាភិបាលមូលដ្ឋាននឹងប្រើប្រាស់វិធានការប្រាំយ៉ាងដូចខាងក្រោម៖

[39] ប្រភព https://www.phnompenhpost.com/national/low-skills-driving-worker-migration-cambodia-report

[40] ប្រភព http://www.emergingmarkets.asia/consulting/news/2016/10/02/migration-cambodia-usaid/

- កាត់បន្ថយឧបសគ្គចំពោះការត្រលប់ទៅតំបន់ជនបទវិញ ដោយផ្តល់ការបណ្តុះបណ្តាលដល់ជនអន្តោប្រវេសន៍ត្រឡប់មកវិញនិងកាត់បន្ថយថ្លៃរដ្ឋបាលដើម្បីចាប់ផ្តើមអាជីវកម្ម។
- កាត់បន្ថយពន្ធសម្រាប់សហគ្រាសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងបុគ្គល។
- ពង្រីកការគាំទ្រដល់សហគ្រាសទាំងនោះដោយផ្តល់ការឧបត្ថម្ភធន ហើយភ្ជាប់ពួកគេទៅនឹងបណ្តាញជំនួញក្នុងស្រុក និងជួយពួកគេបង្កើតវេទិកាពាណិជ្ជកម្មអេឡិចត្រូនិក។
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សហគ្រាស ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបុគ្គលតាមរយៈការផ្តល់ប្រាក់កម្ចី និងពង្រីកលទ្ធភាពឥណទាននៅតាមជនបទ។
- បង្កើនការគាំទ្រដល់សហគ្រិនដែលនៅតំបន់ជនបទ។

បន្ទាប់ពីការអនុវត្តន៍គោលនយោបាយនេះ អត្រានៃការធ្វើចំណាកស្រុកទៅកាន់ទីក្រុងនានាមានការធ្លាក់ចុះ។ ទិន្នន័យរបស់រដ្ឋាភិបាលក៏បានបង្ហាញផងដែរថា ចំនួនអ្នករស់នៅតាមជនបទដែលធ្វើការនៅជិតស្រុកកំណើតរបស់ពួកគេ បានកើនឡើងក្នុងអត្រាលឿនជាងប្រជាជនចំណាកស្រុកក្នុងកំឡុងពេលនោះ។ ដោយនិយាយពីភាពខុសគ្នារវាងទីជនបទ និងទីប្រជុំជន គោលនយោបាយនេះ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅមុខក្នុងការកាត់បន្ថយភាពមិនស្មើគ្នានៃតំបន់ជនបទ និងទីក្រុង។ មួយវិញទៀត សេរីភាវូបនីយកម្ម និងការទទួលបានឱកាសកាន់តែច្រើន វាបានធ្វើឱ្យប្រាក់ចំណូលរបស់ប្រជាជន ដែលរស់នៅតាមជនបទមានការកើនឡើងក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ ហើយគោលនយោបាយលើកកម្ពស់សហគ្រិនភាពជនបទមានសក្តានុពលក្នុងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចផងដែរ។

ទន្ទឹមនឹងនេះដែរ ការបណ្តាក់ទុនលើវិស័យកសិកម្មដែលប្រកបដោយភាពច្នៃប្រឌិត គឺមានតួនាទីសំខាន់ក្នុងការព្យាយាមរបស់ចិនដើម្បីបង្កើនទិន្នផលកសិកម្មរបស់ខ្លួន។ តាមរយៈការផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រសេវាកម្ម គេសង្កេតឃើញថាវាអាចជួយអោយសហគ្រិនភាពមានលទ្ធផ្លាស់ប្តូរពីអ្នកធ្វើការទៅជាម្ចាស់អាជីវកម្មខ្នាតតូច ដែលអាចផ្តល់ការងារបានមួយចំនួនជូនដល់អ្នកដែលរស់នៅតាមទីជនបទ[41]។

[41] ដកស្រង់ចេញពីគេហទំព័រ https://www.cfr.org/blog/guest-post-chinas-back-countryside-policy-step-toward-reducing-rural-urban-disparity

### ១.៨.២. វិធានការរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់បញ្ហាចំណាកស្រុកនៅអាហ្វ្រិក

ការធ្វើចំណាកស្រុក គឺជាចលនារបស់មនុស្សពីកន្លែងមួយទៅកន្លែងមួយទៀត ដោយសារតែការជម្រុញផ្សេងៗដូចជាការស្វែងរកការងារធ្វើ។ បញ្ហាអនាធិបតេយ្យ និងភាពគ្មានការងារធ្វើបានកើតឡើងនៅអាហ្វ្រិក គឺដោយសារតែមានចលនាចំណាកស្រុកពីជនបទទៅកាន់ទីក្រុងច្រើនពេក។ យើងខ្ញុំនឹងលើកយកវិធានការមួយចំនួន ដែលរដ្ឋាភិបាលនៅអាហ្វ្រិកអនុវត្តដើម្បីទប់ស្កាត់និន្នាការនេះ។

#### ១.៨.២.១. កែលម្អវិស័យចិញ្ចឹមជីវិតនៅជនបទ

រដ្ឋាភិបាលអាហ្វ្រិកបានលើកកម្ពស់វិស័យចិញ្ចឹមជីវិត ដើម្បីបង្កើនប្រាក់ចំណូលនៅតាមជនបទនិងកាត់បន្ថយគម្លាតរវាងជនបទ និងទីក្រុង។ ជំហានដំបូងដើម្បីធ្វើឱ្យប្រសើរឡើងនៅក្នុងការអនុវត្តសេដ្ឋកិច្ចនៃវិស័យនេះ គឺការបញ្ចូលទម្រង់ថ្មីនៃអង្គការភូមិ។ ពួកគេគួរតែត្រលប់ទៅជាអង្គភាពធំ ៗ ដើម្បីសម្របសម្រួលដល់ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់ធនធានកសិកម្ម និងសេវាកម្មផ្សេងៗទៀត។ អង្គភាពថ្មីនេះ គួរតែត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដែលមានសក្តានុពលកសិកម្មខ្ពស់។

#### ១.៨.២.២. ផ្តោតលើការបង្កើតហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចមូលដ្ឋាន

ចំណុចនេះ គឺពាក់ព័ន្ធទៅនឹងការកសាងស្ពានផ្លូវថ្នល់ដើម្បីកាត់បន្ថយភាពលំបាកនៃការដឹកជញ្ជូនវត្ថុធាតុដើមកសិកម្មទៅឧស្សាហកម្មកែច្នៃ កសាងសាលារៀន និងផ្តល់សេវាវេជ្ជសាស្ត្រនៅតាមជនបទ។ បន្ថែមពីនេះទៅទៀត សេវាកម្មពង្រីកវិស័យកសិកម្មគួរតែត្រូវបានបង្កើតឡើង និងផ្តល់ជូននៅតាមជនបទ។

#### ១.៨.២.៣. ប្រព័ន្ធវិមជ្ឈការ

ដោយសារតែរដ្ឋាភិបាលជាតិយល់ឃើញថា ភាពលំបាកបានកើតមានឡើងចំពោះការបំពេញតាមតម្រូវការជាច្រើនសម្រាប់ទំនិញ និងសេវាកម្មសាធារណៈ។ ដូច្នេះ រដ្ឋាភិបាល និងសហគមន៍មូលដ្ឋានអាចធ្វើការសំរេចចិត្តដោយខ្លួនឯងបន្ថែមទៀត និងកែតម្រូវនូវគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នានាសម្រាប់ទីក្រុង និងជនបទដើម្បីបំពេញតាមតម្រូវការជាក់លាក់របស់ប្រជាជន។ ការអនុវត្តប្រព័ន្ធវិមជ្ឈការ ផ្តល់ឱ្យរដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍នូវការគ្រប់គ្រងបន្ថែមលើស្ថានការណ៍របស់ពួកគេ។ ការធ្វើបែបនេះបានផ្តល់ឱកាសឱ្យសហគមន៍នៅជនបទកាន់តែច្រើនដើម្បីបន្តផលប្រយោជន៍ផ្ទាល់ខ្លួន និងសម្រេចចិត្តលើផ្លូវអភិវឌ្ឍន៍ដោយខ្លួន

ឯង ហើយអាចជួយធ្វើឲ្យមានតុល្យភាពរវាងទីក្រុង និងជនបទ។

ការកសាងសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋាន និងសហគមន៍នៅតាមទីក្រុង និងជនបទ គឺសំខាន់ណាស់ក្នុងការធ្វើការងារវិមជ្ឈការ។ អភិបាលកិច្ចល្អមានសារៈសំខាន់ជាអាទិភាពក្នុងការងារនេះ គឺត្រូវ មានការយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការរបស់អ្នកក្រ ហើយនឹងតម្រូវការនៃបរិស្ថាននៃមនុស្សជំនាន់ក្រោយផងដែរ។

### ១.៨.២.៤. សេដ្ឋកិច្ចទីផ្សារ

សេដ្ឋកិច្ចទីផ្សារ ដែលផ្អែកលើគោលការណ៍ទីផ្សារសេរីបាននាំឱ្យរដ្ឋាភិបាលមួយចំនួននៅក្នុងតំបន់អាហ្វ្រិកបើកចំហសេដ្ឋកិច្ចនៃប្រទេសរបស់ពួកគេទៅកាន់សេដ្ឋកិច្ចសកល តាមរយៈការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងវិនិយោគ។ ការបើកទីផ្សារក្នុងស្រុកទៅកាន់សេដ្ឋកិច្ចពិភពលោកនាំឱ្យមានការរីកចម្រើននៃបណ្តាញដឹកជញ្ជូន និងទូរគមនាគមន៍។ ហើយនេះមានន័យថា ទំនិញ និងសេវាកម្មពីភូមិ និងតំបន់ជនបទអាចឈានទៅដល់ទីផ្សារពិភពលោកបានយ៉ាងងាយស្រួល ប៉ុន្តែ ក៏មានទំនិញនិងសេវាកម្មពីសកលលោកផងដែរ។ ទីផ្សារអាចទៅដល់ភូមិ និងតំបន់ជនបទ និងមានប្រកួតប្រជែងជាមួយផលិតផលក្នុងស្រុក។

### ១.៨.២.៥. ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់

ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតាមទីប្រជុំជនតូចៗ អាចមានឥទ្ធិពលវិជ្ជមានទៅលើសេដ្ឋកិច្ចនៃតំបន់ជនបទដែលនៅជុំវិញ ប្រសិនបើកំណើននៃការទិញទំនិញឆ្ពោះទៅរកការទិញផលិតផលកសិកម្មនិងមិនមែនកសិកម្មពីតំបន់ជនបទ។ ទាំងនេះអាស្រ័យលើប្រភេទនៃផលិតផលដែលផលិតបាន មានគុណភាព និងតម្លៃ និងការប្រកួតប្រជែងរបស់ពួកគេបើប្រៀបធៀបទៅនឹងផលិតផលដែលនាំមកពីផ្នែកផ្សេងៗនៃប្រទេស។ ការអភិវឌ្ឍសេដ្ឋកិច្ចទីប្រជុំជនតូចៗ អាចនាំទៅរកការកាត់បន្ថយការធ្វើចំណាកស្រុកនៅទីជនបទទៅកាន់ទីប្រជុំជន និងទីក្រុងធំ ហើយវាអាចប្តូរទិសនៃលំហូរអន្តោប្រវេសន៍មកកាន់ទីជនបទវិញ។

### ១.៨.២.៦. ជំរុញវិស័យមិនមែនកសិកម្មនៅតំបន់ជនបទ

ការស្រាវជ្រាវថ្មីៗបានចង្អុលបង្ហាញថា វិស័យមិនមែនកសិកម្ម គឺជាប្រភពនៃប្រាក់ចំណូលដ៏សំខាន់សម្រាប់គ្រួសារនៅតាមជនបទ។ ពលកម្មកសិកម្ម និងប្រាក់ឈ្នួលពលកម្មមិនមែនកសិកម្ម ជាប្រភពប្រាក់ចំណូលដ៏សំខាន់មួយដល់ក្រុមមនុស្សដែលក្រីក្រ ហើយការងារខ្លួនឯងមានសារៈសំខាន់ខ្លាំងណាស់ចំពោះមនុស្សថ្នាក់កណ្តាល។ គំរូនេះបង្ហាញថា វិស័យមិនមែនកសិកម្មអាចដើរតួយ៉ាងសំខាន់ដើម្បីជៀសផុតពីអន្ទាក់នៃភាពក្រីក្រ និងជាសំណាញ់សុវត្ថិភាព

ការពារការធ្វើចំណាកស្រុកទៅកាន់ទីទីក្រុងរយៈពេលវែង[42]។

## ១.៩. សន្និដ្ឋាន

យោងតាមការបកស្រាយខាងលើនេះ យើងអាចសន្និដ្ឋានបានថា បញ្ហាចំណាកស្រុក គឺជាបញ្ហាចម្បងនៅក្នុងប្រទេសកម្ពុជា ដែលរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ និងព្យាយាមរកវិធីសាស្ត្រដោះស្រាយ។ លើសពីនេះទៅទៀត យើងឃើញថា មានទ្រឹស្តីជាច្រើន បានបង្ហាញអំពីមូលហេតុនៃការធ្វើចំណាកស្រុក ផលប៉ះពាល់នៃការធ្វើចំណាកស្រុក និងយុទ្ធសាស្ត្រ ដើម្បីធ្វើការដោះស្រាយបញ្ហានេះ។ ម៉្យាងវិញទៀត យើងក៏បានបង្ហាញពីទ្រឹស្តីគតិយុត្តិមួយចំនួន ដែលទាក់ទងនឹងការធ្វើចំណាកស្រុកនេះផងដែរ។ រដ្ឋាភិបាលបានរិះរកគោលនយោបាយផ្សេងៗ ដើម្បីទប់ស្កាត់ និងកាត់បន្ថយចំនួនជនចំណាកស្រុក ដែលមកកាន់ទីប្រជុំជន ឬទៅក្រៅប្រទេស ឲ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងការដាក់ឲ្យអនុវត្តន៍នូវគោលនយោបាយផ្សេងៗ ដែលមានទិសដៅដោះស្រាយបញ្ហាចំណាកស្រុកនោះ ក៏មានបញ្ហាប្រឈមមួយចំនួន ដែលរាំងស្ទះដល់ការដោះស្រាយនេះផងដែរ។ បន្ថែមពីលើនេះទៅទៀត យើងក៏បានបង្ហាញអំពីវិធានការណ៍ និងយុទ្ធសាស្ត្រមួយចំនួន ដែលប្រទេសដ៏ទៃធ្លាប់បានប្រើប្រាស់ ដើម្បីដោះស្រាយបញ្ហាចំណាកស្រុកនៅក្នុងប្រទេសរបស់គេ យ៉ាងមានប្រសិទ្ធភាពផងដែរ។

[42] ដកស្រង់ចេញពីគេហទំព័រ https://soapboxie.com/world-politics/GOVERNMENT-MEASURES-AIMED-AT-CURBING-RURAL-TO-URBAN-MIGRATION

# ជំពូកទី ២
# ស្ថានភាពទូទៅនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ

# ជំពូកទី ២
# ស្ថានភាពទូទៅនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ

## ២.១. ស្ថានភាពទូទៅរបស់ឃុំប្រាសាទ

### ២.១.១. ប្រវត្តិនៃឃុំប្រាសាទ

យោងទៅតាមសំដីរបស់ដូនជីម្នាក់នៅក្នុងវត្តប្រាសាទ ឃុំប្រាសាទត្រូវបានប្រសិទ្ធិនាមឡើងតាមវត្តប្រាសាទ ដែលវត្តនេះកើតឡើងតាំងពីយូរយារណាស់មកហើយ ពោលគឺកើតឡើងដំបូងគេនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្រហែល ១៥០០ ឆ្នាំមុននៃគ្រឹស្តសករាជមកម្ល៉េះ។ នៅក្នុងវត្ត មានប្រាសាទមួយកសាងតាមបែបរចនាបទឥស្លាម និងសាងសង់ឡើងពីថ្មភក់ ដោយព្រះបាទបក្សីចាំក្រុង នៅកំឡុងឆ្នាំ ៥២០ នៃគ្រឹស្តសករាជ ហើយជនជាតិឥស្លាមក៏ធ្លាប់រស់នៅក្នុងប្រាសាទនេះដែរ។ ម្យ៉ាងទៀត នៅក្នុងវត្តនេះក៏មានវត្ថុបុរាណជាច្រើនដូចជា រទេះ រាជរថមាស ពាងដែលផ្ទុកទៅដោយគ្រឿងអលង្កា មាស ពេជ្រ កែវ កង ជាដើម។ បើតាមដំណាលតគ្នាមក វត្តនេះមានរិទ្ធិបារមីពូកែសក្តិសិទ្ធិខ្លាំងក្លាណាស់ ពោលគឺនៅពេលដែលអ្នកភូមិចង់ផ្សងសុំអ្វីនោះ ពួកគេនឹងបានដូចប្រាថ្នា។ មានគ្រាមួយនោះ មានអ្នកភូមិម្នាក់បានទៅអុជធូបផ្សងសុំចាន លុះដល់ស្អែកឡើង គេឃើញមានចានជាច្រើននៅកន្លែងដែលគាត់បន់ស្រន់នោះ ទើបគាត់យកដងរែកមករែកទៅផ្ទះ។ លើសពីនេះ ពីសង្គមដើម វត្តនេះជាកន្លែងធ្វើសមាធិ និងសំណាក់ធម៌របស់តាយាយ។ សរុបមក ឃុំនេះមានឈ្មោះថាឃុំប្រាសាទ ពីព្រោះតែចាស់ៗពីបុរាណបានយកវត្តប្រាសាទជាគោល ហើយក៏ដាក់ឈ្មោះឃុំនេះ ជាឃុំប្រាសាទ ដូចនេះទៅ[43]។

### ២.១.២. ទីតាំងភូមិសាស្ត្រ

ឃុំប្រាសាទស្ថិតនៅទិសខាងកើតទីរួមស្រុកកំពង់ត្របែក ចម្ងាយ ៧ គីឡូម៉ែត្រ ដែលមានព្រំប្រទល់៖

- ខាងជើងទល់នឹងឃុំកន្សោមអក
- ខាងត្បូងទល់នឹងឃុំអន្សោង
- ខាងកើតទល់នឹងឃុំព្រៃឈរ
- ខាងលិចទល់នឹងឃុំកំពង់ត្របែក

[43] ទិន្នន័យទទួលបានពីការសម្ភាសន៍ដូនជីម្នាក់ក្នុងវត្តប្រាសាទ ដែលស្ថិតនៅក្នុងភូមិប្រាសាទ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

ឃុំប្រាសាទមានភូមិចំនួន ០៩ គឺ ភូមិប្រាសាទ ភូមិចំបក់ ភូមិអំពិល ភូមិពាន់វត្ត ភូមិជ្រលង ភូមិដូនទុង ភូមិបី ភូមិភ្លូង និងភូមិថ្កូវ ។ ឃុំនេះមានផ្ទៃដីសរុប: ២៩០៨ ហិកតា ផ្ទៃដីបង្កបង្កើនផល ២៤១១ហិកតា ផ្ទៃដីសាធារណ: និងផ្ទៃដីលំនៅដ្ឋាន ៤៩៧ ហិកតា ។

### ២.១.៣. ស្ថានភាពប្រជាជន

ស្ថានភាពប្រជាជននៅក្នុងឃុំប្រាសាទមានដូចតទៅៈ

- ចំនួនប្រជាពលរដ្ឋសរុប ១៣០២៨នាក់ ស្រី ៦៤៧៦ នាក់ ចំនួនគ្រួសារ ២៧៩៦ គ្រួសារ ចំនួនខ្នងផ្ទះ ២៥១២។
- ចំនួនមនុស្សពេញវ័យអាយុ ១៨ឆ្នាំឡើងសរុប ៨៧៥៦ នាក់ ស្រី ៤៣១៦ នាក់។
- មុខរបររបស់ប្រជាពលរដ្ឋ ៧៥% ប្រកបរបរធ្វើស្រែ។
- ចំនួនប្រជាពលរដ្ឋចំណាកស្រុកសរុប ១៩១០ នាក់ ស្រី ១០៨២ នាក់។

ការប្រៀបធៀបស្ថានភាពប្រជាជន ដោយផ្អែកលើទិន្នន័យឃុំឆ្នាំ ២០១២ ជាមួយឆ្នាំ ២០១៦ ឃើញថា មានការកើនឡើង ។

### ២.១.៤. សក្តានុពលរបស់ឃុំប្រាសាទ

ឃុំប្រាសាទជាតំបន់វាលរាបគ្មានទន្លេ បឹងបួរ ប្រជាពលរដ្ឋ ៧៥% ជាអ្នកប្រកបមុខរបរធ្វើស្រែ ២៥% ជាអ្នកប្រកបមុខរបរលក់ដូរ និងមានដំណាំរួមផ្សំដូចជា ដាំអំពៅ ត្រសក់ ល្ពៅ ម្រះនទោង ត្រឡាច ត្រកួន ដើម្បីដោះស្រាយជីវភាពគ្រួសារ ។ ប្រជាពលរដ្ឋមួយចំនួន ទៅរកស៊ី ធ្វើកម្មករសំណង់ កម្មកររោចក្រ និងក្រៅប្រទេសដើម្បីកែប្រែជីវភាពរស់នៅក្នុងគ្រួសារ អោយកាន់តែប្រសើរឡើង[44]។

### ២.១.៥. ការវិភាគស្ថានភាពបច្ចុប្បន្ន

ឃុំប្រាសាទ ជាតំបន់វាលរាបហើយស្ថិតនៅទិសខាងកើតនៃស្រុកកំពង់ត្របែក ចម្ងាយ១០ គីឡូម៉ែត មានព្រំប្រទល់ ខាងជើងជាប់នឹងឃុំកន្សោមអក និងឃុំគោខ្ចក ខាងត្បូងជាប់នឹងឃុំអន្សោង ខាងកើតជាប់នឹងឃុំព្រៃឈរ ចំណែកខាងលិចជាប់នឹងឃុំកំពង់ត្របែក ដែលមានផ្ទៃដីសរុបចំនួន ២៩០.៨០គ.ម$^{2}$ ហើយមានចំនួនគ្រួសារ ២ ៧៩៦ គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន

[44] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ១-២

១៣,០១៧ នាក់ ក្នុងនោះ ស្រី ៦,៥១២ នាក់។

**២.១.៥.១. ផ្នែកសេដ្ឋកិច្ច**

ឃុំប្រាសាទ ជាឃុំមួយដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្មធ្វើស្រែចម្ការសម្រាប់ទ្រទ្រង់ជីវិតកក្នុងគ្រួសារនីមួយៗមានធ្វើស្រែវស្សា និងស្រែប្រាំង។ ក្រៅពីរបរធ្វើស្រែប្រជាពលរដ្ឋមួយចំនួនតូចរកស៊ីលក់ដូរ និងធ្វើពាណិជ្ជកម្ម អាជីវកម្មនៅក្នុងផ្សារកអណ្តើក ដែលជាទីប្រជុំជនរបស់ឃុំ។

ទន្ទឹមនឹងនេះផងដែរ ប្រជាជននៅក្នុងឃុំតែងតែមានការជួបប្រទះការលំបាកខ្លះៗដូចជាផ្លូវពិបាកធ្វើដំណើរ ខ្វះប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដីកសិកម្ម ខ្វះការយល់ដឹងពីបច្ចេកទេសកសិកម្ម ខ្វះពូជ មាន់ ទា ជ្រូក ត្រី ខ្វះបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ហើយមានប្រជាពលរដ្ឋមួយចំនួនទៀតបានចេញចេញទៅរកការធ្វើនៅទីក្រុង ជាកម្មករសំណង់ កម្មករលីសែង កម្មកររោងចក្រ -ល-។

ឆ្លងតាមបញ្ហាទាំងអស់នេះ ឃុំបានខិតខំប្រឹងប្រែងស្វែងរកករឧបត្ថម្ភគាំទ្រពីអង្គការនានាមន្ទីរវិស័យសប្បុរសជន និងដៃគូអភិវឌ្ឍន៍ដើម្បីជួយផ្តល់សេវាទាំងអស់នេះ។

**២.១.៥.២. ផ្នែកសង្គមកិច្ច**

ឃុំប្រសាទ មានមន្ទីពេទ្យបង្អែកស្រុក មានបុគ្គលិកសុខាភិបាល បានសហការណ៍ជាមួយភូមិ ឃុំ និងអ្នកស្ម័គ្រចិត្តភូមិ។ ប្រជាពលរដ្ឋមួយចំនួនធំយល់ដឹងពីសារៈប្រយោជន៍នៃការចាក់វ៉ាក់សាំងការពារជម្ងឺប្រាំបីមុខដល់កុមារ យល់ដឹងពីសារៈប្រយោជន៍នៃការពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព យល់ដឹងពីសុខភាពអនាម័យ និងការប្រើប្រាស់ទឹកស្អាត។ ហើយចំពោះវិស័យអប់រំ ឃុំមានមត្តេយ្យសិក្សាសហគមន៍ចំនួន ៣ កន្លែង មានសាលាបឋមសិក្សាចំនួនបួនកន្លែងដែលមានអគាសរុប ១២ ខ្នងស្មើនឹង ៥៣ បន្ទប់ និងមានវិទ្យាល័យមួយកន្លែងដែលមាន ៩ អគារ ស្មើនឹង ៤៤ បន្ទប់។

ទន្ទឹមនឹងការរីកចម្រើនទាំងនេះ ក៏មានប្រជាជនមួយចំនួនដែលមិនទាន់យល់ដឹងពីសុខភាពអនាម័យ សារៈប្រយោជន៍នៃការចាក់ថ្នាំបង្ការជំងឺដល់កុមារ និងការប្រើប្រាស់ទឹកស្អាតមិនទាន់បានត្រឹមត្រូវ ហើយកុមារមួយចំនួនគ្រប់អាយុមិនទាន់បានចូលរៀនគ្រប់គ្នា។ ហេតុដូច្នេះហើយ ឃុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍នានា សូមជួយគាំទ្រលើគម្រោងរបស់ឃុំ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

### ២.១.៥.៣. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន

ឃុំប្រាសាទមានស្រះសហគមន៍ដែលជាជម្រកត្រី និងសម្រាប់ប្រជាពលរដ្ឋនេសាទផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ហើយក៏មានទីប្រជុំជនផ្សារកអណ្តើកជាទីផ្សារទំនិញផងដែរ។ ប៉ុន្តែទីប្រជុំជនផ្សារនេះគ្មានកន្លែងទុកដាក់សម្រាមឲ្យបានត្រឹមត្រូវ គ្មានលូបង្ហូរទឹកស្អុយចេញពីផ្សារដែលជាកត្តាធ្វើឲ្យផ្សារមានភាពកខ្វក់ ហើយឃុំពុំមានលទ្ធភាពដោះស្រាយបញ្ហាទាំងនេះនៅឡើយ។ ឆ្លងកាត់បញ្ហាទាំងនេះឃុំបានខិតខំសហការណ៍ និងស្វែងរកការឧបត្ថម្ភគាំទ្រពីមន្ទីរវិស័យ អង្គការជាតិអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាដើម្បីសុំការគាំទ្រចំពោះគម្រោង ឬសកម្មភាពជាអាទិភាពរបស់ឃុំ។

### ២.១.៥.៤. ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ

ឃុំប្រាសាទមានសន្តិសុខសណ្តាប់ធ្នាប់ល្អ អំពើចោរកម្ម អំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានលើសិទ្ធិស្ត្រី និងកុមារ ការជួញដូរ បញ្ហាទំនាស់ផ្សេងៗ ឃុំបានទប់ស្កាត់ និងចាត់វិធានការណ៍ទាន់ពេលវេលា និងបានសម្របសម្រួលតាមផ្លូវច្បាប់។ ឃុំបានធ្វើការផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ការងារអត្រានុលកូលដ្ឋាន ដែលជំរុញឲ្យប្រជាពលរដ្ឋចុះអត្រានុកូលដ្ឋានបានប្រហែល ៩០%។

ទន្ទឹមនឹងការរីកចម្រើនទាំងនេះឃុំនូវមានជួបបញ្ហាខ្លះដូចជា ក្មេងទំនើង ក្រុមបងតូចបងធំបានវាយតប់គ្នានៅក្នុងពិធីបុណ្យ តាមវត្ត តាមផ្ទះ និងពិធីរៀបមង្គលការជាដើម។ រីឯប្រជាពលរដ្ឋមួយចំនួនទៀតពុំទាន់យល់ដឹងពីច្បាប់ភូមិបាល ជាហេតុបង្កឲ្យមានទំនាស់ដីធ្លីកើតឡើង មួយចំនួនទៀតមិនទាន់យល់ដឹងពីសារៈប្រយោជន៍នៃការចុះសំបុត្រអត្រានុកូលដ្ឋាន ពិសេសកូនដែលទើបកើតឪពុកម្តាយមិនព្រមទៅចុះសំបុត្រកំណើត។

ឆ្លងកាត់បញ្ហាទាំងអស់នេះ ឃុំបានលើកគម្រោង ផ្សព្វផ្សាយច្បាប់ភូមិបាល សារៈប្រយោជន៍នៃការចុះសំបុត្រអត្រានុកូលដ្ឋាន ដើម្បីស្វែងរកការឧបត្ថម្ភគាំទ្រពី មន្ទីរជំនាញ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយដល់ប្រជាពលរដ្ឋនៅក្នុងឃុំ។

### ២.១.៥.៥.ផ្នែកយេនឌ័រ

សព្វថ្ងៃនេះជាសមាជិកនៃអង្គការនានា គណៈកម្មាធិការ គណៈកម្មការ សមាជិកភូមិដែលផ្តល់ផលប្រយោជន៍ដល់ស្ត្រី និងកុមារ សមភាពយេនឌ័រ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការងារអភិវឌ្ឍន៍។ ទន្ទឹមនឹងការរីកចម្រើនទាំងអស់នេះ នៅមានប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់យល់ច្បាស់ពី ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីជាដើម។

ផ្អែកតាមបញ្ហាទាំងអស់នេះ ឃុំបានលើកឡើងនូវគម្រោងមួយចំនួនដូចជា ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហឹង្សាកក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរស្ត្រី និងកុមារ ច្បាប់សិទ្ធិមនុស្ស យេនឌ័រ ដោយសង្ឃឹមជឿជាក់ថាប្រាកដជាមានការគាំទ្រពី មន្ទីរវិស័យ និងដៃគូអភិវឌ្ឍន៍នានា[45]។

## ២.២. ក្របខ័ណ្ឌវិនិយោគ និងគម្រោងវិនិយោគរបស់ឃុំប្រាសាទ

### ២.២.១. ក្របខ័ណ្ឌវិនិយោគ

ថវិការបស់ឃុំប្រសាទ ឆ្នាំ ២០១៧ សរុបចំនួន ៩៨ ៩៥០ ០០០ ៛ ក្នុងនោះទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានមានចំនួន ៣៥០ ០០០ ៛ ហើយថវិកា ទាំងនេះប្រើប្រាស់ផ្តោតសំខាន់លើ៖

- គម្រោងជួសជុលផ្លូវក្រាលខ្សាច់ភ្នំ ប្រវែង ៣ ០០០ ម៉ែត្រ ចំណាយអស់ថវិការចំនួន ៧៩ ៧៣៤ ០០០ ៛ ដែលមានទីតាំងនៅក្នុងភូមិប្រាសាទ និងភូមិភ្លូង។
- គ្រោងជួសជុលផ្លូវលំដីស ប្រវែង ៧៥០ ម៉ែត្រ ចំណាយអស់ថវិកាចំនួន ១៧ ៦២៥ ០០០ ៛ ដែលមានទីតាំងស្ថិតនៅភូមិភ្លូង។

ថវិកាវិនិយោគរបស់ឃុំប្រាសាទក្នុងឆ្នាំ ២០១៧ មានសរុបចំនួន ៩៨ ៩៥០ ០០០ ៛ ដែលក្នុងនោះ ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានមានចំនួន ៣៥០ ០០០ ៛។ ថវិកាទាំងអស់នេះ ផ្តោតសំខាន់ទៅលើការប្រើប្រាស់ដូចជា៖

- គម្រោងជួសជុលផ្លូវក្រាលខ្សាច់ភ្នំប្រវែង ៣ ០០០ ម៉ែត្រ ដែលចំណាយអស់ថវិកាចំនួន ៧៩ ៧៣៤ ០០០ ៛ និងមានទីតាំងស្ថិតនៅក្នុងភូមិប្រាសាទ និងភូមិភ្លូង។
- គម្រោងជួសជុលផ្លូវលំដីសប្រវែង ៧៥០ ម៉ែត្រ ដែលចំណាយអស់ថវិកាចំនួន ១៧ ៦២៥ ០០០ ៛ និងមានទីតាំងស្ថិតនៅភូមិភ្លូង។

### ២.២.២. គម្រោងវិនិយោគ

#### ២.២.២.១.ថវិកាវិនិយោគតាមប្រភព

ឆ្នាំ ២០១៧ ការវិនិយោគនៅក្នុងឃុំប្រសាទបានទទួលប្រភពថវិកាមកពី៖

- ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ចំនួន ៣៥០ ០០០ ៛។
- មូលនិធិអភិវឌ្ឍន៍ឃុំ ចំនួន ៩៨ ៦០០ ០០០ ៛។
- ទុនពីមន្ទីរអភិវឌ្ឍន៍ជនបទ ចំនួន ១២ ០០០ ០០០ ៛។
- ទុនពីអង្គការ ODOV ចំនួន ១៧ ៨៨៤ ០០០ ៛។
- ទុនពីអង្គការវ៉ូមែន ចំនួន ៥ ៥៦០ ០០០ ៛។

[45] ដកស្រង់ចេញពីឯកសារដើម កម្មវិធីវិនិយោគឃុំប្រាសាទ ឆ្នាំ ២០១៧ ជំពូកទី ១

- ទុនពីអង្គការស្អាតកម្ពុជា ចំនួន ១១៣ ៧៦០ ០០០ ៛។
- ទុនពីអង្គការសុខភាព ចំនួន ៣៦ ០០០ ០០០ ៛។
- ទុនពីអង្គការសន្តិសេនា ចំនួន៣២ ៧២០ ០០០ ៛។

លើសពីទៅទៀត ក៏ទទួលបានទុនពី ស្ថាប័ន ក្រុមហ៊ុន និងអង្គការនានាផងដែរ។

**២.២.២.២. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ**

**ក. ផ្នែកសេដ្ឋកិច្ច**

- មានការថែទាំផ្លូវជាប្រចាំ (DBST) ប្រវែង ១ ២០០ ម៉ែត្រចំណាយអស់ប្រហែល ១២ ០០០ ០០០ ៛ ដែលស្ថិតនៅ ភូមិចំបក់។
- បណ្តុះបណ្តាលផ្នែកយេនឌ័រ និងអាហាររូបត្ថម្ភ ចំនួន ៦ វគ្គ ចំណាយអស់ប្រហែល ៥ ១២៤ ០០០ ៛ ដែលស្ថិតនៅក្នុងឃុំ។
- ចែកមាន់ ចំនួន ១ លើក ចំណាយអស់ប្រហែល ២ ២០០ ០០០ ៛ ដែលស្ថិតនៅក្នុងឃុំ។
- ចែកពូជបន្លែ ចំនួន ១ លើក ចំណាយអស់ប្រហែល ១០ ៥៦០ ០០០៛ ដែលស្ថិតនៅក្នុងឃុំ។

ក្រៅពីនេះ ក៏មានសេវាកម្មផ្សេងៗ ដែលជួយដល់ការវិនិយោគផងដែរ ប៉ុន្តែពុំទាន់មានការបញ្ជាក់ចំនួនទឹកប្រាក់ច្បាស់លាស់នោះទេ។

**ខ. ផ្នែកសង្គមកិច្ច**

- កម្មវិធីចម្រោះទឹកបង្គន់អនាម័យ ចំនួន ១ ឆ្នាំ ចំណាយអស់ប្រហែល ៤៨ ០០០ ០០០ ៛ ដែលធ្វើនៅគ្រប់ភូមិ។
- បង្គន់អនាម័យ ចំនួន ១ ឆ្នាំ ចំណាយអស់ប្រហែល ៥ ៧៦០ ០០០ ៛ ដែលធ្វើនៅគ្រប់ភូមិ។
- សាលារៀន ចំនួន ១ ឆ្នាំ ចំណាយអស់ប្រហែល ៦០ ០០០ ០០០ ៛ ស្ថិតនៅសាលារៀន។
- កម្មវិធីផ្តល់ការថែទាំគាំទ្រដល់អ្នកផ្ទុក និងកើតជម្ងឺអេដស៍ និងកុមាររងគ្រោះដោយសារជម្ងឺអេដស៍ ចំនួន ១ ឆ្នាំ ចំណាយអស់ប្រហែល៥ ៥៥៦០ ០០០ ៛ ដែលធ្វើនៅគ្រប់ភូមិ។
- ប័ណ្ណសុខភាព CLTS ចំនួន ១ ឆ្នាំ ចំណាយអស់ប្រហែល ៣៦ ០០០ ០០០ ៛ ដែលធ្វើនៅគ្រប់ភូមិ។

- ផ្សព្វផ្សាយកម្មវិធី CLTS ចំនួន ៣០ ខែ ចំណាយអស់ប្រហែល ៦ ០០០ ០០០ ៛ ដែលធ្វើនៅ ៥ ភូមិ។
- វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយ SCWASH និងផ្សព្វផ្សាយ CLT/BCE ប៉ុន្តែមិនទាន់មានការបញ្ជាក់អំពីចំនួនទឹកប្រាក់នោះទេ។

ក្រៅពីពីរផ្នែកខាងលើ ក៏មានការវិនិយោគលើផ្នែកធនធានធម្មជាតិ និងបរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ និងផ្នែកយេនឌ័រផងដែរ។

### ២.២.២.៣. គម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ

**ក. ផ្នែកសេដ្ឋកិច្ច**

- ជួសជុលផ្លូវលំដីស ប្រវែង ៤,២០ គីឡូម៉ែត ចំណាយអស់ប្រហែល ៩៨ ៧០០ ០០០ ៛ ដែលស្ថិតនៅ ភូមិអំពិល និងភូមិប្រាសាទ។
- សាងសង់លូកាត់ ចំនួន ២៧ កន្លែង ចំណាយអស់ប្រហែល ៥៤ ០០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ជួសជុលផ្លូវក្រាលខ្សាច់ក្រហម ប្រវែង ២ ៥០០ គីឡូម៉ែត ចំណាយអស់ប្រហែល ៦៦ ៤៥៥ ០០០ ៛ ដែលស្ថិតនៅ ភូមិចំនួន៤។
- ថែទាំផ្លូវក្រាលខ្សាច់ក្រហម ប្រវែង ១ ០៦០ គីឡូម៉ែត ចំណាយអស់ប្រហែល ១៦ ៧៦០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់ជីធម្មជាតិ ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្តល់វ៉ាក់សាំងការពារជម្ងឺសត្វ ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ជួសជុលផ្លូវលំដីស ប្រវែង ៤,២០ គីឡូម៉ែត ចំណាយអស់ប្រហែល ៩៨ ៧០០ ០០០ ៛ ដែលស្ថិតនៅ ភូមិអំពិល និងភូមិប្រាសាទ។
- ផ្តល់ពូជត្រីចិញ្ចឹម ចំនួន ១៨ ០០០ ក្បាល ចំណាយអស់ប្រហែល ២ ៧០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្តល់ពូជមាន់ ទា ចំនួន ៣៦០ ក្បាល ចំណាយអស់ប្រហែល ៧ ២០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។

- ជួសជុលផ្លូវលំដីស ប្រវែង ៤,២០ គីឡូម៉ែត ចំណាយអស់ប្រហែល ៩៨ ៧០០ ០០០ រ ដែលស្ថិតនៅ ភូមិអំពិល និងភូមិប្រាសាទ។
- បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ ចំនួន ២ វគ្គ ចំណាយអស់ប្រហែល ៤ ០០០ ០០០ រ ដែលស្ថិតនៅ ភូមិអំពិល និងភូមិប្រាសាទ។
- ជួសជុលផ្លូវលំដីស ប្រវែង ៤,២០ គីឡូម៉ែត ចំណាយអស់ប្រហែល ៩៨ ៧០០ ០០០ រ ដែលស្ថិតនៅគ្រប់ភូមិ។

**ខ.ផ្នែកសង្គមកិច្ច**

- ផ្សព្វផ្សាយដល់ឪពុកម្តាយឲ្យយល់ដឹងពីសារៈប្រយោជន៍នៃការសិក្សា ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ រ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ចំនួន ៤៤៣ នាក់ ចំណាយអស់ប្រហែល ៨៨ ៦០០ ០០០ រ ដែលស្ថិតនៅគ្រប់ភូមិ។
- ការបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ពន្លឿនការសិក្សា និងនាយក នាយិកាសាលា ចំនួន ២ វគ្គ ចំណាយអស់ប្រហែល ៤ ០០០ ០០០ រ ដែលស្ថិតនៅតាមសាលាបឋម។
- ផ្សព្វផ្សាយកម្មវិធីថ្នាក់ពន្លឿនការសិក្សាដល់អាណាព្យាបាលសិស្ស និងសហគមន៍ ចំនួន ១ លើក ចំណាយអស់ប្រហែល ៤០០ ០០០ រ ដែលស្ថិតនៅតាមសាលាបឋម។
- ផ្តល់អាហារូបករណ៍ដល់សិស្សពន្លឿនការសិក្សា (សម្ភារៈសិក្សា សម្លៀកបំពាក់ សៀវភៅពុម្ព) ចំនួន ១ លើក ចំណាយអស់ប្រហែល ៥ ២៣២ ០០០ រ ដែលស្ថិតនៅតាមសាលាបឋម។
- សាងសង់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ ចំនួន ៦ ថ្នាក់ ចំណាយអស់ប្រហែល ១២ ០០០ ០០០ រ ដែលស្ថិតនៅចំនួន ៦ ភូមិ។
- ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ រ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយពីសុខភាពអនាម័យ ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ រ ដែលស្ថិតនៅគ្រប់ភូមិ។
- សាងសង់បង្គន់អនាម័យ ចំនួន៤៥ បង្គន់ ចំណាយអស់ប្រហែល ១៨ ០០០ ០០០ រ ដែលស្ថិតនៅគ្រប់ភូមិ។

- ផ្តល់វ៉ាក់សាំងចាក់ការពារជម្ងឺផ្សេងៗ ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- សាងសង់ប្រព័ន្ធទឹកស្អាត ចំនួន ១ កន្លែង ចំណាយអស់ប្រហែល ៤០ ០០០ ០០០ ៛ ដែលស្ថិតនៅ ភូមិប្រាសាទ។

**គ. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន**

- ផ្សព្វផ្សាយច្បាប់ជលផល ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្តល់ធុងសំរាម ចំនួន ៤ ធុង ចំណាយអស់ប្រហែល ១ ៦០០ ០០០ ៛ ដែលស្ថិតនៅ ភូមិប្រាសាទ។

**ឃ. ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ**

- ផ្សព្វផ្សាយពីច្បាប់គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយច្បាប់ភូមិបាល ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ចំនួន ២ ៥៥៨ ប័ណ្ណ ចំណាយអស់ប្រហែល ២៥ ៨៨០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- សាងសង់អាគារសាលាឃុំ ចំនួន ១ កន្លែង ចំណាយអស់ប្រហែល ៨០ ០០០ ០០០ ៛ ដែលស្ថិតនៅ ភូមិដូនទុង។

**ង. ផ្នែកយេនឌ័រ**

- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ស្ត្រី ចំនួន ១ វគ្គ ចំណាយអស់ប្រហែល ២ ០០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។
- ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិប្រាសាទ។
- ផ្សព្វផ្សាយច្បាប់ទប់ស្កាត់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារចំនួន ១ កន្លែង ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ។

- ផ្សព្វផ្សាយពីល្បិចកលឆបោករបស់របស់ជនល្មើស ចំនួន ៩ លើក ចំណាយអស់ប្រហែល ៣ ៦០០ ០០០ ៛ ដែលស្ថិតនៅគ្រប់ភូមិ[46]។

## ២.៣. រចនាសម្ព័ន្ធនៃការគ្រប់គ្រនរបស់ឃុំប្រាសាទ




រូបភាពទី ២.១ រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ឃុំប្រាសាទ

[46] ដកស្រង់ចេញពីឯកសារដើម កម្មវិធីវិនិយោគឃុំប្រាសាទ ឆ្នាំ ២០១៧ ជំពូកទី ២

❖ **រចនាសម្ព័ន្ធរដ្ឋបាល តួនាទី និងមុខងាររបស់ឃុំ**

រដ្ឋបាលឃុំ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ ហើយមេឃុំជាប្រធានក្រុមប្រឹក្សាឃុំ ។ ខាងក្រោមនេះ គឺជាការបង្ហាញអំពី រចនាសម្ព័ន្ធរដ្ឋបាល តួនាទី និងមុខងាររបស់ឃុំ។ ចំពោះមេឃុំ មានអ្នកជំនួយការពីររូបៈ

- **ជំទប់ទី១ មួយរូប**
- **ជំទប់ទី២ មួយរូប**

ជំទប់ ជាជំនួយការរបស់មេឃុំ ក្នុងការអនុវត្តភារកិច្ចដែលមេឃុំប្រគល់អោយ និងជំនួសមេឃុំទៅតាមឋានានុក្រមនៃជំទប់នៅពេលដែលមេឃុំអវត្តមាន ។ ជំទប់ទី ១ គឺទទួលជួយមេឃុំលើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រីឯជំទប់ទី ២ វិញ គឺទទួលជួយមេឃុំលើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។ មេឃុំ អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែងខាងលើនេះដល់ជំទប់ របស់ខ្លួនបាន។

- **ស្មៀនឃុំ**

ឃុំ ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូប ធ្វើជាស្មៀនឃុំ ។ ស្មៀនឃុំត្រូវបានតែងតាំង ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ និងធានានិរន្តភាពកិច្ចការរដ្ឋបាលឃុំ។ ស្មៀនឃុំ អាចផ្លាស់ប្តូរបានក្នុងករណីមានសំនើរបស់មេឃុំ ដែលអនុលោមតាមការសំរេច របស់ក្រុមប្រឹក្សាឃុំ ។

- **មេភូមិ និងជំនួយការ**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ក្រុមប្រឹក្សាឃុំនីមួយៗត្រូវរៀបចំជ្រើស រើសអោយមានមេភូមិម្នាក់សំរាប់ភូមិនីមួយៗ ចំណុះឃុំរបស់ខ្លួន ។ មេភូមិត្រូវរៀបចំចាត់តាំងអោយមានអនុប្រធានមួយរូប និងសមាជិកមួយរូបជា ជំនួយការ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការមេភូមិ ។

**មេភូមិមានភារកិច្ចដូចខាងក្រោមៈ**

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ ឬ មេឃុំ ប្រគល់អោយ ដើម្បីធានាបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ។
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិ របស់ខ្លួន។

- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ មេឃុំ ដើម្បីចាត់ចែង និងសម្របសំរួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

**មេឃុំ បំពេញតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- អនុវត្តសេចក្តីសំរេចក្រុមប្រឹក្សាឃុំ
- អនុវត្តនូវបទប្បញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ
- ធ្វើសេចក្តីរាយការណ៍ អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ របស់ខ្លួនយ៉ាងតិចអោយបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗ និងជួយដល់ក្រុមប្រឹក្សាឃុំក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំនាច របស់ក្រុមប្រឹក្សាឃុំ ព្រមទាំងកិច្ចការផ្សេងៗទៀត ដែលក្រុមប្រឹក្សាឃុំរបស់ខ្លួនប្រគល់អោយ ។

រដ្ឋបាលឃុំ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមាន ប្រកបដោយចិរភាពសំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំរបស់ខ្លួន ហើយនឹងបំរើផលប្រយោជន៍រួមដល់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។

**រដ្ឋបាលឃុំ មានតួនាទីពីរប្រភេទគឺ៖**

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ និងប្រជាពលរដ្ឋក្នុងឃុំរបស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ មានភារកិច្ចដូចជា៖

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ។
- រៀបចំចាត់ចែងសេវាសាធារណៈ និងមើលការខុសចំពោះកិច្ចការទាំងនោះឲ្យដំណើរការបានល្អ។
- លើកទឹកចិត្តអោយមានការបង្កើនជាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងបេតិកភណ្ឌជាតិ។

- សម្របសម្រួលចំពោះទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីអោយមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក។
- បំពេញកិច្ចការទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[47]។

## ២.៤. ការគ្រប់គ្រងរដ្ឋបាលឃុំ

### ២.៤.១. ក្រុមប្រឹក្សាឃុំប្រាសាទ

ក្រុមប្រឹក្សាឃុំប្រាសាទ មានចំនួន ៩ រូប ដែលក្នុងនោះមានសមាជិកស្រី ១ រូប។ ចំនួនសមាសភាព និងរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាដែលមកពី គណបក្សប្រជាជនកម្ពុជា មានចំនួន ៦ អាសនៈ មកពីគណបក្ស សម រង្ស៊ី មានចំនួន ២ អាសនៈ និងមកពីគណបក្ស សិទ្ធិមនុស្ស មានចំនួន ១ អាសនៈ។

### ២.៤.២. ការលើកកម្ពស់ប្រសិទ្ធិភាព ការគ្រប់គ្រងរដ្ឋបាលឃុំតាមរយៈការប្រជុំ

យោងតាមបទបញ្ជាផ្ទៃក្នុង ក្រុមប្រឹក្សាឃុំ បានធ្វើការប្រជុំអាណត្តិទៀងទាត់ជារៀងរាល់ខែ។ ការប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា បានប្រជុំអនុម័តលើការងារចាំបាច់ និងកិច្ចការផ្សេងៗទៀតដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំបានប្រជុំពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋនូវផែនការ៥ឆ្នាំ និងកម្មវិធីវិនិយោគឃុំ១ឆ្នាំ ម្តងៗស្វែងរកសម្រូវការ និងដោះស្រាយជូនប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ និង គ.ក.ន.ក បានប្រជុំលើកនៅផែនការ និងកម្មវិធីវិនិយោគឃុំបញ្ចូលនូវគម្រោងមួយចំនួនពាក់ព័ន្ធស្ត្រី និងកុមារ ដើម្បីក្រុមប្រឹក្សាឃុំធ្វើការអនុម័ត ។

### ២.៤.៣. ការងាររដ្ឋបាល

ការងារលិខិតស្នាមឃុំប្រាសាទក្នុងរយៈពេល៥ឆ្នាំ ក្នុងការចេញលិខិតមានដូចខាងក្រោម៖

- ដីការដែលបានដាក់ចេញចំនួន ១៥។
- សេចក្តីសម្រេចដែលបានដាក់ចេញចំនួន ៧៦។
- លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ៣២១៧។
- លិខិតដែលបានទទួលជំនួយ ៣៨៨។

### ២.៤.៤. ការផ្តល់សេវារដ្ឋបាល

ក្នុងការធ្វើលិខិតស្នាមផ្សេងៗមានដូចជា ច្បាប់ការ ច្បាប់បុណ្យ ឃុំសម្រេចបានលិខិតស្នាមជូនដល់ប្រជាជនសរុបចំនួន ៨៥៣ នាក់។ ប្រជាជនដែលទទួលបានសំបុត្របញ្ជាក់កំណើតមានចំនួន ១៥៨៤ នាក់ ហើយប្រជាជនដែលទទួលបានសំបុត្រអាពាហ៍ពិពាហ៍មានចំនួន ២៧៤ គូរ

[47] ដកស្រង់ចេញពី ជំពូកទី ៣ រចនាសម្ព័ន្ធរដ្ឋបាលឃុំសង្កាត់ នៃគេហទំព័រ https://km.wikipedia.org/wiki/

និងប្រជាជនដែលទទួលបានសំបុត្រមរណៈភាពមានចំនួន ២៣៦ នាក់ ដែលលិខិតស្នាមទាំងនេះបានធ្វើជូនប្រជាជនតាមសំណូមពរ និងទាន់ពេលវេលា។

ការទំនាក់ទំនង ការគាំទ្រ និងសហប្រតិបត្តិការរវាងរដ្ឋបាលឃុំជាមួយរដ្ឋបាលក្រុង ស្រុក ខេត្ត មន្ទីរ និងអង្គភាពនានារយៈពេល ៥ ឆ្នាំចុងក្រោយនេះ ឃុំបានទំនាក់ទំនងស្វែងរកការងារ និងមានការគាំទ្រពីស្រុក ខេត្ត អង្គការនានា មន្ទីរវិស័យ អង្គការសប្បុរសជន និងដៃគូអភិវឌ្ឍន៍ ដើម្បីសុំជំនួយឧបត្ថម្ភគាំទ្រ និងសហប្រតិបត្តិការនូវគម្រោងអភិវឌ្ឍន៍មូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត សំដៅឲ្យជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង និងកាត់បន្ថយភាពក្រីក្រ[48]។

## ២.៥. ការប្រព្រឹត្តទៅនៃការធ្វើចំណាកស្រុកនៅឃុំប្រាសាទ

### ២.៥.១. ដំណើរការលើករណីសិក្សា

#### ២.៥.១.១. លក្ខណៈរួមអំពីចំនួនប្រជាសាស្ត្រ

នៅក្នុងឆ្នាំ ២០១៥ ចំនួនប្រជាជនសរុបនៅក្នុងឃុំប្រាសាទមានសរុប ១២ ៨៥៤ នាក់ ដែលក្នុងនោះមានប្រជាពលរដ្ឋភេទស្រីចំនួន ៦ ៥៦៦ នាក់ ដែលអត្រាកំណើនប្រចាំឆ្នាំមានចំនួន ៤ ភាគរយ។ ចំនួនគ្រួសារសរុបមាន ២ ៧៧៤ គ្រួសារ ដែលទំហំគ្រួសារជាមធ្យមមាន ៥ នាក់ក្នុង ១ គ្រួសារ ហើយភាគរយស្ត្រីជាមេគ្រួសារមាន ១២ ភាគរយ។ ចំនួនមនុស្សដែលមានអាយុត្រឹម ១៧ ឆ្នាំ មាន ៤ ៥២៧ ស្មើនឹង ៣៥,២ ភាគរយ។ ចំណែកឯប្រជាជនដែលមានអាយុ ១៨ ឆ្នាំ ដល់ ៦០ ឆ្នាំមានចំនួន ៧ ២៨០ នាក់ ស្មើនឹង ៥៦,៦ ភាគរយ និងប្រជាជនដែលមានអាយុ ៦១ ឆ្នាំឡើងមានចំនួន ១ ០៤៧ នាក់ ស្មើនឹង ៨,១ ភាគរយ។

#### ២.៥.១.២. ស្ថានភាពមុខរបរចម្បង

តាមទិន្នន័យឃុំឆ្នាំ ២០១៥ ចំនួនមនុស្សដែលមានមុខរបរចម្បងអាយុ ១៨ ដល់ ៦០ ឆ្នាំមានចំនួន ៧ ២៨០ នាក់ ស្មើនឹង ៩៤,៦% ហើយក្នុងនោះស្ត្រីមាន ៣ ៦៩០ នាក់ ស្មើនឹង ៨០,៤% និងប្រុសមាន ៣ ៥៩០ នាក់ ស្មើនឹង ៨៥,២%។ ចំនួនប្រជាជនដែលមានមុខរបរចម្បងក្នុងវិស័យកសិកម្មមាន ៤ ៦៩៥ នាក់ ស្មើនឹង ៦៨,២% ស្ត្រីមាន ៣៥,៤%។ ចំណែកឯប្រជាជនដែលមានមុខរបរក្នុងផ្នែកសេវាកម្មវិញមានចំនួនសរុប ២ ១៩១ នាក់ ស្មើនឹង ៣១,៨% ស្ត្រីមាន ១៤,៥%។ ក្នុងវិស័យសេវាកម្មនេះ មានអ្នកបម្រើការលក់ដូរ និងជំនួញ ៨,៥% ជាងជួសជុល ១,១% អ្នកដឹកជញ្ជូន

[48] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ២-៣

១,២% អ្នកស៊ីឈ្នួលក្នុងវិស័យកសិកម្ម និងកម្មករសំណង់ ៣,៦% អ្នកបម្រើការក្នុងវិស័យឯកជន (កម្មកររោងចក្រ បុគ្គលិកអង្គការ) ១៤,១% និងអ្នកដែលបម្រើការងារជាមន្ត្រីរាជការ ៣,៣%[49]។

### ២.៥.១.៣. ការធ្វើចំណាកស្រុកស្វែងរកការងារធ្វើ

ដ្យាក្រាមខាងក្រោមនេះ បង្ហាញពីចំនួនអ្នកធ្វើចំណាកស្រុកនៅក្នុង និងក្រៅប្រទេសចាប់តាំងពីឆ្នាំ ២០១៣ រហូតមកដល់ឆ្នាំ ២០១៦។ តាមរយៈការបង្ហាញខាងក្រោម យើងឃើញថាចំនួនអ្នកធ្វើចំណាកស្រុកកើនឡើងយ៉ាងរហ័សចាប់តាំងពីឆ្នាំ ២០១៤ មក ជាពិសេសអ្នកដែលធ្វើចំណាកស្រុកក្នុងប្រទេស។ នៅឆ្នាំ ២០១៣ មានអ្នកចំណាកស្រុកក្នុងប្រទេសត្រឹមតែ ៩២៩ នាក់ ហើយធ្លាក់ចុះមកវិញត្រឹម ៨៦៨ នាក់ និងមានសន្ទុះកើនឡើងជាខ្លាំងរហូតដល់ ១ ៤៩៧ នាក់ ហើយនៅតែបន្តការកើនឡើងជាលំដាប់ដល់ ២០៦០ នាក់ នៅឆ្នាំ ២០១៦។ រីឯអ្នកចំណាកស្រុកក្រៅប្រទេសវិញក៏មានការកើនឡើងជាលំដាប់ផងដែរ ដែលនៅឆ្នាំ ២០១៣ មានចំនួន ៥៩ នាក់ កើនឡើងមកដល់ ៦៣ នាក់ នៅឆ្នាំ ២០១៤ កើនឡើងមកដល់ ៩៧ នាក់នៅឆ្នាំ ២០១៥ ហើយធ្លាក់ចុះបន្តិចមកនៅត្រឹម ៨៦ នាក់ក្នុងឆ្នាំ ២០១៦។

**ដ្យាក្រាមទី ២.១ ចំនួនអ្នកធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេសចាប់តាំងពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៦**




[49] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ៤-៥

ចំនួនអ្នកធ្វើចំណាកស្រុកសរុបក្នុងប្រទេសដែលមានអាយុ ១៨ ឆ្នាំឡើងមាន ១ ៥៩៧ នាក់ ស្មើនឹង ១៨% ក្នុងនោះមានស្រី ៨៩២ នាក់ និងអ្នកធ្វើចំណាកស្រុកទៅក្រៅប្រទេសដែលមានអាយុ ១៨ ឆ្នាំឡើងមានចំនួន ១៧ នាក់ ដែលស្មើនឹង ១,២% នៅក្នុងឆ្នាំ ២០១៥។

**ដ្យាក្រាមទី ២.២ ភាគរយអ្នកធ្វើចំណាកស្រុកក្នុងប្រទេស (អាយុ ១៨ ឆ្នាំឡើង)**




**ដ្យាក្រាមទី ២.៣ ភាគរយអ្នកធ្វើចំណាកស្រុកក្រៅប្រទេស (អាយុ ១៨ ឆ្នាំឡើង)**



### ដ្យាក្រាមទី ២.៤ ចំនួនមនុស្សធ្វើចំណាកស្រុកនៅក្នុងប្រទេស និងក្រៅប្រទេស[50]




## ២.៥.២. ភាពជោគជ័យនៃការកាត់បន្ថយចំណាកស្រុក

នាពេលបច្ចុប្បន្ន ឃុំប្រាសាទបាននឹងកំពុងខិតខំអភិវឌ្ឍន៍ភូមិ-ឃុំទាំងមូលឲ្យមានការរីកចម្រើន និងសំដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាជន ក្នុងគោលបំណងកាត់បន្ថយចំណាកស្រុក។ សមិទ្ធផល ដែលឃុំបានសម្រេចបានលើគោលដៅនេះក្នុងរយៈពេល ៥ ឆ្នាំកន្លងមក (២០១២-២០១៧) មានដូចជា៖

### ២.៥.២.១. វិស័យសេដ្ឋកិច្ច

នៅក្នុងឃុំនេះ ប្រជាជនដែលប្រកបរបរកសិកម្មជាចម្បងមាន ៦៨,២ ភាគរយ ស្មើនឹង ៤ ៦៩៥ នាក់ និង ៣១ ភាគរយទៀត ជាអ្នកដែលមានមុខរបរក្រៅពីវិស័យកសិកម្ម ស្មើនឹង ២ ១៩៤ នាក់។ មុខរបរក្រៅវិស័យកសិកម្មមានដូចជា អ្នកមានមុខរបរផលិតកម្ម មាន ៣ ភាគរយ អ្នកមានមុខរបរផ្នែកសេវាកម្ម ២ ១៩១ នាក់។ ការងារផលិតកម្មមានដូចជា រោងម៉ាស៊ីនកិនស្រូវមធ្យម ឬធំ សិប្បកម្មគ្រឿង សង្ហារឹមពីឈើ សិប្បកម្មផលិតដែក អាលុយមីញ៉ូម និងសិប្បកម្មផលិតទឹកសុទ្ធ។ ការងារសេវាកម្មមានដូចជា លក់គ្រឿងបរិភោគ និងទំនិញប្រើប្រាស់ដូចជា ខោអាវ ស្បែកជើង គ្រឿងក្រអូប គ្រឿងអលង្ការ គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម (តុ ទូ កៅអី) សម្ភារៈសំណង់ សម្ភារៈសិក្សា និងកីឡា និងសេវាកម្មខ្នាតតូច (កាត់សក់ ម៉ាស្សា) ជាដើម។

ការបង្កបង្កើនផលរយៈពេល ៥ ឆ្នាំនេះ ធ្វើឡើងលើផ្ទៃដីសរុប ២ ៩០៨ ហិចតា ដែលក្នុងនោះផ្ទៃដីបង្កបង្កើនផលទាំងសម្រាប់ស្រូវរដូវវស្សាមានចំនួន ២ ៩០៨,៥ ហិចតា ហើយទិន្នផល

[50] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ១៥-១៦

សរុបមាន ៥ ៩៨១ តោន ដែលទិន្នផលមធ្យមមាន ២,៥ តោនក្នុង ១ ហិចតា។ ផ្ទៃដីស្រែប្រាំងទទួលបានទឹកពីប្រព័ន្ធស្រោចស្រពមានចំនួន ៧៧៦ ហិចតា ស្របពេលដែលទិន្នផលស្រូវប្រាំងប្រចាំឆ្នាំគិតជាមធ្យមមានប្រមាណ ៣,៥ តោន ក្នុង ១ ហិចតា និងទិន្នផលស្រូវប្រាំងសរុបប្រចាំឆ្នាំមានចំនួន ២ ៧១៦ តោន។ រីឯទិន្នផលស្រូវនៅរដូវវស្សាវិញមានចំនួន ៣ ២៦៥ តោន ដែលទិន្នផលជាមធ្យមមាន ២ តោនក្នុង ១ ហិចតា។ បរិមាណផលស្រូវជាមធ្យមក្នុង ១ នាក់ គឺ ៤៦៥,៣ គីឡូក្រាម ហើយចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំស្រូវគឺ ៩១ ដុល្លា។ ងាកមកមើលតម្លៃនៃការលក់ស្រូវវិញ តម្លៃលក់ស្រូវជាមធ្យមស្មើនឹង៧៨២,២ រៀលក្នុង ១ គីឡូក្រាម ដែលតម្លៃលក់បានខ្ពស់បំផុតបាន ៨៣៤,៤ រៀល ក្នុង ១ គីឡូក្រាម និងតម្លៃទាបបំផុតគឺ ៧៣០ រៀល ក្នុង ១ គីឡូក្រាម។

ចំពោះការចិញ្ចឹមសត្វនៅក្នុងឃុំវិញ ទឹកប្រាក់នៃសត្វចិញ្ចឹមសរុបទាំងអស់មានចំនួន ៩៣៨ ៤៦៦ ដុល្លា ដែលក្នុងនោះរួមមាន សត្វគោចំនួន ៣ ២៣៧ ក្បាល មានតម្លៃសរុប ៦៤៧ ៤០០ ដុល្លា សត្វក្របីចំនួន ១៤២ ក្បាល មានតម្លៃសរុប ២៨ ៤០០ ដុល្លា សត្វជ្រូកចំនួន ៣ ៦២០ ក្បាល មានតម្លៃសរុប ១៨១ ០០០ ដុល្លា សត្វមាន់ចំនួន ១៥ ៨៥៩ ក្បាល មានតម្លៃសរុប ៦៣ ៤៣៦ ដុល្លា សត្វទាចំនួន ៤ ៣៨៩ ក្បាល មានតម្លៃសរុប ១៣ ១៦៧ ដុល្លា និងសត្វត្រី ២ ០២៥ ក្បាល មានតម្លៃសរុប ៥ ០៦៣ ដុល្លា។ ហើយសរុបចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីការចិញ្ចឹមសត្វ និងវារីវប្បកម្ម ពួកគាត់ទទួលបាន ៧៣ ដុល្លា ក្នុងមនុស្សម្នាក់[51]។

ចំណែក ជីវភាពប្រជាជនរស់នៅបានធូរធារសមរម្យរយៈពេល ៥ ឆ្នាំនេះ គឺប្រជាជនមានផ្ទះសរុប ២៥១២ ខ្នង ដែលផ្ទះថ្មមាន ២៧១ ផ្ទះក្បឿង ១ ០១៥ ផ្ទះស័ង្កសី ១ ១៩៧ ផ្ទះស្លឹក ២៩ រថយន្ត ១៣៥ គ្រឿង ម៉ូតូ ២ ៧១១ គ្រឿង កង់១ ៧៩៦ គ្រឿង ត្រាក់ទ័រភ្ជួរដី ៨ គ្រឿង គោយន្ត ៥៤២ ម៉ាស៊ីនច្រូតស្រូវ ២៤ ម៉ាស៊ីនបោកស្រូវ ៣៥ និងម៉ាស៊ីនច្រូត និងបោកស្រូវ ១២ គ្រឿង។

**២.៥.២.២. វិស័យអប់រំ**

ចំពោះសមិទ្ធផលនៃវិស័យអប់រំនៅក្នុងឃុំប្រាសាទវិញ ឃុំនេះមានសាលាបឋមសិក្សា ៤ កន្លែង (សាលាបឋមសិក្សាត្លុង សាលាបឋមសិក្សាអំពិល សាលាបឋមសិក្សាប្រាសាទ និងសាលាបឋមសិក្សាវត្តប្រាសាទ) អនុវិទ្យាល័យ និងវិទ្យាល័យ ១ កន្លែង (សាលាអនុវិទ្យាល័យ និងវិទ្យាល័យកំពង់ត្របែក) មត្តេយ្យរដ្ឋ ៣ កន្លែង និងមត្តេយ្យសហគមន៍ ៣ កន្លែង។

[51] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ៧-១៤

លទ្ធផលនៃការសិក្សារយៈពេល ៥ ឆ្នាំចុងក្រោយនេះមានដូចខាងក្រោម៖

- សិស្សដែលបានចុះឈ្មោះចូលរៀនបឋមសិក្សាមានចំនួន ១ ៨១៥ នាក់ ដែលក្នុងនោះសិស្សស្រីមាន ៨៣០ នាក់ ហើយមានគ្រូបង្រៀន ៥៨ នាក់។
- សិស្សដែលបានចុះឈ្មោះចូលរៀនអនុវិទ្យាល័យ និងវិទ្យាល័យមានចំនួន ១ ៣១០ នាក់ ដែលក្នុងនោះសិស្សស្រីមាន ៦៤៧ នាក់ ហើយគ្រូបង្រៀនមានចំនួន ៩១ នាក់។
- សិស្សដែលបានចុះឈ្មោះចូលរៀនមត្តេយ្យសិក្សាមានចំនួន ១៩៦ នាក់ ដែលក្នុងនោះសិស្សស្រីមាន ១៩៦ នាក់ ហើយគ្រូបង្រៀនមានចំនួន ៨ នាក់។

សិស្សប្រឡងជាប់បាក់ឌុបរយៈពេល ៥ ឆ្នាំ ២០១២-២០១៧ មានដូចខាងក្រោម៖

- សិស្សប្រឡងជាប់ឆ្នាំ ២០១២ មានសរុប ៣៧៩ នាក់ ស្រី ២១១ នាក់។
- សិស្សប្រឡងជាប់ឆ្នាំ ២០១៣ មានសរុប ៤០៣ នាក់ ស្រី ២៦៤ នាក់។
- សិស្សប្រឡងជាប់ឆ្នាំ ២០១៤ មានសរុប ១៣៩ នាក់ ស្រី ៩៩ នាក់។
- សិស្សប្រឡងជាប់ឆ្នាំ ២០១៥ មានសរុប ២១៦ នាក់ ស្រី ១១៨ នាក់។
- សិស្សប្រឡងជាប់ឆ្នាំ ២០១៦ មានសរុប ២៧៤ នាក់ ស្រី ១៣១ នាក់[52]។

បន្ថែមលើនេះទៅទៀត សិស្សដែលអាចមានលទ្ធភាពរៀនបន្តនៅសកលវិទ្យាល័យមានចំនួន ២៦៦ នាក់ ក្នុងនោះមាន ១៣១ ជាសិស្សស្រី។ ចម្ងាយមធ្យមពីភូមិទៅសាលាបឋមសិក្សាមានប្រវែងត្រឹមតែ ០,៦ គីឡូម៉ែត និងពីភូមិទៅអនុវិទ្យាល័យ និងវិទ្យាល័យមានជាមធ្យម ២,២ គីឡូម៉ែត[53]។

#### ២.៥.២.៣. វិស័យសុខាភិបាល

កន្លងមក ការអភិវឌ្ឍលើវិស័យសុខាភិបាលនៅក្នុងឃុំប្រាសាទមានស្ថានភាពដូចតទៅ៖

- ពង្រឹង និងពង្រីកប្រព័ន្ធ សុខាភិបាល ដើម្បីធានាផ្តលសេវាសុខភាពជូនប្រជាពលរដ្ឋ។

[52] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ៤-៦

[53] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ៤២, ២៣

- ប្រកបដោយប្រសិទ្ធិភាព គុណភាព និងសមធម៌ ។ ជម្រុញការថែទាំ លើកកម្ពស់សុខភាពមាតាទារក និងកុមារ សុខភាពបន្តពូជ អាហារូបបត្ថម្ភ និងអប់រំសុខភាព ។ បង្កើនការងារ បង្ការ និងប្រយុទ្ធនឹងជម្ងឺឆ្លង និងជម្ងឺរាំរ៉ៃផ្សេងៗ ។
- ពង្រឹងសេវា សង្គ្រោះសម្តពបន្ទាន់ និងសេវាថែទាំនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ក្នុងនោះ គឺមានមន្ទីរពេទ្យបង្អែកកំពង់ត្របែក ។
- បង្កើនអត្រាគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការគ្រប់មុខ វ៉ាក់សាំង រួមទាំងបញ្ចូលវ៉ាក់សាំងថ្មីៗ ពង្រឹងយន្តនាការ ផ្តល់ថ្នាំបង្ការបន្ថែម ដើម្បីឈានទៅបំបាត់កញ្ជ្រិល និងតេតាណូសលើទារកនៅឆ្នាំ២០១២។ បន្តជម្រុញ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជម្ងឺគ្រុនចាញ់ សំដៅឈានទៅលុបបំបាត់ទាំងស្រុងនូវជម្ងឺនេះនៅត្រឹមឆ្នាំ២០១៥[54]។

នៅក្នុងឆ្នាំ ២០១៥ ទារកដែលបានចាប់កំណើតមានសរុប ២២១ នាក់ ដែលក្នុងនោះចំនួនកុមារស្លាប់ក្រោមអាយុ ៥ ឆ្នាំ មានតែ ១ នាក់គត់ ហើយគ្មានទារកដែលស្លាប់ក្រោយពេលកើតរយៈពេល ១ ខែនោះទេ។ អត្រាស្លាប់របស់ទារកក្នុង ១០០០ កំណើតមាន ០ ភាគរយ ខណៈដែលស្ត្រីនៅក្នុងភូមិ-ឃុំបានយល់ដឹងពីបញ្ហាសុខភាពអំឡុងពេលពរពោះ និងពេលសម្រាល ដោយក្នុងនោះភាគរយរបស់ស្ត្រីដែលសម្រាលកូនដោយឆ្មបពេទ្យមាន ១០០ ភាគរយ។ ក្រោយសម្រាលកុមារដែលមានអាយុចន្លោះពី ៩ ខែ ដល់ ១២ ខែ ទាំងអស់ (១០០ ភាគរយ) បានចាក់ថ្នាំបង្ការគ្រប់ចំនួន។ រីឯជម្ងឺដង្កាត់ផ្សេងៗទៀតដូចជា ជម្ងឺរបេង គ្រុនឈាម និងគ្រុនចាញ់ មិនបានឆក់យកជីវិតអ្នកភូមិម្នាក់ណាឡើយ។ ដោយឡែក នៅក្នុងភូមិ-ឃុំនេះ មានចំនួនគ្រួសារមានសមាជិកកើតជម្ងឺ ឬផ្ទុកជម្ងឺអេដស៍សរុបចំនួន ១៤ គ្រួសារ ក្នុងឆ្នាំ ២០១៥ ដែលចំនួននេះមានថយចុះពីចំនួន ១៧ គ្រួសារនៅឆ្នាំ ២០១៣។ ម្យ៉ាងវិញទៀត ចម្ងាយមធ្យមពីភូមិទៅកាន់មណ្ឌលសុខភាពមានប្រវែងត្រឹមតែ ២,២ គីឡូម៉ែត។

#### ២.៥.២.៤. វិស័យគមនាគមន៍

នៅក្នុងឃុំប្រាសាទ ផ្ទៃដីសរុបមានចំនួន ២ ៩០៨ គីឡូម៉ែតការ៉េ ដែលប្រវែងផ្លូវសរុបមាន ៣១ ២៩៥ ម៉ែត្រ ក្នុងនោះប្រវែងផ្លូវតាមបណ្តាឃុំសង្កាត់មាន ១៩ ២៩៥ ម៉ែត្រ ប្រវែងផ្លូវខេត្តស្រុកឆ្លងកាត់តាមបណ្តាឃុំសង្កាត់ ៤០០០ ម៉ែត្រ និង ប្រវែងផ្លូវជាតិឆ្លងកាត់បណ្តាឃុំសង្កាត់ ៨ ០០០

[54] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ៦

ម៉ែត្រ[55]។ ចំនួនខ្សែផ្លូវធំៗដែលមាននៅក្នុងឃុំសង្កាត់មានចំនួន ៧ ខ្សែ ក្នុងនោះផ្លូវប្រភេទ ឌីប៊ីអេសធី (DBST) មានប្រវែង ៨០០ ម៉ែត្រ ផ្លូវលំក្រាលគ្រួសក្រហមខ្សាច់ភ្នំមានចំនួន ៥ ៤០០ ម៉ែត្រ ផ្លូវលំដីសមានប្រវែង ៤ ១៩៥ ម៉ែត្រ និងផ្លូវលំធម្មតាដែលមិនទាន់លើកដីរួចមានប្រវែង ៨ ៩០០ ម៉ែត្រ[56]។ ការអភិវឌ្ឍគមនាគមន៍ផ្សេងៗទៀតមានដូចខាងក្រោម៖

- ផ្លូវក្រាលខ្សាច់ភ្នំ ៣ខ្សែ ប្រវែង ៤០៩០ម៉ែត្រ។
- ផ្លូវធ្វើដីស ៨ខ្សែ ប្រវែង ១២១៣០ម៉ែត្រ។
- ផ្លូវថែទាំ ២ខ្សែ ប្រវែង ៩៧០០ម៉ែត្រ។
- ផ្លូវកអណ្ដើក-មេសាង ១ខ្សែ ប្រវែង ២៨០០ម៉ែត្រ។

ចំណែកឯផ្លូវក្រាលកៅស៊ូ ពីផ្សារកអណ្ដើក ទៅភ្នំឈើកាច់មានការបរិច្ចាកថវិកាពី៖

- ក្នុងនោះប្រវែង ១៩៥០ម៉ែត្រ ជាថវិការបស់រដ្ឋាភិបាល។
- ផ្លូវធម្មតាលើកដោយប្រជាជន មានប្រវែង ១៤.១៤០ម៉ែត្រ។
- ដាក់លូ បង្ហូរទឹកកាត់ផ្លូវចំនួន ២៦ កន្លែង។

ឃុំបានសហការជាមួយសុរិយាដី បានផ្ដល់ប្លង់កម្មសិទ្ធិជូនប្រជាពលរដ្ឋបាន ១១៧០៥ ក្បាលដីផ្ដល់បានប័ណ្ណកម្មសិទ្ធិ ៤៧៥៤ ប្លង់។

#### ២.៥.២.៥. វិស័យធារាសាស្ត្រ

វិស័យធារាសាស្ត្រនៅក្នុងឃុំប្រាសាទក្នុងរយៈពេលកន្លងមកមានការរីកចម្រើនដូចជា៖

- ស្ដារប្រឡាយ ប្រវែង ៨០០០ ម៉ែត្រ។
- ដាក់លូរំដោះទឹកភ្លៀងតាមបណ្ដោយផ្លូវជាតិប្រវែង ១៨០០ ម៉ែត្រ។
- បានធ្វើលូរំដោះទឹកស្អុយ ប្រវែង ១២០០ ម៉ែត្រ[57]។

#### ២.៥.២.៦. ការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនី

នៅក្នុងឃុំប្រាសាទមានការផ្គត់ផ្គង់ទឹកស្អាតចំនួន ៥ ភូមិ ដែលក្នុងនោះមានប្រជាជនចំនួន ២ ៧៧៤ គ្រួសារទទួលបានទឹកស្អាតប្រើប្រាស់បើតាមទិន្នន័យឃុំក្នុងឆ្នាំ ២០១៥។ ប្រព័ន្ធទឹកនៅក្នុងភូមិ-ឃុំនេះ មាន ២ យ៉ាងគឺ ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកអណ្ដូងស្នប់ ឬអណ្ដូងចម្រុះ។

[55] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ២៥-២៨, ១៦

[56] ដកស្រង់ចេញពីទិន្នន័យមូលដ្ឋានឃុំពីមន្ទីរផែនការខេត្តព្រៃវែង ឆ្នាំ ២០១៥ ទំព័រទី ២

[57] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ៨

គ្រួសារដែលមានទឹកស្អាតប្រើប្រាស់មានតែ ១៥០ គ្រួសារប៉ុណ្ណោះ ខណៈពេលដែលគ្រួសារដែលនៅសេសសល់ចំនួន ២ ៦២៤ គ្រួសារទៀតប្រើប្រាស់ទឹក ដែលបានមកពីប្រភពអណ្តូងស្នប់ ឬអណ្តូងចម្រុះ។ នៅក្នុងភូមិទាំង ៩ ក្នុងឃុំប្រាសាទនេះមានអណ្តូងស្នប់ និងអណ្តូងសរុបចំនួន ២ ១៦០ អណ្តូង ដែលប្រជាជនកំពុងប្រើប្រាស់សព្វថ្ងៃ។ ក្រឡេកមកមើល ផ្នែកបណ្តាញអគ្គិសនីវិញ ភ្នាក់ងារអគ្គិសនីបានដាក់ខ្សែភ្លើងឆ្លងកាត់បានចំនួនទាំង ៩ ភូមិ គឺ ភូមិប្រសាទ ភូមិចំបក់ ភូមិពាន់វត្ត ភូមិជ្រលង ភូមិដូនទុង ភូមិបី ភូមិភ្លង និងភូមិថ្កូវ។ ប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់បានចំនួន ២៤៧៤ គ្រួសារ ដែលស្មើនឹង ៩០%។ នៅក្នុងភូមិប្រាសាទ ភាគរយផ្ទះដែលមានបណ្តាញអគ្គិសនីប្រើប្រាស់មាន ៧១% ភូមិចំបក់ ៩៩,៨% ភូមិអំពិល ៣៩,៥% ភូមិពាន់វត្ត ៩៤,២% ភូមិជ្រលង ៧០% ភូមិដូនទុង ៣៦,៧% ភូមិបី ១០០% ភូមិភ្លង ៣០,៥% និងភូមិថ្កូវ ៨០%[58]។

### ២.៥.២.៧. ការធានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយកន្លងមកនេះ ឃុំប្រាសាទមានសន្តិសុខល្អប្រសើរ ប្រជាពលរដ្ឋមានសេចក្តីសុខ មិនមានការព្រួយបារម្ភអំពីសុវត្ថិភាព និងសន្តិសុខភូមិឡើយ។ ចំពោះបទល្មើសព្រហ្មទណ្ឌវិញ សមត្ថកិច្ច និងអាជ្ញាធរភូមិ-ឃុំ បានបង្ក្រាប និងឃាត់ខ្លួនជនសង្ស័យភេទប្រុសចំនួន ៩ នាក់ និងវត្ថុតាងមានម៉ូតូ ៣ គ្រឿង ហើយបញ្ជូនទៅតុលាការ។ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ប្រព្រឹត្តទៅ និងមានដំណើរការល្អប្រសើរ។ ភ្នាក់ងារភូមិ-ឃុំបានចុះប្រជុំ ផ្សព្វផ្សាយ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពចំនួន ៩ ភូមិ មានលក្ខណៈ ៩ យ៉ាង ចំនួន ១៤ លើក ដែលមានប្រជាពលរដ្ឋចូលរួម ៥ ៩៨៧ នាក់។ ក្រៅពីនេះ ភ្នាក់ងារភូមិ-ឃុំ ក៏បានចុះផ្សព្វផ្សាយ បើកវេទិកាសាធារណៈចំនួន ៩ ភូមិ ចំនួន ៦ លើក ដែលមានប្រជាពលរដ្ឋចូលរួម ៤ ៦៥០ នាក់[59]។

ក្រៅពីភាពជោគជ័យខាងលើនេះ ភូមិ-ឃុំក៏សម្រេចបានសមិទ្ធផលមួយចំនួនផ្សេងទៀតផងដែរ ដែលមានដូចជាការកាត់បន្ថយភាពក្រីក្រ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ប្រជាជនឲ្យយល់ដឹងច្បាស់ពីការប្រកបរបររកស៊ី ឬអាជីវកម្មផ្សេងៗដោយខ្លួនឯង។ ដោយការខិតខំប្រឹងប្រែងរបស់ឃុំ និងកិច្ចសហការពីប្រជាពលរដ្ឋផងនោះ ប្រជាជនឃុំប្រាសាទមានជីវភាព និងចំណេះដឹង

---

[58] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ៣៥, ៦

[59] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ១០

ប្រសើរជាងមុន ទាំងផ្នែកជំនាញបច្ចេកទេសក្នុងវិស័យកសិកម្ម និងចំណេះដឹងផ្សេងៗ។

## ២.៥.៣. ការលំបាកក្នុងការកាត់បន្ថយចំណាកស្រុក

ទោះបីជាក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ការអភិវឌ្ឍឃុំមានការរីកចម្រើនទាំងលើវិស័យសេដ្ឋកិច្ច វិស័យអប់រំ វិស័យសុខាភិបាល វិស័យគមនាគមន៍ វិស័យធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនី និងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សំដៅកាត់បន្ថយការធ្វើចំណាកស្រុកក៏ដោយ ក៏ឃុំនៅតែមានការងារសេសសល់ និងបញ្ហាប្រឈមក្នុងការងារអភិវឌ្ឍន៍ភូមិដ្ឋានមិនទាន់តាមសំណូមពររបស់ប្រជាពលរដ្ឋ ហើយជីវភាពរបស់ប្រជាពលរដ្ឋនៅមានការខ្វះខាត និងនាំគ្នាធ្វើចំណាកស្រុក។

### ២.៥.៣.១. បញ្ហានិកម្មភាព

ភាពគ្មានការងារធ្វើនៅឃុំប្រាសាទ ជាបញ្ហាប្រឈម ដែលឃុំកំពុងយកចិត្តទុកដាក់។ ដោយសារតែប្រជាជនភាគច្រើននៅក្នុងឃុំនេះប្រកបរបរកសិកម្ម ហើយកសិកម្មបច្ចុប្បន្នបានអភិវឌ្ឍន៍មកជាកសិកម្មទំនើប ប្រើប្រាស់គ្រឿងចក្រធំៗ ដែលអាចជំនួសឲ្យកម្លាំងមនុស្សបានច្រើន ដូច្នេះហើយទើបបណ្តាលឲ្យប្រជាពលរដ្ឋ ដែលធ្លាប់តែរកប្រាក់ចំណូលតាមរយៈការលក់កម្លាំងពលកម្មក្នុងវិស័យកសិកម្មនេះ ត្រូវបង្ខំចិត្តស្វែងរកការងារផ្សេងៗជំនួសឲ្យការងារ ដែលខ្លួនធ្លាប់ធ្វើ។ ប៉ុន្តែ ការស្វែងរកការងារក្នុងភូមិ-ឃុំ មិនមែនជាការងាយស្រួលឡើយ ដោយសារតែនៅក្នុងភូមិ-ឃុំមិនសូវសំបូរការងារធ្វើ ហើយការងារភាគច្រើនផ្តល់ប្រាក់ចំណូលបានតិចតួចមិនសមស្របនឹងការបញ្ចេញពលកម្មនោះទេ។ ម្ល៉ោះហើយ ទើបប្រជាជនទាំងនោះនាំគ្នាចាកចេញពីស្រុកកំណើតទៅកាន់ទីប្រជុំជនផ្សេងៗ ជាពិសេសមកកាន់ទីក្រុងភ្នំពេញ និងទៅកាន់ប្រទេសជិតខាងក្នុងគោលបំណងស្វែងរកការងារធ្វើ ដោយសារតែបច្ចុប្បន្នវិស័យវាយនភ័ណ្ឌរោងចក្រកាត់ដេរ និងវិស័យសំណង់កំពុងរីកលូតលាស់ដូចផ្សិតនៅក្នុងទីក្រុងភ្នំពេញ។ ក្រៅពីនេះ កម្មករ-កម្មការនីកាត់ដេរ កំពុងទទួលបានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល លើបញ្ហាផ្សេងៗជាច្រើន ដូចជាបញ្ហាសុវត្ថិភាពការងារ បញ្ហាប្រាក់បៀវត្សរ៍ និងបញ្ហាសិទ្ធិការងារ។ នេះសបញ្ជាក់ឲ្យឃើញថា ដោយសារតែការបង្កើតការងារនៅក្នុងឃុំនៅមានកម្រិត ដែលមិនអាចបំពេញតម្រូវការរបស់ប្រជាជនដែលរស់នៅតំបន់ទាំងនោះបាន នាំឲ្យពួកគាត់សម្រេចចិត្តធ្វើការចំណាកស្រុក។

### ២.៥.៣.២ បញ្ហាប្រែប្រួលអាកាសធាតុ

ឃុំប្រាសាទ ជាតំបន់វាលរាប ប៉ុន្តែតែងតែជួបប្រទះនូវផលប៉ះពាល់ពីគ្រោះធម្មជាតិ ទឹកជំនន់ ទឹកភ្លៀង ទឹកទន្លេ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត។ ២ ភូមិខាងលិច គឺភូមិជ្រលង និងភូមិ

ប្រាសាទ តែងជួបប្រទះជាញឹកញាប់នូវគ្រោះទឹកជំនន់ រីឯគ្រោះរាំងស្ងួតវិញតែងកើតឡើងនៅភូមិទាំង ៩ គឺភូមិប្រាសាទ ភូមិចំបក់ ភូមិដូនទុង ពាន់វត្ត អំពិល ភូមិបី ភូមិក្លូង ភូមិថ្កូវ ភូមិជ្រលង និងភូមិប្រាសាទ។ ដូចដែលបានបញ្ជាក់ពីខាងលើហើយថា ប្រជាជនភាគច្រើនរស់នៅដោយការពឹងផ្អែកលើវិស័យ កសិកម្ម ហើយការធ្វើកសិកម្មពួកគាត់ពុំសូវទទួលបានទិន្នផលល្អនោះទេ ពោលគឺដោយសារតែ អាកាសធាតុមានការប្រែប្រួលខុសពីអតីតកាល។ ប្រជាជននៅក្នុងតំបន់នេះភាគច្រើនធ្វើកសិកម្ម រង់ចាំទឹកភ្លៀង ក៏ប៉ុន្តែអាកាសធាតុនាពេលបច្ចុប្បន្នប្រែប្រួលមិនទៀងទាត់ ធ្វើឲ្យរដូវប្រាំងប្រែជារដូវ វស្សាធ្លាក់ភ្លៀងជោកជាំលិចដំណាំដាំដុះ ឯរដូវវស្សាប្រែជារដូវប្រាំងរាំងស្ងួតហួតហែងគ្មានភ្លៀងធ្លាក់។ កត្តាមិនប្រក្រតីរបស់អាកាសធាតុហើយ បានបំផ្លិចបំផ្លាញផលដំណាំរបស់ពួកគាត់ ធ្វើឲ្យពួកគាត់ ខាតបង់ ហើយមិនមានលទ្ធភាពផ្គត់ផ្គង់គ្រួសារដែលកំពុងមានតម្រូវការ ក៏ដូចជាខ្វះខាតលុយកាក់ ក្នុងការចាយវាយប្រចាំថ្ងៃ និងសងបំណុលដែលគាត់ជំពាក់គេផងនោះ ជាហេតុនាំឲ្យគាត់បោះបង់ ចោលដីស្រែចម្ការ ហើយងាកមករកការធ្វើចំណាកស្រុកស្វែងរកការងារ ផ្សេងៗធ្វើវិញ។ យោងទៅតាមទិន្នន័យស្ថិតិរបស់ឃុំប្រាសាទនៅក្នុងឆ្នាំ ២០១៥ ចំនួនប្រជាជនដែលខ្ចីលុយពីមីក្រូហិរញ្ញវត្ថុ និងធនាគារមាន ១៧២១ នាក់ មានការកើនឡើងបើធៀបនឹងឆ្នាំ ២០១៣ ដែលមានចំនួន ១ ១៦៣ នាក់។

### ២.៥.៣.៣. បញ្ហាកង្វះថវិកាក្នុងការអភិវឌ្ឍភូមិ-ឃុំ

នៅក្នុងឃុំប្រាសាទ មានគម្រោងអភិវឌ្ឍន៍ជាច្រើន ដែលមានទិសដៅកាត់បន្ថយបញ្ហាចំណាកស្រុក ជាពិសេសការផ្ដោតយកចិត្តទុកដាក់លើផ្នែកប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏ប៉ុន្តែដោយសារតែថវិការបស់រដ្ឋសម្រាប់ការអភិវឌ្ឍនៅមានកម្រិត នាំឲ្យការអភិវឌ្ឍនៅក្នុងភូមិ-ឃុំពុំទាន់សម្រេចបានពេញលេញនោះទេ។ នៅតាមតំបន់មួយចំនួននៅក្នុងឃុំមានការកសាងប្រព័ន្ធធារាសាស្ត្រហើយ ប៉ុន្តែនៅតែមានការខ្វះខាតនៅក្នុងតំបន់ខ្លះដែរ។ ចំណែកឯហេដ្ឋារចនាសម្ព័ន្ធវិញក៏ដូចគ្នាដែរ មានការកសាងផ្លូវលំ ការដាក់ប្រព័ន្ធលូផ្សេងៗ ការស្តារប្រឡាយទឹក ប៉ុន្តែការអនុវត្តគម្រោងទាំងនេះមានភាពយឺតយ៉ាវ ដោយសារតែកញ្ចប់ថវិកាមានមិនគ្រប់គ្រាន់ ហើយជួនកាលការនាំមកនូវថវិកាអភិវឌ្ឍន៍ភូមិ-ឃុំមានភាពយឺតយ៉ាវ។ លើសពីនេះ ឃុំមិនត្រឹមតែយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍវិស័យទាំងពីរខាងលើនោះទេ ប៉ុន្តែថែមទាំងបានបែងចែកថវិកាមួយចំនួនសម្រាប់កសាង និងអភិវឌ្ឍន៍លើវិស័យផ្សេងៗទៀត។ ការខ្វះខាតថវិកា និងភាពយឺតយ៉ាវនៃការផ្តល់ថវិកាអភិវឌ្ឍន៍ភូមិ-ឃុំនេះហើយ បង្កើតបានជាឧបសគ្គរាំងស្ទះដល់ដំណើរការ

អភិវឌ្ឍន៍ឃុំ ដែលបង្កើតឲ្យមានការធ្វើចំណាកស្រុកទៅកាន់ទីប្រជុំជន ដែលមានការរីកចម្រើន និងអភិវឌ្ឍន៍ល្អប្រសើរជាង[60]។

#### ២.៥.៣.៤. បញ្ហាកង្វះដីធ្វើស្រែចម្ការ

បញ្ហាកង្វះដី គឺជាមូលហេតុមួយក្នុងមូលហេតុចម្បងជាច្រើន ដែលបង្ខំឲ្យប្រជាពលរដ្ឋសម្រេចចិត្តធ្វើការចំណាកស្រុក។ ដោយសារតែកង្វះខាតដីធ្វើស្រែចម្ការនេះហើយ បានធ្វើឲ្យជីវភាពរបស់ពួកគាត់ជួបប្រទះនឹងការលំបាក ដោយគ្មានការងារធ្វើ និងមិនអាចរកប្រាក់ចំណូលគ្រប់គ្រាន់ ដើម្បីមកផ្គត់ផ្គង់គ្រួសារបាន។ ជាទូទៅ គ្រួសារដែលមានដីស្រែតិចជាងមួយហិចតាមានរហូតទៅដល់ ៩៦១ គ្រួសារនៅក្នុងឆ្នាំ ២០១៥ ហើយគ្រួសារដែលគ្មានដីស្រែផ្ទាល់ខ្លួនមានចំនួន ៦៣ គ្រួសារ[61]។

### ២.៥.៤. ដំណោះស្រាយក្នុងការកាត់បន្ថយចំណាកស្រុក

#### ២.៥.៤.១. គោលនយោបាយអភិវឌ្ឍន៍ឃុំប្រសាទបន្តឆ្នាំ ២០១៧-២០២២

គោលនយោបាយអភិវឌ្ឍន៍ឃុំប្រាសាទឆ្នាំ ២០១៧-២០២២ នេះ មានគោលដៅជាច្រើន ដែលក្នុងនោះគោលដៅទាំងនេះ ក៏អាចជួយដោះស្រាយបញ្ហាចំណាកស្រុកនៅក្នុងឃុំបានផងដែរ។ គោលដៅនៃការអភិវឌ្ឍនេះរួមមាន៖

- ខិតខំយកចិត្តទុកដាក់លើកកម្ពស់ ប្រជាធិបតេយ្យ នៅភូមិដ្ឋាន និងសិទ្ធិសេរីភាពរបស់ប្រជាជនគ្រប់ៗរូប ប្រជាជនរស់នៅដោយភាពសុខដុមរមនាគ្មានការបែងចែកនិន្នាការនយោបាយ អតីតកាល ភេទ ជំនឿ សាសនា ដើមកំណើត ជាតិ និងឋានៈក្នុងសង្គមឡើយ ។
- ឃុំត្រូវផ្តោតទៅលើការអភិវឌ្ឍន៍ សេដ្ឋកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។
- ឃុំត្រូវមានហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍គ្រប់គ្រាន់ និងល្អ។
- ឃុំត្រូវមានសន្តិសុខស្បៀង សន្តិសុខទឹក និងសន្តិសុខថាមពលអគ្គសនី។
- ឃុំត្រូវផ្តល់សេវាសង្គមនានា ជូនដល់ប្រជាជនបានឆាប់រហ័សប្រកបដោយ គុណភាព តម្លាភាព ជឿទុកចិត្ត។

[60] ដកស្រង់ចេញពីកិច្ចសម្ភាសន៍ជាមួយមេឃុំប្រាសាទ លោក លឹម ផេង

[61] ដកស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ ទំព័រទី ១២

- ឃុំខិតខំលើកកម្ពស់ ស្ថានភាពរស់នៅរបស់ស្ត្រី កុមារ ជនពិការ ចាស់ជរា និងក្រុមងាយរងគ្រោះផ្សេងៗទៀត ។
- ឃុំត្រូវមានភាពជាដៃគូដ៏ប្រសើរ ជាមួយសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន។
- ខិតខំលើកកម្ពស់ សុចរិតភាព ភាពស្អាតស្អំ គ្មានអំពើពុករលួយ និងគ្មានការរំលោភអំណាច។
- ឃុំត្រូវធានាដល់សន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម[62]។

### ២.៥.៤.២. ការបណ្តុះបណ្តាលទិដ្ឋាជីវៈជូនដល់ប្រជាពលរដ្ឋ

ក្រៅពីគោលនយោបាយអភិវឌ្ឍន៍ឃុំខាងលើ ដំណោះស្រាយមួយទៀតដែលអាចកាត់បន្ថយចំណាកស្រុកបាននោះគឺ ការចុះបង្ហាត់បង្រៀន និងបណ្តុះបណ្តាលដល់ប្រជាជននូវការធ្វើកសិកម្មតាមបច្ចេកទេសតាមរយៈ ការចេះបង្កើតជីធម្មជាតិ ឬជីសរីរាង្គដោយខ្លួនឯង ដែលចំណាយតិច តែទទួលបានទិន្នផលខ្ពស់ ទោះបីជាដីស្រែរបស់ពួកគាត់មានទំហំតូចក៏ដោយ និងអាចបង្កបង្កើនផលបាន ២ ឬ ៣ ដងក្នុង ១ ឆ្នាំ ទោះបីក្នុងរដូវប្រាំង។ ម៉្យាងទៀត ការបង្រៀនឲ្យប្រជាពលរដ្ឋយល់ដឹងអំពីការគ្រប់គ្រងផ្នែកសេដ្ឋកិច្ចគ្រួសារក៏មានការចាំបាច់ផងដែរ ដូចជាការគ្រប់គ្រងចំណូល-ចំណាយជាដើម។ ក្រៅពីការងារកសិកម្ម ដំណាំដាំដុះ ការបណ្តុះបណ្តាលបន្ថែមលើកសិកម្មចិញ្ចឹមសត្វគួរតែបានធ្វើឡើង ដើម្បីបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគាត់ ដែលអាចជួយសម្រួលដល់ជីវភាពគ្រួសារឲ្យមានភាពល្អប្រសើរឡើងផងដែរ។ មានអង្គការស្ម័គ្រចិត្ត ឬអង្គការក្រៅរដ្ឋាភិបាលនានាបាននឹងកំពុងបន្តខិតខំស្វែងរកវិធីសាស្ត្រផ្សេងៗ ដើម្បីជួយដោះស្រាយជីវភាពដល់ប្រជាជនក្រីក្រទាំងឡាយ តាមរយៈការបណ្តុះបណ្តាលខាងលើនេះ ក្នុងគោលដៅបង្កើតមុខរបរក្នុងស្រុកជូនដល់ប្រជាជន ដែលអាចកាត់បន្ថយបញ្ហាចំណាកស្រុកផងដែរ។

### ២.៥.៤.៣. ការទាក់ទាញវិនិយោគិន

ដោយមើលឃើញពីបញ្ហាកង្វះការងារនៅក្នុងឃុំប្រាសាទ នៅតែមានសន្ទុះកើនឡើងជាលំដាប់ ឃុំ និងរដ្ឋាភិបាល ទាំងថ្នាក់ក្រោមជាតិ និងថ្នាក់លើជាតិ បានព្យាយាមស្វែងរកដៃគូ

[62] ដកស្រង់ចេញពីរបាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ ទំព័រទី ១៣

ពាណិជ្ជកម្ម ដើម្បីមកបណ្ដាក់ទុន ដូចជាការបង្កើតរោងចក្រ ក្រុមហ៊ុន តំបន់សេដ្ឋកិច្ចពិសេស -ល-។ សព្វថ្ងៃ ឃុំប្រាសាទបានខិតខំយកចិត្តទុកដាក់ដើម្បីពង្រីក និងពង្រឹងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ សំដៅទាក់ទាញអ្នកវិនិយោគ ជាពិសេសផ្លូវថ្នល់ ស្ពាន ទឹក ភ្លើង ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងការដឹកជញ្ជូន។ ដូចគ្នានេះដែរ ក្រុមប្រឹក្សាឃុំ និងសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ក៏បាននឹងកំពុងខិតខំប្រឹងប្រែងរក្សាសន្តិសុខ និងសណ្ដាប់ធ្នាប់ក្នុងភូមិ-ឃុំ កាត់បន្ថយអំពើចោរកម្ម លួច ឆក់ ប្លន់ ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន។ បន្ថែមពីលើនេះទៅទៀត ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ ក៏បានបង្កើត និងរៀបចំគម្រោងអភិវឌ្ឍន៍ផ្សេងៗជាច្រើនដែលអាចទាក់ទាញដល់អ្នកវិនិយោគទុនមកបណ្ដាក់ទុននៅក្នុងឃុំប្រាសាទ ដូចដែលយើងខ្ញុំបានរៀបរាប់នៅក្នុងក្របខ័ណ្ឌវិនិយោគ និងគម្រោងវិនិយោគរបស់ឃុំប្រាសាទខាងលើនេះ។

ដំណោះស្រាយមួយទៀតនោះ គឺការបែងចែកក្រុមព្រឹក្សាភូមិ-ឃុំ ដើម្បីតាមដានសកម្មភាព ឬបញ្ហាមិនប្រក្រតីមួយចំនួន ដូចជាបញ្ហាវិវាទដីធ្លី ឬបញ្ហាជម្លោះផ្សេងៗ ដើម្បីងាយស្រួលស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងមូលដ្ឋាននោះភ្លាមៗតែម្ដង[63]។

## ២.៦. សន្និដ្ឋាន

បន្ទាប់ពីការបង្ហាញខាងលើ យើងអាចទាញសេចក្ដីសន្និដ្ឋានបានថា ការធ្វើចំណាកស្រុកនៅក្នុងឃុំប្រាសាទ គឺជាបញ្ហាមួយដែលគួរឲ្យកត់សម្គាល់។ ស្ថានភាពអ្នកធ្វើចំណាកស្រុកនៅក្នុងឃុំប្រាសាទ មានទាំងការធ្វើចំណាកស្រុកស្វែងរកការងារធ្វើទាំងក្នុង និងក្រៅប្រទេស។ ទោះបីជាឃុំ និងរដ្ឋាភិបាលព្យាយាមខិតខំប្រឹងប្រែងរកវិធីសាស្ត្រ ដើម្បីកាត់បន្ថយបញ្ហាចំណាកស្រុកក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមជាច្រើន ដែលត្រូវការការដោះស្រាយ ដូចជាបញ្ហានិកម្មភាព បញ្ហាបម្រែបម្រួលអាកាសធាតុ បញ្ហាកង្វះថវិកាសម្រាប់ការអភិវឌ្ឍភូមិ-ឃុំ និងបញ្ហាកង្វះដីធ្វើស្រែចម្ការ។ ទន្ទឹមនឹងបញ្ហាដែលបានជួបប្រទះខាងលើ ឃុំក៏សម្រេចបានភាពជោគជ័យក្នុងការកាត់បន្ថយបញ្ហាចំណាកស្រុកបានប្រសើរជាងមុនដែរ។ ភាពជោគជ័យ ដែលសម្រេចបានកន្លងមកនេះ គឺការអភិវឌ្ឍឲ្យប្រសើរឡើងនៃវិស័យផ្សេងៗ រួមមាន វិស័យសេដ្ឋកិច្ច វិស័យអប់រំ វិស័យសុខាភិបាល វិស័យគមនាគមន៍ វិស័យធារាសាស្ត្រ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត និងវិស័យសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ។ ក្រោមការអភិវឌ្ឍ និងការជួយជ្រោមជ្រែងពីសំណាក់មេភូមិ និងមេឃុំលើវិស័យទាំងអស់នេះ គេសង្កេតឃើញថា ភាពក្រីក្រត្រូវបានកាត់បន្ថយ ចំនួនមនុស្សធ្វើចំណាកស្រុកក៏មានតិចជាងមុន ដែលទាំងអស់នេះសបញ្ជាក់ឲ្យឃើញពីសកម្មភាពវិជ្ជមានក្នុងការ

[63] ដកស្រង់ចេញពីកិច្ចសម្ភាសន៍ជាមួយមេឃុំប្រាសាទ លោក លឹម ផេង

កាត់បន្ថយចំណាកស្រុករបស់ឃុំ។ ចំពោះបញ្ហាប្រឈមទាំង ៤ ធំៗខាងលើ ឃុំមានដំណោះស្រាយ ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនោះដូចជា គោលនយោបាយអភិវឌ្ឍន៍ឃុំប្រសាទបន្តឆ្នាំ ២០១៧-២០២២ ដែលមាន ៩ ចំនុច ការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាពលរដ្ឋ ការទាក់ទាញវិនិយោគិន និងការបែងចែកក្រុមព្រឹក្សាភូមិ-ឃុំ ដើម្បីដោះស្រាយរាល់បញ្ហាជម្លោះផ្សេងៗជូនប្រជាពលរដ្ឋ សំដៅដល់ការអភិវឌ្ឍឃុំប្រាសាទទាំងមូលឲ្យមានភាពរីកចម្រើន និងដោះស្រាយបញ្ហាចំណាកស្រុកឲ្យមានប្រសិទ្ធិភាព។

# ជំពូកទី ៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

# ជំពូកទី ៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១ ស្ថានភាពទូទៅ

### ៣.១.១ អាយុ និងភេទរបស់ជនចំណាកស្រុក

ដ្យាក្រាមទី ៣.១ ការបែងចែកក្រុមអាយុ និងភេទរបស់ជនចំណាកស្រុកគិតជាភាគរយ




ដ្យាក្រាមខាងលើនេះ បានបង្ហាញអំពីចំនួនអាយុ និងភេទនៃប្រជាជនដែលធ្វើការចំណាកស្រុកទៅកាន់ទីប្រជុំជន និងក្រៅប្រទេស។ តាមរយៈការចុះសិក្សាស្រាវជ្រាវ និងស្រង់យកទិន្នន័យដោយផ្ទាល់ យើងបានរកឃើញថា ប្រជាជនដែលមានអាយុចាប់ពី ១៦ ដល់ ២០ ឆ្នាំ មានប្រមាណ ៩,៧% ដែលធ្វើការចំណាកស្រុក ក្នុងនោះមានស្ត្រីប្រមាណ ៦០% ផងដែរ។ ជនចំណាកស្រុកដែលស្ថិតនៅចន្លោះអាយុចាប់ពី ២១ ដល់ ២៥ ឆ្នាំ មាន ៣៧% ដែលមានស្រី ៥៥,២៦% ។ ចំណែកឯអ្នកចំណាកស្រុកដែលមានអាយុចាប់ពី ២៦ ដល់ ៣០ ឆ្នាំ មានប្រហែល ៣០% ក្នុងនោះមានស្ត្រីចូលរួមប្រមាណ ៣៥,៤៨% ហើយជនចំណាកស្រុកដែលមានអាយុ ៣១ ដល់ ៣៥ ឆ្នាំ មាន ១៤,៦% ខណៈដែលមានស្ត្រីចូលរួម ៣៣,៣៣%។ ក្រុមប្រជាជនចំណាកស្រុកដែលមានអាយុ ៣៦ ដល់ ៤០ ឆ្នាំ មានប្រមាណ ៥,៨% ក្នុងនោះមានស្ត្រី ១៦,៦៧% រីឯអ្នកធ្វើចំណាកស្រុកដែលមានអាយុលើសពី ៤០ ឆ្នាំ មាន ៣% ដែលក្នុងនោះមានស្ត្រី ៣៣,៣៣% បានចូលរួមផងដែរ។

តាមការបកស្រាយខាងលើ បានបង្ហាញឲ្យឃើញថា ក្រុមអាយុដែលបានធ្វើការចំណាកច្រើនជាងគេ គឺស្ថិតនៅអាយុចន្លោះពី ២១ ដល់ ២៥ ឆ្នាំ។ ហើយចំនួនស្ត្រីដែលមានអាយុពី ១៦

ដល់ ២៥ ឆ្នាំ គឺបានធ្វើការចំណាកស្រុកច្រើនជាងបុរស ផ្ទុយមកវិញ ចាប់ពីក្រុមអាយុ ២៦ ដល់ ៤០ ឆ្នាំ គឺបុរសមានចំនួនច្រើនជាងស្ត្រីវិញ។

### ៣.១.២ ស្ថានភាពគ្រួសាររបស់អ្នកចំណាកស្រុក

យោងការធ្វើបទសម្ភាសន៍ដោយផ្ទាល់ជាមួយ ទេសន្តរប្រវេសន៍ចំនួន ១០៣ រូប យើងឃើញថា គ្រួសារដែលមានសមាជិក ៥ នាក់ មាន ២៤,៣% ហើយគ្រួសារដែលមានសមាជិក ៤ នាក់ មាន ១៩,៤%។ ចំណែកឯគ្រួសារដែលមានសមាជិក ៣ នាក់ មាន ២០,៤% និង១៥,៥% ចំពោះគ្រួសារដែលមានអ្នកនៅក្រោមបន្ទុកចំនួន ៦ នាក់ ក្រៅពីនេះមានគ្រួសារតិចតួចដែលមានចំនួនសមាជិក ២ នាក់ ឬ ៧ នាក់ ឬ ៨ នាក់ ឬ ៩ នាក់ ឬ ១០នាក់។ មួយវិញទៀត យើងរកឃើញថាគ្រួសារដែលមានសមាជិក ២ នាក់ ជួយរកចំណូលផ្គត់ផ្គង់គ្រួសារមាន ៥៦,៣% រីឯគ្រួសារដែលមានអ្នករកចំណូលផ្គត់ផ្គង់តែម្នាក់មានត្រឹមតែ ១០,៧% ប៉ុណ្ណោះ។ គ្រួសារដែលមានអ្នកជួយរកចំណូល ៣ នាក់ មាន ២១,៤% ហើយ ៨,៧% សំរាប់គ្រួសារដែលមានអ្នករកចំណូល ៤ នាក់។ ចំណែកឯ គ្រួសារដែលមានអ្នករកចំណូលមកជួយគ្រួសារ ៥ នាក់ មាន ១,៩% និង ៧ នាក់ មាន ១%។ លើសពីនេះទៅទៀត យើងឃើញថាគ្រួសារដែលមានសមាជិក ២ នាក់ ធ្វើការចំណាកស្រុកមាន ៤៨,៥% និង ១ នាក់ មាន ៤០,៨%។ គ្រួសារខ្លះមានអ្នកចំណាកស្រុក ៣ នាក់ ឬ ៤ នាក់ ឬ ៥ នាក់ ឬ ៦ នាក់ ឬ ៧ នាក់ ដែលស្មើនឹងប្រមាណ ១០,៧%។

### ៣.១.៣ កម្រិតវប្បធម៌របស់អ្នកចំណាកស្រុក

**ដ្យាក្រាមទី ៣.២ ការបង្ហាញអំពីកម្រិតអប់រំរបស់អ្នកចំណាកស្រុកតាមភេទគិតជាភាគរយ**




ការសិក្សាអប់រំ គឺមានភាពចាំបាច់ណាស់សំរាប់បុគ្គលម្នាក់ៗ ប៉ុន្តែដោយសារតែលក្ខណ្ឌលំបាកផ្សេងៗ ក៏សម្រេចចិត្តបញ្ឈប់ការសិក្សា។ យោងតាមការចុះសម្ភាសន៍ យើងទទួលបានថា ប្រជាជនចំណាកស្រុកដែលរៀនបានត្រឹមថ្នាក់អនុវិទ្យាល័យមាន ៥៥,៣% ក្នុងនោះមានស្ត្រី

៤០,៤% ហើយថ្នាក់បឋមសិក្សាមាន ២៥,២% ដែលមានស្ត្រី ៦៥,៤%។ ចំណែកឯ អ្នកដែលរៀនត្រឹមថ្នាក់វិទ្យាល័យមាន ១៦,៥% ស្ត្រី ១៧,៧% ហើយថ្នាក់មហាវិទ្យាល័យមានបុរស ១%។ ស្ត្រីដែលធ្វើការចំណាកស្រុកដោយមិនចេះអក្សរមាន ១,៩%។

### ៣.១.៤. ប្រភពព័ត៌មាននៃការធ្វើចំណាកស្រុក

**តារាងទី ៣.១. ប្រភពព័ត៌មាននៃការធ្វើចំណាកស្រុកគិតជាភាគរយ**

| | |
|---|---|
| បងប្អូន | ៥៩,២% |
| មិត្តភក្តិ | ២២,៣% |
| អ្នកជិតខាង (ក្នុងភូមិ) | ១១,៧% |
| ការផ្សព្វផ្សាយតាមប្រព័ន្ធសង្គមផ្សេងៗ | ៦,៨% |

នៅក្នុងភូមិទាំង ៩ របស់ឃុំប្រាសាទនេះ អ្នកចំណាកស្រុកភាគច្រើនទទួលបានព័ត៌មានពីបងប្អូនញាតិមិត្តរបស់ខ្លួន ដែលមានរហូតទៅដល់ ៥៩,២%។ ២២,៣% ទៀតចាកចេញពីស្រុកតាមការណែនាំរបស់មិត្តភក្តិ ឬទៅតាមគ្នាជាក្រុម ជាពិសេសយុវជន និងយុវនារី។ ឯអ្នកជិតខាងក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ដំណឹងទាក់ទងនឹងការចំណាកស្រុកនេះផងដែរ ដោយពលរដ្ឋចំណាកស្រុក ១១,៧% ធ្វើការចំណាកស្រុកតាមរយៈដំណឹងរបស់អ្នកជិតខាង។ មានភាគតិចនៃប្រជាពលរដ្ឋចំណាកស្រុកប៉ុណ្ណោះ ដែលទទួលបានការផ្តល់ដំណឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗដូចជា វិទ្យុ ទូរទស្សន៍ និង Facebook ជាដើម។

### ៣.១.៥. រយៈពេលនៃការធ្វើចំណាកស្រុក

**ដ្យាក្រាមទី ៣.៣. ភាគរយនៃរយៈពេលធ្វើចំណាកស្រុក**




តាមរយៈដ្យាក្រាមទី ៣.៣ ខាងលើនេះ ប្រជាជនចំណាកស្រុកចាកចេញពីស្រុកកំណើតក្នុងអំឡុងពី ១ ទៅ ៣ ឆ្នាំ ដែលមានចំនួនច្រើនជាងគេរហូតទៅដល់ ៤៨,៦%។ ចំពោះអ្នកចំណាក

ស្រុកដែលមានបទពិសោធន៍ពី ៤ ទៅ ៦ ឆ្នាំ មាន ៣៣% អ្នកចាកចេញពីស្រុកយូរឆ្នាំពី ៧ ទៅ ១០ ឆ្នាំ មាន ១៤,៦% និងអ្នកដែលចាកចេញពីស្រុក ១២ ទៅ ១៩ ឆ្នាំ មាន ៣,៩%។ សូមបញ្ជាក់ថា អ្នកធ្វើចំណាកស្រុកទាំងនេះមិនមែនចាកចេញពីស្រុកកំណើតរហូតអស់រយៈពេលយូរយ៉ាងនេះទេ ប៉ុន្តែពួកគាត់តែងធ្វើដំណើរទៅមករវាងស្រុកកំណើត និងទីកន្លែងធ្វើការរបស់គាត់ នៅពេលចុងសប្តាហ៍ ចុងខែ ឬពេលបុណ្យជាតិផ្សេងៗ។

### ៣.១.៦. គោលដៅនៃការធ្វើចំណាកស្រុក

**តារាងទី ៣.២ គោលដៅនៃអ្នកធ្វើចំណាកស្រុកគិតជាភាគរយ**

| ចំណាកស្រុកនៅក្នុងប្រទេស | ចំណាកស្រុកទៅក្រៅប្រទេស |
|---|---|
| ៨២,៥% | ១៧,៥% |

តាមរយៈទិន្នន័យដែលស្រង់បានពីកម្រងសំណួរ ភាគច្រើននៃប្រជាជនតែងធ្វើចំណាកស្រុកនៅក្នុងស្រុកទេសរបស់ខ្លួន គ្រាន់តែឆ្ងាយពីស្រុកកំណើតរបស់ខ្លួនប៉ុណ្ណោះ។ ពួកគាត់ទាំងនោះ ៨២,៥% បានធ្វើដំណើរចេញពីស្រុកទៅស្វែងរកការងារនៅទីប្រជុំជនធំៗផ្សេងៗ ជាពិសេសទីក្រុងភ្នំពេញតែម្តង។ ចំណែក ប្រជាជន ១៧,៥% ដែលជាចំនួនតិចតួចប៉ុណ្ណោះ ដែលហ៊ានចាកឆ្ងាយពីស្រុកកំណើត ព្រមទាំងប្រទេសកំណើតខ្លួន ទៅកាន់ប្រទេសដទៃទៀត ក្នុងបំណងចង់ស្វែងរកការងារល្អ ប្រាក់ខែខ្ពស់ និងឱកាសផ្សេងៗក្នុងការសិក្សា និងឈានចូលទៅក្នុងពិភពលោកថ្មី ដែលអភិវឌ្ឍន៍ និងរីកចម្រើនជាងប្រទេសខ្លួន។

## ៣.២. ប្រភេទនៃការងារនៃអ្នកធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ

**តារាងទី ៣.៣ ប្រភេទការងារនៃអ្នកធ្វើចំណាកស្រុកក្នុងឃុំប្រាសាទគិតជាភាគរយ**

| | |
|---|---|
| ការងាររោងចក្រ | ៤៤,៧% |
| ការងារសំណង់ | ២៣,៣% |
| ការងារកសិកម្ម និងឧស្សាហកម្ម | ១០,៧% |
| អ្នកបម្រើតាមហាង | ៤,៩% |
| បើកឡាន និងត្រាក់ទ័រ | ៤,៩% |
| រត់ម៉ូតូឌុប ឬរ៉ឺម៉កកង់បី | ២,៩% |
| អ្នកលក់ដូរ | ១,៩% |
| ផ្សេងៗ | ៦,៨% |

មានការងារជាច្រើន ដែលទាក់ទាញប្រជាជនចំណាកស្រុកនៅក្នុងឃុំប្រាសាទឲ្យចាកចេញឆ្ងាយពីស្រុកកំណើត។ យោងតាមការចុះអង្កេតទិន្នន័យរបស់ក្រុមយើងខ្ញុំ បានរកឃើញថាការងារទាំងនោះរួមមាន ការងារជាកម្មកររោងចក្រមាន ៤៥% ការងារជាកម្មករសំណង់មាន ២៣,៣% ការងារផ្នែកកសិកម្ម និងឧស្សាហាកម្ម ១០,៧% អ្នកបម្រើតាមហាង ឬតាមផ្ទះ ៤,៩% ការងារជាអ្នកបើកឡាន និងត្រាក់ទ័រ ៤,៩% ការងារជាអ្នករត់ម៉ូតូឌុប ឬរ៉ឺម៉កកង់បីមាន ២,៩% ការងារជាអ្នកលក់ដូរមាន ១,៩% និងការងារផ្សេងៗទៀត ៦,៨ % ជាអ្នកធ្វើការងារសិប្បកម្មគ្រឿងជ័រ ជាងឈើ ឬដែក ការងាររដ្ឋ ឬក្រុមហ៊ុនផ្សេងៗ សន្តិសុខ -ល- ដែលទាំងអស់នេះ ជាទិន្នន័យស្រង់ពីក្នុងចំណោមប្រជាជនចំនួន ១០៣ នាក់នៃចំនួនប្រជាជនចំណាកស្រុកក្នុងភូមិទាំង ៩ ក្នុងឃុំប្រាសាទ។

## ៣.៣. មូលហេតុនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទ

**តារាងទី ៣.៤ មូលហេតុនៃការធ្វើចំណាកស្រុកក្នុងឃុំប្រាសាទគិតជាភាគរយ**

| | |
|---|---|
| ជីវភាពលំបាក | ៧៨,៦% |
| កង្វះការងារ | ៦៧% |
| កង្វះដីធ្លី | ២៩,១% |
| សន្សំលុយ និងរកចំណូលបន្ថែម | ១៦,៥% |
| មុខរបរមិនកាក់កប | ៧,៨% |
| ចង់មានសេរីភាព | ៦,៨% |
| ចង់ទទួលបានបទពិសោធន៍ការងារ | ១,៩% |
| រៀនមិនចូល | ១,៩% |
| បញ្ហាផ្សេងៗទៀត | ៦,៨% |

យោងទៅតាមតារាងខាងលើ បានបង្ហាញឲ្យឃើញថា បញ្ហាចំណាកស្រុកកើតឡើងដោយសារមូលហេតុមួយចំនួនដូចជា បញ្ហាជីវភាពលំបាកមាន ៧៨,៦% បញ្ហាកង្វះការងារ ៦៧% បញ្ហាកង្វះដីធ្លីធ្វើស្រែចម្ការ ២៩,១% ការចង់សន្សំលុយ និងរកចំណូលបន្ថែមដើម្បីជួយគ្រួសារមាន ១៦,៥% បញ្ហាមុខរបរមិនកាក់កប ៧,៨% បញ្ហាការចង់ទទួលបាននូវសេរីភាព ៦,៨% ការចង់ទទួលបានបទពិសោធន៍ការងារថ្មីមាន ១,៩% អ្នករៀនមិនចូលមាន ១,៩% និងបញ្ហាផ្សេងៗ ៦,៨% ទៀត។

### ៣.៣.១. ជីវភាពលំបាក

ដូចដែលបានបញ្ជាក់ពីក្នុងជំពូកទី ២ មកហើយថា ប្រជាជនភាគច្រើននៅក្នុងឃុំនេះស្ទើរ ៨០% មានមុខរបរជាអ្នកធ្វើស្រែចម្ការ។ ប៉ុន្តែ បញ្ហាអាកាសធាតុក្តៅហួតហែងខ្លាំង បណ្តាលឲ្យប្រជាជននៅក្នុងភូមិ-ឃុំជួបលំបាកនឹងផលលំបាកជាច្រើន។ ម្យ៉ាងទៀត ប្រព័ន្ធទឹកដូចជាប្រឡាយទឹកផ្សេងៗនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ រីឯប្រភពទឹកដូចជាត្រពាំង បឹង ស្ទឹង ទន្លេ ក៏ស្ងួតហួតហែងនៅរដូវប្រាំង និងនៅឆ្ងាយពីផ្ទះប្រជាជន។ មូលហេតុទាំងអស់នេះ នាំឲ្យពួកគាត់មានការលំបាកក្នុងការធ្វើកសិកម្ម នាំឲ្យទិន្នផលថយចុះ ឬមិនអាចធ្វើកសិកម្មបានតែម្តង។ ដូច្នេះ ប្រជាជនទាំងនោះនឹងជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារ ដោយសារតែពួកគាត់មិនមានប្រាក់ចំណូល ហើយប្រាក់ដែលពួកគាត់បានប្រើប្រាស់ជាដើមទុនក្នុងការធ្វើកសិកម្មក៏ត្រូវខាតបង់ថែមទៀតផង។ បន្ថែមពីលើនេះទៅទៀត កសិករមួយចំនួនធំតែងខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ ធនាគារ ឬអ្នកចងការប្រាក់ផ្សេងៗ មកធ្វើជាមូលធនក្នុងការធ្វើកសិកម្ម ជាពិសេសចំណាយទៅលើគ្រាប់ពូជ ជី និងការចំណាយផ្សេងៗទៀត។ ដោយសារតែទិន្នផលកសិកម្មទាប ម្យ៉ាងទីផ្សារកសិផលក៏ផ្តល់តម្លៃឲ្យកសិករផងនោះ កសិករមួយចំនួនមានការខាតបង់ធំធេង ព្រមទាំងជំពាក់បំណុលគេ គ្មានប្រាក់សងថែមទៀត។ បញ្ហាទាំងអស់នេះ បានធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងសភាពក្រីក្រ រកព្រឹកខ្វះល្ងាច និងសម្រេចចិត្តធ្វើចំណាកស្រុក។

### ៣.៣.២. កង្វះការងារ

បញ្ហាកង្វះការងារ គឺជាបញ្ហាចម្បងទី ២ បន្ទាប់ពីបញ្ហាជីវភាពលំបាក ដែលធ្វើឲ្យប្រជាជនបង្ខំចិត្តធ្វើចំណាកស្រុក។ តាមរយៈការចុះអង្កេតដោយផ្ទាល់ យើងសង្កេតឃើញថា ប្រជាជនជាច្រើនពុំមានការងារធ្វើក្រៅពីការប្រកបរបរកសិកម្មនោះឡើយ។ នេះដោយសារតែ ការអភិវឌ្ឍនៅមានកម្រិត ទាំងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា គមនាគមន៍ សាលារៀន មន្ទីរពេទ្យ និងប្រព័ន្ធធារាសាស្ត្រ ដែលបណ្តាលឲ្យអ្នកវិនិយោគមិនមានចំណាប់អារម្មណ៍ចង់មកបណ្តាក់ទុនវិនិយោគនៅក្នុងតំបន់នេះ។ ការងារកសិកម្មមិនទទួលបានផលចំណេញ ឯការងារក្នុងស្រុកភូមិក៏មានមិនគ្រប់គ្រាន់ ប្រជាជនមួយចំនួន ដែលជួបបញ្ហាលំបាកនេះ បាននាំគ្នាធ្វើចំណាកស្រុកចេញពីស្រុកភូមិ ដើម្បីស្វែងរកការងារធ្វើនៅឯទីក្រុង ឬទីប្រជុំជនផ្សេងៗ ដែលមានការអភិវឌ្ឍប្រសើរជាង សង្ឃឹមថានឹងទទួលបានការងារល្អ និងជួយធ្វើឲ្យជីវភាពខ្លួនឯង ព្រមទាំងក្រុមគ្រួសារមានភាពប្រសើរឡើង។

### ៣.៣.៣. ការខ្វះដីធ្លីធ្វើស្រែចម្ការ

ការខ្វះខាតដីធ្លីសម្រាប់ធ្វើស្រែចម្ការ ក៏ជាមូលហេតុដែលនាំឲ្យប្រជាជនធ្វើចំណាកស្រុកផងដែរ។ ដោយសារតែមានដីតិចតួច ការធ្វើកសិកម្ម (ស្រូវ) បានត្រឹមតែហូប ហើយមានទិន្នផលសម្រាប់លក់តិចតួច ជាហេតុនាំឲ្យពួកគាត់ពុំមានលទ្ធភាពក្នុងការផ្គត់ផ្គង់គ្រួសារ។ តាមបទសម្ភាសន៍ជាក់ស្តែង ប្រជាជនភាគច្រើនមានដីត្រឹមតែ ៤ ទៅ ៥ A ឬកន្លះហិចតា សម្រាប់ធ្វើស្រែចម្ការតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយទើប ពួកគាត់ទទួលបានទិន្នផលកសិកម្មតិចតួច ហើយអ្នកខ្លះទៀតធ្វើស្រែមិនគ្រប់ហូបផង។ លើសពីនេះទៅទៀត ប្រជាជនមួយចំនួនបានលក់ដីស្រែចម្ការរបស់ខ្លួនអស់ ដើម្បីមើលជម្ងឺខ្លួនឯង ក៏ដូចជាឪពុក ម្តាយ ជីដូន ជីតា ចាស់ជរា ដើម្បីបានប្រាក់ព្យាបាល។ ក្រោយពីពុំមានដីសម្រាប់ធ្វើស្រែចម្ការ ជម្រើសរបស់គាត់ គឺមានតែការចាកចេញពីស្រុកដើម្បីស្វែងរកការងារផ្សេងៗធ្វើ។

### ៣.៣.៤. សន្សំលុយ និងរកចំណូលបន្ថែម

ប្រជាជនដែលធ្វើការចំណាកស្រុកមួយចំនួនបានលើកឡើងថា ការធ្វើស្រែចម្ការពុំអាចផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់បានទេ ហេតុដូច្នេះហើយ បានជាពួកគាត់ចេញទៅរកការងារធ្វើដើម្បីទទួលបានកម្រៃបន្ថែមទៀត។ម្យ៉ាងវិញទៀត អ្នកដែលមានភាពខ្វះខាត ក៏សម្រេចចិត្តចាកចោលស្រុករកចំណូលបន្ថែម ដើម្បីជួយផ្គត់ផ្គង់ក៏ដូចជាលើកកម្ពស់ជីវភាពគ្រួសារឲ្យកាន់តែប្រសើរឡើង។ រីឯយុវជន-យុវនារី ក្មេងៗមួយចំនួនទៀត ចាកចោលស្រុក ដើម្បីទៅធ្វើការសន្សំលុយ ក្នុងគោលបំណងរកដើមទុនមកចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន និងដោយសារតែការងារនៅទីក្រុង ឬទីប្រជុំជនផ្តល់ឲ្យនូវប្រាក់កម្រៃច្រើនជាងនៅជនបទ។

### ៣.៣.៥. មុខរបរមិនរកាក់ទាក់

ការប្រកបរបរមិនសមដូចប្រាថ្នា ជាពិសេសការប្រកបរបរកសិកម្ម ក៏ជាកត្តាមួយដែលជម្រុញឲ្យពួកគាត់ធ្វើចំណាកស្រុកផងដែរ។ ទិន្នផលកសិកម្មទាប ទីផ្សារកសិផលមានតម្លៃថោក រីឯទំនិញ ដែលត្រូវការប្រើប្រាស់សព្វថ្ងៃរួមមាន ម្ហូបអាហារ ថ្នាំពេទ្យ សម្លៀកបំពាក់ជាដើម និងការចំណាយទៅលើថ្លៃដើមក្នុងការផលិតមានតម្លៃខ្ពស់។ ជាក់ស្តែង តម្លៃទីផ្សារសត្វជ្រូកនៅក្នុងឆ្នាំ ២០១៨ នេះ ពុំអាចប្រកួតប្រជែងជាមួយនឹងតម្លៃជ្រូកនាំចូលពីប្រទេសជិតខាង ដែលបណ្តាលឲ្យពួកគាត់អស់ទឹកចិត្តនឹងតស៊ូបន្តអាជីវកម្មរបស់ខ្លួន ហើយប្តូរទៅជាធ្វើការ ឬស៊ីឈ្នួលឲ្យគេ ដើម្បីទទួលបានចំណូលផ្គត់ផ្គង់គ្រួសារវិញម្តង។ មិនត្រឹមតែប៉ុននេះ ការលក់ដូរនៅក្នុងភូមិ-

ឃុំក៏ពុំសូវមានភាពកាក់កបល្អប្រសើរដែរ ដោយសារតែប្រជាជនភាគច្រើនចេញទៅស្វែងរកការងារនៅក្រៅស្រុកអស់ហើយ។

**៣.៣.៦. ចង់មានសេរីភាព**

ដោយសារតែការចង់រស់នៅជាមួយភាពឯករាជ្យ និងចង់ដើរហើរទៅប្រភពខាងក្រៅផងនោះ ពួកគាត់ខ្លះក៏សម្រេចចិត្តធ្វើការចំណាកស្រុកដែរ។ យុវជន-យុវនារីមួយចំនួនចាកចេញពីស្រុកកំណើតដោយសារតែការចង់ទទួលបានសេរីភាព និងរស់នៅឯករាជ្យដោយខ្លួនឯង ពោលគឺរៀនរស់ដោយខ្លួនឯង មិនពឹងផ្អែកលើគ្រួសារ ក៏ដូចជាអ្នកដទៃ។

**៣.៣.៧. ចង់ទទួលបានបទពិសោធន៍ការងារ**

ការចង់ដឹង ចង់ស្គាល់ ចង់ទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មី ក៏ជាកត្តាដែលបណ្ដាលឲ្យមានការធ្វើចំណាកស្រុកដែរ។ អ្នកធ្វើចំណាកស្រុកខ្លះយល់ឃើញថា ការទៅស្វែករកការងារធ្វើនៅខាងក្រៅស្រុកបានធ្វើឲ្យពួកគាត់អាចទទួលបាននូវអ្វីៗ ដែលថ្មី ទាំងបទពិសោធន៍ការងារ និងការរស់នៅផងដែរ។

**៣.៣.៨. រៀនមិនចូល**

បងប្អូនចំណាកស្រុកមួយចំនួនបាននិយាយថា ពួកគាត់ធ្វើចំណាកស្រុកដោយសារគាត់រៀនមិនចូល រៀនមិនចេះ ហើយក៏សម្រេចចិត្តឈប់រៀនតែម្ដងទៅ។ បន្ទាប់ពីការបោះបង់ការសិក្សាចោលហើយ ពួកគាត់ក៏បានសម្លឹងមើលឃើញការងារនៅឯទីប្រជុំជន ដើម្បីទទួលបានប្រាក់កកម្រៃមកបំពេញតម្រូវការរបស់ពួកគាត់។

**៣.៣.៩. បញ្ហាផ្សេងៗទៀត**

ក្រៅពីបញ្ហាដែលបានរៀបរាប់ខាងលើ ក៏មានបញ្ហាផ្សេងៗ ទៀត រួមមាន ការជួបប្រទះនឹងគ្រោះធម្មជាតិ ការសម្រេចទៅតាមបងប្អូន និងមិត្តភក្ដិ ការមិនទទួលបានប្រាក់ចំណេញពីការងារកសិកម្មពីព្រោះផលិតផលកសិកម្មមានតម្លៃទាប ចំណែកឯអ្នកមួយចំនួនក៏ផ្លាស់ទៅធ្វើការនៅតំបន់ផ្សេងដោយសារតែពួកគាត់ប្រឡងជាប់ជាមន្ត្រីរាជការ -ល-។

**៣.៤. ផលប៉ះពាល់នៃការធ្វើចំណាកស្រុកនៅក្នុងឃុំប្រាសាទ**

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក យើងសង្កេតឃើញថា ការធ្វើចំណាកស្រុកផ្ដល់ផលវិជ្ជមាន និងអវិជ្ជមានជាច្រើនដល់អ្នកធ្វើចំណាកស្រុក ក៏ដូចជាក្រុមគ្រួសាររបស់ពួកគាត់។

**៣.៤.១. ផលវិជ្ជមាន**

តាមរយៈបទសម្ភាសន៍ជាមួយនឹងប្រជាពលរដ្ឋក្នុងឃុំប្រាសាទ ការធ្វើចំណាកស្រុក

ផ្តល់អត្ថប្រយោជន៍មួយចំនួនជូនទៅដល់ពួកគាត់ ជាពិសេសគឺអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច។

### ៣.៤.១.១. ស្ថានភាពជីវភាពប្រជាជន

**ដ្យាក្រាមទី ៣.៤ ជីវភាពប្រជាជនមុនធ្វើចំណាកស្រុក**




តាមរយៈកិច្ចសម្ភាសន៍ដោយផ្ទាល់ជាមួយប្រជាជននៃឃុំប្រាសាទ និងតាមរយៈការបង្ហាញរបស់ដ្យាក្រាម ៣.៤ ខាងលើ មុនពេលធ្វើចំណាកស្រុក ប្រជាពលរដ្ឋដែលមានជីវភាពក្រខ្សត់ពោលគឺប្រជាពលរដ្ឋដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ (មានប្រាក់ចំណូលតិចជាង ៣ ៨៧១ រៀល) មាន ១៤,៦% ហើយជាងពាក់កណ្តាលនៃប្រជាពលរដ្ឋស្មើនឹង ៥៦,៣% មានជីវភាពក្រីក្រ រីឯ ២៩,១% ទៀតជាប្រជាពលរដ្ឋដែលមានជីវភាពមធ្យម។ ចំណែកឯប្រជាពលរដ្ឋដែលមានជីវភាពមានបានវិញ បទសម្ភាសន៍យើងខ្ញុំមិនបានជួបប្រជាពលរដ្ឋដែលមានជីវភាពធូរធារ ហើយធ្វើការចំណាកស្រុកនោះទេ។

**ដ្យាក្រាមទី ៣.៥ ជីវភាពប្រជាជនក្រោយពេលធ្វើចំណាកស្រុក**




ក្រោយពីការធ្វើចំណាកស្រុក យើងសង្កេតឃើញថា ប្រជាពលរដ្ឋមួយភាគធំមានជីវភាពល្អប្រសើរជាងមុន ទោះបីជាប្រជាពលរដ្ឋមួយចំនួនអះអាងថា ពួកគាត់ទទួលបានប្រាក់ចំណូលច្រើនជាងមុនតែបន្តិចប៉ុណ្ណោះ បើប្រៀបធៀបមុនពេល និងក្រោយពេលពួកគាត់ធ្វើចំណាក

ស្រុក។ ដ្យាក្រាម ៣.៥ ខាងលើនេះ បង្ហាញថា ប្រជាពលរដ្ឋ ៧៣,៨% ទទួលបានជីវភាពប្រសើរឡើង ក្រោយពេលដែលពួកគាត់ចាកចេញពីស្រុកទៅរកការងារផ្សេងៗនៅទីប្រជុំជននានាពិសេសភ្នំពេញ និងប្រទេសក្រៅ ពីព្រោះពួកគាត់មួយចំនួនទទួលបានប្រាក់ខែច្រើនជាងមុន ហើយមួយចំនួនទៀតដែលមិនធ្លាប់មានប្រាក់ចំណូលទាល់តែសោះ (យុវជន យុវនារី ដែលនៅសិក្សា) ក្រោយពេលទទួលបានការងារនៅក្រៅស្រុកកំណើត ពួកគេអាចយកប្រាក់ចំណូលដែលខ្លួនរកបាននោះមកជួយផ្គត់ផ្គង់គ្រួសារ ព្រមទាំងកាត់បន្ថយចំណាយក្នុងគ្រួសារ។ ចំពោះប្រជាពលរដ្ឋ ២៥,២% បានត្អូញត្អែរថា ពួកគាត់នៅតែមានជីវភាពលំបាកដដែល ទោះបីជាក្រោយពេលគាត់ធ្វើចំណាកស្រុកក៏ដោយ។ នេះដោយសារតែ ពួកគាត់មួយចំនួនទទួលបានការងារមិនសូវល្អ មួយចំនួនទៀតត្រូវចំណាយលើថ្លៃម្ហូបអាហារ ថ្លៃទឹកភ្លើង និងថ្លៃផ្ទះជួលអស់ច្រើន ដែលស្ទើរតែមិនសល់លុយប្រាក់ខែ។ ម៉្យាងទៀត ១% ទៀត បានលើកឡើងថា គាត់មានជីវភាពកាន់តែដុនដាបជាងមុនក្រោយពេលធ្វើចំណាកស្រុក ដោយហេតុថា ពួកគាត់មួយចំនួនបានចាញ់បោកជនខិលខូច ឬមិនទទួលបានប្រាក់ខែនៅចុងខែ ព្រោះថៅកែរត់ចោល ឬមិនបើកឲ្យ -ល-។

#### ៣.៤.១.២. ចំណេះដឹង និងបទពិសោធន៍

យោងតាមទិន្នន័យដែលបានដកស្រង់ចេញពីការសម្ភាសន៍ ប្រជាពលរដ្ឋ ៨៧,៥% បានបញ្ជាក់ថា ក្រោយពីពួកគាត់ចាកចេញពីស្រុក ពួកគាត់មិនត្រឹមតែទទួលបានប្រាក់ខែសមរម្យនោះទេ ប៉ុន្តែពួកគាត់ថែមទាំងទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗ និងប្លែកៗ តាមរយៈការសង្កេត ការបង្ហាត់បង្រៀន និងបង្ហាញផ្លូវពីរបៀបរបបនៃការងារពីអ្នកជំនាញថែមទៀតផង។ ច្រើនជាងនេះទៅទៀត ពួកគាត់បានយល់ដឹងអំពីបទពិសោធន៍ជីវិតក្នុងការរស់នៅ និងការចូលរួមក្នុងសង្គមខាងក្រៅរួមមាន ការចេះគិតគូរពិចារណាបានវែងឆ្ងាយ ការចេះសម្របខ្លួនទៅតាមស្ថានភាព និងកាលៈទេសៈ ការប្រើប្រាស់ពាក្យពេជន៍ និងអាកប្បកិរិយាផ្សេងៗឲ្យបានសមរម្យ ការចេះសម្រេចចិត្តដោយខ្លួនឯង និងការចេះដោះស្រាយបញ្ហានានាជាដើម។

### ៣.៤.២. ផលអវិជ្ជមាន

ក្រៅពីផលវិជ្ជមានខាងលើនេះ ការធ្វើចំណាកស្រុកក៏បានផ្តល់គុណវិបត្តិជាច្រើនដល់ប្រជាពលរដ្ឋចំណាកស្រុក និងក្រុមគ្រួសារគាត់ផងដែរ។

**តារាងទី ៣.៥ ផលអវិជ្ជមាននៃការធ្វើចំណាកស្រុកគិតជាភាគរយ**

| | |
|---|---|
| នឹកផ្ទះ និងគ្រួសារ | ៦៣,១% |
| ការងារមានភាពពិបាក | ៥៧,៣% |

| | |
|---|---|
| មិនមានសុវត្ថិភាព | ២៦.២% |
| របៀបរបបនៃការរស់នៅ | ១៦,៥% |
| បញ្ហាម្ហូបអាហារ | ១៨,៦% |
| តម្លៃទឹក, ភ្លើង, ផ្ទះ | ៩,៧% |
| ថៅហ្វាយស្ដីបន្ទោស | ២,៩% |
| បញ្ហាសុខភាព | ២,៩% |
| បញ្ហានៃការបើកប្រាក់ខែ | ១,៩% |
| មិនមានបញ្ហាពិបាក | ២,៩% |
| ផ្សេងៗ | ៤,៩% |

### ៣.៤.២.១. នឹកផ្ទះ និងគ្រួសារ

តាមរយៈការលើកឡើងរបស់ប្រជាជនដែលធ្វើចំណាកស្រុកប្រមាណ ៦៣,១% គាត់បាននិយាយថា ការរស់នៅ និងធ្វើការងារឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងផ្ទះសម្បែងរបស់ខ្លួន ធ្វើឲ្យពួកគាត់ជួបការលំបាកយ៉ាងខ្លាំង ពីព្រោះពួកគាត់តែងតែនឹករលឹក និងព្រួយបារម្ភពីសុខទុក្ខរបស់ក្រុមគ្រួសារ ជាពិសេសអ្នកដែលមានឪពុកម្ដាយចាស់ជរា និងកូនតូចៗនៅឯផ្ទះ។ ការឃ្លាតឆ្ងាយបែបនេះ ធ្វើឲ្យពួកគាត់ពុំបានផ្ដល់ភាពកក់ក្ដៅដល់គ្រួសាររបស់ពួកគាត់។

### ៣.៤.២.២. ការងារមានភាពពិបាក

ការត្អូញត្អែររបស់ប្រជាជនប្រមាណ ៥៧,៣% បានប្រាប់ថាការងារដែលពួកគាត់ធ្វើមានច្រើនលើសលប់ពីសមត្ថភាព និងកម្លាំងរបស់ពួកគាត់ ដែលធ្វើឲ្យពួកគាត់មានភាពហត់នឿយជាខ្លាំងក្នុងការធ្វើការងារប្រចាំថ្ងៃ។ ម្យ៉ាងវិញទៀត ពួកគាត់ថែមទាំងត្រូវថៅកែ ឬថៅហ្វាយនាយស្ដីបន្ទោស ក្រៅពីការខិតខំធ្វើការងារទាំងអស់នោះ។ ដូចគ្នានេះដែរ ពួកគាត់មួយចំនួនត្រូវបានថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្ម ដូចជាការបង្ខំឲ្យធ្វើការងារលើសម៉ោង និងការបើកប្រាក់ខែឲ្យមិនទៀងទាត់។ លើសពីនេះ ការសុំច្បាប់ឈប់សម្រាកនៅពេលដែលមានជម្ងឺ ឬបុណ្យទានម្ដងៗ មានភាពលំបាក ជាហេតុធ្វើឲ្យកប្រជាជនមួយចំនួនបង្ខំចិត្តធ្វើការទាំងឈឺ និងមិនសប្បាយចិត្ត។

### ៣.៤.២.៣. បញ្ហាសុវត្ថិភាព

មានប្រជាជនដល់ទៅ ២៦,២% ដែលបានលើកឡើងពីបញ្ហាសុវត្ថិភាពនៅពេលដែលខ្លួនរស់នៅក្រៅពីស្រុកភូមិ ដែលរួមមានទាំងសុវត្ថិភាពការងារ និងសន្តិសុខសង្គម។ ជាក់ស្ដែង កម្មករ-កម្មការនីរោងចក្រមួយចំនួនតែងដួលសន្លប់ ដោយសារប្រព័ន្ធខ្យល់នៅក្នុងរោងចក្រមានមិន

គ្រប់គ្រាន់ ឬក៏ការពុលក្រណាត់ផ្សេងៗ។ ដូចគ្នានេះដែរ កម្មករសំណង់ក៏ប្រឈមនឹងបញ្ហាសុវត្ថិភាពមួយចំនួនធំដែរ ដូចជាការធ្លាក់ពីលើផ្ទះ ដំបូល ឬអាគារខ្ពស់ៗ ដោយសារតែសំណង់មិនធ្វើទៅតាមបច្ចេកទេសត្រឹមត្រូវតាមស្តង់ដា គ្មានប្រើខ្សែយោងដើម្បីសុវត្ថិភាពកម្មករ ឬការសាងសង់ជន្ទល់មិនបានរឹងមាំ។ រីឯពេលយប់ ពួកគាត់ត្រូវដេកយាមការដ្ឋាន ដែលស្ងាត់ជ្រងំ ពេលខ្លះឆ្ងាយពីទីក្រុង ទីប្រជុំជន ឬភូមិឃុំនានា ជាហេតុបណ្តាលឲ្យពួកគាត់មានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជាខ្លាំង។ បន្ថែមពីលើនេះទៅទៀត អ្នកមួយចំនួនដែលចេញពីធ្វើការយប់ ឬធ្វើការថែមម៉ោង ហើយធ្វើដំណើរត្រឡប់ទៅផ្ទះជួល ព្រមទាំងនៅតែម្នាក់ឯង ក៏មានភាពភ័យខ្លាចថានឹងជួបក្រុមក្មេងទំនើង ចោរលួច ឆក់ ប្លន់ផ្សេងៗ ។ ម្យ៉ាងវិញទៀត អ្នកភូមិក៏បានលើកឡើងថា កន្លែងធ្វើការរបស់ពួកគាត់នៅឆ្ងាយពីទីកន្លែងស្នាក់នៅ ដែលធ្វើឲ្យពួកគាត់មានការលំបាកក្នុងការធ្វើដំណើរ ដូចជា បញ្ហាចរាចរណ៍ និងបញ្ហាសុវត្ថិភាពផ្សេងៗ។ លើសពីនេះ គ្រោះថ្នាក់ចរាចរណ៍ជាកត្តាមួយដែលនាំឲ្យប្រជាជនចំណាកស្រុកមានភាពភ័យខ្លាចយ៉ាងខ្លាំង ពិសេសពេលពួកគាត់ធ្វើដំណើរត្រឡប់ទៅស្រុកកំណើតរបស់ពួកគាត់ពេលបុណ្យទានម្តងៗ។ យើងដឹងហើយថា ជារៀងរាល់ឆ្នាំគ្រោះថ្នាក់ចរាចរណ៍កើតមានច្រើនបំផុត នៅពេលប្រជាជនចំណាកស្រុកត្រឡប់ទៅផ្ទះនៅក្នុងឱកាសពិធីបុណ្យជាតិផ្សេងៗ ហើយគ្រោះថ្នាក់ខ្លះទៀតមានដូចជា គ្រោះថ្នាក់ចរាចរណ៍នៃឡានដឹកកម្មករ កម្មការនីរោងចក្រ -ល- ដែលតែងកើតមានជាញឹកញាប់។

**៣.៤.២.៤. ស្ថានភាពនៃការរស់នៅ**

របៀបរបបរស់នៅក៏ជាបញ្ហាលំបាកមួយដែរចំពោះជនចំណាកស្រុក។ ១៦.៥% នៃពួកគាត់បានជួបនឹងបញ្ហានេះ ហើយវាកើតឡើងដោយសារតែភាពមិនអាច ឬលំបាកក្នុងការសម្របខ្លួនទៅនឹងអាកាសធាតុ ក៏ដូចជាវប្បធម៌ប្រទេសដទៃ (សម្រាប់អ្នកចំណាកស្រុកទៅបរទេស)។ ជាឧទាហរណ៍ ប្រជាជនដែលទៅប្រទេសកូរ៉េ បានបញ្ជាក់ថា អាកាសធាតុនៅប្រទេសនោះត្រជាក់ខ្លាំងពេក ដែលបណ្តាលឲ្យពួកគាត់ពិបាកស៊ូទ្រាំ ហើយពេលខ្លះទៀតអាចប្រឈមនឹងជម្ងឺផ្សេងៗ ជាពិសេសជម្ងឺគាំងបេះដូង ឬខ្យល់គរ ដោយសារតែការបើកម៉ាស៊ីនកម្តៅនៅក្នុងបន្ទប់តូចចង្អៀតគ្មានខ្យល់អុកស៊ីសែនចេញចូលគ្រប់គ្រាន់។ លើសពីនេះ វប្បធម៌ និងបែបបទរស់នៅផ្សេងៗនៅបរទេសហាក់ខុសប្លែកខ្លាំងពីវប្បធម៌ និងបែបបទរស់នៅក្នុងស្រុកខ្លួន ដែលពេលខ្លះបណ្តាលឲ្យពួកគាត់មិនអាចសម្របខ្លួននឹងរឿងទាំងអស់នោះបាន (Culture Shock)។ ក្រឡេកមកមើលជនចំណាកស្រុកមកទីក្រុងភ្នំពេញវិញ គាត់មួយចំនួនក៏ពិបាករស់នៅក្នុងទីក្រុងផងដែរ ដោយសារទីក្រុងអ៊ូអរពេក ហើយមានភាពមមាញឹក និងរញ៉េរញ៉ៃ។

**៣.៤.២.៥. បញ្ហាម្ហូបអាហារ**

បើយោងទៅតាមការអង្កេតទិន្នន័យ ប្រជាជនប្រមាណ ១៤,៦% ជួបនឹងបញ្ហាលំបាកផ្នែកម្ហូបអាហារនៅពេលដែលខ្លួនធ្វើចំណាកស្រុក ជាពិសេសបងប្អូនប្រជាជន ដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស។ ចំពោះប្រជាជនដែលទៅក្រៅប្រទេសបានបង្ហាញថា ចំណីអាហារមួយចំនួនពិបាកនឹងបរិភោគ ពីព្រោះពួកគាត់មិនចេះហូបចំណីអាហារប្រទេសដទៃ ព្រោះខ្លួនធ្លាប់តែហូបចំណីអាហារស្រុកទេសខ្លួន។ ពួកគាត់ក៏បានបន្ថែមទៀតថា ម្ហូបអាហារខ្លះមានខ្លាញ់ច្រើន ហឹរខ្លាំង ឬផ្អែមខ្លាំងពេក ដែលនាំឲ្យពួកគាត់ពិបាកហូបចុក។ ចំពោះប្រជាជនដែលធ្វើចំណាកស្រុកមកទីក្រុងភ្នំពេញវិញ បានអះអាងថា ម្ហូបអាហារនៅទីក្រុងមានជាតិគីមីច្រើន ព្រោះនាំចូលពីប្រទេសជិតខាង មិនធម្មជាតិដូច បន្លែ ផ្លែឈើ សាច់ ត្រី ដែលពួកគាត់ធ្លាប់ហូបក្នុងស្រុករបស់ពួកគាត់។ ឯអ្នកមួយចំនួនទៀត លើកឡើងថា តម្លៃម្ហូបអាហារនៅទីក្រុងមានតម្លៃថ្លៃ។

**៣.៤.២.៦. បញ្ហាតម្លៃទឹក ភ្លើង និងផ្ទះជួល**

ប្រជាជនចំណាកស្រុកប្រមាណ ៩,៧% និយាយថា ការកើនឡើងតម្លៃទឹក ភ្លើង និងផ្ទះជួលក៏ជាទុក្ខលំបាករបស់ពួកគាត់ដែរ។ ដោយសារតែពួកគាត់ធ្វើការឆ្ងាយពីផ្ទះ ពួកគាត់ត្រូវជួលផ្ទះគេព្រមទាំងបង់ថ្លៃទឹកភ្លើងខ្លួនឯង ដែលនាំឲ្យពួកគាត់មិនសូវជានៅសល់ប្រាក់សម្រាប់សន្សំ ឬផ្ញើរទៅឲ្យឪពុកម្ដាយ ឬក្រុមគ្រួសារនៅឯស្រុកនោះទេ។

**៣.៤.២.៧. ចៅហ្វាយស្ដីបន្ទោស**

ប្រមាណ ២,៩% នៃអ្នកធ្វើចំណាកស្រុកបាននិយាយថា ការទទួលការស្ដីបន្ទោសពីចៅវាយនាយក៏ជាផលលំបាកដែលបានកើតឡើងចំពោះពួកគាត់ផងដែរ។ ពេលខ្លះធ្វើការងារហត់នឿយហើយ ត្រូវចៅកែស្ដីឲ្យទៀត អ្នកខ្លះទ្រាំពុំបាននឹងការដៀលត្មះ ក៏ផ្លាស់ប្ដូរការងារទៅកន្លែងថ្មីមួយទៀត។

**៣.៤.២.៨. បញ្ហាសុខភាព**

សុខភាពគឺ មានសារៈសំខាន់ណាស់សំរាប់មនុស្សម្នាក់ៗ ប៉ុន្តែពួកគាត់ពេលខ្លះបានខិតខំធ្វើការងារទាំងសុខភាពទ្រុឌទ្រោម។ ប្រជាជនចំណាកស្រុក ២,៩% បានជួបប្រទះបញ្ហាសុខភាពនេះ កំឡុងពេលបំពេញការងារ។

**៣.៤.២.៩. បញ្ហានៃការបើកប្រាក់ខែ**

អ្នកធ្វើចំណាកស្រុក ១,៩% បានបង្ហាញថា បញ្ហានៃការបើកប្រាក់ខែជូនបុគ្គលិកនេះ បានកើតឡើងនៅកន្លែងការងាររបស់គាត់។ អ្នកមួយចំនួន ត្រូវបានចៅកែកេងប្រវ័ញ្ចលើកម្លាំងពលកម្មដោយធ្វើការហើយ បើកប្រាក់ខែឲ្យមិនគ្រប់ ឬបើកប្រាក់ខែឲ្យយឺតយ៉ាវជាដើម។

#### ៣.៤.២.១០. មិនមានបញ្ហាពិបាក

ប្រជាជនមួយចំនួនបានជួបប្រទះរាល់បញ្ហាខាងលើ ប៉ុន្តែក៏មានអ្នកចំណាកស្រុក ២,៩% ដែលបញ្ចេញយោបល់ថា ពួកគាត់ពុំមានជួបប្រទះបញ្ហាអ្វីទេ ទាំងការងារ និងការរស់នៅគឺ សុខសប្បាយជាធម្មតា។

#### ៣.៤.២.១១. បញ្ហាផ្សេងៗទៀត

ចំណែកឯប្រជាជនចំណាកស្រុក ៤,៩% បានប្រាប់អំពីផលលំបាកផ្សេងៗទៀតដែលពួកគាត់បានជួបប្រទះ។ ក្រៅពីផលលំបាកខាងលើ មានបញ្ហាមួយចំនួនផ្សេងទៀតរួមមាន ការកើតមានជម្លោះនៅកន្លែងធ្វើការរវាងអ្នករួមការងារជាមួយគ្នា កន្លែងធ្វើការពុំមានផាសុខភាពត្រឹមត្រូវ ពិបាកក្នុងការ ស្នើរសុំច្បាប់ពេលមានបុណ្យទាន ឬការរៀបអាពាហ៍ពិពាហ៍ និងពិបាកក្នុងការនិយាយជាមួយជនបរទេស ដោយសារតែពួកគាត់ពុំចេះភាសា នៅពេលដែលពួកគាត់ធ្វើចំណាកស្រុកទៅក្រៅប្រទេស។

### ៣.៥. ទស្សនៈនៃជនចំណាកស្រុកនៅក្នុងឃុំប្រាសាទ

បើយោងទៅតាមមិតិយោបល់របស់អ្នកចំណាកស្រុកក្នុងឃុំនេះ ពួកគាត់ ៥៩,២% គិតថាការធ្វើចំណាកស្រុកជាឱកាសល្អ ពីព្រោះពួកគាត់ទទួលបានការងារធ្វើ មានប្រាក់ខែសមរម្យ និងអាចជួយលើកកម្ពស់ជីវភាពគ្រួសាររបស់ខ្លួន។ ចំណែក ១៣,៦% ទៀតគិតថា វាជាការគម្រាមកំហែងមកដល់ខ្លួន ដោយសារបញ្ហាមួយចំនួនដូចជា បញ្ហាការងារ ការរស់នៅ និងសុវត្ថិភាព។ ដោយឡែក ប្រជាជន ២៧,២% ទៀត គិតថាការធ្វើចំណាកស្រុកនេះ ជាឱកាសល្អ ហើយស្របពេលនេះក៏ជាការគម្រាមកំហែងដល់ពួកគាត់ផងដែរ។ ដោយហេតុនេះហើយ ក្រោយពីការសាកសួរ និងចុះសង្កេតរបស់ក្រុមយើងខ្ញុំ ពលរដ្ឋចំណាកស្រុកចំនួន ៨៣,៥% មានបំណងចង់បញ្ឈប់ការធ្វើចំណាកស្រុក ហើយវិលត្រឡប់មកស្រុកកំណើតវិញ និង ១៦,៥% ទៀត នៅតែមានបំណងបន្តធ្វើចំណាកស្រុក មិនវិលត្រឡប់មកស្រុកកំណើតវិញនោះទេ។ មូលហេតុដែលពួកគាត់ចង់បន្ត ឬបញ្ឈប់ការធ្វើចំណាកស្រុករបស់ពួកគាត់នឹងបង្ហាញជូននៅខាងក្រោមនេះ។

**តារាងទី ៣.៦ មូលហេតុនៃការបន្ត ឬបញ្ឈប់ការធ្វើចំណាកស្រុកគិតជាភាគរយ**

| | | |
|---|---|---|
| បន្តការធ្វើចំណាកស្រុក | មានការងារល្អ និងប្រាក់ខែសមរម្យ | ១៥,៥% |
| | មិនចង់ធ្វើស្រែ | ១% |
| បញ្ឈប់ការធ្វើចំណាកស្រុក | ជួបជុំគ្រួសារ | ៦៦% |
| | រកស៊ីខ្លួនឯង | ២៤,៣% |
| | ភាពលំបាកនៃការរស់នៅ និងការងារ | ១៧,៥% |

### ៣.៥.១. មូលហេតុដែលបន្តការធ្វើចំណាកស្រុក

តាមទិន្នន័យដែលស្រង់បាន ប្រជាជនប្រមាណ ១៦,៥% មានបំណង និងមិនចង់បញ្ឈប់ការធ្វើចំណាកស្រុក ហើយវិលមករស់នៅស្រុកកំណើតវិញនោះទេ។ នេះដោយហេតុថា ១៥,៥% នៃពួកគាត់ទទួលបានការងារល្អ និងជាប់លាប់ ព្រមទាំងទទួលបានប្រាក់ខែសមរម្យ ដែលធ្វើឲ្យគាត់មិននឹកចង់ត្រឡប់មកស្រុកកំណើតវិញ។ នៅស្រុកកំណើត មិនសូវមានការងារធ្វើ ហើយនៅពេលរកការងារបានធ្វើហើយ ប្រាក់ខែក៏បានតិចតួច មិនច្រើន និងមិនសល់។ ឯប្រជាជនមួយចំនួនតូចស្មើនឹង ១% ទៀត បានថ្លែងថា ពួកគាត់នឹងបន្តធ្វើចំណាកស្រុក ពីព្រោះពួកគាត់មិនចង់នៅស្រុកកំណើតធ្វើស្រែចម្ការ ដោយសារតែការធ្វើស្រែចម្ការមានភាពហត់នឿយ និងពិបាក ហើយម៉្យាងទៀតទិន្នផលក៏ទទួលបានតិចតួច។ បើប្រៀបធៀបនឹងការធ្វើការនៅទីក្រុង ឬទីប្រជុំជនវិញ ពួកគាត់ទទួលបានប្រាក់ខែសមរម្យ ហើយការងារមិនហត់នឿយ និងពិបាកដូចការធ្វើស្រែចម្ការនោះទេ។

### ៣.៥.២. មូលហេតុដែលបញ្ឈប់ការធ្វើចំណាកស្រុក

យោងទៅតាមតារាងខាងលើ ប្រជាជនធ្វើចំណាកស្រុកភាគច្រើន ៨៣,៥% មានគោលបំណងចង់ឈប់ធ្វើចំណាកស្រុក ហើយវិលមករស់នៅស្រុកកំណើតរបស់ខ្លួនឯណោះវិញ។ មូលហេតុទីមួយ គឺពួកគាត់ទាំងអស់នោះ អាចមានពេលជួបជុំ និងមើលថែក្រុមគ្រួសាររបស់ខ្លួន ដែលមូលហេតុនេះគិតជាភាគរយមាន ៦៦%។ តាមរយៈបទសម្ភាសន៍ ពួកគាត់បានប្រាប់យ៉ាងជាក់ច្បាស់ថា គ្មាននរណាម្នាក់ចង់រស់នៅឆ្ងាយពីផ្ទះ ប្រពន្ធ កូន ឪពុក ម្ដាយ ជីដូន ជីតា និងបងប្អូនរបស់ ដែលខ្លួនតែងតែមានសេចក្តីនឹករឮក និងព្រួយបារម្ភជានិច្ចនោះឡើយ ក៏ប៉ុន្តែដោយសារភាពគ្មានការងារធ្វើ និងជីវភាពលំបាករបស់គ្រួសារ ពួកគាត់ត្រូវបង្ខំចិត្តធ្វើការចំណាកស្រុកដើម្បីទៅរកការងារ ឬឱកាសផ្សេងៗ ដែលអាចជួយសម្រួលដល់ការរស់នៅរបស់ពួកគាត់។ លើសពីនេះ ពួកគាត់មួយចំនួនធំសង្ឃឹមថា ភូមិ-ឃុំមានការអភិវឌ្ឍ សម្បូរទៅដោយការងារគ្រប់ប្រភេទ បន្ថែមពីលើការងាររោងចក្រ ដែលអាចផ្តល់កម្រិតប្រាក់ខែសមស្របទៅឲ្យគាត់ នោះពួកគាត់ច្បាស់នឹងត្រឡប់មកធ្វើការនៅក្នុងស្រុកវិញ ជាជាងធ្វើការនៅកន្លែងដទៃដែលខ្លួនមិនសូវស្គាល់។

មូលហេតុទីពីរ គឺត្រឡប់មកស្រុកវិញដើម្បីបង្កើតមុខរបរផ្សេងៗដោយខ្លួនឯង ដែលមូលហេតុនេះមាន ២៤,៣%។ ភាគច្រើននៃអ្នកធ្វើចំណាកស្រុកនៅក្នុងឃុំនេះធ្វើចំណាកស្រុកទៅកាន់ទីក្រុងភ្នំពេញ ឬបរទេស ក្នុងគោលបំណងសន្សំលុយកាក់។ នៅពេលដែលពួកគាត់សន្សំលុយគ្រប់គ្រាន់ ដែលអាចនឹងដំណើរការអាជីវកម្មខ្លួនឯងផ្ទាល់បានហើយ នោះពួកគាត់នឹងត្រឡប់មក

ស្រុកកំណើតវិញ ដើម្បីចាប់ផ្ដើមអាជីវកម្មរបស់ពួកគាត់។ ជាទូទៅ ពួកគាត់តែងទៅធ្វើការសន្សំលុយនៅពេលដែលពួកគាត់នៅលីវ ឬមិនទាន់មានគ្រួសារ ក៏ប៉ុន្តែនៅពេលដែលពួកគាត់មានគ្រួសារហើយនោះ ពួកគាត់តែងត្រឡប់មកស្រុកវិញ ដើម្បីដំណើរការអាជីវកម្មផ្សេងៗ ដែលមានដើមទុនពីប្រាក់ដែលពួកគាត់ខំសន្សំគ្រាគាត់ធ្វើការនៅក្រៅស្រុកកំណើត។

មូលហេតុទីបី គឺភាពលំបាកនៃការរស់នៅ និងការងារនៅទីក្រុង ឬប្រទេសក្រៅ ដែលមូលហេតុនេះមាន ១៧,៥%។ ដូចដែលយើងខ្ញុំបានរៀបរាប់ខាងលើពីផលអវិជ្ជមាននៃការធ្វើចំណាកស្រុក ការរស់នៅ និងធ្វើការនៅទីក្រុងក៏ដូចជានៅប្រទេសដទៃ ផ្ដល់ការលំបាកជាច្រើនដល់ពលរដ្ឋចំណាកស្រុករបស់យើង។ បញ្ហាទាំងអស់នោះមានដូចតទៅ ការពិបាកសម្របខ្លួនទៅនឹងសង្គម របៀបរបប បែបបទ ទំនៀមទម្លាប់ ឬវប្បធម៌ដទៃ ព្រមទាំងអាកាសធាតុផងដែរ បញ្ហាសុវត្ថិភាពម្ហូបអាហារ ការងារ និងការធ្វើដំណើរ ការងារធ្ងន់ និងហត់នឿយ រងការស្ដីបន្ទោសសព្វគ្រប់បែបយ៉ាងពីថៅហ្វាយនាយ ការចំណាយច្រើនជាងចំណូល ជាពិសេសទៅលើថ្លៃទឹក ភ្លើង ម្ហូបអាហារ និងផ្ទះជួល ហើយជាចុងក្រោយគឺការចាញ់បោកថៅកែ ឬថៅហ្វាយផ្នែកកម្លាំងពលកម្ម -ល-។

## ៣.៦. ដំណោះស្រាយចំពោះបញ្ហាចំណាកស្រុកក្នុងឃុំប្រាសាទ

តាមរយៈការធ្វើអង្កេតជាមួយប្រជាពលរដ្ឋចំណាកស្រុកចំនួន ១០៣ នាក់ យើងទទួលបានដំណោះស្រាយដើម្បីដោះស្រាយបញ្ហាចំណាកស្រុកមានដូចខាងក្រោម៖

**តារាងទី ៣.៧ ដំណោះស្រាយបញ្ហាចំណាកស្រុកក្នុងឃុំប្រាសាទ**

| | |
|---|---|
| ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ | ៧៧,៧% |
| បង្កើតការងារចម្រុះ | ៧៣,៨% |
| ប្រាក់ខែសមរម្យ | ៣០,១% |
| ទីផ្សារតម្លៃផលិតផលកសិកម្មខ្ពស់ | ២៩,១% |
| បណ្ដុះបណ្ដាលកសិកម្ម និងជំនាញវិជ្ជាជីវៈ | ១០,៧% |
| តម្លៃទំនិញ និងសេវាកម្មថោក | ៩,៧% |
| សុវត្ថិភាពសន្តិសុខសង្គម | ២,៩% |

### ៣.៦.១ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ

យោងតាមរយៈយោបល់របស់ប្រជាពលរដ្ឋដែលចំណាកស្រុកបានលើកឡើងថា ដើម្បីដោះស្រាយបញ្ហាចំណាកស្រុកដែលកំពុងកើតឡើងនៅក្នុងឃុំប្រាសាទនេះ រដ្ឋាភិបាលត្រូវផ្ដោត

ការយកចិត្តទុកដាក់លើការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ។ អ្នកចំណាកស្រុកប្រមាណ ៧៧,៧% បាននិយាយថា ការកសាងផ្លូវថ្នល់ ផ្លូវលំ ស្ពាន មន្ទីរពេទ្យ សាលារៀន និងការបង្កើតឲ្យមានប្រឡាយទឹកខ្វាត់ខ្វែងដើម្បីផ្គត់ផ្គង់ក្នុងវិស័យកសិកម្ម គឺមានសារៈសំខាន់ណាស់សំរាប់ពួកគាត់។ លើសពីនេះ ពួកគាត់អាចប្រកបរបរកសិកម្មបាន ២ ឬ ៣ លើក ក្នុងមួយឆ្នាំ ហើយការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធបែបនេះ អាចជួយសម្រួលដល់ការធ្វើដំណើរ និងបង្ករភាពងាយស្រួលដល់ការងារដឹកជញ្ជូនផ្សេងៗផងដែរ។ មួយវិញទៀត ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រអាចធ្វើឲ្យប្រជាពលរដ្ឋមានជីវភាពធូធារជាងមុន ដោយសារតែពួកគាត់នឹងទទួលបានទិន្នផលខ្ពស់ពីការងារកសិកម្ម និងការងារក្រៅពីកសិកម្មផងដែរ។ បច្ចុប្បន្ននេះ ការធ្វើកសិកម្មរបស់ពួកគាត់ពុំសូវទទួលបានផលល្អទេ ដោយសារតែកង្វះទឹកក្នុងការស្រោចស្រពដំណាំការធ្វើស្រែចម្ការប្រវាស់ទឹកភ្លៀង ពេលខ្លះពុំទទួលបានផលសោះ ទាំងអស់នេះហើយដែលធ្វើឲ្យគាត់ចំណាកស្រុក។ អ្វីដែលពួកគាត់ចង់បាននោះ គឺមានប្រព័ន្ធទឹកគ្រប់គ្រាន់ និងហេដ្ឋារចនាសម្ព័ន្ធល្អ ដែលដូចគ្នានឹងការបកស្រាយរបស់ គំរូ Lewis ដែរ។

### ៣.៦.២. បង្កើតការងារចម្រុះ

បើយើងក្រឡេកមើលទៅលើការងារផ្សេងៗនៅក្នុងឃុំប្រាសាទនេះ ការងារភាគច្រើនជាការងារកសិកម្ម ប៉ុន្តែដោយយើងដឹងហើយថាការងារកសិកម្មនៅក្នុងប្រទេសយើងមិនមានបច្ចេកទេសត្រឹមត្រូវ ជាហេតុនាំឲ្យទទួលបានទិន្នផលទាប ហើយម្យ៉ាងទៀតប្រទេសយើងបាននឹងកំពុងប្រែខ្លួនពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម ប្រជាជនភាគច្រើនបានសម្រេចចិត្តធ្វើចំណាកស្រុក។ អ្នកចំណាកស្រុក ៧៣,៨% បានប្រាប់ថា នៅក្នុងស្រុកមិនមានការងារគ្រប់គ្រាន់នោះទេ។ ហេតុដូច្នេះហើយ គាត់ចង់ឲ្យរដ្ឋាភិបាលជួយដោះស្រាយបញ្ហានេះ តាមរយៈការបង្កើតការងារចម្រុះផ្សេងៗ ទាំងការងាររោងចក្រ និងសហគ្រាស ព្រមទាំងការងារដទៃៗទៀត។ ពួកគាត់សង្ឃឹមថា រដ្ឋាភិបាលអាចនឹងទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅប្រទេសឲ្យមកវិនិយោគនៅក្នុងភូមិ-ឃុំជាជាងការវិនិយោគនៅជិត ឬនៅក្នុងទីក្រុង ដែលមានការរីកចម្រើនលូតលាស់ស្រាប់ហើយ។ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស រោងចក្រ សហគ្រាស និងជម្រុញឲ្យមានដំណើរការអាជីវកម្មផ្ទាល់ខ្លួន ជាអ្វីដែលពួកគាត់ចង់ទទួលបាន ដើម្បីឲ្យគាត់អាចត្រឡប់មកស្រុកកំណើតវិញ និងទទួលបានការងារធ្វើ។ ពួកគាត់បានបន្តទៀតថា រដ្ឋាភិបាលគួរតែបង្កើតបទបញ្ញត្តិ ឬច្បាប់ផ្សេងៗ ដែលហាមឃាត់ ឬរឹតបន្តឹងរោងចក្រកុំឲ្យមាននៅក្នុងទីក្រុង តែគួរតែរើទីតាំង ឬសាងសង់នៅទីជនបទ ប៉ុន្តែសម្រួលដល់បញ្ហាពន្ធ

ផ្សេងៗដូចជាពន្ធលើប្រាក់ចំណេញ និងបញ្ហាដំណើរការឯកសារកលិខិតស្នាមក្នុងការមកវិនិយោគនៅក្នុងស្រុកភូមិ។ លើសពីនេះ រដ្ឋាភិបាលគួរតែផ្សព្វផ្សាយ និងជម្រុញឲ្យប្រជាពលរដ្ឋដែលមានជីវភាពគ្រាន់បើឲ្យចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន ទោះបីជាអាជីវកម្មខ្នាតតូចក៏ដោយ តាមរយៈការបញ្ចុះពន្ធផ្សេងៗ និងផ្តល់អត្រាការប្រាក់កម្ចីទាបបំផុត។ ស្របជាមួយនឹងការពន្យល់របស់គំរូ Harris-Todaro ដែលបង្ហាញថា ប្រជាជននាំគ្នាធ្វើចំណាកស្រុកដោយសារតែពួកគាត់ខ្វះការងារធ្វើ ការធ្វើបែបនេះនឹងអាចឲ្យភូមិ-ឃុំមានការអភិវឌ្ឍ និងការងារចម្រុះ ដែលនាំឲ្យប្រជាជនមានភាពងាយស្រួលក្នុងការស្វែងរកការងារធ្វើ ក៏ដូចជាមិនបាច់ចាកចេញពីស្រុកដើម្បីរកការងារធ្វើទៀតនោះទេ។

### ៣.៦.៣. ប្រាក់ខែសមរម្យ

ពលរដ្ឋចំណាកស្រុកប្រមាណ ៣០,១% បានទាមទារឲ្យមានការដោះស្រាយលើបញ្ហាប្រាក់ខែរបស់ពួកគាត់។ ពួកគាត់សង្ឃឹមថា ការងារដែលមាននៅក្នុងស្រុកភូមិរបស់គាត់ ទាំងការងាររោងចក្រក្តី ឬការងារផ្សេងៗទៀតក្តី នឹងផ្តល់ប្រាក់កម្រៃសមល្មមនឹងពលកម្មដែលពួកគាត់បានបញ្ចេញ ហើយនឹងអាចផ្គត់ផ្គង់ជីវភាពគ្រួសារគាត់បានសមរម្យ ពោលគឺអាចមានប្រាក់សេសសល់ខ្លះសម្រាប់សន្សំ និងមិនមែនពិបាកតស៊ូនៅចុងខែនោះទេ។ ជាក់ស្តែង ពលរដ្ឋមួយចំនួនបានបញ្ជាក់ប្រាប់ថា នៅក្នុងភូមិ-ឃុំរបស់ពួកគាត់មានវិនិយោគិនមកបោះទុនវិនិយោគ និងបង្កើតការងារជូនប្រជាពលរដ្ឋដែរ ប៉ុន្តែប្រាក់ខែដែលពួកគាត់ទទួលបានពីការធ្វើការងារនៅរោងចក្រនោះមិនសមស្របនោះទេ។ ពួកគាត់ធ្វើការច្រើនម៉ោង ប៉ុន្តែទទួលបានប្រាក់ចំណូលតិច។ លើសពីនេះទៅទៀត នៅខែខ្លះ ការបើកប្រាក់ខែពីថៅកែរបស់ពួកគាត់មានភាពយឺតយ៉ាវ ពេលខ្លះយឺតរហូតទៅដល់កន្លះខែ ឯពេលខ្លះទៀត ពួកគាត់មិនទទួលបានប្រាក់ខែក្នុងរយៈពេលមួយខែពេញដែលពួកគាត់ធ្វើការ។ ដូចនេះ គាត់បានសំណូមពរឲ្យរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរភូមិ-ឃុំ និងសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ឲ្យជួយចាត់ចែងចុះមកអន្តរាគមនលើបញ្ហានេះ ឬបង្កើតឡើងជាច្បាប់ដើម្បីរឹតបន្តឹងទៅលើបញ្ហានេះចំពោះម្ចាស់សហគ្រាស ឧស្សាហកម្ម និងអាជីវកម្មផ្សេងៗ និងលើកកម្ពស់សិទ្ធិរបស់កម្មករ កម្មការនី ឬបុគ្គលិកក្រោមបង្គាប់ ជាពិសេសទាក់ទងនឹងកម្រិតប្រាក់ខែជាដើម ដូចដែលទ្រឹស្តី សេដ្ឋកិច្ច Neoclassic បានលើកឡើងនៅក្នុងជំពូកទី១។ លើសពីនេះ ប្រជាជនដែលធ្វើការនៅតាមខេត្តគួរតែទទួលបាននូវសេវារបបសន្តិសុខសង្គម (ប.ស.ស) ដូចអ្នកដែលធ្វើការនៅទីក្រុងដែរ។ បើសិនជាបញ្ហាអស់នេះត្រូវបានដោះស្រាយ ហើយអនុវត្តបានតាមសំណូមពររបស់គាត់បានយ៉ាងជោគជ័យ បញ្ហាចំណាកស្រុកនៅក្នុងភូមិ-ឃុំនេះ

ច្បាស់នឹងត្រូវបានកាត់បន្ថយ ហើយប្រជាពលរដ្ឋនឹងនាំគ្នាត្រឡប់មកធ្វើការនៅក្នុងស្រុកកំណើតវិញ ដោយមិនបាច់ឃ្លាតឆ្ងាយពីផ្ទះ និងក្រុមគ្រួសារបងប្អូន។

**៣.៦.៤ ទីផ្សារតម្លៃផលិតផលកសិកម្មខ្ពស់**

យោងតាម ទ្រឹស្តីសេដ្ឋកិច្ចថ្មី តម្លៃទីផ្សារផលិតផលកសិកម្ម ក៏ជាមូលហេតុមួយដែលបណ្តាលឲ្យប្រជាជនធ្វើការចំណាកស្រុកផងដែរ។ យោងតាមប្រជាជនប្រមាណ ២៩,១% បានបង្ហាញថាអ្នកចំណាកស្រុកមួយចំនួនចេញទៅស្វែងរកការងារធ្វើនៅទីក្រុង ឬ ទីប្រជុំជន គឺដោយសារតែតម្លៃផលិតផលកសិកម្មនៅលើទីផ្សារមានតម្លៃទាបពេក ដែលធ្វើឲ្យពួកគាត់មិនអាចទទួលបានប្រាក់ចំណេញបាន។ ជាក់ស្តែងដូចបងប្រុសម្នាក់ដែលរស់នៅក្នុងឃុំប្រាសាទ បាននិយាយថា មុនពេលគាត់ធ្វើចំណាកស្រុកទៅធ្វើការនៅទីក្រុងភ្នំពេញ គាត់គឺជាកសិករម្នាក់ និងចិញ្ចឹមសត្វតិចតួច ក៏ប៉ុន្តែដោយសារតម្លៃទីផ្សារផលិតផលទាបពេក តែការចំណាយទៅលើថ្លៃដើមខ្ពស់ នោះពុំទទួលបានប្រាក់ចំណេញសោះ ពេលខ្លះខាតទៀតផង។ ដូច្នេះហើយ បានជាគាត់បោះបង់កាងារនេះចោល ហើយបែរទៅការចំណាកស្រុកដើម្បីស្វែងរកការងារផ្សេងវិញ។ ពួកគាត់មួយចំនួនលើកឡើងថា រដ្ឋាភិបាលត្រូវជួយរកទីផ្សារផលិតផលកសិកម្មឲ្យពួកគាត់ និងជួយការពារផលិតករក្នុងស្រុកដើម្បីប្រកួតប្រជែងជាមួយទីផ្សារបរទេស។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលគួរតែពង្រីកការនាំចេញផលិតផលកសិកម្មចូលក្នុងឆាកអន្តរជាតិឲ្យបានច្រើន ដើម្បីឲ្យ ទីផ្សារផលិតផលកសិកម្មមានតម្លៃខ្ពស់ នោះប្រជាជននឹងងាកមករកការងារកសិកម្មវិញមិនខាន។ ប្រជាជនភាគច្រើនត្អូញត្អែថា ផលិតផលកសិកម្មដែលគាត់ផលិតបានមានតម្លៃថោក ហើយពិបាកប្រកួតប្រជែងជាមួយនឹងទីផ្សារបរទេសទៀតផង ដូចនេះហើយពួកគាត់ចង់ឲ្យមានការលូកដៃចូលជួយជ្រុំជ្រែងពីរដ្ឋដើម្បីដោះស្រាសរាល់បញ្ហាខាងលើ។

**៣.៦.៥. បណ្តុះបណ្តាលកសិកម្ម**

ដោយសារតែភាពខ្វះខាតនូវចំណេះដឹង ជំនាញ និងបទពិសោធន៍ផ្សេងៗ លើផ្នែកកសិកម្មធ្វើឲ្យប្រជាជនមួយភាគធំត្រូវបង្ខំចិត្តធ្វើចំណាកស្រុក។ ប្រជាជន ១០,៧% ដែលធ្វើចំណាកស្រុកបានអំពាវនាវឲ្យរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗជួយបណ្តុះបណ្តាល និងបង្រៀនប្រជាជនក្នុងភូមិពីការធ្វើកសិកម្មបែបទំនើប ក្នុងនោះមានដូចជាបច្ចេកទេសក្នុងការធ្វើស្រែចម្ការដាំបន្លែ និងចញ្ចឹមសត្វមាន់ ទា គោ ក្របី ជ្រូក ត្រី -ល-។ ការបណ្តុះបណ្តាលលើការធ្វើជីកសិកម្មបែបធម្មជាតិ (ជីសរីរាង្គ) ការជ្រើសរើសពូជស្រូវ ដំណាំ បន្លែ ឬសត្វផ្សេងៗ ការបង្កើតថ្នាំសម្លាប់សត្វល្អិត និងថ្នាំព្យាបាលជម្ងឺដង្កាត់ដំណាំ ឬសត្វផ្សេងៗបែបធម្មជាតិ បច្ចេកទេសបញ្ចូលទឹក

និងការកសាងប្រព័ន្ធស្រោចស្រពក្នុងស្រែចម្ការ ដែលអាចធ្វើឲ្យដំណាំទទួលបានទឹកគ្រប់គ្រាន់ និងអាចធ្វើស្រែយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ព្រមទាំងការរើស ឬធ្វើចំណីសត្វតាមបែបធម្មជាតិ ដែលធ្វើឡើងពីវត្ថុធាតុដើមមានស្រាប់នៅក្នុងស្រុកភូមិ ឬស្រែចម្ការរបស់ខ្លួន សុទ្ធសឹងតែជាការបង្ហាត់បង្រៀនយ៉ាងសំខាន់ៗដែលអាចជួយឲ្យវិស័យកសិកម្មក្នុងភូមិរីកចម្រើន និងទទួលបានទិន្នផលល្អ នោះប្រជាជននឹងឈប់បោះបង់ដីស្រែចម្ការ ដែលខ្លួនមាន ហើយទៅធ្វើការនៅក្រៅស្រុកភូមិខ្លួនទៀតហើយ។

### ៣.៦.៦. តម្លៃទំនិញ និងសេវាកម្មទាប

នៅក្នុងភូមិទាំង ៩ នៅក្នុងឃុំប្រាសាទ តម្លៃទំនិញ និងសេវាកម្មផ្សេងៗនៅមានតម្លៃខ្ពស់នៅឡើយ ដែលនាំឲ្យប្រជាជនក្រីក្រ ឬមានជីវភាពលំបាកមួយចំនួនពិបាករស់នៅ ហើយចំណាកស្រុកទៅកាន់ទីប្រជុំជនការងារ ក្នុងគោលបំណងទទួលបានការងារ និងប្រាក់កម្រៃគ្រាន់បើជាងមុន។ តម្លៃទំនិញ និងសេវាកម្មនៅតែមានតម្លៃខ្ពស់ ពីព្រោះប្រជាកសិករ និងប្រជាជននៅតែពុំទាន់មានលទ្ធភាពផលិតបាននូវទំនិញក្នុងស្រុកនៅឡើយ រីឯទំនិញដែលផលិតបានទៀតសោតពុំមានទីផ្សារសម្រាប់លក់ ឬមិនអាចផ្គត់ផ្គង់តាមតម្រូវការដែលចង់បាន ឯទំនិញខ្លះទៀតពុំមានគុណភាព និងផលិតឡើងដោយគ្មានស្តង់ដាត្រឹមត្រូវ ជាហេតុនាំឲ្យអតិថិជនពុំមានតម្រូវការទិញទំនិញទាំងនោះ។ ទំនិញភាគច្រើនត្រូវបាននាំចូលពីប្រទេសជិតខាង ជាពិសេសផលិតផលម្ហូបអាហារ ភេសជ្ជៈវេចខ្ចប់ជាកំប៉ុង ឬកញ្ចប់ ដែលអាចរក្សាទុកបានរយៈពេលយូរ បន្លែ ផ្លែឈើ គ្រឿងអេឡិចត្រូនិចផ្សេងៗ។ ដោយហេតុនេះហើយ ប្រជាជនចំណាកស្រុក ៩,៧% ចង់ឲ្យថ្លៃទំនិញ និងសេវាកម្មផ្សេងៗមានតម្លៃថោកសមរម្យ ដែលនាំឲ្យគាត់អាចរស់នៅ និងសម្របខ្លួនក្នុងស្រុកភូមិបាន មិនចាំបាច់ធ្វើចំណាកស្រុក។ រដ្ឋាភិបាលគួរចាំបាច់លើកទឹកចិត្តឲ្យផលិតករក្នុងស្រុក មិនថាសិប្បកម្មតូចតាច ឬសហគ្រាស រោងចក្រធំៗនោះទេ តាមរយៈការបន្ទាបពន្ធផ្សេងៗទាក់ទងនឹងអាជីវកម្ម ដើម្បីឲ្យពួកគាត់មានលទ្ធភាពទទួលបានប្រាក់ចំណេញគួរសម និងផ្តល់ឲ្យនូវប្រាក់កម្ចីសម្រាប់ធ្វើអាជីវកម្មផ្ទាល់ខ្លួនក្នុងអត្រាការប្រាក់ទាប។ ក្រៅពីនេះ រដ្ឋាភិបាលគួរគប្បីផ្តល់ឲ្យអ្នកគ្រប់គ្នាឲ្យទទួលបានព័ត៌មានស្តីពីទីផ្សារតម្លៃឲ្យបានច្បាស់លាស់ និងស្វែងរកទីផ្សារឲ្យសិប្បករ ឬសហគ្រិននានា នៅពេលដែលទំនិញផលិតបានរួចរាល់។ បន្ថែមពីនេះទៅទៀត រដ្ឋាភិបាលអាចធ្វើនយោបាយសារពើពន្ធ នយោបាយរូបិយវត្ថុ ឬអនុវត្តគោលនយោបាយផ្សេងៗទៀត ដែលធ្វើតម្លៃទំនិញ និងសេវាកម្មផ្សេងៗ មានលំនឹង មិនឡើង ឬចុះខ្លាំង និងលឿនពេក។ ប្រសិនបើបញ្ហា

ទាំងអស់នេះបានដោះស្រាយ ប្រជាជនចំណាកស្រុកនឹងត្រឡប់មករស់នៅ និងធ្វើការនៅស្រុកកំណើតខ្លួនវិញយ៉ាងប្រាកដ។

### ៣.៦.៧. សុវត្ថិភាពសន្តិសុខសង្គម

ការរស់នៅទីកន្លែងដែលពោរពេញទៅសុវត្ថិភាព មានសណ្តាប់ធ្នាប់ និងសន្តិសុខល្អ គឺជាការចង់បានរបស់មនុស្សគ្រប់គ្នា។ ការធ្វើចំណាកស្រុក ក៏អាចបណ្តាលមកពីកត្តាសន្តិសុខសង្គមផងដែរ តាមរយៈការទទួលបានព័ត៌មានពីអ្នកធ្វើចំណាកស្រុកប្រមាណ ២,៩% បានលើកឡើងថាប្រជាជនមួយចំនួនបានធ្វើចំណាកស្រុកដោយសារតែ ពួកគាត់ពិបាករស់នៅក្នុងតំបន់នោះ។ បន្ថែមពីនេះទៅទៀត សកម្មភាពដែលបង្ករឲ្យមានភាពលំបាកដល់ប្រជាជនរួមមាន: ក្មេងទំនើង ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ចោរកម្ម និងសកម្មភាពអសន្តិសុខផ្សេងៗទៀត។ ពួកគាត់សូមស្នើរសុំដល់រដ្ឋាភិបាលឲ្យជួយពង្រឹង សមត្ថកិច្ចថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិបន្ថែមទៀតដើម្បីចុះបង្ក្រាបនិងទប់ស្កាត់ឲ្យបានទាន់ពេលវេលា។ បើមិនដូច្នេះទេ ពួកគាត់មិនអាចទ្រាំរស់នៅក្នុងសភាពព្រួយបារម្ភ និងភ័យខ្លាចបែបនេះទេ។ មួយវិញទៀត ពួកគាត់មានការព្រួយបារម្ភចំពោះកូនៗ ដែលនៅក្មេងវ័យ ខ្លាចពួកគេរងឥទ្ធិពលពីសកម្មភាពមិនល្អទាំងនោះ ហើយខ្លាចពួកជនខឹលខូចអូសទាញដើរក្នុងផ្លូវដែលសង្គមស្អប់ឃ្ពើមផងដែរ។ ដូច្នេះ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់បន្ថែមទៀតចំពោះការពង្រឹងភូមិ-ឃុំមានសុវត្ថិភាព ដើម្បីការពារសណ្តាប់ធ្នាប់សង្គម និងបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍នោះ។

## ៣.៧ សន្និដ្ឋាន

យោងតាមការបង្ហាញខាងលើ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា ការធ្វើចំណាកស្រុកបណ្តាលមកពីកត្តាមួយចំនួនរួមមាន: ជីវភាពលំបាក កង្វះការងារ កង្វះដីធ្លី មុខរបរមិនកាក់កបចង់មានសេរីភាព និងបញ្ហាផ្សេងៗទៀត។ ក្រៅពីនេះ យើងបានបង្ហាញអំពីស្ថានភាពផ្លាសប្តូររបស់ប្រជាជនមុន និងក្រោយពេលធ្វើការចំណាកស្រុក ហើយយើងបានរកឃើញទៀតថាការធ្វើចំណាកស្រុកមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ គុណសម្បត្តិមានដូចជា ការរីកចម្រើនផ្នែកហិរញ្ញវត្ថុ និងការកើនឡើងចំនេះដឹង និងបទពិសោធន៍ ចំណែកឯគុណវិបត្តិវិញមានដូចជា នឹកផ្ទះ និងគ្រួសារ ការងារមានភាពពិបាកខ្លាំង មិនមានសុវត្ថិភាព ពិបាកក្នុងការរស់នៅ បញ្ហាម្ហូបអាហារ និងបញ្ហាផ្សេងៗទៀត។ បន្ថែមពីនេះ យើងបានរកឃើញដំណោះស្រាយដើម្បីការកាត់បន្ថយបញ្ហាចំណាកស្រុកដែលកំពុងកើតឡើងនៅក្នុងឃុំប្រាសាទផងដែរ។ យោងតាមអ្នកចំណាកស្រុកដែលរស់នៅក្នុងឃុំប្រាសាទដោយផ្ទាល់ បានបញ្ចេញមតិថា ដើម្បីដោះស្រាយបញ្ហាចំណាកស្រុកនេះ

បានលុះត្រាតែ រដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនរួមមានៈ ការកសាងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រព័ន្ធធារាសាស្ត្រឲ្យមានភាពល្អប្រសើរឡើង ការបង្កើតការងារចម្រុះដល់ប្រជាពលរដ្ឋដើម្បីឲ្យពួកគាត់អាចទទួលបានការងារធ្វើគ្រប់ៗគ្នា ការផ្តល់ប្រាក់ខែសមរម្យដល់ពួកគាត់ ត្រូវស្វែងរកទីផ្សារតម្លៃផលិតផលកសិកម្មដល់កសិករ បណ្តុះបណ្តាលផ្នែកកសិកម្ម ដើម្បីឲ្យពួកគាត់យល់ដឹងអំពីការធ្វើ កសិម្មបែបទំនើប និងត្រូវស្តង់ដា ផ្តល់តម្លៃទំនិញ និងសេវាកម្មទាប និងបង្កើតឲ្យមានសុវត្ថិភាពសន្តិសុខសង្គម។ ម្យ៉ាងវិញទៀត យើងរកឃើញថាដំណោះស្រាយដែលមានសក្តានុពលខ្ពស់ក្នុងការដោះស្រាយបញ្ហាចំណាកស្រុកនៅក្នុងឃុំប្រាសាទនេះ គឺ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រ និងការបង្កើតការងារចម្រុះ។ ដូច្នេះ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់លើបញ្ហាទាំងពីរនេះជាចម្បង ដោយសារតែវាជាតម្រូវការចាំបាច់របស់ប្រជាជន ហើយវានឹងមានប្រសិទ្ធិភាពក្នុងការដោះស្រាយ ដែលមានគោលដៅកាត់បន្ថយបញ្ហាចំណាកស្រុកនៅក្នុងភូមិ-ឃុំប្រាសាទបាន។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការសិក្សាស្រាវជ្រាវក្រោមប្រធានបទ " **ការធ្វើចំណាកស្រុក** " នៅក្នុងភូមិ-ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង អស់រយៈពេលជាច្រើនខែមកនេះ យើងអាចសរុបសេចក្តីសន្និដ្ឋានបានថា ប្រជាជនទាំងឡាយដែលសម្រេចចិត្តធ្វើការចំណាកស្រុក គឺដោយសារតែកត្តារុញច្រានខ្លាំងជាងកត្តាអូសទាញ។ ហេតុតែការប្រកបមុខរបរការងារមិនាបានកាក់កប និងមានបញ្ហាជាច្រើនដែលរារាំងដល់ការរស់នៅផងនោះ ពួកគាត់ក៏សម្រេចចិត្តចំណាកស្រុកចេញទៅរកការងារធ្វើនៅទីប្រជុំជន ឬទីក្រុងភ្នំពេញ មិនត្រឹមតែប៉ុណ្ណោះអ្នកខ្លះឈានទៅដល់ការចំណាកស្រុកចេញទៅធ្វើការនៅក្រៅប្រទេសថែមទៀតផង។ បញ្ហាដែលមានឥទ្ធិពលខ្លាំងទៅលើការធ្វើចំណាកស្រុកនោះរួមមាន ជីវភាពលំបាក កង្វះការងារ កង្វះដីធ្លី មុខរបរមិនកាក់កប ចង់មានសេរីភាព និងបញ្ហាផ្សេងៗទៀត។ ក្រៅពីនេះ បញ្ហាចំណាកស្រុកក៏បណ្តាលមកពីកត្តាអូសទាញមួយចំនួនដែរ។ ប្រជាជនភាគច្រើនធ្វើការចំណាកស្រុក គឺដោយសារតែភាពខុសគ្នារវាងប្រាក់ខែនៅតាមទីជនបទ និងទីក្រុង និងការចង់ដឹងចង់ស្គាល់នូវអ្វីថ្មីៗ ព្រមទាំងការចង់មានសេរីភាពផង នោះក៏សម្រេចចិត្តចំណាកស្រុកតែម្តង។ ប្រសិនបើពួកគាត់អាចមានការងារធ្វើដែលទទួលបានប្រាក់ខែសមរម្យដូចនៅតាមតំបន់ទីប្រជុំជននោះ ពួកគាត់បានលើកឡើងថា ពួកគាត់នឹងមិនធ្វើការចំណាកស្រុកទេ។ នេះបញ្ជាក់ឲ្យឃើញថា បញ្ហាចំណាកស្រុកដែលបណ្តាលមកពីភាពខុសគ្នានៃប្រាក់ឈ្នួលនេះ គឺស្រមតាមទ្រឹស្តីសេដ្ឋកិច្ច Neoclassic ដែលបានបង្ហាញនៅក្នុងជំពូកទី១។

លើសពីនេះទៅទៀត ការធ្វើចំណាកស្រុកបានជះឥទ្ធិពលទាំងផលវិជ្ជមាន និងអវិជ្ជមានទៅដល់បុគ្គល គ្រួសារ និងសង្គមជាតិទាំងមូលផងដែរ។ យើងសង្កេតឃើញថា ពួកគាត់មានប្រាក់ចំណូល និងជីវភាពល្អប្រសើរជាងមុន ហើយពលករចំណាកស្រុកអាចនាំមកនូវគំនិតថ្មីៗ និងចំណេះដឹង និងបទពិសោធន៍ការងារទៀតផង។ ប៉ុន្តែទន្ទឹមនឹងមានផលល្អ វាក៏ជះឥទ្ធិផលអវិជ្ជមានដល់សង្គមជាតិផងដែរ។ ដោយសារតែការធ្វើចំណាកស្រុកមានការកើនឡើងមកទីក្រុងភ្នំពេញ ធ្វើឲ្យជួបបញ្ហាមួយចំនួនដូចជា ការកកស្ទះចរាចរណ៍ សកម្មភាពអសន្តិសុខ ការបំពុលទីក្រុង...។ ហើយគុណវិបត្តិដែលអ្នកចំណាកស្រុកតែងតែជួបប្រទះនោះ គឺមានដូចជា ការនឹកផ្ទះ និងគ្រួសារ បញ្ហាការងារដែលមានភាពពិបាកខ្លាំង បញ្ហាការងារដែលមិនមានសុវត្ថិភាពហើយគ្មានការទទួលខុសត្រូវពីម្ចាស់ក្រុមហ៊ុន បញ្ហាពិបាកក្នុងការរស់នៅ និងសម្របសម្រួលទៅនឹងស្ថានភាពថ្មី បញ្ហាម្ហូបអាហារ និងបញ្ហាផ្សេងៗទៀត។

យោងតាមការចុះសិក្សាស្រាវជ្រាវ យើងបានរកឃើញដំណោះស្រាយដែលមានប្រសិទ្ធិភាពដើម្បីដោះស្រាយបញ្ហាចំណាកស្រុកនៅក្នុងឃុំប្រាសាទនោះ គឺមានដូចជា ការកសាងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រព័ន្ធធារាសាស្ត្រ ការបង្កើតការងារចម្រុះដល់ប្រជាពលរដ្ឋដើម្បីឲ្យពួកគាត់អាចទទួលបានការងារធ្វើគ្រប់ៗគ្នា ការផ្តល់ប្រាក់ខែសមរម្យដល់ពួកគាត់ ការស្វែងរកទីផ្សារតម្លៃផលិតផលកសិកម្មដល់កសិករ ការចុះបណ្តុះបណ្តាលផ្នែកកសិកម្មពីសំណាក់អ្នកមានជំនាញ ដើម្បីឲ្យពួកគាត់យល់ដឹងអំពីការធ្វើកសិម្មបែបទំនើប និងត្រូវតាមស្តង់ដា ផ្តល់តម្លៃទំនិញនិងសេវាកម្មទាប និងធ្វើឲ្យមានសុវត្ថិភាពសន្តិសុខសង្គមជូនដល់ពួកគាត់ផងដែរ។ បន្ថែមពីនេះទៅទៀត ដើម្បីដោះស្រាយបញ្ហាខាងលើបាន រដ្ឋាភិបាលគួរតែពង្រឹងផ្នែកសុខភាព, អនាម័យ, និងសាងសង់សាលារៀន និងមន្ទីពេទ្យជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះផងដែរ។ ម្យ៉ាងវិញទៀត គួរតែរៀបចំផែនការទាក់ទាញអ្នកវិនិយោគក្នុង និងក្រៅប្រទេសឲ្យមកបន្តាក់ទុននៅទីនោះ ដើម្បីផ្តល់ការងារជូនដល់ប្រជាពលរដ្ឋនៅទីនោះ។ កន្លងមកនេះ ឃុំបានអភិវឌ្ឍឲ្យមានភាពប្រសើរឡើងនៃវិស័យផ្សេងៗ រួមមាន វិស័យសេដ្ឋកិច្ច វិស័យអប់រំ វិស័យសុខាភិបាល វិស័យគមនាគមន៍ វិស័យធារាសាស្ត្រ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត និងវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដែលបានធ្វើឲ្យការធ្វើចំណាកស្រុកមានការធ្លាក់ចុះ ប៉ុន្តែនៅតែមិនទាន់ជាទីគាប់ចិត្តនៅឡើយ។

## ២.អនុសាសន៍

តាមរយៈការសិក្សាជុំវិញប្រធានខាងលើនេះ ដើម្បីជាជំនួយជួយដល់ការដោះស្រាយបញ្ហាចំណាកស្រុកនៅក្នុងឃុំប្រាសាទឲ្យមានប្រសិទ្ធិភាព។ យើងខ្ញុំជាប្រជាពលរដ្ឋ និងជានិស្សិត សូមបញ្ចេញមតិយោបល់ ក៏ដូចជាផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទរួមមាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ វត្តអារាម ជាពិសេសការអភិវឌ្ឍគមនាគមន៍ ដែលជួយក្នុងការដឹកជញ្ជូនផលិតផលកសិកម្មផ្សេងៗទៅកាន់ទីផ្សារ និងទាក់ទាញវិនិយោគិនទាំងឡាយ ក៏ដូចជាជួយសម្រួលដល់អ្នកប្រកបអាជីវកម្មផ្ទាល់ខ្លួនផងដែរ។
- អភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដូចជាប្រឡាយទឹកជាដើមឲ្យមានច្រើនខ្វាត់ខ្វែង ដើម្បីជួយសម្រួលដល់ការធ្វើស្រែចម្ការរបស់ប្រជាកសិករ។
- រដ្ឋាភិបាលគួរតែផ្តោតលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមទីជនបទ ពីព្រោះការធ្វើបែបនេះនឹងជួយផ្តល់ការងារចម្រុះដល់ប្រជាជន ថែមទាំងជួយឲ្យពួកគាត់មាន

ឱកាសអាចបង្កើតអាជីកម្មដោយខ្លួនឯងបានតាមរយៈការលក់ដូរ ការដឹកជញ្ជូន-ល-។

- លើកទឹកចិត្តដល់ក្រុមហ៊ុនដែលវិនិយោគនៅទីជនបទ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ចំពោះក្រុមហ៊ុនដែលបង្កើតតាមតំបន់ដាច់ស្រយាល ដូចជាការបន្ធូរបន្ថយពន្ធដល់អ្នកវិនិយោគណាដែលស្ម័គ្រទៅសាងសង់រោងចក្រ ឬក្រុមហ៊ុននៅជនបទ ដែលការធ្វើបែបនេះក៏អាចបង្កើតការងារនៅតាមទីជនបទបានផងដែរ។
- រដ្ឋាភិបាលគួរសហការណ៍ជាមួយអាជ្ញាធរភូមិឃុំ ដើម្បីពិនិត្យមើលលើប្រាក់ឈ្នួល ឬប្រាក់ខែ ដែលម្ចាស់សហគ្រាស ក្រុមហ៊ុន ឬអាជីវកម្មផ្សេងៗផ្តល់ជូនទៅដល់កម្មករ ឬបុគ្គលិក ដើម្បីឲ្យសមស្របទៅនឹងកម្លាំងពលកម្មរបស់ពួកគាត់ និងអាចផ្គត់ផ្គង់គ្រួសារ ក៏ដូចជាមានជីវភាពសមរម្យ។
- ធានាតម្លៃផលិតផលកសិកម្មជូនប្រជាពលរដ្ឋ ដោយសារតែប្រទេសយើងជាប្រទេសកសិកម្ម ដូច្នេះរដ្ឋគួរតែយកចិត្តទុកដាក់លើវិស័យនេះ។ តាមយោបល់របស់យើងខ្ញុំ រដ្ឋត្រូវតែហ៊ានទទួលខុសត្រូវចំពោះតម្លៃផលិតផលកសិកម្មក្នុងមួយឆ្នាំៗ ព្រមទាំងផ្តល់ព័ត៌មានតម្លៃនៃផលិតផលកសិកម្មនីមួយៗ ឲ្យប្រជាពលរដ្ឋដឹង។
- រដ្ឋាភិបាលគួរគប្បីស្វែងរកទីផ្សារកសិកម្មជូនប្រជាពលរដ្ឋតាមរយៈការស្វែងរកដៃគូពាណិជ្ជកម្មអន្តរជាតិ។
- បណ្តុះបណ្តាលផ្នែកកសិកម្មទំនើបជូនប្រជាពលរដ្ឋ ដោយអាចឲ្យពួកគាត់ធ្វើស្រែបានយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ព្រមទាំងទទួលបានទិន្នផលខ្ពស់។ បន្ថែមពីលើនេះទៀត ជំនាញវិជ្ជាជីវៈផ្សេងៗដែលអាចផ្តល់ការងារដល់ប្រជាពលរដ្ឋជនបទ គួរតែត្រូវបានបង្ហាត់បង្រៀនដល់ពួកគាត់។
- រដ្ឋាភិបាលគួរចាត់វិធានការថែរក្សាលំនឹងនៃថ្លៃទំនិញ និងសេវាកម្មផ្សេងៗនៅជនបទ ដើម្បីកុំឲ្យតម្លៃទំនិញ និងសេវាកម្មចេះតែឡើងថ្លៃជាបន្តបន្ទាប់ និងតាមតែសំដីរបស់ឈ្មួញកណ្តាល។
- អាជ្ញាធរភូមិឃុំត្រូវចាំបាច់ថែរក្សាសណ្តាប់ធ្នាប់ក្នុងភូមិ ឃុំ តាមរយៈការបង្ក្រាបបទល្មើសឆក់ ប្លន់ លួច ជួញដូរគ្រឿងញៀន -ល- ដើម្បីធានាដល់សុវត្ថិភាពប្រជាជន។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារជាភាសាខ្មែរ


1. សារណាបញ្ចប់ការសិក្សារបស់និស្សិត កែវ បូរិន្ទ និងចន សុផាន់ណាក់ ចំណងជើង មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់ពលករមកទីក្រុងភ្នំពេញ ឆ្នាំ ២០១១
2. ព្រឹត្តបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី៣ បោះពុម្ពផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០១៧
3. គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាខែ ធ្នូ ឆ្នាំ ២០១៤ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
4. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទំព័រទី ៥៩-៨៣
5. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
6. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ បោះពុម្ពផ្សាយដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
7. របាយការណ៍បូកសរុបវាយតម្លៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧ និងគោលនយោបាយរបស់គណបក្សសម្រាប់អភិវឌ្ឍន៍ឃុំប្រាសាទពីឆ្នាំ ២០១២-២០១៧
8. កម្មវិធីវិនិយោគឃុំប្រាសាទ ឆ្នាំ ២០១៧
9. ព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ ពីប្រភពទិន្នន័យមូលដ្ឋានឃុំសង្កាត់ ខែធ្នូ ឆ្នាំ ២០១៥ នៃឃុំប្រាសាទ
10. ទិន្នន័យមូលដ្ឋានឃុំពីមន្ទីរផែនការខេត្តព្រៃវែង ឆ្នាំ ២០១៥
11. កិច្ចសម្ភាសន៍ជាមួយមេឃុំប្រាសាទ លោក លឹម ផេង
12. ទិន្នន័យទទួលបានពីការសម្ភាសន៍ដូនជីម្នាក់ក្នុងវត្តប្រាសាទ ដែលស្ថិតនៅក្នុងភូមិប្រាសាទ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង
13. ព័ត៌មានថ្មីៗ សរសេរដោយលឹម តុលា ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ ២០១៧ ក្រោមចំណងជើងថា ចំណាកស្រុកពីជនបទចូលទីក្រុងភ្នំពេញៈ បញ្ហាប្រឈមទាំងជនបទ និងទីក្រុង! ដកស្រង់ចេញពីគេហទំព័រ https://thmeythmey.com/?page=detail&id=51308

## ២. ឯកសារជាភាសាអង់គ្លេស

Report of the Cambodian Rural Urban Migration Project (Crump) of Ministry of Planning, Published on August 2012, Retrieved from http://cambodia.unfpa.org/en/publications/migration-cambodia

Chen, D. (2018) Cambodia’s low rate of unemployment doesn’t tell whole story, report finds.

*The Phnom Penh Post*. Retrieved from https://www.phnompenhpost.com/national/ cambodias-low-rate-unemployment-doesnt-tell-whole-story-report-finds

Maza, C. (2016). Low skills driving worker migration from Cambodia: report. *The Phnom Penh Post.* Retrieve from: https://www.phnompenhpost.com/national/low-skills-driving-worker-migration-cambodia-report

Njuguna, E. (2016). Government Measures Aimed at Curbing Rural-to-Urban Migration in Africa. *Soapboxie*. Retrieve from: https://soapboxie.com/world-politics/GOVERNMENT-MEASURES-AIMED-AT-CURBING-RURAL-TO-URBAN-MIGRATION

Sandberg, M. (2013). Unemployment in Cambodia. *Empowering Youth*. Retrieve from: http://pepyempoweringyouth.org/unemployment-in-cambodia/

Segal, A. (2015). Guest Post: China’s "Back to the Countryside" Policy: A Step Toward Reducing Rural-Urban Disparity. *Council on Foreign Relations*. Retrieve from: https://www.cfr.org/blog/guest-post-chinas-back-countryside-policy-step-toward-reducing-rural-urban-disparity

Yusran, R. (2011). Violence, Exploitation, and Abuse and Discrimination in Migration Affecting Women and Children in ASEAN: A Baseline Study. *Human Rights Resource Centre of University of Indonesia-Depok Campus*, 389.

## ៣. ឯកសារដកស្រង់ចេញពីគេហទំព័រ

1. http://www.striking-women.org/module/migration/history-migration https://www.ultimatevisa.com/types-of-migration/
2. https://knoema.com/atlas/Cambodia/GDP-per-capita
3. http://www.worldbank.org/en/country/cambodia/overview
4. http://www.cambodiainvestment.gov.kh/country-overview/economic-situation.htmlttps://www.adb.org/countries/cambodia/economy#tabs-0-0
5. http://documents.worldbank.org/curated/en/780641494510994888/pdf/114938-PUBLIC-may-16-8pm-Cambodia-Economic-report-v2-s.pdf
6. https://tradingeconomics.com/cambodia/unemployment-rate
7. http://www.emergingmarkets.asia/consulting/news/2016/10/02/migration-cambodia-usaid/
8. http://family.jrank.org/pages/1170/Migration-Theories-Migration.html
9. https://www.futurelearn.com/courses/migration-theories/0/steps/35078

10. http://www.sociologydiscussion.com/demography/migration-demography/top-3-models-of-migration/3160
11. https://www.rfa.org/khmer/policy-of-gdp-04212017223842.html
12. https://km.wikipedia.org/wiki/

# ឧបសម្ព័ន្ធទី ១

## ឧបសម្ព័ន្ធទី ១៖ កម្រងសំណួរ

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំទី៤ ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ បាននឹងកំពុងសរសេរសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទ **"ការធ្វើចំណាកស្រុក"** ។ គោលបំណងនៃការសម្ភាសន៍នេះ គឺដើម្បីប្រមូលទិន្នន័យពីលោកអ្នក ដើម្បីជួយក្នុងការសរសេរនិក្ខេបបទរបស់យើងខ្ញុំ និងវិភាគពីមូលហេតុ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក និងស្វែងរកដំណោះស្រាយដើម្បីបញ្ឈប់បញ្ហានេះ។ យើងខ្ញុំសូមសន្យាថា រាល់ព័ត៌មានទាំងអស់ដែលលោកអ្នកបានផ្តល់ឲ្យនឹងត្រូវរក្សាជាសម្ងាត់។ សូមអរគុណសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់អស់លោកអ្នក យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងផ្តល់ព័ត៌មានយ៉ាងសុក្រិតដល់យើងខ្ញុំ។

ភេទ ______ អាយុ ______ រស់នៅភូមិ ______________

1. តើអ្នកមានសមាជិកគ្រួសារប៉ុន្មាននាក់? ________
   តើមានសមាជិកប៉ុន្មាននាក់ដែលជួយរកចំណូលមកផ្គត់ផ្គង់គ្រួសារ? ___________
2. តើអ្នកមានចំណេះដឹងកម្រិតណាមុនពេលធ្វើចំណាកស្រុក?
   ☐ មិនចេះអក្សរ ☐ បឋមសិក្សា ☐ អនុវិទ្យាល័យ
   ☐ វិទ្យាល័យ ☐ មហាវិទ្យាល័យ ☐ ផ្សេងៗ ____________
3. នៅក្នុងគ្រួសាររបស់អ្នក តើមានមនុស្សប៉ុន្មាននាក់ធ្វើចំណាកស្រុក? ___________
4. តើអ្នកទទួលបានព័ត៌មានពីការធ្វើចំណាកស្រុកតាមរយៈអ្វីខ្លះ?

☐ ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធសង្គមផ្សេងៗ ☐ បងប្អូន

☐ មិត្តភក្តិ ☐ អ្នកជិតខាង (ក្នុងភូមិ)

5. តើអ្នកធ្លាប់ធ្វើចំណាកស្រុកដែរឬទេ? ☐ ធ្លាប់ ☐ មិនធ្លាប់
   រយៈពេលប៉ុន្មាន? ______________
6. តើអ្នកធ្វើចំណាកស្រុកទៅណា?

☐ ក្នុងប្រទេស ☐ ក្រៅប្រទេស

7. តើអ្នកចំណាកស្រុកទៅធ្វើការងារអ្វី?

☐ កម្មកររោងចក្រ ☐ កម្មករសំណង់ ☐ រត់ម៉ូតូឌុប ☐ បុគ្គលិកបម្រើតាមផ្ទះ

☐ អ្នកបម្រើតាមហាង ☐ លក់ដូរ ☐ ផ្សេងៗ __________

8. តើមានមូលហេតុអ្វីខ្លះ ដែលជម្រុញឲ្យអ្នកសម្រេចចិត្តធ្វើចំណាកស្រុក? (ចម្លើយអាចជ្រើសរើសបានលើសពីមួយ)

☐ ខ្វះដីធ្វើស្រែចម្ការ ☐ មុខរបរមិនកាក់កប ☐ ខ្វះការងារធ្វើ

☐ ចង់មានសេរីភាព ☐ ជីវភាពលំបាក ☐ ផ្សេងៗ ____________

9. តើអ្នកធ្វើការប៉ុន្មានម៉ោងក្នុង១ថ្ងៃ? __________ ហើយប៉ុន្មានថ្ងៃក្នុង១អាទិត្យ? ________

10. តើអ្នកទទួលបានប្រាក់ឈ្នួល ឬប្រាក់ខែប៉ុន្មាន? ______________

11. តើអ្នកជួបប្រទះនឹងភាពលំបាកអ្វីខ្លះនៅពេលធ្វើចំណាកស្រុក (ពេលទៅដល់ និងពេលកំពុងរស់នៅស្រុកទេសផ្សេង)? (ចម្លើយអាចជ្រើសរើសបានលើសពីមួយ)

☐ នឹកផ្ទះ និងគ្រួសារ ☐ ការងារមានភាពលំបាក ☐ បញ្ហាម្ហូបអាហារ

☐ របៀបរបបនៃការរស់នៅ ☐ មិនមានសុវត្ថិភាព ☐ ផ្សេងៗ ______

12. តើអ្នកទទួលបានផលប្រយោជន៍អ្វីខ្លះពីការធ្វើចំណាកស្រុក? (ចម្លើយអាចជ្រើសរើសបានលើសពីមួយ)

☐ ចំណេះដឹង និងបទពិសោធន៍ ☐ មានជីវភាពប្រសើរជាងមុន

☐ មានសុខភាពល្អជាងមុន ☐ ផ្សេងៗ_______________

13. តើអ្នកមានជីវភាពកម្រិតណាមុនពេលធ្វើចំណាកស្រុក?

☐ ក្រខ្សត់ ☐ ក្រីក្រ ☐ មធ្យម ☐ មានបាន

តើអ្នកទទួលបានប្រាក់ចំណូលប៉ុន្មានក្នុង ១ឆ្នាំ មុនពេលធ្វើចំណាកស្រុក? __________

14. តើអ្នកមានជីវភាពប្រែប្រួលយ៉ាងណាខ្លះ បន្ទាប់ពីធ្វើចំណាកស្រុក?

☐ មានជីវភាពប្រសើរជាងមុន ☐ ជីវភាពដដែល ☐ ជីវភាពយ៉ាប់យ៉ឺនជាងមុន

15. តើអ្នកមានទស្សនៈយ៉ាងណាចំពោះការធ្វើចំណាកស្រុក?

☐ ជាឱកាសល្អ ☐ ជាការគំរាមកំហែង ☐ ជាឱកាសល្អ និងជាការគំរាមកំហែង

16. តើអ្នកមានបំណងចង់ត្រឡប់មកស្រុកកំណើតវិញ ហើយឈប់ធ្វើចំណាកស្រុកដែរឬទេ?

☐ ចង់ ☐ មិនចង់

ហេតុអ្វី? ______________________________________________

______________________________________________________

17. តើធ្វើដូចម្តេចទើបអ្នកឈប់ធ្វើចំណាកស្រុក? តាមទស្សនៈរបស់អ្នក រដ្ឋាភិបាលគួរធ្វើយ៉ាងណាខ្លះ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកនៅក្នុងសហគមន៍របស់អ្នក?

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________

**សូមអរគុណ!**

# ឧបសម្ព័ន្ធទី ២

# ឧបសម្ព័ន្ធទី ២៖ ស្រង់ទិន្នន័យពីការសម្ភាសន៍ដែលត្រូវបានប្រើប្រាស់ក្នុងជំពូក ៣




| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Gender | Numeric | 8 | 0 | Gender of migrant workers | {1, Male}... | 88, 99 | 8 | Right | Nominal | Input |
| 2 | Age | Numeric | 8 | 0 | Age of migrant workers | None | 88, 99 | 8 | Right | Nominal | Input |
| 3 | Village | Numeric | 8 | 0 | Village of migrant workers | {1, Thkov}... | 88, 99 | 8 | Right | Nominal | Input |
| 4 | Q1.1 | Numeric | 8 | 0 | Family members | None | 88, 99 | 8 | Right | Nominal | Input |
| 5 | Q1.2 | Numeric | 8 | 0 | Family members who earn money | None | 88, 99 | 8 | Right | Nominal | Input |
| 6 | Q2 | Numeric | 8 | 0 | Education before migrate | {1, illiterate}... | 88, 99 | 8 | Right | Ordinal | Input |
| 7 | Q3 | Numeric | 8 | 0 | Family members who migrate | None | 88, 99 | 8 | Right | Nominal | Input |
| 8 | Q4 | Numeric | 8 | 0 | Information of migrate | {1, Social Medias}... | 88, 99 | 8 | Right | Nominal | Input |
| 9 | Q5.1 | Numeric | 8 | 0 | Used to migrate or not | {1, Yes}... | 88, 99 | 8 | Right | Nominal | Input |
| 10 | Q5.2 | Numeric | 8 | 0 | Time of migrate (Years) | None | 88, 99 | 8 | Right | Nominal | Input |
| 11 | Q6 | Numeric | 8 | 0 | Destination of migrate | {1, Home Country}... | 88, 99 | 8 | Right | Nominal | Input |
| 12 | Q7 | Numeric | 8 | 0 | Job of migrate | {1, Factory worker}... | 88, 99 | 8 | Right | Nominal | Input |
| 13 | Q8.1_Reasons | Numeric | 8 | 0 | Lack of land for farming | {1, Yes}... | None | 8 | Right | Nominal | Input |
| 14 | Q8.2 | Numeric | 8 | 0 | Business not going well | {1, Yes}... | None | 8 | Right | Nominal | Input |
| 15 | Q8.3 | Numeric | 8 | 0 | Lack of jobs | {1, Yes}... | None | 8 | Right | Nominal | Input |
| 16 | Q8.4 | Numeric | 8 | 0 | Finding freedom | {1, Yes}... | None | 8 | Right | Nominal | Input |
| 17 | Q8.5 | Numeric | 8 | 0 | Poverty | {1, Yes}... | None | 8 | Right | Nominal | Input |
| 18 | Q8.6 | Numeric | 8 | 0 | Save money | {1, Yes}... | None | 8 | Right | Nominal | Input |
| 19 | Q8.7 | Numeric | 8 | 0 | Knowlege&experieces | {1, Yes}... | None | 8 | Right | Nominal | Input |
| 20 | Q8.8 | Numeric | 8 | 0 | Not good at learning | {1, Yes}... | None | 8 | Right | Nominal | Input |
| 21 | Q8.9 | Numeric | 8 | 0 | Other reasons | {1, Yes}... | None | 8 | Right | Nominal | Input |
| 22 | Q9.1 | Numeric | 8 | 0 | Working hours per day | None | 88, 99 | 8 | Right | Nominal | Input |
| 23 | Q9.2 | Numeric | 8 | 0 | Working days per week | None | 88, 99 | 8 | Right | Nominal | Input |
| 24 | Q10 | Dollar | 8 | 0 | Wage per month | None | $88, $99 | 8 | Right | Nominal | Input |

File Edit View Data Transform Analyze Graphs Utilities Extensions Window Help

| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 25 | Q11.1_Difficulties | Numeric | 8 | 0 | Homesick and miss family | {1, Yes}... | None | 8 | Right | Nominal | Input |
| 26 | Q11.2 | Numeric | 8 | 0 | Difficult workload | {1, Yes}... | None | 8 | Right | Nominal | Input |
| 27 | Q11.3 | Numeric | 8 | 0 | Food | {1, Yes}... | None | 8 | Right | Nominal | Input |
| 28 | Q11.4 | Numeric | 8 | 0 | Living Situation | {1, Yes}... | None | 8 | Right | Nominal | Input |
| 29 | Q11.5 | Numeric | 8 | 0 | Insecurity | {1, Yes}... | None | 8 | Right | Nominal | Input |
| 30 | Q11.6 | Numeric | 8 | 0 | Electricity,water,rental prices | {1, Yes}... | None | 8 | Right | Nominal | Input |
| 31 | Q11.7 | Numeric | 8 | 0 | Blaming from boss | {1, Yes}... | None | 8 | Right | Nominal | Input |
| 32 | Q11.8 | Numeric | 8 | 0 | Bad health condition | {1, Yes}... | None | 8 | Right | Nominal | Input |
| 33 | Q11.9 | Numeric | 8 | 0 | Recieving salary late | {1, Yes}... | None | 8 | Right | Nominal | Input |
| 34 | Q11.10 | Numeric | 8 | 0 | No difficulties | {1, Yes}... | None | 8 | Right | Nominal | Input |
| 35 | Q11.11 | Numeric | 8 | 0 | Others | {1, Yes}... | None | 8 | Right | Nominal | Input |
| 36 | Q12.1_Benefit | Numeric | 8 | 0 | Knowlege and Experiences | {1, Yes}... | None | 8 | Right | Nominal | Input |
| 37 | Q12.2 | Numeric | 8 | 0 | Better living condition | {1, Yes}... | None | 8 | Right | Nominal | Input |
| 38 | Q12.3 | Numeric | 8 | 0 | Better health | {1, Yes}... | None | 8 | Right | Nominal | Input |
| 39 | Q12.4 | Numeric | 8 | 0 | Others | {1, Yes}... | None | 8 | Right | Nominal | Input |
| 40 | Q13.1 | Numeric | 8 | 0 | Standard of living before migrate | {1, Under poverty line}... | 88, 99 | 8 | Right | Ordinal | Input |
| 41 | Q13.2 | Comma | 8 | 0 | Income before migrate (a year) (Riel) | None | 88, 99 | 20 | Right | Nominal | Input |
| 42 | Q14 | Numeric | 8 | 0 | Living condition after migrate | {1, Better}... | 88, 99 | 8 | Right | Nominal | Input |
| 43 | Q15 | Numeric | 8 | 0 | View of migrate | {1, Good opportunity}... | 88, 99 | 8 | Right | Nominal | Input |
| 44 | Q16.1 | Numeric | 8 | 0 | Continue or stop migrate | {1, Stop}... | 88, 99 | 8 | Right | Nominal | Input |
| 45 | Q16.2.1 | Numeric | 8 | 0 | Work & live with family | {1, Yes}... | None | 8 | Right | Nominal | Input |
| 46 | Q16.2.2 | Numeric | 8 | 0 | Run own businesses | {1, Yes}... | None | 8 | Right | Nominal | Input |
| 47 | Q16.2.3 | Numeric | 8 | 0 | Stable job & reasonable wages | {1, Yes}... | None | 8 | Right | Nominal | Input |
| 48 | Q16.2.4 | Numeric | 8 | 0 | Difficulties of living & working in PP | {1, Yes}... | None | 8 | Right | Nominal | Input |
| 49 | Q16.2.5 | Numeric | 8 | 0 | Don't want to do the farming | {1, Yes}... | None | 8 | Right | Nominal | Input |

Data View Variable View

File Edit View Data Transform Analyze Graphs Utilities Extensions Window Help

| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 33 | Q11.9 | Numeric | 8 | 0 | Recieving salary late | {1, Yes}... | None | 8 | Right | Nominal | Input |
| 34 | Q11.10 | Numeric | 8 | 0 | No difficulties | {1, Yes}... | None | 8 | Right | Nominal | Input |
| 35 | Q11.11 | Numeric | 8 | 0 | Others | {1, Yes}... | None | 8 | Right | Nominal | Input |
| 36 | Q12.1_Benefit | Numeric | 8 | 0 | Knowlege and Experiences | {1, Yes}... | None | 8 | Right | Nominal | Input |
| 37 | Q12.2 | Numeric | 8 | 0 | Better living condition | {1, Yes}... | None | 8 | Right | Nominal | Input |
| 38 | Q12.3 | Numeric | 8 | 0 | Better health | {1, Yes}... | None | 8 | Right | Nominal | Input |
| 39 | Q12.4 | Numeric | 8 | 0 | Others | {1, Yes}... | None | 8 | Right | Nominal | Input |
| 40 | Q13.1 | Numeric | 8 | 0 | Standard of living before migrate | {1, Under poverty line}... | 88, 99 | 8 | Right | Ordinal | Input |
| 41 | Q13.2 | Comma | 8 | 0 | Income before migrate (a year) (Riel) | None | 88, 99 | 20 | Right | Nominal | Input |
| 42 | Q14 | Numeric | 8 | 0 | Living condition after migrate | {1, Better}... | 88, 99 | 8 | Right | Nominal | Input |
| 43 | Q15 | Numeric | 8 | 0 | View of migrate | {1, Good opportunity}... | 88, 99 | 8 | Right | Nominal | Input |
| 44 | Q16.1 | Numeric | 8 | 0 | Continue or stop migrate | {1, Stop}... | 88, 99 | 8 | Right | Nominal | Input |
| 45 | Q16.2.1 | Numeric | 8 | 0 | Work & live with family | {1, Yes}... | None | 8 | Right | Nominal | Input |
| 46 | Q16.2.2 | Numeric | 8 | 0 | Run own businesses | {1, Yes}... | None | 8 | Right | Nominal | Input |
| 47 | Q16.2.3 | Numeric | 8 | 0 | Stable job & reasonable wages | {1, Yes}... | None | 8 | Right | Nominal | Input |
| 48 | Q16.2.4 | Numeric | 8 | 0 | Difficulties of living & working in PP | {1, Yes}... | None | 8 | Right | Nominal | Input |
| 49 | Q16.2.5 | Numeric | 8 | 0 | Don't want to do the farming | {1, Yes}... | None | 8 | Right | Nominal | Input |
| 50 | Q17.1 | Numeric | 8 | 0 | Good infrastructure and irrigation sys... | {1, Yes}... | None | 8 | Right | Nominal | Input |
| 51 | Q17.2 | Numeric | 8 | 0 | Reasonable wages | {1, Yes}... | None | 8 | Right | Nominal | Input |
| 52 | Q17.3 | Numeric | 8 | 0 | Low cost of spending | {1, Yes}... | None | 8 | Right | Nominal | Input |
| 53 | Q17.4 | Numeric | 8 | 0 | High price market of agricultural prod... | {1, Yes}... | None | 8 | Right | Nominal | Input |
| 54 | Q17.5 | Numeric | 8 | 0 | Variety of jobs in the community | {1, Yes}... | None | 8 | Right | Nominal | Input |
| 55 | Q17.6 | Numeric | 8 | 0 | Good social security | {1, Yes}... | None | 8 | Right | Nominal | Input |
| 56 | Q17.7 | Numeric | 8 | 0 | Train farmers about the farming skill | {1, Yes}... | None | 8 | Right | Nominal | Input |

Data View | Variable View

File Edit View Data Transform Analyze Graphs Utilities Extensions Window Help

Visible: 56 of 56 Va

| | Gender | Age | Village | Q1.1 | Q1.2 | Q2 | Q3 | Q4 | Q5.1 | Q5.2 | Q6 | Q7 | Q8.1_Reasons | Q8.2 | Q8.3 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 21 | 1 | 8 | 3 | 4 | 3 | 2 | 1 | 4 | 2 | 7 | 2 | 2 | 2 |
| 2 | 1 | 25 | 1 | 3 | 2 | 4 | 2 | 4 | 1 | 6 | 1 | 1 | 1 | 2 | 2 |
| 3 | 2 | 20 | 1 | 3 | 2 | 2 | 2 | 3 | 1 | 3 | 1 | 1 | 2 | 2 | 2 |
| 4 | 1 | 26 | 1 | 3 | 1 | 4 | 1 | 1 | 1 | 3 | 2 | 7 | 2 | 2 | 1 |
| 5 | 1 | 30 | 1 | 10 | 7 | 3 | 7 | 2 | 1 | 2 | 1 | 9 | 2 | 2 | 1 |
| 6 | 1 | 32 | 1 | 6 | 2 | 3 | 1 | 2 | 1 | 10 | 1 | 1 | 2 | 2 | 2 |
| 7 | 1 | 26 | 1 | 4 | 2 | 3 | 2 | 2 | 1 | 8 | 1 | 9 | 2 | 2 | 1 |
| 8 | 1 | 22 | 1 | 5 | 3 | 4 | 1 | 3 | 2 | 3 | 1 | 2 | 2 | 2 | 1 |
| 9 | 1 | 22 | 1 | 4 | 3 | 4 | 2 | 4 | 1 | 4 | 1 | 5 | 2 | 2 | 1 |
| 10 | 2 | 24 | 1 | 4 | 2 | 3 | 2 | 2 | 1 | 6 | 1 | 1 | 2 | 2 | 1 |
| 11 | 1 | 25 | 1 | 5 | 2 | 3 | 1 | 2 | 1 | 4 | 1 | 2 | 1 | 2 | 1 |
| 12 | 1 | 23 | 2 | 4 | 2 | 3 | 1 | 2 | 1 | 2 | 1 | 3 | 2 | 2 | 1 |
| 13 | 1 | 28 | 2 | 3 | 2 | 2 | 2 | 4 | 1 | 3 | 1 | 2 | 2 | 2 | 1 |
| 14 | 1 | 28 | 2 | 3 | 2 | 3 | 2 | 3 | 1 | 6 | 1 | 2 | 2 | 2 | 1 |
| 15 | 2 | 35 | 2 | 6 | 4 | 2 | 2 | 2 | 1 | 5 | 1 | 1 | 1 | 1 | 1 |
| 16 | 2 | 22 | 2 | 3 | 2 | 3 | 2 | 2 | 1 | 2 | 1 | 1 | 2 | 2 | 1 |
| 17 | 2 | 25 | 2 | 5 | 2 | 3 | 1 | 4 | 1 | 6 | 1 | 1 | 2 | 2 | 1 |
| 18 | 1 | 30 | 1 | 4 | 2 | 3 | 2 | 2 | 1 | 6 | 1 | 2 | 1 | 2 | 1 |
| 19 | 1 | 31 | 2 | 7 | 2 | 3 | 2 | 4 | 1 | 12 | 1 | 2 | 2 | 2 | 1 |
| 20 | 2 | 20 | 2 | 5 | 4 | 2 | 2 | 2 | 1 | 6 | 1 | 1 | 1 | 2 | 2 |
| 21 | 1 | 35 | 2 | 2 | 2 | 3 | 1 | 4 | 1 | 4 | 2 | 7 | 1 | 2 | 1 |
| 22 | 1 | 37 | 2 | 6 | 1 | 2 | 1 | 2 | 1 | 3 | 1 | 2 | 2 | 2 | 1 |

Data View Variable View

File Edit View Data Transform Analyze Graphs Utilities Extensions Window Help

Visible: 56 of 56 Va

| | Q8.4 | Q8.5 | Q8.6 | Q8.7 | Q8.8 | Q8.9 | Q9.1 | Q9.2 | Q10 | Q11.1_Difficulties | Q11.2 | Q11.3 | Q11.4 | Q11.5 | Q11.6 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 1 | 1 | 2 | 2 | 2 | 10 | 6 | $1,400 | 1 | 2 | 2 | 2 | 2 | 2 |
| 2 | 2 | 2 | 2 | 2 | 2 | 2 | 8 | 6 | $170 | 1 | 2 | 2 | 2 | 2 | 2 |
| 3 | 2 | 2 | 1 | 2 | 2 | 2 | 8 | 6 | $180 | 1 | 2 | 2 | 2 | 2 | 2 |
| 4 | 2 | 2 | 2 | 2 | 2 | 2 | 8 | 5 | $1,800 | 1 | 2 | 1 | 2 | 2 | 2 |
| 5 | 2 | 2 | 2 | 2 | 2 | 2 | 8 | 7 | $240 | 1 | 1 | 1 | 2 | 2 | 2 |
| 6 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $150 | 2 | 2 | 2 | 2 | 2 | 1 |
| 7 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $150 | 1 | 2 | 2 | 2 | 2 | 2 |
| 8 | 2 | 2 | 2 | 2 | 2 | 2 | 8 | 7 | $300 | 1 | 1 | 1 | 1 | 2 | 2 |
| 9 | 2 | 2 | 2 | 2 | 2 | 2 | 8 | 6 | $200 | 2 | 1 | 1 | 1 | 2 | 2 |
| 10 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $150 | 1 | 2 | 2 | 2 | 2 | 2 |
| 11 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $200 | 2 | 1 | 1 | 1 | 2 | 2 |
| 12 | 2 | 1 | 2 | 2 | 2 | 2 | 10 | 7 | $310 | 1 | 2 | 2 | 2 | 1 | 2 |
| 13 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $150 | 1 | 1 | 2 | 2 | 1 | 2 |
| 14 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $280 | 1 | 1 | 2 | 2 | 1 | 2 |
| 15 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $170 | 1 | 1 | 2 | 2 | 2 | 2 |
| 16 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $150 | 1 | 2 | 2 | 2 | 2 | 2 |
| 17 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $170 | 1 | 1 | 2 | 2 | 2 | 2 |
| 18 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $68 | 1 | 1 | 2 | 2 | 2 | 2 |
| 19 | 2 | 1 | 2 | 2 | 2 | 2 | 8 | 6 | $188 | 1 | 2 | 2 | 2 | 2 | 2 |
| 20 | 2 | 2 | 1 | 2 | 2 | 2 | 8 | 6 | $170 | 1 | 2 | 2 | 2 | 2 | 2 |
| 21 | 2 | 1 | 2 | 2 | 2 | 2 | 8 | 5 | $1,400 | 1 | 2 | 2 | 2 | 2 | 2 |
| 22 | 2 | 2 | 2 | 2 | 2 | 2 | 8 | 6 | $300 | 2 | 1 | 2 | 2 | 2 | 2 |

Data View Variable View

File Edit View Data Transform Analyze Graphs Utilities Extensions Window Help

Visible: 56 of 56 Varial

| | Q11.7 | Q11.8 | Q11.9 | Q11.10 | Q11.11 | Q12.1_Benefit | Q12.2 | Q12.3 | Q12.4 | Q13.1 | Q13.2 | Q14 | Q15 | Q16.1 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 2 | 2 | 2 | 2 | 1 | 1 | 2 | 2 | 3 | 0 | 1 | 1 | 2 |
| 2 | 2 | 2 | 2 | 2 | 2 | 1 | 1 | 2 | 2 | 2 | 1,200,000 | 1 | 1 | 2 |
| 3 | 2 | 2 | 2 | 2 | 2 | 1 | 1 | 2 | 2 | 3 | 2,000,000 | 1 | 1 | 1 |
| 4 | 2 | 2 | 2 | 2 | 2 | 1 | 1 | 2 | 2 | 3 | 0 | 1 | 1 | 1 |
